អង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា

# កម្រងខ្លឹមសារសង្ខេបនៃនីតិវិធី និង សាលក្រម/សាលដីកាក្នុងសំណុំរឿង ០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា



(ឯកសារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី)

# កម្រងខ្លឹមសារសង្ខេបនៃនីតិវិធីនិងសាលក្រម/សាលដីកា ក្នុងសំណុំរឿង ០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

(ឯកសារសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី)




# មាតិកា

**១.** សារលិខិតពីប្រធានរដ្ឋបាលស្ដីទី....................៤

**២.** អារម្ភកថារបស់សហមេធាវីនាំមុខ....................៦

**៣.** សេចក្ដីសង្ខេបខ្លីនៃសំណុំរឿង ០០២ ជំនុំជម្រះលើ លោក ខៀវ សំផន លោក នួន ជា លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ ....................១០

**៤.** កម្រងរូបថតថ្នាក់ដឹកនាំ ចៅក្រម ភាគី និងមេធាវី....................២៦

**៥.** សេចក្ដីសង្ខេបនៃសាលក្រមសំណុំរឿង ០០២/០១....................៤២

**៦.** សេចក្ដីសង្ខេបនៃសាលដីកាសំណុំរឿង ០០២/០១....................៦៣

**៧.** សេចក្ដីសង្ខេបនៃសាលក្រមសំណុំរឿង ០០២/០២....................៨៨

**៨.** សេចក្ដីសង្ខេបនៃសាលដីកាសំណុំរឿង ០០២/០២....................១១៨

**៩.** បញ្ជីឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណី....................១៥៥



*រូបអ្នកតាដំបងដែក ៖ សាក្សី និងអ្នកជំនាញ ស្បថចំពោះមុខអ្នកតាដំបងដែក មុនត្រូវបានសាកសួរដោយចៅក្រម។*




# ១. សារលិខិតពី ប្រធានរដ្ឋបាលស្ដីទី



អ៊ំ ពូ មីង និងបងប្អូនទាំងអស់ជាទីគោរពរាប់អាន!

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) គឺជាស្ថាប័នតុលាការក្នុងស្រុកមួយដែលត្រូវបានបង្កើតឡើងស្រប តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ អ.វ.ត.ក មានយុត្តាធិការ កាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឃោរឃៅ ដែលបាន ប្រព្រឹត្តនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ បន្ទាប់ពីបានបញ្ចប់សព្វគ្រប់ កិច្ចការងារយុត្តាធិការរបស់ខ្លួននៅចុងឆ្នាំ២០២២ អ.វ.ត.ក ត្រូវបន្តអនុវត្តមុខងារសេសសល់របស់ខ្លួនពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥ ក្រោមស្មារតីនៃកិច្ចព្រមព្រៀងបន្ថែមរវាង រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដែលរួមមានការផ្តល់ការការពារដល់ជនរងគ្រោះ ការត្រួតពិនិត្យ ការអនុវត្តសំណង ដែលបានសម្រេចផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងការផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ។

ជនរងគ្រោះដែលនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ គឺជាកម្លាំងជំរុញមួយនៅក្នុងដំណើរការ ទាំងមូលរបស់ អ.វ.ត.ក ក្នុងរយៈពេល១៦ឆ្នាំចុងក្រោយនេះ។ មិនថា តាមរយៈការចូលរួមផ្នែកនីតិវិធីរបស់ពួកគាត់ ក្នុងដំណាក់កាលនៃការស៊ើបអង្កេត និងការជំនុំជម្រះសេចក្តីក្នុងនាមជាអ្នកប្តឹង ឬដើមបណ្តឹងរដ្ឋប្បវេណី ឬតាម រយៈការចូលរួមរបស់ពួកគាត់នៅក្នុងគំនិតផ្តួចផ្តើមរបស់សង្គមស៊ីវិល ក្នុងការកសាងឱ្យមានការផ្សះផ្សា និងការ ស្វែងរកការពិតនៅខាងក្រៅបន្ទប់សវនាការនោះទេ ជនរងគ្រោះដែលនៅរស់រានមានជីវិតបានចែករំលែករឿងរ៉ាវ របស់ពួកគាត់ និងបានបញ្ចេញសំឡេងរបស់ពួកគាត់ឱ្យគេបានដឹង។ សិក្ខាសាលាស្តីពីជនរងគ្រោះ ត្រូវបានរៀបចំ ឡើងដោយ អ.វ.ត.ក នៅខែឧសភា ឆ្នាំ២០២២ ដែលភាគីពាក់ព័ន្ធទាំងអស់បានពិភាក្សា និងបង្កើតគំនិតដែល អ.វ.ត.ក អាចរួមបញ្ចូលប្រកបដោយអត្ថន័យនូវគំនិតផ្តួចផ្តើមរបៀបណា និងគម្រោងបែបណាពាក់ព័ន្ធនឹងជន រងគ្រោះ ទៅជាផ្នែកបញ្ចូលគ្នាដ៏សំខាន់មួយនៃការងារសេសសល់របស់ខ្លួន។

ការចងក្រងនូវសេចក្តីសម្រេចរបស់ អ.វ.ត.ក គឺជាសក្ខីភាពមួយនៃការទទួលស្គាល់ និងការផ្តល់យុត្តិធម៌ ជូនជនរងគ្រោះទាំងអស់។ ខ្ញុំមានជំនឿថា អ៊ំ ពូ មីង និងបងប្អូនទាំងអស់ពេញចិត្តចំពោះសេចក្តីសម្រេច និង ព័ត៌មានសង្ខេបផ្សេងៗ ស្តីពីសំណុំរឿងដែលបានចងក្រងភ្ជាប់មកជាមួយនេះ។

**ឯកឧត្តម ក្រាញ់ តូនី**
**ប្រធានរដ្ឋបាលស្តីទី**




# ២. អារម្ភកថា របស់សហមេធាវីនាំមុខ




ក្នុងរបបកម្ពុជាប្រជាធិប្បតេយ្យ មានមនុស្សស្ទើរតែទូទាំងប្រទេសបានរងទុក្ខក្រោមការដឹកនាំរបស់អង្គការដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដើមបណ្តឹងរដ្ឋប្បវេណី គឺជាអ្នកដែលស្ថិតនៅក្នុងចំណោមអ្នក ដែលបានរងទុក្ខវេទនាទាំងនេះ ហើយភាគច្រើនជាការរងទុក្ខផ្ទាល់ខ្លួន និងបានដាក់ពាក្យសុំតាំងខ្លួនជាភាគីនៅចំពោះមុខសាលាក្តីខ្មែរក្រហម និងចូលរួមយ៉ាងសកម្មក្នុងការរកយុត្តិធម៌ដោយមានជំនួយពីមេធាវីរបស់ខ្លួន។

ជាក់ស្តែងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣១រូប បានផ្តល់សក្ខីកម្មនៅចំពោះមុខ អង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០១ និង ៦៣រូប នៅក្នុងសំណុំរឿង ០០២/០២។ សំណេរជាលាយលក្ខណ៍អក្សរជាច្រើនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានស្រង់មកប្រើប្រាស់ដោយសហចៅក្រមស៊ើបអង្កេត និងជាពិសេសអង្គជំនុំជម្រះទាំងសាលាដំបូង និងតុលាការកំពូល បានប្រើប្រាស់នៅក្នុងសាលក្រម និងសាលដីការបស់ខ្លួន។ ទាំងនេះគឺជាការផ្តល់នូវតម្លៃជាភស្តុតាងជាច្រើនដល់ព័ត៌មាន ដែលផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី។ ក្រៅពីការរួមចំណែកក្នុងការស្វែងរកការពិតក្នុងនីតិវិធីតុលាការ ព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ក៏ចូលរួមនាំសង្គមឱ្យយល់ដឹងកាន់តែច្បាស់អំពីការពិតនៅក្រោមរបបកម្ពុជាប្រជាធិប្បតេយ្យ។

សេចក្តីសង្ខេបខ្លីនៃដំណើររឿងក្តីនេះ គឺជាខ្លឹមសារដែលអង្គភាពសហមេធាវីនាំមុខ សរសេរឡើងដើម្បីផ្តល់ភាពងាយស្រួលក្នុងការអាន និងយល់ដឹងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីអំពីដំណើរការក្តី និងខ្លឹមសារខ្លះៗ នៃសាលក្រម និងសាលដីកាតែប៉ុណ្ណោះ។ វាមិនមែនជាព័ត៌មាន ដែលជំនួសឱ្យសេចក្តីសម្រេចផ្លូវការ ឬឯកសារនីតិវិធីផ្លូវការរបស់តុលាការឡើយ។

**ពេជ អង្គ និង ហ្វាល់ហ្វូនី ខៃបណាត**
**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
**ក្នុងសំណុំរឿង០០២**



# ៣. សេចក្តីសង្ខេបខ្លីនៃ សំណុំរឿង ០០២ ជំនុំជម្រះលើ លោក ខៀវ សំផន លោក នួន ជា លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ

(ឯកសារជំនួយស្មារតីសម្រាប់
ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២)



# សេចក្តីសង្ខេបខ្លីនៃសំណុំរឿង ០០២ ជំនុំជម្រះលើលោក ខៀវ សំផន លោក នួន ជា លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ

**(ឯកសារជំនួយស្មារតីសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២)**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើតដោយច្បាប់ដែលត្រូវបានប្រកាសឱ្យប្រើ នៅថ្ងៃ១០ ខែសីហា ឆ្នាំ២០០១ ហើយត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ និងដោយមានកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញាបានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០២ និងបានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម មួយចំនួនទៀត។ សហព្រះរាជអាជ្ញាបានចេញដីកាសន្និដ្ឋានស្ថាពរនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ ។

តាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ មានចំនួនសរុប៣៨៦៥រូប។ ពួកគាត់បានចាប់ផ្តើមដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណីនៅកំឡុងខែតុលា ឆ្នាំ២០០៧។

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេត បានចេញដីកាដំណោះស្រាយ ដោយសម្រេចបញ្ជូនជនជាប់ចោទ៤រូប រួមមាន លោក នួន ជា លោក អៀង សារី លោកស្រី អៀង ធីរិទ្ធ និងលោក ខៀវ សំផន ទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីវិនិច្ឆ័យទោសតាមច្បាប់ ពីបទចោទទាំងឡាយពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។

អង្គជំនជុំជម្រះសាលាដំបូងបានទទួលសំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក អនុលោមតាមសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ដែលបានចេញដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១។

បទចោទក្នុងសំណុំរឿង ០០២ ត្រូវបានបំបែកចេញជាសំណុំរឿង ០០២/០១ និង ០០២/០២ ព្រមទាំងផ្នែកដែលនៅសេសសល់។

## ១. សំណុំរឿង ០០២/០១

### ក. ដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០១ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក

- ជនជាប់ចោទពីររូបបានទទួលមរណភាព គឺលោក អៀង សារី បានទទួលមរណភាពកាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ និងលោកស្រី អៀង ធីរិទ្ធ បានទទួល មរណភាពនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥។

- ជនជាប់ចោទពីររូបដែលត្រូវបានជំនុំជម្រះ គឺលោក នួន ជា អតីតប្រធានសភាតំណាងប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យ និងលោក ខៀវ សំផន អតីតប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ។

- វិសាលភាពនៃការជំនុំជម្រះនៃសំណុំរឿង ០០២/០១ ផ្តោតទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពាក់ព័ន្ធទៅនឹង៖

    - ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីក្រុងភ្នំពេញនៅ ខែមេសា ឆ្នាំ១៩៧៥ (ជម្លៀសដំណាក់កាលទី១)

    - ការផ្លាស់ទីលំនៅប្រជាជនពីភូមិភាគឧត្តរចាស់/កណ្តាល និរតី បស្ចឹម និងបូព៌ា (ជម្លៀសដំណាក់កាលទី២) និង

    - ការសម្លាប់ទាហានរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃក្នុងខេត្តពោធិ៍សាត់។

- អង្គជំនុំជម្រះសាលាដំបូង បានបើកសវនាការ ពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣។

- អង្គជំនុំជម្រះសាលាដំបូង បានប្រកាសសាលក្រមនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ បន្ទាប់ពីសវនាការប្រព្រឹត្តទៅអស់រយៈពេល២២២ថ្ងៃ។

- បុគ្គលចំនួន៩២ រូប បានមកផ្តល់ភស្តុតាងនៅក្នុងកំលុងពេលសវនាការជំនុំជម្រះក្តីនេះ ដែលរួមមាន៖

    - សាក្សីជំនាញចំនួន៣ រូប ។

    - សាក្សីបញ្ជាក់អង្គហេតុចំនួន៥៣ រូប និង សាក្សីបញ្ជាក់អត្តចរិតជនជាប់ចោទចំនួន៥ រូប។

    - ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៣១ រូប។

    - លើសពីនេះទៀត គ្រូពេទ្យព្យាបាលជនជាប់ចោទចំនួន២ រូប និងអ្នកជំនាញផ្នែកវេជ្ជសាស្រ្តចំនួន២ រូប ក៏បានមកផ្តល់សក្ខីកម្មអំពីស្ថានភាពសុខភាពរបស់ជនជាប់ចោទដែរ។

## ខ. សាលក្រមនៃសំណុំរឿង ០០២/០១

សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ប្រកាសថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ បានសម្រេចថា៖

- ជនជាប់ចោទមានពិរុទ្ធភាពពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់នៃការជម្លៀសដោយបង្ខំ ការធ្វើឱ្យប៉ះពាល់ដល់ សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និង ការបាត់ខ្លួនដោយបង្ខំ)។

- ដាក់ទោសជនជាប់ចោទទាំងពីរ ឱ្យជាប់ពន្ធនាគារអស់មួយជីវិត។

- ទទួលស្គាល់គម្រោងសំណងសម្រាប់ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ចំនួន១១ គម្រោង និង មិនទទួលស្គាល់២ គម្រោង។

- គម្រោងសំណងទាំង ១១ ដែលត្រូវបានទទួលស្គាល់មាន៖

  - គម្រោងទី១៖ ទិវាជាតិនៃការចងចាំ
  - គម្រោងទី២៖ ការសាងសង់បូជនីយដ្ឋានសម្រាប់រំឭកចំពោះជនរងគ្រោះ
  - គម្រោងទី៣៖ ការព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម
  - គម្រោងទី៤៖ ក្រុមជួយខ្លួនឯង
  - គម្រោងទី៥៖ ការតាំងពិព័រណ៍អចិន្ត្រៃយ៍
  - គម្រោងទី៦៖ ការតាំងពិព័រណ៍ចល័ត
  - គម្រោងទី៧៖ ការតាក់តែងជំពូកជាក់លាក់ ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្ស ទួលពោធិ៍ជ្រៃ
  - គម្រោងទី៨៖ ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព
  - គម្រោងទី៩៖ ការបោះពុម្ពកូនសៀវភៅពីដំណើរការនៃសំណុំរឿង ០០២/០១
  - គម្រោងទី១០៖ ការបោះពុម្ព និង ផ្សព្វផ្សាយសាលក្រមទាំងមូល និងជាសង្ខេប

- គម្រោងទី១១៖ ការផ្សាយឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងគេហទំព័ររបស់ អ.វ.ត.ក។

- គម្រោងសំណងចំនួន ២ ដែលមិនត្រូវបានទទួលស្គាល់ ដោយសារគ្មានថវិកា និងខ្វះឯកសារ៖

  - គម្រោងទី១២៖ ការសាងសង់ស្តូបសាធារណៈ ។

  - គម្រោងទី១៣៖ ការកសាងស្តូបរំលឹកដល់ជនរងគ្រោះរបបខ្មែរក្រហម សម្រាប់ប្រជាជនខ្មែរនៅបារាំង។

## គ. បណ្ដឹងសារទុក្ខទៅនឹងសាលក្រមសំណុំរឿង ០០២/០១

- ភាគី ដែលបានដាក់បណ្ដឹងសារទុក្ខជំទាស់ទៅនឹងសាលក្រម អង្គជំនុំជម្រះសាលាដំបូង ចំពោះផ្នែកសេចក្ដីសម្រេចថាមានទោស (ពិរុទ្ធភាព) តាមបទចោទ៖

  - មេធាវីការពារក្ដីរបស់លោក នួន ជា និង ខៀវ សំផន

  - ព្រះរាជអាជ្ញា

  **សំគាល់៖** សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មានសិទ្ធិធ្វើបណ្ដឹងសារទុក្ខចំពោះសាលក្រមលើផ្នែកសំណងប៉ុណ្ណោះ (តែជ្រើសមិនធ្វើ) និងមិនមានសិទ្ធិធ្វើបណ្ដឹងសារទុក្ខចំពោះផ្នែកសេចក្ដីសម្រេចអំពីពិរុទ្ធភាពឡើយ ប៉ុន្តែបានធ្វើការឆ្លើយតបនឹងសារណាបណ្ដឹងសារទុក្ខរបស់មេធាវីការពារក្ដីលើពិរុទ្ធភាព ដោយលើកជាពិសេសភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី)។

- សវនាការលើបណ្ដឹងសារទុក្ខ៖

  - អង្គជំនុំជម្រះតុលាការកំពូល បានបើកសវនាការលើបណ្ដឹងសារទុក្ខ (ដំណាក់កាលបឋម) នៅថ្ងៃទី២ ទី៣ និង៦ ខែកក្កដា ឆ្នាំ២០១៥ ក្នុងនោះមានសាក្សី៣ រូប ដែលបានមកផ្ដល់សក្ខីកម្ម (ទាក់ទងនឹងគោលនយោបាយសម្លាប់អតីតទាហាន និងអ្នករដ្ឋការលន់ ណុល)។

  - នៅថ្ងៃទី១៦ ទី១៧ និងទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ អង្គជំនុំជម្រះតុលាការកំពូលបានបើកសវនាការលើបណ្ដឹងសារទុក្ខ (ដំណាក់កាលចុងក្រោយ)។

### ឃ. ការប្រកាសសាលដីកាសំណុំរឿង០០២/០១៖

- ការប្រកាសសាលដីការបស់ តុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦។

- អង្គជំនុំជម្រះតុលាការកំពូល បានតម្កល់ទុកសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង អំពីការផ្តន្ទាទោសជនជាប់ចោទទាំងពីរ គឺលោក នួន ជា និងលោក ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិត អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងករណីពីរ គឺ៖

  ១. ជម្លៀសដំណាក់កាលទី១៖ ជម្លៀសចេញពីភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

  ២. ជម្លៀសដំណាក់កាលទី២៖ ជម្លៀសនៅចុងឆ្នាំ១៩៧៥ ដល់ចុងឆ្នាំ១៩៧៧។

  ដោយឡែក ករណីចោទប្រកាន់លើការទទួលខុសត្រូវចំពោះការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ត្រូវបានទម្លាក់ចោល ដោយអង្គជំនុំជម្រះតុលាការកំពូល ដោយសារគ្មានភស្តុតាងគ្រប់គ្រាន់ អំពីការទទួលខុសត្រូវរបស់លោក នួន ជា និងលោក ខៀវ សំផន។

## ២. សំណុំរឿង ០០២/០២

### ក. បទចោទ៖

- ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

- ឧក្រិដ្ឋកម្មសង្គ្រាម (ការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩)

### ខ. វិសាលភាពនៃអង្គហេតុ និងលំដាប់នៃការជំនុំជម្រះក្តី៖

- សហករណ៍៖ សហករណ៍ត្រាំកក់ រួមទាំងការប្រព្រឹត្តលើពុទ្ធសាសនិកជន និងដែលពាក់ព័ន្ធនឹងមន្ទីរសន្តិសុខក្រាំងតាចាន់

- ការដ្ឋានការងារ៖ ការដ្ឋានទំនប់១មករា ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម

- ការប្រព្រឹត្តិលើក្រុមមនុស្សជាក់លាក់៖ ជនជាតិចាម ជនជាតិវៀតណាម និងអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ

- មន្ទីរសន្តិសុខនិងការបោសសម្អាតផ្ទៃក្នុង៖ អូរកន្សែង ភ្នំក្រោល និងមន្ទីរសន្តិសុខ ស-២១

- ការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍

- លក្ខណៈនៃជម្លោះប្រដាប់អាវុធ

- តួនាទីរបស់ជនជាប់ចោទ

## គ. សវនាការលើសំណុំរឿង០០២/០២៖

- សវនាការលើអង្គសេចក្តី បានចាប់ផ្តើមនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ហើយដំណើរការរហូតមកទល់ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ គឺមានចំនួនថ្ងៃសវនាការ ២៧៤ថ្ងៃ។

- អង្គជំនុំជម្រះ បានបើកសវនាការស្តាប់សក្ខីកម្មសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី លើអង្គហេតុ ដែលស្ថិតក្នុងវិសាលភាពខាងលើមានចំនួន១៨៥ នាក់ ក្នុងនោះមាន៖

  - សាក្សីចំនួន ១១៤ នាក់

  - ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៣ នាក់ ដែលបានផ្តល់សក្ខីកម្ម ក្នុងសំណុំរឿង ០០២/០២ នៅក្នុងវិសាលភាពដូចខាងក្រោម៖

    ១. សហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ (ដើមបណ្តឹងរដ្ឋប្បវេណី ១៤រូប)

    ២. ការដ្ឋានទំនប់១មករា (៥រូប)

    ៣. ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង (២រូប)

    ៤. ការដ្ឋានទំនប់ត្រពាំងថ្ម (៤រូប)

    ៥. ការធ្វើទុក្ខបុកម្នេញលើជនជាតិចាម (៥រូប)

៦. ការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាម (៧រូប)

៧. មន្ទីរសន្តិសុខអូរកន្សែង (គ្មាន)

៨. មន្ទីរសន្តិសុខភ្នំក្រោល (១រូប)

៩. មន្ទីរសន្តិសុខ ស-២១ ឬទួលស្លែង (៦រូប)

១០. ការបោសសម្អាតផ្ទៃក្នុង (៣រូប)

១១. អាពាហ៍ពិពាហ៍ដោយបង្ខំ (១២រូប)

១២. លក្ខណៈនៃជម្លោះប្រដាប់អាវុធ (គ្មាន)

១៣. តួនាទីរបស់ជនជាប់ចោទ (៤រូប)

- អ្នកជំនាញចំនួន ៨ នាក់។

- សហមេធាវីនាំមុខបានដាក់សារណាបញ្ចប់ការពិភាក្សាដេញដោលនៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៧ និងសំណើសុំទទួលស្គាល់សំណងក្នុងសំណុំរឿង ០០២/០២ ត្រូវបានដាក់នៅថ្ងៃទី២០ ខែ០៥ ឆ្នាំ២០១៧។

- សវនាការស្តីអំពីសេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោលត្រូវចាប់ផ្តើមធ្វើនៅថ្ងៃទី១៣ ដល់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧។

## ឃ. សាលក្រមសំណុំរឿង០០២/០២ របស់អង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះ បានប្រកាសសាលក្រមសំណុំរឿង ០០២/០២ ជាសាធារណៈនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ហើយចេញផ្សាយសាលក្រមទាំងបីភាសានៅថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១៩ ដែលយើងខ្ញុំសូមសង្ខេបខ្លឹមសារ ដូចតទៅ៖

១. ចំពោះបទចោទលើជនជាប់ចោទ៖

- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ សាលក្រមប្រកាសថាលោក នួន ជា និងលោក ខៀវ សំផន មានពិរុទ្ធភាពពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល

ការនិរទេស ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗ ទៀត (ក្រោមទម្រង់នៃការបាត់ខ្លួនដោយបង្ខំ ការជម្លៀសដោយបង្ខំ ការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ)។

- ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍៖ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា៖

  - លោក នួន ជា មានពិរុទ្ធភាពពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជនជាតិវៀតណាមផង និងក្រុមជនជាតិចាមផង។

  - លោក ខៀវ សំផន មានពិរុទ្ធភាពពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការធ្វើមនុស្សឃាតលើសមាជិកក្រុមជនជាតិវៀតណាម ប៉ុន្តែអង្គជំនុំជម្រះ មិនបានប្រកាសថាលោក ខៀវ សំផន មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិចាមឡើយ។

- ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ៖ សាលក្រមប្រកាសថា លោក នួន ជា និងលោក ខៀវ សំផន មានពិរុទ្ធភាពពីឧក្រិដ្ឋកម្មសង្គ្រាម ដោយការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់)។

២. អង្គហេតុចោទប្រកាន់/វិសាលភាពនៃការជំនុំជម្រះមាន៖

- សហករណ៍និងការដ្ឋានការងារ៖ សហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។

- មន្ទីរសន្តិសុខនិងទីតាំងសម្លាប់មនុស្ស៖ មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោល។

- ការកំណត់គោលដៅលើក្រុមជាក់លាក់៖ ជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

- ការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍។

## ៣. សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង៖

- សម្រេចផ្ដន្ទាទោសជនជាប់ចោទទាំងពីរថាមានពិរុទ្ធភាពលើបទចោទតាមអង្គហេតុខាងលើ និងសម្រេចឱ្យលោក នួន ជា និងលោកខៀវ សំផន ជាប់ពន្ធនាគារ អស់មួយជីវិត។

- ទទួលស្គាល់គម្រោងសំណងចំពោះដើមបណ្ដឹងរដ្ឋប្បវេណី ចំនួន១៣ គម្រោង និងមិនទទួលស្គាល់ ២ គម្រោង។

- គម្រោងសំណង១៣ ដែលត្រូវបានទទួលស្គាល់មាន៖

    - គម្រោងទី១៖ គម្រោង កម្មវិធីសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម (នៅក្នុងទូរស័ព្ទដៃ)

    - គម្រោងទី២៖ ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការបណ្ដុះបណ្ដាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ។

    - គម្រោងទី៣៖ គម្រោងអណ្ដើកក្លាហាន៖ គម្រោងអន្តរព័ត៌មានប្រកបដោយភាពច្នៃប្រឌិត ដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រ និងភាពក្លាហានរបស់ពលរដ្ឋនៅកម្ពុជា។

    - គម្រោងទី៤៖ គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាមនិងខ្មែរក្រហម។

    - គម្រោងទី៥៖ ផ្កាស្លាក្រោមអង្គការ ។

    - គម្រោងទី៦៖ សំឡេងពីជនជាតិភាគតិច៖ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជន អំពីការប្រព្រឹត្តមកលើជនជាតិភាគតិចវៀតណាម និងចាម ដែលបានរស់នៅក្នុងប្រទេសកម្ពុជា ក្នុងរយៈពេលនៃរបបខ្មែរក្រហម ។

    - គម្រោងទី៧៖ រឿងរ៉ាវដែលមិនធ្លាប់បានគេដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានចូលរួមក្នុងសំណុំរឿង០០២/០២ នៅអ.វ.ត.ក ។

    - គម្រោងទី៨៖ ពេលវេលាដែលត្រូវចងចាំ៖ ការប្រកួតប្រជែងរបស់យុវជនក្នុងការតាក់តែងបទចម្រៀង ស្ដីពីការចងចាំនៅកម្ពុជា ។

    - គម្រោងទី៩៖ ផ្ទាំងគំនូរដើម្បីការចងចាំនៅក្រាំងតាចាន់ ។

- គម្រោងទី១០៖ មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធ អ.វ.ត.ក (គម្រោងនេះបានផ្លាស់ប្តូរទីតាំងទៅក្បែរអាគារទីស្តីការគណៈរដ្ឋមន្ត្រី)។

- គម្រោងទី១១៖ ការព្យាបាលនិងការផ្សះផ្សាសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ។

- គម្រោងទី១២៖ ការអប់រំផ្នែកច្បាប់និងសិទ្ធិពលរដ្ឋដល់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិច ។

- គម្រោងទី១៤៖ វេទិកាអប់រំសាធារណៈនិងការតាំងពិព័រណ៍ជាអចិន្ត្រៃយ៍អំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ។

- គម្រោងសំណងទាំង ២ ដែលមិនត្រូវបានទទួលស្គាល់មាន៖

  - គម្រោងទី១៣៖ ផ្នែកមួយនៃគម្រោងដែលជាសកម្មភាពដែលមានលក្ខណៈជាការផ្តល់ថវិកាផ្ទាល់ជូនបុគ្គលម្នាក់ៗ នៅក្នុងគម្រោងទី១៣ «លើកកម្ពស់សុខភាព និងសុខមាលភាពផ្លូវចិត្ត និងកាត់បន្ថយហានិភ័យនៃភាពក្រីក្រ និងការកាត់ផ្តាច់ពីសង្គមនៃដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងបុគ្គលចាស់ជរាដែលងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា» មិនត្រូវបានទទួលស្គាល់ឡើយ ដោយវាមានលក្ខណៈជាសកម្មភាព ដែលមិនមានលក្ខណៈសមូហភាព និងផ្លូវចិត្ត។

  - គម្រោងទី១៥៖ ប្រជាជនជាតិដើមភាគតិចកម្ពុជា និង ប៉ុល ពត ។

## ង. សវនាការលើបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០២

- ភាគីដែលបានដាក់បណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ៖

  - ក្រុមមេធាវីការពារក្តីរបស់លោក នួន ជា បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលកក្រមសំណុំរឿង ០០២/០២ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ប៉ុន្តែក្រុមមេធាវីការពារក្តីមិនទាន់បានដាក់បណ្តឹងសាទុក្ខនៅឡើយទេ ដោយលោក នួន ជា បានទទួលមរណភាពនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩។ ដូច្នេះ ការជំនុំជម្រះក្តីលោក នួន ជា ត្រូវបានបញ្ចប់។

  - មេធាវីការពារក្តីលោក ខៀវ សំផន បានដាក់បណ្តឹងសាទុក្ខនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ មានជាង២០០ មូលដ្ឋានបណ្តឹង។

- សហព្រះរាជអាជ្ញា បានដាក់បណ្តឹងសាទុក្ខនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ពាក់ព័ន្ធការបង្ខំរួមភេទលើបុរស ។

- សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (យើងអាចធ្វើបណ្តឹងសារទុក្ខជំទាស់ទៅនឹងសាលក្រម បានតែក្នុងករណីរឿងសំណងប៉ុណ្ណោះ តែយើងអាចឆ្លើយតបទៅនឹងបណ្តឹងសារទុក្ខរបស់មេធាវីការពារក្តីផងដែរ)។

▸ ការឆ្លើយតបបណ្តឹងសាទុក្ខរបស់ភាគី ៖

- មេធាវីការពារក្តីលោក ខៀវ សំផន បានឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញានៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩។

- សហព្រះរាជអាជ្ញា បានឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០។

- សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយតបចំពោះបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១។

▸ សវនាការលើបណ្តឹងសារទុក្ខនៃសំណុំរឿង ០០២/០២ ៖

- អង្គជំនុំជម្រះតុលាការកំពូល បានបើកសវនាការលើបណ្តឹងសាទុក្ខនៅថ្ងៃទី១៦ ដល់ ទី១៩ ខែសីហា ឆ្នាំ២០២១ តាមប្រព័ន្ធសោទស្សន៍ នៅតុលាការដោយផ្ទាល់ ។

- ដោយមូលហេតុការរាលដាលនៃជំងឺកូវីដ១៩ ដើមបណ្តឹងរដ្ឋប្បវេណី១៥ រូបប៉ុណ្ណោះ បានចូលរួមស្តាប់សវនាការតាមប្រព័ន្ធសោទស្សន៍នៅទីតាំងតុលាការផ្ទាល់។

- អង្គជំនុំជម្រះតុលាការកំពូល បានប្រកាសសាលដីកាស្ថាពរនៅ
ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០២២។

- អង្គជំនុំជម្រះតុលាការកំពូល បានទទួលយកផ្នែកខ្លះ និងបដិសេធផ្នែកខ្លះនៃបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន និង បានតម្កល់ការដាក់ពិរុទ្ធភាពលើលោក ខៀវ សំផន ដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង ព្រមទាំងតម្កល់ការប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតលើ ខៀវ សំផន ក្នុងសំណុំរឿង០០២/០២ ដែលត្រូវអនុវត្តត្រួតគ្នាជាមួយនឹងទោសដាក់ពន្ធនាគារអស់មួយជីវិតក្នុងសំណុំរឿង០០២/០១។

**១.** ការបដិសេធការដាក់ពិរុទ្ធភាពលើលោក ខៀវ សំផន ៖

- ពី «បទជួយទំនុកបម្រុងនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាតដោយចេតនាប្រយោល» នៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ទំនប់១មករា ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ដោយកែប្រែប្រភេទគតិយុត្តនៃបទល្មើស ដោយសម្រេចដាក់ពិរុទ្ធភាពលោក ខៀវ សំផន ពី «បទមនុស្សឃាតដោយចេតនាប្រយោល នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈសហឧក្រិដ្ឋកម្មរួម» វិញ។

- ពីបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅមន្ទីរសន្តិសុខភ្នំក្រោល។

- ពីបទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលើប្រជាជនថ្មី នៅការដ្ឋានធ្វើការទំនប់១មករា ។

**២.** ការតម្កល់ការដាក់ពិរុទ្ធភាពលើលោក ខៀវ សំផន ៖

- ពីបទការសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធនឹងអង្គហេតុនៃការសម្លាប់ជនជាតិចាម ដែលបានកើតឡើងនៅភូមិទ្រា និងវត្តអូរត្រកួន និងការសម្លាប់ជនជាតិវៀតណាមក្នុងខេត្តស្វាយរៀង ខេត្តកំពង់ឆ្នាំង នៅវត្តខ្សាច់ក្នុងខេត្តសៀមរាប និងខេត្តក្រចេះ ព្រមទាំងមន្ទីរសន្តិសុខអូរកន្សែង។

- ពីបទការដាក់ឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធនឹងអង្គហេតុនៃការធ្វើការដោយបង្ខំរបស់អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខភ្នំក្រោល។

- ពីបទការនិរទេសជនជាតិវៀតណាមនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធនឹងអង្គហេតុនៃការនិរទេសប្រជាជនវៀតណាមចេញពីស្រុកត្រាំកក់ និងពីខេត្តព្រៃវែង។

- ពីបទការធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធនឹងអង្គហេតុនៃការធ្វើបាបផ្លូវចិត្ត និងផ្លូវកាយលើជនជាតិចាមនៅភូមិទ្រា ស្រុកក្រូចឆ្មា ខេត្តត្បូងឃ្មុំ។

- ពីបទការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លើជនជាតិចាម និងការចាត់ទុកជា «សត្រូវពិតឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា» ព្រមទាំងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និង «ប្រជាជនថ្មី» នៅសហករណ៍ត្រាំកក់ ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម

ទំនប់១មករា (មិនពាក់ព័ន្ធនឹង «ប្រជាជនថ្មី») ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល។

- ពីបទការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធនឹងអង្គហេតុនៃការរើសអើងលើជនជាតិចាម។

- ពីបទការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនានៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធទៅនឹងអង្គហេតុនៃការរើសអើងចំពោះពុទ្ធសាសនិក និងព្រះសង្ឃនៃពុទ្ធសាសនា។

- ពីបទការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធទៅនឹងអង្គហេតុនៃការរើសអើងជនជាតិវៀតណាមនៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខអូរកន្សែង និងខេត្តព្រៃវែង និងខេត្តស្វាយរៀង។

- ពីបទអំពើអមនុស្សធម៌ដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើដែលត្រូវបានចាត់ទុកថាជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ពាក់ព័ន្ធទៅនឹងអង្គហេតុនៃការធ្វើឱ្យបាត់ខ្លួននៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខ ក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល។

- ពីបទអំពើអមនុស្សធម៌ដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើដែលត្រូវបានចាត់ទុកថាជាការផ្លាស់ទីដោយបង្ខំ ពាក់ព័ន្ធទៅនឹងអង្គហេតុនៃការផ្លាស់ទីដោយបង្ខំជនជាតិចាមក្នុងកំលុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីពីរ។

- ពីបទអំពើអមនុស្សធម៌ដទៃទៀត ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ និងបន្ថែមលើសពីនេះពីបទអំពើអមនុស្សធម៌ដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងទម្រង់នៃអំពើហិង្សាផ្លូវភេទដែលត្រូវបានចាត់ទុកថាជាការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ដោយបង្ខំពាក់ព័ន្ធទៅនឹងជនរងគ្រោះជាស្ត្រី។ ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូល បានទទួលយកផ្នែកខ្លះនៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងសម្រេចដាក់ពិរុទ្ធភាពលើលោក ខៀវ សំផន ពីបទអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបន្ថែមលើសនេះពីបទអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃអំពើហិង្សាផ្លូវភេទ ដែលត្រូវបានចាត់ទុកថា ជាការរួមភេទដោយបង្ខំ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំពាក់ព័ន្ធទៅនឹងជនរងគ្រោះជាបុរស។

- ពីបទរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ពាក់ព័ន្ធទៅនឹងអង្គហេតុនៃការសម្លាប់ដោយចេតនា ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ ការបង្កឱ្យមានការឈឺចាប់

ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬសុខភាព ការដកហូតឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ និងទៀងទាត់ និងការឃុំឃាំងខុសច្បាប់លើជនស៊ីវិល។

- ពីបទប្រល័យពូជសាសន៍ ពាក់ព័ន្ធទៅនឹងអង្គហេតុនៃការសម្លាប់ជនជាតិវៀតណាម។

## ច. មុខងារដែលនៅសេសសល់ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ

- នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ អ.វ.ត.ក បានផ្លាស់ប្តូរទីតាំងរបស់ខ្លួនមកនៅទីតាំងជិតទីស្តីការគណៈរដ្ឋមន្ត្រី គឺនៅអាគារជាមួយមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹង អ.វ.ត.ក ដើម្បីអនុវត្តមុខងារ ដែលនៅសេសសល់ក្នុងរយៈពេលបីឆ្នាំ ដូចជាការងារផ្សព្វផ្សាយអំពីកិច្ចការរបស់សាលាក្តីខ្មែរក្រហម កិច្ចការជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណី កិច្ចការចំណាត់ថ្នាក់ឯកសារ និងកិច្ចការនានាដទៃទៀតជាប្រយោជន៍ដល់ជនរងគ្រោះ និងសាធារណជនទូទៅ។

## ឆ. ការលើកលែងការចោទប្រកាន់ទៅលើបទចោទដែលសេសសល់ក្នុងសំណុំរឿង០០២

បទចោទខាងក្រោមនៅក្នុងសំណុំរឿង០០២ មិនត្រូវបានយកមកជំនុំជម្រះឡើយ មានដូចជា៖

១. ការជម្លៀសប្រជាជន ដំណាក់កាលទី៣។

២. ការដ្ឋានការងារ ព្រៃស (ស-២៤)។

៣. មន្ទីរសន្តិសុខ៖ សង់ កោះខ្យង ព្រៃដំរីស្រុត វត្តគិរីរម្យ វត្តធ្លក គោកក្តួច ទីតាំងសម្លាប់នៅស្រុក១២ (ភូមិភាគបស្ចឹម) កន្លែងសម្លាប់មនុស្សនៅព្រៃត្រពាំងអំពិលការជម្លៀសមនុស្សក្នុងស្រុក១២ បន្ទាប់ពីថ្ងៃទី០៧ ខែមេសា កន្លែងសម្លាប់មនុស្សនៅស្ទឹងតូច។

៤. ការធ្វើទុក្ខបុកម្នេញលើក្រុមជាក់លាក់៖ ការធ្វើទុកបុកម្នេញលើពុទ្ធសាសនិក (ទូទាំងប្រទេស)។

## ៣. ឯកសារសំខាន់ពាក់ព័ន្ធផ្សេងៗ សម្រាប់អាន និង ស្រាវជ្រាវ (សូមភ្ជាប់ទៅគេហទំព័រខាងក្រោម)

១. តំណភ្ជាប់ទៅសាលក្រម និងសាលដីកាពេញលេញរបស់ អង្គជំនុំជម្រះសាលាដំបូង និងតុលាការកំពូល ក្នុងសំណុំរឿង ០០២៖

- សាលក្រម ០០២/០១៖ https://www.eccc.gov.kh/km/document/court/saalkrmsmnnumryang-00201
- សាលដីកា ០០២/០១៖ https://www.eccc.gov.kh/km/document/court/saaltiikaa-smnnumryang-00201
- សាលក្រម ០០២/០២៖ https://www.eccc.gov.kh/km/document/court/saalkrmsmnnumryang-00202
- សាលដីកា ០០២/០២៖ https://www.eccc.gov.kh/km/document/court/saaltiikaa-smnnumryang-00202

២. កម្មវិធីរៀនប្រវត្តិសាស្ត្រខ្មែរក្រហម នៅក្នុងទូរស័ព្ទដៃ៖ ទាញយកពី

GET IT ON Google Play ឬ Available on the iPhone App Store

- វាយពាក្យនេះ «App-learning on Khmer Rouge History» ឬ «Khmer Rouge History» ក្នុង Google Play or App Store នៅក្នុងទូរស័ព្ទដៃរបស់ លោកអ្នក ពេលនោះលោកអ្នកនឹងឃើញសញ្ញានេះ (ខាងស្តាំដៃ) រួចចុច Install ជាការស្រេច។




# ៤. កម្រងរូបថត ថ្នាក់ដឹកនាំ ចៅក្រម ភាគី និងមេធាវី

# រូបថតថ្នាក់ដឹកនាំដែលតំណាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ



*ឯកឧត្តមទេសរដ្ឋមន្ត្រី សុខ អាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោក ហាន់ កូរ៉ែល អគ្គលេខាធិការរងសម្រាប់កិច្ចការច្បាប់ នៃអង្គការសហប្រជាជាតិ នៅក្នុងពិធីចុះហត្ថលេខា លើកិច្ច ព្រម ព្រៀង នៃបង្កើត អ.វ.ត.ក នៅថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ២០០៣។*








# រូបថតថ្នាក់ដឹកនាំដែលតំណាង រាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ









*ថ្នាក់ដឹកនាំ អ.វ.ត.ក និងដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២។*

# រូបថតតុលាការ

## អង្គជំនុំជម្រះតុលាការកំពូល




## អង្គជំនុំជម្រះសាលាដំបូង




## អង្គបុរេជំនុំជម្រះ






# រូបថតភាគីនៅក្នុងតុលាការ

## សហចៅក្រមស៊ើបអង្កេត










## សហព្រះរាជអាជ្ញា

















# រូបថតភាគីនៅក្នុងតុលាការ



## មេធាវីនិងជនជាប់ចោទ








## មេធាវីនិងដើមបណ្តឹងរដ្ឋប្បវេណី











# រូបថតសកម្មភាពរបស់ជនរងគ្រោះដូចជា សិក្ខាសាលា ឬវេទិកាផ្សេងៗ រៀបចំឡើងដោយអង្គភាពគាំពារជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី



*គម្រោងសំណង៖ ផ្កាស្លាក្រោមអង្គការ*



*គម្រោងសំណង៖ ក្រុមជួយខ្លួនឯង*



*គម្រោងសំណង៖ ការតាំងពិពណ៌ចល័ត*



*គម្រោងសំណង៖ ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព*



*វេទិកាដើមបណ្ដឹងរដ្ឋប្បវេណីអំពីនិងមេធាវី*



*វេទិកាដើមបណ្ដឹងរដ្ឋប្បវេណីអំពីនិងមេធាវី*

# រូបថតសកម្មភាពរបស់ជនរងគ្រោះដូចជា សិក្ខាសាលា ឬវេទិកាផ្សេងៗ រៀបចំឡើងដោយអង្គភាពគាំពារជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី



មេធាវីនាំមុខផ្តល់ព័ត៌មានមុនសវនាការ



មេធាវី ទ្រី ស្រីនណា ជួបជាមួយដើមបណ្តឹង



មេធាវី ហុង គឹមសួន ជួបជាមួយដើមបណ្តឹង



មេធាវី ឡោ ជុនធី ជួបជាមួយដើមបណ្តឹង



វេទិកាដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី



មេធាវី វ៉ែន ពៅ ជួបជាមួយដើមបណ្តឹង




# រូបថតដើមបណ្តឹងរដ្ឋប្បវេណី ចូលរួមផ្តល់សក្ខីកម្មនៅពេលសវនាការ

## ១. សំណុំរឿង ០០២/០១



**១.** ដើមបណ្តឹងរដ្ឋប្បវេណី ក្លាន ហ្វិត
ផ្តល់សក្ខីកម្ម ០៦ ធ្នូ ២០១១
១០-១១ មករា ២០១២



**២.** ដើមបណ្តឹងរដ្ឋប្បវេណី រម៉ាម យុន ហៅ ខាំភី
ផ្តល់សក្ខីកម្ម ៧ ធ្នូ ២០១២



**៣.** ដើមបណ្តឹងរដ្ឋប្បវេណី ឯម អឿន
ផ្តល់សក្ខីកម្ម
២៣ និង ២៧-២៩ សីហា ២០១២



**៤.** ដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ
ផ្តល់សក្ខីកម្ម ១៩-២២ តុលា ២០១២



**៥.** ដើមបណ្តឹងរដ្ឋប្បវេណី លោក ជុំ សុខា
ផ្តល់សក្ខីកម្ម ២២ តុលា ២០១២



**៦.** ដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បុននី
ផ្តល់សក្ខីកម្ម ២៤ តុលា ២០១២



**៧.** ដើមបណ្តឹងរដ្ឋប្បវេណី មុំ សមអឿន
ផ្តល់សក្ខីកម្ម ៦ វិច្ឆិកា ២០១២



**៨.** ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់
ផ្តល់សក្ខីកម្ម១៤ វិច្ឆិកា ២០១២



**៩.** ដើមបណ្តឹងរដ្ឋប្បវេណី អោ រី
ផ្តល់សក្ខីកម្ម ២២ វិច្ឆិកា ២០១២



**១០.** ដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី តឹង សុខា
ផ្តល់សក្ខីកម្ម ៤ ធ្នូ ២០១២



**១១.** ដើមបណ្តឹងរដ្ឋប្បវេណី ពេជ្រ ស្រីផល
ផ្តល់សក្ខីកម្ម ៥ ធ្នូ ២០១២



**១២.** ដើមបណ្តឹងរដ្ឋប្បវេណី គឹម វ៉ាន់ឌី
ផ្តល់សក្ខីកម្ម ៥ ធ្នូ ២០១២



**១៣.** ដើមបណ្តឹងរដ្ឋប្បវេណី
AFFONÇO Denise
ផ្តល់សក្ខីកម្ម ១២-១៣ ធ្នូ ២០១២



**១៤.** ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ
ផ្តល់សក្ខីកម្ម ៧ កុម្ភៈ ២០១៣



**១៥.** ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន
ផ្តល់សក្ខីកម្ម ២៩ មេសា ២០១៣



**១៦.** ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី
ផ្តល់សក្ខីកម្ម ២៣ ឧសភា ២០១៣



**១៧.** ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សូធារី
ផ្តល់សក្ខីកម្ម ២៧ ឧសភា ២០១៣



**១៨.** ដើមបណ្តឹងរដ្ឋប្បវេណី អូន ផល្លី
ផ្តល់សក្ខីកម្ម ២៧ ឧសភា ២០១៣



**១៩.** ដើមបណ្តឹងរដ្ឋប្បវេណី សាំង រ៉ាត់
ផ្តល់សក្ខីកម្ម២៧ ឧសភា ២០១៣



**២០.** ដើមបណ្តឹងរដ្ឋប្បវេណី យស់ ផល
ផ្តល់សក្ខីកម្ម ២៧ ឧសភា ២០១៣



**២១.** ដើមបណ្តឹងរដ្ឋប្បវេណី ធុច ផាន់ដារា-ស
ផ្តល់សក្ខីកម្ម ២៩ ឧសភា ២០១៣



**២២.** ដើមបណ្តឹងរដ្ឋប្បវេណី ចាន់ សុជាតិ
ផ្តល់សក្ខីកម្ម ២៩ ឧសភា ២០១៣



**២៣.** ដើមបណ្តឹងរដ្ឋប្បវេណី ឆេង អេងលី
ផ្តល់សក្ខីកម្ម ២៩ ឧសភា ២០១៣



**២៤.** ដើមបណ្តឹងរដ្ឋប្បវេណី ហួ ចន្ថា
ផ្តល់សក្ខីកម្ម ២៩ ឧសភា ២០១៣



**២៥.** ដើមបណ្តឹងរដ្ឋប្បវេណី នូ ហ៊ន
ផ្តល់សក្ខីកម្ម ៣០ ឧសភា ២០១៣



**២៦.** ដើមបណ្តឹងរដ្ឋប្បវេណី
សុផាន់ សូវ៉ាន់នី
ផ្តល់សក្ខីកម្ម ៣០ ឧសភា ២០១៣



**២៧.** ដើមបណ្តឹងរដ្ឋប្បវេណី យិន រុំដួល
ផ្តល់សក្ខីកម្ម ៣០ ឧសភា ២០១៣



**២៨.** ដើមបណ្តឹងរដ្ឋប្បវេណី ប៉ូ ឌីណា
ផ្តល់សក្ខីកម្ម ៣០ ឧសភា ២០១៣



**២៩.** ដើមបណ្តឹងរដ្ឋប្បវេណី បេ សុផានី
ផ្តល់សក្ខីកម្ម ៤ មិថុនា ២០១៣



**៣០.** ដើមបណ្តឹងរដ្ឋប្បវេណី សឿន សុវណ្ណី
ផ្តល់សក្ខីកម្ម ៤ មិថុនា ២០១៣



**៣១.** ដើមបណ្តឹងរដ្ឋប្បវេណី សេង ស៊ីវុត្ថា
ផ្តល់សក្ខីកម្ម ៤ មិថុនា ២០១៣

## ២. សំណុំរឿង ០០២/០២



**១.** ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី
ផ្តល់សក្ខីកម្ម៖ ២៣ មករា ២០១៥



**២.** ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡុន
ផ្តល់សក្ខីកម្ម៖ ២៦-២៧ មករា ២០១៥



**៣.** ដើមបណ្តឹងរដ្ឋប្បវេណី អៀម យេន
ផ្តល់សក្ខីកម្ម ១-២ មេសា ២០១៥



**៤.** ដើមបណ្តឹងរដ្ឋប្បវេណី បេង បឿន
ផ្តល់សក្ខីកម្ម ២ មេសា ២០១៥



**៥.** ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ
ផ្តល់សក្ខីកម្ម ៣ មេសា ២០១៥



**៦.** ដើមបណ្តឹងរដ្ឋប្បវេណី ឡិប នាង
ផ្តល់សក្ខីកម្ម ៣ មេសា ២០១៥



**៧.** ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ
ផ្តល់សក្ខីកម្ម ១២ កុម្ភៈ ២០១៥



**៨.** ដើមបណ្តឹងរដ្ឋប្បវេណី ស.ស
ផ្តល់សក្ខីកម្ម ២៤ មីនា ២០១៥



**៩.** ដើមបណ្តឹងរដ្ឋប្បវេណី តាក សាន់
ផ្តល់សក្ខីកម្ម ១ មេសា ២០១៥



**១០.** ដើមបណ្តឹងរដ្ឋប្បវេណី ចាន់ ធីម
ផ្តល់សក្ខីកម្ម ២ មេសា ២០១៥



**១១.** ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន
ផ្តល់សក្ខីកម្ម ២៦ មីនា ២០១៥



**១២.** ដើមបណ្តឹងរដ្ឋប្បវេណី យែម ឌុន្នី
ផ្តល់សក្ខីកម្ម ២-៣ មេសា ២០១៥



**១៣.** ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន
ផ្តល់សក្ខីកម្ម ៤-៦ កុម្ភៈ ២០១៥
២៥ មីនា ២០១៥



**១៤.** ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង
ផ្តល់សក្ខីកម្ម ១ កញ្ញា ២០១៥



**១៥.** ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី
ផ្តល់សក្ខីកម្ម ២៦ ឧសភា ២០១៥



**១៦.** ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ
ផ្តល់សក្ខីកម្ម ១ កញ្ញា ២០១៥



**១៧.** ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា
ផ្តល់សក្ខីកម្ម ២ មិថុនា ២០១៥



**១៨.** ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ
ផ្តល់សក្ខីកម្ម ២ កញ្ញា ២០១៥



**១៩.** ដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហល់
ផ្តល់សក្ខីកម្ម ២៥ សីហា ២០១៥



**២០.** ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត
ផ្តល់សក្ខីកម្ម ២ កញ្ញា ២០១៥



**២១.** ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន
ផ្តល់សក្ខីកម្ម ២៧ កក្កដា ២០១៥



**២២.** ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន
ផ្តល់សក្ខីកម្ម ២៤ មិថុនា ២០១៥



**២៣.** ដើមបណ្តឹងរដ្ឋប្បវេណី គន់ សៀក
ផ្តល់សក្ខីកម្ម ១៧ មិថុនា ២០១៥



**២៤.** ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន
ផ្តល់សក្ខីកម្ម ១៧ កញ្ញា ២០១៥



**២៥.** ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ
ផ្តល់សក្ខីកម្ម ២៩ កុម្ភៈ ២០១៦



**២៦.** ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ
ផ្តល់សក្ខីកម្ម ២៩ កុម្ភៈ ២០១៦



**២៧.** ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ
ផ្តល់សក្ខីកម្ម ២៨ កញ្ញា ២០១៥



**២៨.** ដើមបណ្តឹងរដ្ឋប្បវេណី សុះ ម៉ីន
ផ្តល់សក្ខីកម្ម ៨ កញ្ញា ២០១៥



**២៩.** ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំងច្រើត
ផ្តល់សក្ខីកម្ម ២ ធ្នូ ២០១៥



**៣០.** ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន
ផ្តល់សក្ខីកម្ម ២៥ មករា ២០១៦



**៣១.** ដើមបណ្តឹងរដ្ឋប្បវេណី ខូង មួយ
ផ្តល់សក្ខីកម្ម ២ មីនា ២០១៦



**៣២.** ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី
ផ្តល់សក្ខីកម្ម ២០ មករា ២០១៦



**៣៣.** ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ខឿន
ផ្តល់សក្ខីកម្ម ៣ ធ្នូ ២០១៥



**៣៤.** ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ធី
ផ្តល់សក្ខីកម្ម ២៩ កុម្ភៈ ២០១៦



**៣៥.** ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ
ផ្តល់សក្ខីកម្ម ១ មីនា ២០១៦



**៣៦.** ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន
ផ្តល់សក្ខីកម្ម ២៧ ឧសភា ២០១៥



**៣៧.** ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន
ផ្តល់សក្ខីកម្ម ៣ មេសា ២០១៥



**៣៨.** ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី
ផ្តល់សក្ខីកម្ម ១៨ មេសា ២០១៦



**៣៩.** ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន
ថ្ងៃផ្តល់សក្ខីកម្ម
២៨-២៩ មិថុនា ២០១៦



**៤០.** ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន
ផ្តល់សក្ខីកម្ម ១៧ សីហា ២០១៦



**៤១.** ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត
ផ្តល់សក្ខីកម្ម ៣០ មីនា ២០១៦



**៤២.** ដើមបណ្តឹងរដ្ឋប្បវេណី ផៃ ហ៊ាប
ផ្តល់សក្ខីកម្ម ១១ សីហា ២០១៦



**៤៣.** ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត
ផ្តល់សក្ខីកម្ម ១១ សីហា ២០១៦



**៤៤.** ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ិន
ផ្តល់សក្ខីកម្ម ១៥ សីហា ២០១៦



**៤៥.** ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា
ថ្ងៃផ្តល់សក្ខីកម្ម៖ ១៥ សីហា ២០១៦



**៤៦.** ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម
ផ្តល់សក្ខីកម្ម ១៥ សីហា ២០១៦



**៤៧.** ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី
ផ្តល់សក្ខីកម្ម ១១ សីហា ២០១៦



**៤៨.** ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន
ផ្តល់សក្ខីកម្ម
២២-២៣ សីហា ២០១៦



**៤៩.** ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សូជាវី
ផ្តល់សក្ខីកម្ម
២៣-២៤ សីហា ២០១៦



**៥០.** ដើមបណ្តឹងរដ្ឋប្បវេណី យស ផល
ផ្តល់សក្ខីកម្ម ២៥ សីហា ២០១៦



**៥១.** ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន
ផ្តល់សក្ខីកម្ម
២៩-៣០ សីហា ២០១៦



**៥២.** ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប
ផ្តល់សក្ខីកម្ម
៣០-៣១ សីហា ២០១៦



**៥៣.** ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន
ផ្តល់សក្ខីកម្ម
១៥-១៦ កញ្ញា ២០១៦



**៥៤.** ដើមបណ្តឹងរដ្ឋប្បវេណី សា ឡៃហ៊ាង
ផ្តល់សក្ខីកម្ម ១៩ កញ្ញា ២០១៦



**៥៥.** ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់
ផ្តល់សក្ខីកម្ម ១២ វិច្ឆិកា ២០១៦



**៥៦.** ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុខឿន
ផ្តល់សក្ខីកម្ម ២០-២៤ តុលា ២០១៦



**៥៧.** ដើមបណ្តឹងរដ្ឋប្បវេណី កុល ណៃម
ផ្តល់សក្ខីកម្ម ២៤ តុលា ២០១៦



**៥៨.** ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត
ផ្តល់សក្ខីកម្ម ២៤ តុលា ២០១៦



**៥៩.** ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន
ផ្តល់សក្ខីកម្ម ២៥ តុលា ២០១៦



**៦០.** ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ
ផ្តល់សក្ខីកម្ម ១១ វិច្ឆិកា ២០១៦



**៦១.** **ដើមបណ្តឹងរដ្ឋប្បវេណី**
ជាវ នៀបហៅ ខៀវ នាប
ផ្តល់សក្ខីកម្ម ១ ធ្នូ ២០១៦



**៦២.** **ដើមបណ្តឹងរដ្ឋប្បវេណី** ព្រាប ធុន
ផ្តល់សក្ខីកម្ម ៥ ធ្នូ ២០១៦



**៦៣.** **ដើមបណ្តឹងរដ្ឋប្បវេណី** សុន ឯម
ផ្តល់សក្ខីកម្ម ២១ វិច្ឆិកា ២០១៦



# ៥. សេចក្តីសង្ខេប នៃសាលក្រម សំណុំរឿង ០០២/០១

# សេចក្តីសង្ខេបនៃសាលក្រម សំណុំរឿង ០០២/០១




## ១. សេចក្តីផ្តើម

១. ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១។ សំអាងហេតុដែលមានអានុភាពតាមផ្លូវច្បាប់គឺជាសំអាងហេតុ ដែលសរសេរពេញលេញជាលាយលក្ខណ៍អក្សរនៅក្នុងសាលក្រមដែលអាចរកបានភ្លាមៗ ជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ក្រោយពីសវនាការប្រកាសសាលក្រមនេះ។

២. សំណុំរឿង ០០២ ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ នួន ជា និង ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥រហូតដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។ ក្រោយពីសហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ដែលបានបញ្ចប់ការស៊ើបអង្កេតតាមផ្លូវតុលាការដោយប្រើរយៈពេលអស់ជិត ៣ ឆ្នាំ នួន ជា និងខៀវ សំផន ត្រូវបានបញ្ជូនមកជំនុំជម្រះ ។ ដំបូងឡើយ សំណុំរឿងនេះមានរួមបញ្ចូលជនជាប់ចោទពីរនាក់ផ្សេងទៀត គឺ អៀង ធីរិទ្ធ និង អៀង សារី។ នៅក្នុងឆ្នាំ ២០១១ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង អៀង ធីរិទ្ធ ត្រូវបានផ្អាក ហើយបទចោទប្រកាន់ទាំងឡាយប្រឆាំងនឹងរូបគាត់ ត្រូវបានបំបែកចេញពីសំណុំរឿង បន្ទាប់ពី អង្គជំនុំជម្រះរកឃើញថាគាត់មិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការ ដោយសារតែជំងឺវង្វេងវង្វាន់ស្មារតីដែលចេះតែវិវត្តន៍ទៅមុខ។ មរណភាពរបស់ អៀង សារី ក្នុងឆ្នាំ ២០១៣ បានរំលត់បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីទាំងអស់ប្រឆាំងនឹងរូបគាត់នៅចំពោះមុខអ.វ.ត.ក។

៣. នៅក្នុងអំឡុងពេលចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ នួន ជា ត្រូវបានចោទប្រកាន់ថាជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ជាប្រធានសភាតំណាងប្រជាជន ហើយពេលខ្លះជានាយករដ្ឋមន្ត្រីស្តីទីនៃរដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ខៀវ សំផន ត្រូវបានចោទប្រកាន់ថាមានតួនាទីជាច្រើននៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ ដោយតួនាទីទាំងនោះរួមមាន ជាប្រធានគណៈប្រធានរដ្ឋផងដែរ។ គាត់ក៏ត្រូវបានចោទប្រកាន់ផងដែរថា ជាប្រធានមន្ទីរនយោបាយ ៨៧០ និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា។

៤. សវនាការបឋមក្នុងសំណុំរឿង ០០២ ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១។ នៅខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ ទៅជាការជំនុំជម្រះតូចៗមួយចំនួន ដោយសារតែទំហំ និងភាពស្មុគស្មាញនៃដីកាដំណោះស្រាយព្រមទាំងបញ្ហាវ័យចាស់ និងសុខភាពរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះសាលាដំបូងបានកម្រិតវិសាលភាពសម្រាប់ការជំនុំជម្រះវគ្គដំបូងនៃសំណុំរឿង ០០២ (ដែលចាប់ពីពេលនោះមកត្រូវបានហៅថាជា «សំណុំរឿង០០២/០១») ត្រឹមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ (ដែលនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ ត្រូវបាន ហៅថា «ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)» និងការផ្លាស់ទីលំនៅប្រជាជននៅតាមតំបន់ផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ រហូតដល់ខែធ្នូ ឆ្នាំ១៩៧៧ («ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)»)។ អង្គជំនុំជម្រះសាលាដំបូងចាប់ផ្តើមធ្វើសវនាការពិនិត្យភស្តុតាងនៅថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០១១ ហើយនៅក្នុងខែ តុលា ឆ្នាំ ២០១២ បន្ទាប់ពីបានទទួលសំណើពីការិយាល័យសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចពង្រីកវិសាលភាពពាក់ព័ន្ធនឹងបទចោទនានានៅក្នុងសំណុំរឿង ០០២/០១ ដោយដាក់បញ្ចូលនូវបទចោទនានា ពាក់ព័ន្ធនឹងការសម្លាប់អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ នៅខែមេសា ឆ្នាំ ១៩៧៥។

៥. វិសាលភាពនៃបទចោទនានាដែលទាក់ទងនឹងសំណុំរឿង ០០២/០១ រួមមាន ការចោទប្រកាន់ទៅលើអង្គហេតុនានា ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទចំពោះឧក្រិដ្ឋកម្មដូចតទៅ៖

- ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជនជាប់ចោទត្រូវបានចោទប្រកាន់ថាត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល អំពើអមនុស្សធម៌ផ្សេងៗទៀត (ក្នុងទម្រង់ជាការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ) និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ក្នុងទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស)។

- ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនចេញ ចូល និងនៅក្នុងភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) ភូមិភាគនិរតី ភូមិភាគបូព៌ា និងភូមិភាគបស្ចិម ចាប់ពីខែ កញ្ញា ឆ្នាំ ១៩៧៥ ដល់ខែ ធ្នូ ឆ្នាំ ១៩៧៧ ជនជាប់ចោទត្រូវបានចោទប្រកាន់ថាត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងៗទៀត (ក្នុងទម្រង់ជាការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ) អំពើអមនុស្សធម៌ផ្សេងៗទៀត (ក្នុងទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) ព្រមទាំងអំពើអមនុស្សធម៌ផ្សេងៗទៀត (ក្នុងទម្រង់ជាការបាត់ខ្លួនដោយបង្ខំ)។

- ពាក់ព័ន្ធទៅនឹងទួលពោធិ៍ជ្រៃ ជនជាប់ចោទត្រូវបានចោទប្រកាន់ថាត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចំពោះ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាលនិងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

៦. ជនជាប់ចោទម្នាក់ៗត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ តាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមដែលមានគោលបំណងរួម ដើម្បីអនុវត្តបដិវត្តសង្គមនិយមឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា តាមរយៈដំណើរការ «មហាលោតផ្លោះ មហាអស្ចារ្យ» និងដើម្បីការពារបក្សប្រឆាំងនឹងខ្មាំង តាមគ្រប់មធ្យោបាយដែលចាំបាច់។ ដើម្បីសម្រេចគោលបំណងរួមនេះ ជនជាប់ចោទត្រូវបានចោទប្រកាន់ថា បានរៀបចំបង្កើតគោលនយោបាយមួយចំនួន ដែលការអនុវត្តគោលនយោបាយនេះបានបណ្តាលឲ្យ និង/ឬ មានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយចំនួន ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ ហើយដែលជនជាប់ចោទមានចេតនាប្រព្រឹត្ត។ ជនជាប់ចោទក៏ត្រូវបានចោទប្រកាន់បន្ថែមទៀតថា បានរៀបចំផែនការ បានបញ្ជា បានញុះញង់ ជួយ និងជំរុញ ឲ្យកើតមាននូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានរៀបរាប់ខាងលើ។ ជាចុងក្រោយ ជនជាប់ចោទក៏ត្រូវបានចោទប្រកាន់ផងដែរថា ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។

៧. ក្នុងអំឡុងពេលសវនាការលើភ័ស្តុតាងដែលមានរយៈពេល ២០ ខែ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មរបស់បុគ្គលចំនួន ៩២ រូប ដែលរួមមាន អ្នកជំនាញចំនួន ៣ រូប សាក្សីអង្គហេតុចំនួន ៥៣ រូប សាក្សីអត្តចរិតចំនួន ៥ រូប និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣១ រូប។ ឯកសារភ័ស្តុតាងជាង ៥.៨០០ ឯកសារ ត្រូវបានយកមកពិនិត្យដេញដោល និងទទួលយកដាក់បញ្ចូលទៅក្នុងសំណុំរឿង ដែលសរុបមានឯកសារទាំងបីភាសាជាផ្លូវការចំនួនជាង ២២២.០០០ ទំព័រ។ អង្គជំនុំជម្រះបានទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹករបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ១.១២៤ ដែលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះមិនបានមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះជំនួសឲ្យការផ្តល់សក្ខីកម្មផ្ទាល់មាត់។ សវនាការលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ ត្រូវបានបញ្ចប់នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ត្រូវបានធ្វើឡើងនៅក្នុងខែ តុលា ឆ្នាំ ២០១៣។

៨. មុនពេលចាប់ផ្តើមធ្វើសវនាការពិនិត្យភ័ស្តុតាង អង្គជំនុំជម្រះសាលាដំបូងបានដោះស្រាយទៅលើបញ្ហាអញ្ញត្រកម្ម និងបញ្ហានីតិវិធីជាច្រើន ដែលអង្គជំនុំជម្រះពិចារណាឃើញថាជាឧបសគ្គចម្បងចំពោះការចាប់ផ្តើមសវនាការ ខណៈដែលបញ្ហាផ្សេងៗទៀត ត្រូវបានយកទៅដោះស្រាយនៅក្នុងសាលក្រម។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា អង្គជំនុំជម្រះមានយុត្តាធិការលើ បុគ្គល នួន ជា និង ខៀវ សំផន និងសម្រេចថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវបានចោទប្រកាន់ចំពោះជនជាប់ចោទក្នុងសំណុំរឿង ០០២/០១ គឺស្ថិតនៅក្នុងកម្មវត្ថុនៃការត្រួតពិនិត្យ និងស្ថិតក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។

## ២. បរិបទប្រវត្តិសាស្ត្រ

៩. ជាបឋម អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលលើការវិវត្តផ្នែកប្រវត្តិសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជា និងគោលនយោបាយរបស់បក្សនេះ រួមទាំងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ព្រមទាំងការកំណត់គោលដៅចំពោះអ្នករដ្ឋការស៊ីវិល និងទាហាននៃរបបសាធារណរដ្ឋខ្មែរ។ អង្គជំនុំជម្រះក៏បានពិនិត្យមើល

ទៅលើស្ថានភាពទូទៅនៅក្នុងទីក្រុងភ្នំពេញមុនពេលមានការវាយសម្រុកចុងក្រោយរបស់ខ្មែរក្រហមទៅលើទីក្រុងភ្នំពេញ ដែលបានចាប់ផ្តើមនៅក្នុងខែមករា ឆ្នាំ ១៩៧៥ ហើយបានចូលកាន់កាប់ និងផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញដោយបង្ខំ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។

**១០.** អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ក្នុងឆ្នាំ ១៩៥៩ ទូ សាមុត ប៉ុល ពត និង នួន ជា បានចាប់ផ្តើមដំណើរការបង្កើតបក្សកុម្មុយនីស្តកម្ពុជាថ្មីមួយ ដើម្បីគេចចេញពីឥទ្ធិពលរបស់វៀតណាម ដែលមានចរិតលក្ខណៈជាបក្សកម្មុយនីស្តឥណ្ឌូចិន ជាលើកដំបូង។ គោលការណ៍គ្រឹះរបស់បក្សនេះគឺប្រជាធិបតេយ្យប្រមូលផ្តុំ និងម៉ាក្សលេនីននិយម។ សន្និបាតបក្សលើកទីមួយត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ដែលនៅក្នុងពេលនោះមានការអនុម័តលក្ខន្តិកៈបក្ស និងមានការតែងតាំងគណៈកម្មាធិការដឹកនាំ ។ ទូ សាមុត ត្រូវបានតែងតាំងជា លេខាបក្ស ចំណែក នួន ជា ត្រូវបានតែងតាំងជាអនុលេខាបក្ស ហើយ ប៉ុល ពត និង ម៉ា ម៉ង់ ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍។ បន្ថែមពីលើសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ សមាជិកគណៈកម្មាធិការមជ្ឈិមក៏ត្រូវបានជ្រើសរើសផងដែរ ដោយរួមមាន អៀង សារី, កែវ មាស, ចុង, និង វន វ៉េត។ សន្និបាតបក្សលើកទីពីរនៅខែ កុម្ភៈ ឆ្នាំ ១៩៦៣ ដែលនៅពេលនោះ ប៉ុល ពត ត្រូវបានតែងតាំងជាលេខាបក្ស ហើយ នួន ជា ជាអនុលេខាបក្ស បានបញ្ជាក់សាជាថ្មីអំពីការប្រើប្រាស់ហិង្សានយោបាយ និងហិង្សាបដិវត្តន៍។ នៅក្នុងសន្និបាតបក្សលើកទីបីដែលត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ១៩៧១ បានបញ្ជាក់សាជាថ្មីអំពីមាគ៌ាយុទ្ធសាស្ត្ររបស់បក្ស ដែលត្រូវបានអនុម័តនៅក្នុងសន្និបាតបក្សលើកទីមួយ និងលើកទីពីរ។

**១០.** រហូតដល់ឆ្នាំ១៩៦៩ សេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាបានធ្លាក់ចុះ ហើយមានភាពមិនច្បាស់លាស់អំពីថាតើកម្ពុជាអាចនឹងធ្លាក់ចូលក្នុងសង្គ្រាមនៅក្នុងប្រទេសវៀតណាមដែរ ឬ យ៉ាងណា បើទោះបីជា សម្តេច នរោត្តម សីហនុ មានគោលនយោបាយអព្យាក្រឹត្យជាផ្លូវការក៏ដោយ។ ចាប់ពីឆ្នាំ១៩៦៩ មក ការហិនហោច ការទម្លាក់គ្រាប់បែករបស់អាមេរិកនៅក្នុងប្រទេសកម្ពុជា បានរុញច្រានឲ្យកងទ័ពវៀតណាមខាងជើងកាន់តែខិតចូលមកក្នុងប្រទេស ដែលធ្វើឲ្យវិបត្តិនេះកាន់តែមានភាពតានតឹងថែមទៀត។ នៅក្នុងឆ្នាំ១៩៧០ លន់ នល់ ក្រោមការគាំទ្រពីសហរដ្ឋអាមេរិកបានទម្លាក់ សម្តេច នរោត្តម សីហនុ ដែលនៅពេលនោះទ្រង់កំពុងស្ថិតនៅក្រៅប្រទេសកម្ពុជា។ សម្តេច នរោត្តម សីហនុ ក្រោយមក បានបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ដែលជាចលនានយោបាយមួយដើម្បីប្រយុទ្ធប្រឆាំងនឹងអ្នកទម្លាក់ព្រះអង្គ។ នៅក្នុងខែឧសភា ឆ្នាំដដែលនោះ សម្តេច នរោត្តម សីហនុ ដោយមានការគាំទ្រយ៉ាងស្ងៀមស្ងាត់ពីបក្សកុម្មុយនីស្តកម្ពុជា បានបង្កើតរដ្ឋាភិបាលនិរទេសថ្មីមួយដែលមានឈ្មោះថា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ខៀវ សំផន គឺជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលតាមរយៈតួនាទីនេះគាត់បានដើរតួធ្វើជាអ្នកទំនាក់ទំនងរវាង សម្តេច នរោត្តម សីហនុ និង ប៉ុល ពត។ រដ្ឋបាលរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា មិនមានអំណាចជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាឡើយ បើទោះបីជា សម្តេច នរោត្តម សីហនុ នៅបន្តមានឥទ្ធិពលនៅលើឆាកអន្តរជាតិក៏ដោយ។ តាមពិតទៅបក្សកុម្មុយនីស្តកម្ពុជាទេដែលជាអ្នកទទួលខុសត្រូវលើការតស៊ូប្រដាប់អាវុធនៅក្នុងប្រទេសកម្ពុជានោះ។ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយតឹងរ៉ឹងក្នុងការរក្សាការសម្ងាត់ហើយមិនបង្ហាញអត្តសញ្ញាណ របស់ពួកគេជាសាធារណៈឡើយ។ ពួកគេនិយមប្រើប្រាស់ពាក្យ «អង្គការ» ដែលជាពាក្យមិនច្បាស់លាស់ និងជាពាក្យបិទបាំង សំដៅជាស្ថាប័ន ដែលបានដឹកនាំប្រទេស ហើយដែលប្រជាជនធម្មតា

យល់ថា មានអំណាចគ្រប់គ្រងលើប្រទេសទាំងមូល។ ពួកគេថែមទាំងបានប្រើប្រាស់បុគ្គលសាធារណៈ ដែលទទួលបានការគោរព ដូចជា ខៀវ សំផន និង សម្តេច នរោត្តម សីហនុ ទាំងក្នុងប្រទេស និងអន្តរជាតិ ដើម្បីជាការបិទបាំងចំពោះសកម្មភាព និង គោលនយោបាយរបស់ពួកគេ។

**១២.** តាំងពីមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានបង្កើត និងអនុវត្ត គោលនយោបាយទាំងឡាយដែលជាកម្មវត្ថុនៃសំណុំរឿង ០០២ ។ តាមអានុភាពនៃដីកាសម្រេចបំបែក កិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង គោលនយោបាយពីរក្នុងចំណោមគោលនយោបាយ ទាំងប្រាំ បានក្លាយជាកម្មវត្ថុនៃការចោទប្រកាន់ ដែលត្រូវបានលើកយកមកជំនុំជម្រះ នៅក្នុង សំណុំរឿង ០០២/០១ ហើយត្រូវបានពិនិត្យយ៉ាងលម្អិត។ គោលនយោបាយទាំងពីរនោះគឺ ទីមួយ ការ ផ្លាស់ទីលំនៅប្រជាជនជាបន្តបន្ទាប់ពីទីក្រុង និងទីប្រជុំជន ទៅកាន់តំបន់ជនបទ ព្រមទាំងពីតំបន់ ជនបទមួយ ទៅកាន់តំបន់ជនបទមួយផ្សេងទៀត និងទីពីរ ការកំណត់គោលដៅទៅលើក្រុមជាក់លាក់ មួយចំនួន ជាពិសេស សំដៅទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ រួមទាំង អ្នករដ្ឋការស៊ីវិល និងអតីតនាយទាហាន ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ។ គោលនយោបាយដទៃទៀតនឹងត្រូវលើកយក មកពិនិត្យលម្អិតនៅក្នុងសំណុំរឿង ០០២/០២ និងការជំនុំជម្រះក្រោយៗទៀត ។

**១៣.** ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន អង្គជំនុំជម្រះយល់ឃើញថា ចាប់តាំងពីឆ្នាំ ១៩៧០ មក ប្រជាជនត្រូវបានខ្មែរក្រហមបង្ខំឲ្យផ្លាស់ទីលំនៅចេញពីភូមិ ហើយបញ្ជូនទៅកាន់តំបន់ដាច់ស្រយាល។ មានវិធីសាស្ត្រដូចគ្នាក្នុងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ដែលបានឈានដល់កម្រិតខ្ពស់បំផុត នៅ ពេលខ្មែរក្រហមបានត្រួតត្រាប្រទេសទាំងមូល ហើយប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញ និង ទីក្រុងនានាដទៃទៀត ត្រូវបានផ្លាស់ទីលំនៅចេញទាំងអស់។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុក អ្នកទីក្រុងថាមិនស្មោះត្រង់ ហើយបានសន្និដ្ឋានថា ពួកគេអាក្រក់ ទាំងផ្នែកនយោបាយ និងផ្នែក មនោគមន៍វិជ្ជា ហើយពិបាកគ្រប់គ្រងពួកគេ ប្រសិនបើអនុញ្ញាតឲ្យពួកគេស្នាក់នៅក្នុងទីក្រុង។ អង្គជំនុំជម្រះ សាលាដំបូងរកឃើញថា ការជម្លៀសប្រជាជនចេញពីទីក្រុងមានហេតុផលពីរយ៉ាង គឺ ដើម្បីទប់ស្កាត់ ខ្មាំងមិនឲ្យបង្កអស្ថេរភាពដល់កម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជា និងដើម្បីទប់ស្កាត់កម្មាភិបាលកុំឲ្យ ពុករលួយតាមអ្នកទីក្រុង។

**១៤.** ពាក់ព័ន្ធនឹងគោលនយោបាយកំណត់គោលដៅ បើទោះបីជាមិនមានសេចក្តីណែនាំជាលាយលក្ខណ៍អក្សរ ចំពោះបញ្ហានេះក៏ដោយ តែអង្គជំនុំជម្រះរកឃើញថា បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតគោលនយោបាយ កំណត់គោលដៅចំពោះអ្នករដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ។ គោលនយោបាយពាក់ព័ន្ធនឹង ការចាប់ខ្លួនទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានអនុវត្តកាន់តែតឹងតែងចាប់ពីឆ្នាំ ១៩៧០ រហូតដល់ឆ្នាំ ១៩៧៥។ ពីដំបូងឡើយ មានការបែងចែកខុសគ្នារវាងទាហាន លន់ នល់ និងអ្នកដែលត្រូវ បានគេចោទថា ជា «គិញ»៖ ជាញឹកញាប់ ទាហានត្រូវបានគេយកទៅអប់រំកែប្រែ ហើយត្រូវបានលើកលែង ទោស ចំណែកឯគិញវិញត្រូវបានគេសម្លាប់ចោល។ ប៉ុន្តែចាប់តាំងពីអំឡុងឆ្នាំ ១៩៧២ ដល់ឆ្នាំ ១៩៧៣ ទាហាននៃរបបសាធារណរដ្ឋខ្មែរ មិនសូវត្រូវបានគេលើកលែងទោសទៀតទេ ដោយជាញឹកញាប់ ពួកគេត្រូវ បានសម្លាប់ចោល ប្រសិនបើពួកកងទ័ពបក្សកុម្មុយនីស្តកម្ពុជាចាប់ខ្លួនពួកគេបាន។ ការប្រែប្រួលនូវគោល នយោបាយក្នុងការកំណត់គោលដៅទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនេះ ត្រូវបានកត់សម្គាល់

តាមរយៈការកើនឡើងនៃការប្រើប្រាស់ហិង្សា។ នៅពេលប៉ុន្មានខែជិតដល់ពេលវាយសម្រុកចុងក្រោយទៅលើទីក្រុងភ្នំពេញនោះ រណសិរ្សរួបរួមជាតិកម្ពុជាបានប្រើប្រាស់ភាសាផ្សះផ្សានៅក្នុងការផ្សព្វផ្សាយតាមវិទ្យុចំពោះទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដោយប្រាប់ដល់ពួកគេឲ្យផ្ដាច់ខ្លួន និងចូលរួមជាមួយខ្មែរក្រហម។ អង្គជំនុំជម្រះរកឃើញថា សារទាំងអស់នេះ គឺជាការព្យាយាមដោយមានការគិតទុកជាមុន ដើម្បីកាត់បន្ថយការប្រឆាំងចំពោះការវាយចូលរបស់ពួកខ្មែរក្រហម និងដើម្បីបោកបញ្ឆោតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរឲ្យយល់ថាពួកគេមានសុវត្ថិភាព។

## ៣. ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១

**១៥.** អង្គជំនុំជម្រះសាលាដំបូងរកឃើញថា នៅព្រឹកថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ កងទ័ពខ្មែរក្រហមមកពីភូមិភាគនានានៅទូទាំងប្រទេសកម្ពុជា បានវាយសម្រុក និងចូលមកក្នុងទីក្រុងភ្នំពេញពីទិសដៅនានា។ កងពលធំនានារបស់ខ្មែរក្រហមបានគ្រប់គ្រងតំបន់ផ្សេងៗនៅក្នុងទីក្រុងភ្នំពេញ។ នៅប៉ុន្មានម៉ោងបន្ទាប់ពីខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ ប្រជាជនបានអបអរសាទរ ដោយជឿជាក់ថា សន្តិភាពនឹងវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញហើយ។ ប៉ុន្តែ នៅប៉ុន្មានម៉ោងក្រោយមកទៀត ពួកខ្មែរក្រហមបានចាប់ផ្ដើមបង្គាប់ឲ្យប្រជាជនចាកចេញពីភ្នំពេញភ្លាមៗ។ ខ្មែរក្រហមបានប្រាប់ប្រជាជនក្នុងទីក្រុងថា ការជម្លៀសនេះធ្វើឡើងជាបណ្ដោះអាសន្នទេ ហើយការជម្លៀសនេះមានគោលបំណងការពារប្រជាជនឲ្យរួចពីការទម្លាក់គ្រាប់បែករបស់ពួកអាមេរិក ឬក៏ដើម្បីឲ្យអង្គការអាចធានាពីសុវត្ថិភាពនៅក្នុងទីក្រុង។ សូម្បីតែប្រជាជនដែលមិនជឿលើការលើកឡើងរបស់ខ្មែរក្រហមទាំងនេះ ក៏ត្រូវតែចេញពីភ្នំពេញដែរ ដោយសារតែពួកគេទទួលរងការគំរាមកំហែងពីកងទ័ពខ្មែរក្រហម។

**១៦.** កងទ័ពខ្មែរក្រហម ទទួលបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងតាមគ្រប់មធ្យោបាយ។ ប្រជាជនទីក្រុងភ្នំពេញបានទទួលរងការគំរាមកំហែង និងការធ្វើបាបលើរូបរាងកាយ។ អ្នកដែលមិនស្ដាប់តាម ឬ រឹងទទឹងត្រូវបានគេបាញ់ចោល និងសម្លាប់ចោលនៅនឹងកន្លែង។ ទោះបីជាមានកំដៅក្ដៅខ្លាំងយ៉ាងណាក៏ដោយ ក៏ប្រជាជនទាំងអស់ក្នុងទីក្រុងភ្នំពេញ ត្រូវបានបង្ខំឲ្យចាកចេញ ដោយគ្មានការលើកលែងឡើយ រួមទាំងព្រះសង្ឃ មនុស្សចាស់ជរា កុមារ អ្នកជំងឺ និងអ្នករបួសក្នុងមន្ទីរពេទ្យ ស្ត្រីមានផ្ទៃពោះ និងស្ត្រីទើបឆ្លងទន្លេរួចជាដើម។ ដើមបណ្ដឹងរដ្ឋប្បវេណី ពិន យ៉ាថៃ បានពិពណ៌នាថា នៅពេលដែលពួកគាត់ធ្វើដំណើរចាកចេញពីទីក្រុងកាន់តែឆ្ងាយ អ្នកជំងឺ អ្នករបួស អ្នកទន់ខ្សោយ និងជនចាស់ជរា កាន់តែច្រើន បានត្អូញត្អែរអំពីការអស់កម្លាំង ហើយពួកគេ បានឃើញសាកសពដែលទុកចោលនៅតាមផ្លូវកាន់តែច្រើនឡើងៗ។ អ្នកស្រី ពេជ ស្រីផល បានបញ្ជាក់ថា នៅពេលដែលពួកគាត់ទៅដល់ស្ទឹងមានជ័យ ពួកគាត់បានឃើញសាកសពនៅលើគ្រែពេទ្យ ដែលគេទុកចោលតាមផ្លូវ។ អ្នកស្រី ពេជ ស្រីផល ដោយសារតែគ្មានទឹកដោះគោ ទឹកដោះម្ដាយ ឬថ្នាំពេទ្យសម្រាប់កូនគាត់ គាត់ត្រូវបំបៅកូនដោយទឹកតែប៉ុណ្ណោះ ហើយមិនយូរប៉ុន្មាន កូនរបស់គាត់បានស្លាប់ ហើយគេបានបង្គាប់គាត់ឲ្យកប់សាកសពកូននោះនៅក្នុងព្រៃ។ អ្នកដទៃទៀត ដូចជា កូនស្រីពៅរបស់អ្នកស្រី បៃ សុផានី មានជំងឺរាកមួល ក្អួត ហើយបានស្លាប់ដោយសារតែគ្មានថ្នាំសង្កូវព្យាបាល។

**១៧.** នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនក្នុងទីក្រុងភ្នំពេញមានចំនួនប្រមាណពី ២.០០០.០០០ ទៅ

២.៥០០.០០០ នាក់។ ប្រជាជនជាច្រើនបានគេចខ្លួនមកទីក្រុងដើម្បីគេចចេញពីការវាយប្រយុទ្ធ និងការបាញ់ផ្លោងនៅតំបន់ផ្សេងៗ។ បន្ទាប់ពីទទួលបានបញ្ជាឲ្យចាកចេញពីទីក្រុង ប្រជាជនទាំងនោះបានប្រើប្រាស់គ្រប់មធ្យោបាយដែលពួកគាត់មាន ដើម្បីចាកចេញពីភ្នំពេញដោយភាគច្រើនធ្វើដំណើរដោយថ្មើរជើង តែមានអ្នកខ្លះធ្វើដំណើរតាមកង់ តាមរទេះរុញ និងតាមឡាន ដែរ។ ការធ្វើដំណើរជួបប្រទះការលំបាកវេទនាយ៉ាងខ្លាំង ដោយសារកង្វះអាហារ ទឹកផឹក ថ្នាំពេទ្យ និងជម្រកស្នាក់នៅ ហើយអ្នកដែលត្រូវគេជម្លៀសជាច្រើនត្រូវទទួលរងភាពភ័យរន្ធត់ការគំរាមកំហែងឬក៏រងអំពើហិង្សាពីសំណាក់កងទ័ពខ្មែរក្រហម។ មានហេតុការណ៍ជាច្រើនដែលកងទ័ពខ្មែរក្រហមបានបាញ់ និងសម្លាប់ប្រជាជនស៊ីវិលក្នុងពេលជម្លៀស ហើយប្រជាជនដទៃទៀតជាច្រើនបានស្លាប់ដោយសារការហេវហត់អស់កម្លាំងខ្លាំង កង្វះអាហារូបត្ថម្ភ ឬជំងឺ។ ដើមបណ្តឹងរដ្ឋប្បវេណី ឆេង អេងលី បានរម្លឹកថា ខ្លួនបានឃើញកងទ័ពខ្មែរក្រហមចាប់ហែកទារកម្នាក់ដែលកំពុងតែយំ ហើយកំពុងតែវារលើសាកសពម្តាយរបស់វា។ អ្នកត្រូវបានគេជម្លៀសជាច្រើន រួមទាំងកូនក្មេងផងនោះ ត្រូវបានបំបែកចេញពីក្រុមគ្រួសាររបស់ពួកគេ។

**១៨.** ខ្មែរក្រហមបានបង្កើតប៉ុស្តិ៍ត្រួតពិនិត្យជាច្រើនតាមបណ្តោយផ្លូវចេញពីទីក្រុងភ្នំពេញ និងតាមទីប្រជុំជនមួយចំនួនផ្សេងទៀត ដោយនៅតាមប៉ុស្តិ៍ទាំងនោះ ប្រជាជនត្រូវបានគេឆែកឆេរ និងសាកសួរពីប្រវត្តិរូប ពីសមាជិកក្រុមគ្រួសារ និងពីការងារដែលពួកគេបានធ្វើនៅភ្នំពេញ។ ប្រជាជនជាច្រើនដែលត្រូវបានកំណត់អត្តសញ្ញាណដោយពួកខ្មែរក្រហមថា ជាអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានគេចាប់ខ្លួន ហើយបន្ទាប់មកបានបាត់ខ្លួន ឬក៏ត្រូវគេសម្លាប់នៅប៉ុន្មានថ្ងៃក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ អ្នកដែលត្រូវបានគេជម្លៀសចេញពីភ្នំពេញទាំងអស់បានធ្វើដំណើរអស់រយៈពេលជាច្រើនថ្ងៃ ឬ ច្រើនសប្តាហ៍ ហើយបានតាំងទីលំនៅតាមទីជនបទនៅក្នុងភូមិភាគនានា នៅទូទាំងប្រទេស។

**១៩.** អង្គជំនុំជម្រះសាលាដំបូងរកឃើញថា យ៉ាងតិចក៏មានប្រជាជនចំនួនពីរលាននាក់ត្រូវបានកងទ័ពខ្មែរក្រហមបង្ខំឲ្យចាកចេញពីទីក្រុងភ្នំពេញ ដោយប្រើប្រាស់លេសកុហកបោកបញ្ឆោត និងការគំរាមកំហែង ភាគច្រើនដោយប្រើកាំភ្លើងភ្ជង់ ដោយសឹងតែគ្មានប្រាប់ជាមុន ហើយធ្វើឡើងក្នុងកាលៈទេសៈមានការភ័យរន្ធត់ និងដោយមានអំពើហិង្សា ដែលបណ្តាលឲ្យប្រជាជនជាច្រើនត្រូវបានសម្លាប់ចោល ឬបានស្លាប់ដោយសារការហេវហត់អស់កម្លាំងខ្លាំង ការអត់អាហារ ឬជំងឺផ្សេងៗ។ អង្គជំនុំជម្រះមិនជឿលើការលើកឡើងរបស់មេធាវីការពារក្តីដែលថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺដើម្បីការពារសុវត្ថិភាពប្រជាជនពីការទំលាក់គ្រាប់បែករបស់អាមេរិក។ ផ្ទុយទៅវិញ មេដឹកនាំរបស់បក្សកុម្មុនីស្តកម្ពុជាខ្លួនឯងជាច្រើន បានមកទីក្រុងភ្នំពេញ បន្ទាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានស្នាក់នៅក្នុងទីកន្លែងនានា ដោយគ្មានការរៀបចំវិធានការការពារទីតាំងរបស់ពួកគេប្រឆាំងនឹងការទម្លាក់គ្រាប់បែកសោះឡើយ ដែលតាមពិតបានបញ្ចប់តាំងពីឆ្នាំ ១៩៧៣ មកម្ល៉េះ។ ដូចគ្នានេះដែរ អង្គជំនុំជម្រះមិនជឿទេថា ការខ្វះស្បៀងអាហារនៅទីក្រុងភ្នំពេញ គឺជាមូលហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះ។ កងទ័ពរបស់បក្សកុម្មុនីស្តកម្ពុជា បានវាយប្រហារតាមដងទន្លេមេគង្គ និងព្រលានយន្តហោះពោធិ៍ចិនតុង ដែលទីកន្លែងទាំងពីរនេះ គឺជាកន្លែងដែលត្រូវបានប្រើប្រាស់ខ្លាំង សម្រាប់ផ្គត់ផ្គង់ស្បៀងអាហារដល់ប្រជាជនរស់នៅក្នុងទីក្រុងមុនពេលភ្នំពេញដួលរលំ។ ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានគ្រប់គ្រងផ្លូវគមនាគមន៍ទាំងអស់ រួមទាំងទន្លេមេគង្គ និងព្រលានយន្តហោះពោចិនតុងដែលនៅដំណើរការនៅឡើយ និងផែកំពង់សោមដែលពីមុនធ្លាប់បានប្រើប្រាស់សម្រាប់ការការផ្គត់ផ្គង់នាំចូល។ បើទោះបីជាមានការខ្វះខាត

ស្បៀងអាហារក៏ដោយ ក៏មេដឹកនាំបក្សកុម្មុនីស្តកម្ពុជាដោយអនុវត្តជំហរឯករាជ្យ និងចំណេះរបស់ខ្លួនបាន បដិសេធជំនួយមនុស្សធម៌របស់បរទេស លុះត្រាតែជាជំនួយគ្មានលក្ខណ្ឌ ហេតុដូច្នេះហើយ ទើបមិនមាន ការធានាស្បៀងអាហារគ្រប់គ្រាន់ដើម្បីផ្តល់ឲ្យអ្នករស់នៅទីក្រុងភ្នំពេញ។ ហេតុដូច្នេះ អង្គជំនុំជម្រះ បដិសេធ សេចក្តីសន្និដ្ឋានដែលថា វាមានភាពចាំបាច់ និងមានភាពសមាមាត្រ នៅក្នុងការលៈទេសៈនេះ ដើម្បីជម្លៀស ប្រជាជនចេញឲ្យអស់ពីទីក្រុងភ្នំពេញទាំងមូល។

២០. ការសន្និដ្ឋានសមហេតុផលតែមួយគត់ គឺថា ដោយផ្អែកទៅលើបទពិសោធន៍ និងការអនុវត្តពីមុនរបស់បក្ស ក្នុងការជម្លៀសប្រជាជនចេញពីតំបន់ដទៃទៀត និងសម្រាប់ហេតុផលយោធាសេដ្ឋកិច្ច និងមនោគមវិជ្ជា នោះថ្នាក់ដឹកនាំបានសម្រេចចិត្តជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដើម្បីឲ្យថ្នាក់ដឹកនាំអាចគ្រប់គ្រង ប្រជាជនបានល្អ និងការពារកុំឲ្យខ្មាំងបង្កអស្ថេរភាពដល់កងទ័ពបក្សកុម្មុយនីស្តកម្ពុជា។

## ៤. ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)

២១. អង្គជំនុំជម្រះយល់ឃើញថា ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ការការពារ និងការកសាងប្រទេស បានក្លាយជាមាគ៌ាចម្បងរបស់បក្ស។ បក្សបានផ្តោតសំខាន់លើការកសាង និងការពង្រីកសហករណ៍ ដើម្បី ពង្រឹងការតស៊ូវណ្ណៈទាំងពីរ ពោលគឺ «ភាពផ្តាច់ការនៃវណ្ណៈអធន» និង ផលកសិកម្ម ដើម្បីធានាបាននូវ បដិវត្តន៍សង្គមនិយម។ ដើម្បីកសាង និងពង្រីកសហករណ៍ឲ្យបាននោះ បក្សត្រូវផ្លាស់ទីលំនៅប្រជាជន។ មេដឹកនាំបក្សមានជំនឿថា ការផ្លាស់ទីលំនៅប្រជាជនអនុញ្ញាតឲ្យបក្សអាចជម្នះលើបញ្ហាប្រឈមនានាក្នុង ការកសាង និងការពារប្រទេស និងក្នុងការរៀបចំប្រជាជន សេដ្ឋកិច្ច នយោបាយ និងយោធាឡើងវិញ។

២២. អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ១៩៧៧ មានប្រជាជន យ៉ាងតិចបំផុតក៏បីទៅបួនសែននាក់ ត្រូវបានគេផ្លាស់ទីលំនៅដោយបង្ខំចេញពីទីតាំងមួយចំនួនក្នុងខេត្ត កណ្តាល កំពង់ធំ កំពង់ចាម តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ព្រៃវែង និងស្វាយរៀង (ភូមិភាគកណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា) ទៅកាន់ខេត្តបាត់ដំបង និងពោធិ៍សាត់ (ភូមិភាគពាយ័ព្យ) ខេត្តកំពង់ធំ (ភូមិភាគកណ្តាល) និងខេត្តព្រះវិហា (តំបន់ ១០៣)។ អង្គជំនុំជម្រះរកឃើញទៀតថា ចាប់ពី ខែកញ្ញា ឆ្នាំ១៩៧៥ ដល់ខែធ្នូ ឆ្នាំ១៩៧៧ មានប្រជាជនជាងបីសែននាក់ត្រូវបានគេផ្លាស់ទីលំនៅទៅ កាន់ខេត្តក្រចេះ (តំបន់ ៥០៥) ព្រមទាំងមានការផ្លាស់ទីលំនៅ នៅក្នុង និងចេញពីខេត្តព្រៃវែង និង ខេត្តស្វាយរៀង (ភូមិភាគបូព៌ា) និងនៅក្នុងខេត្តកំពង់ធំ និងកំពង់ចាម (ភូមិភាគកណ្តាល) និងនៅ ក្នុងខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ)។ មិនមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីឲ្យអង្គជំនុំជម្រះ ដោយផ្អែកលើ លក្ខខណ្ឌតម្រូវនៃភ័ស្តុតាង សន្និដ្ឋានថា មានប្រជាជន ត្រូវបានគេផ្លាស់ទីលំនៅទៅកាន់ខេត្តសៀមរាប (តំបន់ ១០៦) និងទៅខេត្តកំពង់ចាម (ភូមិភាគកណ្តាល) នោះទេ។

២៣. នៅក្នុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ ប្រជាជនភាគច្រើនត្រូវបានគេបញ្ជាឲ្យចាកចេញពី ទីកន្លែងរបស់ពួកគេ ហើយត្រូវបានផ្លាស់ទីលំនៅ ដោយមានការតាមឃ្លាំមើលពីសំណាក់កងទ័ពប្រដាប់ អាវុធ។ អ្នកណាដែលបដិសេធមិនផ្លាស់ទីលំនៅ ឬមានបំណងរត់គេច ត្រូវចាប់ខ្លួន ឃុំខ្លួន ឬត្រូវបានគេ បញ្ជូនទៅតាមការជម្លៀសក្នុងដំណាក់កាលក្រោយបន្ថែមទៀត។ កងទ័ពខ្មែរក្រហមមិនបានជួយ ហើយជា

ញើកញ្ញាប់មិនបានផ្តល់ព័ត៌មានអំពីគោលដៅរបស់អ្នកដែលត្រូវគេផ្លាស់ទីលំនៅនោះឡើយ។ កងទ័ព និងកម្មាភិបាលខ្មែរក្រហម បានផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ តាមមធ្យោបាយផ្សេងៗ ជាច្រើន ដូចជាការគំរាមកំហែង ការបង្ខិតបង្ខំ និងការបោក បញ្ឆោត។ ប្រជាជនទទួលរងការភ័យខ្លាច ហើយត្រូវរស់នៅក្នុងស្ថានភាពភ័យរន្ធត់ មិនហ៊ាន ឬមិនអាច មិនគោរពតាម ឬសួរនាំពីការបញ្ជាទាំងនោះឡើយ។ ក្នុងពេលឈប់សម្រាកមួយភ្លែតនៅផ្សារសំរោងយោង កូនប្រុសរបស់ គង់ វ៉ាច ដែលមានជំងឺរាគ និងហើមដៃជើងបានស្លាប់។ កងទ័ពខ្មែរក្រហមបានបង្គាប់ឲ្យ គង់ វ៉ាច ទុកសាកសពកូនរបស់គាត់ជាមួយពួកគេ ហើយគាត់មិនបានដឹងថា ពួកគេយកសាកសពកូនរបស់គាត់ទៅធ្វើអ្វីនោះឡើយ។

២៤. ប្រជាជនត្រូវបានគេដឹកជញ្ជូនតាមមធ្យោបាយផ្សេងៗ ដូចជាឡាន ទូក រទេះគោ និងថ្មើរជើង។ ស្ថានភាពនៃការជម្លៀសប្រជាជនគឺអាស្រ័យលើមធ្យោបាយនៃការដឹកជញ្ជូន។ឧទាហរណ៍ ឡានដែលទៅកន្លែងប្រមូលផ្តុំដូចជាភ្នំពេញ និងកំពង់ឆ្នាំង (ភូមិភាគបស្ចិម) មានភាពចង្អៀតណែនតាន់តាប់។ ប្រជាជនត្រូវបានគេតាមដានជាប់ជារហូត ហើយពួកគាត់គ្មានទឹកផឹក និងម្ហូបអាហារគ្រប់គ្រាន់ទេ ហើយមិនអនុញ្ញាតឲ្យពួកគាត់យកអីវ៉ាន់តាមខ្លួនឡើយ។ ប្រជាជនធ្លាក់ខ្លួនឈឺនៅលើឡាន តែពួកគេមិនទទួលបានការជួយជ្រោមជ្រែងអ្វីទាំងអស់។ អ្នកដែលត្រូវបានដឹកជញ្ជូនតាមឡាន ត្រូវបានយាមកាមដោយកងទ័ពខ្មែរក្រហមប្រដាប់ដោយអាវុធ ដែលបានបាញ់ប្រជាជនណាដែលព្យាយាមរត់គេច។ ប្រជាជនជាច្រើនធ្លាក់ខ្លួនឈឺមានជំងឺរាគ ហើយត្រូវតែបន្ទោបង់នៅលើឡានតែម្តង។ ដោយសារតែការហេវហត់អស់កម្លាំងខ្លាំង ការអត់អាហារ ឬជំងឺ ប្រជាជនខ្លះក៏បានស្លាប់។

២៥. អង្គជំនុំជម្រះរកឃើញថា អ្នកដែលសុខចិត្តចាកចេញដោយសារតែស្ថានភាពរស់នៅដ៏លំបាកវេទនានោះ បានចាកចេញពីស្ថានភាពរស់នៅដ៏អាក្រក់ ដែលពួកខ្មែរក្រហមបានបង្កើតឡើងហើយជាយថាហេតុ ការចាកចេញដោយស្ម័គ្រចិត្តដោយដើម្បីទៅរស់នៅកន្លែងថ្មីដោយមានការសន្យាពីពួកខ្មែរក្រហមអំពីការទទួលបានស្ថានភាពរស់នៅមួយដែលប្រសើរជាងនោះ មិនអាចត្រូវបានមើលឃើញកើតមាន តាមការជ្រើសរើសពិតប្រាកដនោះឡើយ។

## ៥. ទួលពោធិ៍ជ្រៃ

២៦. អង្គជំនុំជម្រះយល់ឃើញថា ភ្លាមៗបន្ទាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ យ៉ាងតិចណាស់ ក៏មានអ្នករដ្ឋការនៃរបប លន់ នល់ ប្រមាណ ២៥០ នាក់ ត្រូវបានគេដឹកពីខេត្តពោធិ៍សាត់ទៅទួលពោធិ៍ជ្រៃ ហើយសម្លាប់ចោលនៅទីនោះ។ ការសម្លាប់នោះត្រូវបានធ្វើឡើងដោយកងទ័ពខ្មែរក្រហមមកពីភូមិភាគពាយ័ព្យ។ កងទ័ពមកពីកងវរៈសេនាតូចលេខ ២០១ ឬ២០២ បានទទួលភារកិច្ចឲ្យយាមការពារផ្លូវ នៅពេលធ្វើការសម្លាប់នោះ។ ជនរងគ្រោះដែលរួមទាំងអ្នករដ្ឋការ និងទាហាន លន់ នល់ នៃរបបមុន ដែលបានចុះចាញ់ ហើយមិនបានចូលរួមក្នុងសកម្មភាពប្រឆាំងណាមួយផងនោះ ត្រូវបានគេកំណត់មុខសញ្ញាស្របតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយក្រោយមកយកទៅសម្លាប់ដោយកប់ចោលនៅទួលពោធិ៍ជ្រៃ ឬត្រូវបានរុញបញ្ចូលទៅក្នុងស្រះដោយប្រើប្រាស់គ្រឿងចក្រដែលបញ្ជូនមកដោយគណៈកម្មាធិការភូមិភាគ។

## ៦. ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

**២៧.** អង្គជំនុំជម្រះជឿជាក់ថា ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងរហូតដល់ យ៉ាងហោចណាស់ ខែធ្នូ ឆ្នាំ១៩៧៧ ដែលជាពេលវេលាស្ថិតក្រោមយុត្តាធិការនៃសំណុំរឿង ០០២/០១ នោះ មានការវាយប្រហារជាប្រព័ន្ធ និងក្នុងទ្រង់ទ្រាយធំប្រឆាំងនឹងប្រជាជនស៊ីវិលនៅក្នុងប្រទេស កម្ពុជា។ ការវាយប្រហារនេះ បានកើតឡើងក្នុងទម្រង់ជាច្រើន ដែលក្នុងនោះ មានការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការបាត់ខ្លួនដោយបង្ខំ ការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់មនុស្ស និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ ការវាយប្រហារនេះ បានបណ្តាលឲ្យប្រជាជនស៊ីវិលរាប់លាននាក់នៅក្នុងប្រទេសកម្ពុជារងគ្រោះ ហើយធ្វើឲ្យជនភៀសខ្លួនជាច្រើននាក់បានរត់គេចទៅប្រទេសជិតខាង។ ការវាយប្រហារនេះ ត្រូវបានធ្វើឡើង ដើម្បីជំរុញ និងអនុលោមតាមគោលនយោបាយ និងផែនការរបស់បក្សក្នុងការកសាងសង្គមនិយម និងការការពារប្រទេស។ អង្គជំនុំជម្រះជឿជាក់ថា ការវាយប្រហារនេះមានទ្រង់ទ្រាយធំទាំងផ្នែកវិសាលភាពភូមិសាស្ត្រ ក៏ដូចជាចំនួនជនរងគ្រោះដែរ។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា ការវាយប្រហារនេះ មានលក្ខណៈជាប្រព័ន្ធ ដោយសារតែឧក្រិដ្ឋកម្មដែលមានវិសាលភាព និងទំហំធំបែបនេះ មិនអាចត្រូវបានធ្វើឡើងដោយគ្មានការគ្រោងទុកនោះឡើយ ហើយក៏ត្រូវបានធ្វើឡើងដើម្បីជំរុញ និងអនុលោមតាមគោលនយោបាយបក្ស។ អង្គជំនុំជម្រះយល់ឃើញថា ការវាយប្រហារនេះមានគោលដៅប្រឆាំងនឹងប្រជាជនស៊ីវិលក្នុងប្រទេសកម្ពុជា។

**២៨.** ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) អង្គជំនុំជម្រះយល់ឃើញថា មានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងទម្រង់ជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗ ទៀត ក្នុងទម្រង់ជាការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់មនុស្ស។

**២៩.** ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២ អង្គជំនុំជម្រះយល់ឃើញថា មានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងទម្រង់ជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្នុងទម្រង់ជាការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំ។

**៣០.** ពាក់ព័ន្ធដល់ហេតុការណ៍ផ្សេងៗនៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះយល់ឃើញថា ការសម្លាប់ដែលបានរៀបរាប់ខាងលើ អាចត្រូវបានចាត់ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងទម្រង់ ជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ។

## ៧. សហឧក្រិដ្ឋកម្មរួម

**៣១.** ទាក់ទងនឹងការចោទប្រកាន់អំពីសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះបានសន្និដ្ឋានថា ដីកាដំណោះស្រាយដូចដែលបានកម្រិតត្រឹមវិសាលភាពក្នុងសំណុំរឿង ០០២/០១ មិនបានចោទប្រកាន់ជនជាប់ចោទឲ្យទទួលខុសត្រូវលើការសម្លាប់រង្គាល ដោយផ្អែកលើសហឧក្រិដ្ឋកម្មរួម ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន

ដំណាក់កាលទី១ ឬទី២នោះទេ។ លើសពីនេះទៀត ដីកាដំណោះស្រាយ មិនបានចោទប្រកាន់ជនជាប់ចោទឲ្យទទួលខុសត្រូវលើការបាត់ខ្លួនដោយបង្ខំ ដោយផ្អែកលើសហ-ឧក្រិដ្ឋកម្មរួម ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ នោះដែរ។ ដីកាដំណោះស្រាយក៏មិនបានចោទប្រកាន់ជនជាប់ចោទឲ្យទទួលខុសត្រូវលើការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដោយផ្អែកលើសហឧក្រិដ្ឋកម្មរួម ពាក់ព័ន្ធនឹងហេតុការណ៍ផ្សេងៗ នៅទួលពោធិ៍ជ្រៃដែរ។ ចំពោះឧក្រិដ្ឋកម្មជាក់លាក់ទាំងអស់នេះ អង្គជំនុំជម្រះបានសន្និដ្ឋានថា ដីកាដំណោះស្រាយបានចោទប្រកាន់ជនជាប់ចោទឲ្យទទួលខុសត្រូវ ដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវផ្សេងៗ ជាច្រើន ក្រៅពីសហឧក្រិដ្ឋកម្មរួម។ ទោះជាយ៉ាងណាក៏ដោយ ក៏សហឧក្រិដ្ឋកម្មរួម ត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មផ្សេងៗ ទៀតជាច្រើនដូចបានរៀបរាប់ខាងលើ។

៣២. អង្គជំនុំជម្រះ រកឃើញថា នៅក្នុងអំឡុងពេលដែលពាក់ព័ន្ធក្នុងសំណុំរឿង ០០២/០១ មានបុគ្គលជាច្រើនដែលមានគោលបំណងរួម ក្នុងការអនុវត្តបដិវត្តសង្គមនិយមឆាប់រហ័ស តាមរយៈដំណើរការ «មហាលោតផ្លោះ មហាអស្ចារ្យ» និងការការពារបក្សប្រឆាំងនឹងខ្មាំងខាងក្នុង និងខ្មាំងខាងក្រៅ តាមគ្រប់មធ្យោបាយដែលចាំបាច់ ហើយពួកគេទាំងនោះរួមមានទាំង សមាជិកគណៈ កម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម រដ្ឋមន្ត្រីក្នុងជួររដ្ឋាភិបាល និងលេខាភូមិភាគ (ដូចជា ប៉ុល ពត នួន ជា ខៀវ សំផន អៀង សារី សុន សេន វន វ៉េត តា ម៉ុក សោ ភឹម រស់ ញឹម កុយ ធួន កែ ពក ចាន់ សំ ជូវ ជេត អៀង ធីរិទ្ធ និង ម៉ី ប្រាង)។ ភ័ស្តុតាងបានបង្ហាញថា គោលបំណងរួមនៃការកសាង និងការការពារប្រទេសឲ្យឆាប់រហ័សតាមរយៈបដិវត្តសង្គមនិយម ដោយផ្អែកលើគោលការណ៍នៃការរក្សាការសម្ងាត់ ភាពឯករាជ្យ ខ្លួនទីពឹងខ្លួន និងសមូហភាវូបនីយកម្ម ត្រូវបានបង្កើតឡើងយ៉ាងច្បាស់លាស់ចាប់តាំងពីខែមិថុនា ឆ្នាំ១៩៧៤ និងបន្តអនុវត្តយ៉ាងហោចណាស់រហូតដល់ខែធ្នូ ឆ្នាំ១៩៧៧។

៣៣. អង្គជំនុំជម្រះយល់ឃើញថា មានការអនុវត្តសហឧក្រិដ្ឋកម្មរួម ដើម្បីសម្រេចគោលបំណងរួម តាមរយៈមធ្យោបាយមួយចំនួន ក្នុងនោះមានគោលនយោបាយផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុង និងទីប្រជុំជននានា និងពីទីជនបទមួយទៅកាន់ទីជនបទមួយទៀត។ អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មទាំងឡាយ ដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន ដំណាក់កាលទី១ និងដំណាក់កាលទី២ ត្រូវបានអនុវត្តឡើង ដើម្បីជំរុញផែនការ និងគោលនយោបាយរបស់បក្ស។ អង្គជំនុំជម្រះយល់ឃើញថា បក្សបានបែងចែកប្រជាជនកម្ពុជាទៅតាមវណ្ណៈរបស់ខ្លួន ហើយថា «ប្រជាជនថ្មី» ដែលជាអតីតអ្នករស់នៅក្នុងទីក្រុងទាំងអស់ ដែលត្រូវបានជម្លៀសទៅកាន់ទីជនបទ នៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ត្រូវបានយកទៅអប់រំកែប្រែ។ បក្សកុម្មុយនីស្តកម្ពុជាមិនទុកចិត្ត «ប្រជាជនថ្មី» ឡើយ ពីព្រោះអ្នកទាំងនោះត្រូវបានគេយល់ថាជាខ្មាំងនយោបាយ និងសង្គមរបស់បដិវត្តន៍ និងប្រព័ន្ធសមូហភាព។ លើសពីនេះទៀត សមាសភាពមិនល្អទាំងអស់ ដែលមិនអាចអប់រំកែប្រែបាន និង «ពួកដែលនៅសេសសល់» ទាំងអស់នៃរបបសក្តិភូមិ ចក្រពត្តិ និងមូលធននិយម នឹងត្រូវបានលុបបំបាត់ចោល។ ជនណាដែលបានប្រឆាំង ឬ គេយល់ឃើញ ឬសន្មតថាបានប្រឆាំងនឹងបដិវត្តន៍ និងប្រព័ន្ធសមូហភាពនោះ ត្រូវបានកំណត់ជា គោលដៅនៃការធ្វើបាប និងអំពើហិង្សា។ អង្គជំនុំជម្រះយល់ឃើញទៀតថាសមាជិកសហឧក្រិដ្ឋ-កម្មរួមត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ។

៣៤. អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងអំឡុងពេលដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០២/០១ មានសហឧក្រិដ្ឋកម្មរួម ដែលត្រូវបានអនុវត្តឡើង ដើម្បីសម្រេចគោលបំណងរួម តាមរយៈមធ្យោបាយផ្សេងៗ រួមទាំង តាមរយៈគោលនយោបាយក្នុងការកំណត់គោលដៅទៅលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ អង្គជំនុំជម្រះយល់ឃើញថា ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ ត្រូវបានអនុវត្តឡើង ដើម្បីជំរុញផែនការ និងគោលនយោបាយរបស់បក្ស ហើយថា យ៉ាងហោចណាស់ សមាជិកម្នាក់ក្នុងចំណោមសមាជិកនៃសហឧក្រិដ្ឋកម្មរួម ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ។ នៅពេលនេះ អង្គជំនុំជម្រះធ្វើការសង្ខេបអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទម្នាក់ៗ នៅក្នុងរឿងក្តីនេះ។

## ៨. តួនាទី និងមុខងាររបស់ នួន ជា

៣៥. នួន ជា ដែលមានឈ្មោះកំណើត ឡៅ គឹមលន កើតនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩២៦ នៅភូមិវត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង។ នៅក្នុងឆ្នាំ១៩៤១ គាត់បានផ្លាស់ទៅរស់នៅប្រទេសថៃ ដែលនៅទីនោះគាត់បានសិក្សា និងបម្រើការងារនៅក្រសួងហិរញ្ញវត្ថុ និង ក្រសួងការបរទេសប្រទេសថៃ។ នៅក្នុងឆ្នាំ១៩៥០ គាត់បានចូលរួមជាមួយបក្សកុម្មុយនីស្តថៃ ហើយក្រោយមកបានត្រឡប់មកប្រទេសកម្ពុជាដើម្បីចូលរួមចលនាតស៊ូ។ ក្រោយមក នួន ជា បាន ចូលរួមនៅក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិន។ ចាប់ពីអំឡុងឆ្នាំ១៩៥០ មក នួន ជា កាន់តែមានភាពសកម្មខ្លាំងឡើង នៅពេលដែលគាត់បានចូលរួមនៅក្នុងសកម្មភាពអប់រំ និងឃោសនា។ ក្នុងនាមជាសមាជិក គណៈកម្មាធិការបក្សក្រុង គាត់ក៏បានធ្វើការងារជាសម្ងាត់ផងដែរនៅក្នុងចលនាបដិវត្ត នៅក្នុងទីក្រុងភ្នំពេញ ខណៈពេលដែលគាត់បម្រើការងារជាច្រើនដូចជា គ្រូបង្រៀន អ្នកលក់ដូរ ឬជាស្មៀននៅក្រុមហ៊ុននាំចេញ-នាំចូលមួយ។ នៅក្នុងឆ្នាំ១៩៥៥ ឬឆ្នាំ១៩៥៦ នួន ជា ត្រូវបានគេណែនាំឲ្យស្គាល់ ប៉ុល ពត។ ប៉ុល ពត និង នួន ជា ដែលអ្នកទាំងពីរជាសមាជិកបក្សប្រជាជនបដិវត្តកម្ពុជា ពីដំបូង បានធ្វើការងារជាមួយគ្នាជាជំនួយការឲ្យ ទូ សាមុត។

៣៦. ក្នុងអំឡុងសន្និបាតបក្សលើកទីមួយនៅក្នុងឆ្នាំ១៩៦០ គាត់ត្រូវបានជ្រើសតាំងជាអនុលេខាបក្ស ហើយបក្សបានប្តូរឈ្មោះមកជាបក្សពលករកម្ពុជា។ នួន ជា បានរក្សាមុខតំណែងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជានេះ នៅក្នុងគ្រប់ពេល ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់ក៏ជាសមាជិកពេញសិទ្ធិមួយរូបផងដែរ ទាំងនៅក្នុងគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការ អចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន។ ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៦ នៅពេលខ្លះ នួន ជា បានបំពេញមុខនាទីជាផ្លូវការជានាយករដ្ឋមន្ត្រីស្តីទីនៃរបបកម្ពុជាប្រជាធិបតេយ្យរហូតដល់ឆ្នាំ១៩៧៧ នៅពេលដែល ប៉ុល ពត ចាប់ផ្តើមបន្តមុខនាទីរបស់គាត់វិញ។

៣៧. នួន ជា ទទួលខុសត្រូវជាចម្បងទៅលើបញ្ហាផ្សេងៗ ដែលពាក់ព័ន្ធនឹងការឃោសនា និងការអប់រំកសិករ កម្មាភិបាល និងសមាជិកបក្សផ្សេងទៀត ដោយផ្តោតជាពិសេសទៅលើគោលការណ៍សំខាន់ៗ និងគោលនយោបាយសេដ្ឋកិច្ចរបស់បក្ស។ ការទទួលខុសត្រូវជាផ្លូវការរបស់ នួន ជា ខាងផ្នែកឃោសនាការ និងបញ្ហាពាក់ព័ន្ធនឹងការអប់រំ រួមទាំងកិច្ចការវិន័យសីលធម៌របស់កម្មាភិបាល និងបញ្ហាសន្តិសុខផ្ទៃក្នុងផ្សេងៗទៀត ព្រមទាំងសភាពការណ៍ខ្មាំងជាទូទៅផងដែរ ដោយគាត់បានជំរុញឲ្យវែកមុខ និងកំចាត់ខ្មាំង។

៣៨. អង្គជំនុំជម្រះមិនជឿទៅលើភ័ស្តុតាងដែលថា នួន ជា ជាសមាជិកមួយរូបនៃគណៈកម្មាធិការយោធានៃបក្សកុម្មុយនីស្តកម្ពុជាទេ។ ទោះបីជាយ៉ាងណាក៏ដោយ ការចូលរួមរបស់គាត់នៅក្នុងកិច្ចការយោធា និងសន្តិសុខទាក់ទងគ្នាជាស្វ័យប្រវត្តិទៅនឹងអំណាចដ៏យូរឆ្នាំរបស់គាត់នៅក្នុងបក្សនេះ។ នួន ជា បានចូលរួមយ៉ាងសកម្មក្នុងប្រតិបត្តិការរបស់កងទ័ព ជាពិសេសពាក់ព័ន្ធនឹងសង្គ្រាមប្រឆាំងនឹងវៀតណាម ការទទួលរបាយការណ៍ជាប្រចាំ និងការផ្តល់ការណែនាំពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ ទាំងដោយផ្ទាល់ ឬតាមរយៈសេចក្តីសម្រេចរបស់បក្ស។

៣៩. ដោយសារតួនាទីខ្ពង់ខ្ពស់នៅក្នុងថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា នួន ជា ធ្វើការគ្រប់គ្រងលើសកម្មភាពទាំងអស់របស់បក្ស ដោយលើសពីតួនាទី និងការទទួលខុសត្រូវដែលត្រូវបានប្រគល់ឲ្យគាត់ ជាផ្លូវការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទៅទៀត។ អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ នួន ជា និង ប៉ុល ពត មានអំណាចធ្វើសេចក្តីសម្រេចចុងក្រោយរបស់បក្ស។ ក្នុងឋានៈជាអនុលេខាបក្សការគ្រប់គ្រងរបស់គាត់មិនមែនមានត្រឹមតែការធ្វើសេចក្តីសម្រេចផ្នែកនយោបាយប៉ុណ្ណោះទេ ប៉ុន្តែមានរហូតដល់ខាងផ្នែករដ្ឋាភិបាល និងរដ្ឋបាលរបស់របបកម្ពុជាប្រជាធិបតេយ្យ រួមទាំងកិច្ចការយោធាផងដែរ។

## ៩. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា

៤០. យោងតាមដីកាដំណោះស្រាយ ដែលត្រូវបានកំណត់សម្រាប់សំណុំរឿង ០០២/០១ នួន ជា តាមរយៈសហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះរួមមាន ការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ដែលរួមមានទាំងការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ដែលរួមមានទាំងការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) និងការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលដោយការកាប់សម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។ យោងតាមដីកាដំណោះស្រាយ នួន ជា បានចូលរួមដោយចេតនា ឬបានរួមចំណែកក្នុងការរៀបចំ និងអនុវត្តគោលបំណងរួម ដែលធ្វើឲ្យមាន និង/ឬ ជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងមុន និងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្នុងតួនាទីរបស់គាត់ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា សមាជិកគណៈកម្មាធិការយោធា និងជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និង គណៈកម្មាធិការអចិន្ត្រៃយ៍ នួន ជា បានចូលរួមនៅក្នុងកិច្ចប្រជុំជាន់ខ្ពស់នានា ដែលមានការបង្កើត គោលនយោបាយ ព្រមទាំងបានចូលរួមនៅក្នុងការពន្យល់បង្ហាញអំពី ឯកសារគោលនយោបាយជាផ្លូវការនានារបស់បក្សកុម្មុយនីស្តកម្ពុជា និងនៅក្នុងការអនុម័ត និងជំរុញគោលនយោបាយនានារបស់បក្សកុម្មុយនីស្តកម្ពុជា តាមរយៈសុន្ទរកថា ការឃោសនា និងវគ្គសិក្សានយោបាយ។ ដោយផ្អែកលើមូលដ្ឋាននេះ ដីកាដំណោះស្រាយក៏បានចោទប្រកាន់ផងដែរថា នួន ជា បានរៀបចំផែនការ បញ្ជា ញុះញង់ ជួយ និងជំរុញ ឬម្យ៉ាងទៀត ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះបទឧក្រិដ្ឋទាំងអស់ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១។

**៤១.** អង្គជំនុំជម្រះយល់ឃើញថា នួន ជា បានរួមចំណែកយ៉ាងសំខាន់ចំពោះការរៀបចំផែនការ តាមរយៈការចូលរួមរបស់គាត់នៅក្នុងគោលនយោបាយ និងការឃោសនា ការអប់រំ និងការបណ្តុះ បណ្តាលមហាជន ដែលតាមរយៈកិច្ចការទាំងនេះ គាត់បានរួមចំណែកនៅក្នុងការបង្កើត ការរៀបចំ ផែនការ ការផ្សព្វផ្សាយ និងការអនុវត្តគោលបំណងរួម។ ក្នុងនាមជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ នួន ជា គឺជាតួអង្គដ៏សំខាន់ដែលទទួលខុសត្រូវចំពោះការរៀបចំតាក់តែងគោលនយោបាយរបស់បក្ស។ គាត់បានចូលរួមនៅក្នុងកិច្ចប្រជុំនានា ដែលនៅក្នុងកិច្ចប្រជុំនោះ បានសម្រេចទៅលើការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ និងការផ្លាស់ទីលំនៅប្រជាជនផ្សេងៗទៀត។ នៅមុនពេល និងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានចូលរួមយ៉ាងសកម្មទៅលើការឃោសនា និងការបណ្តុះបណ្តាលកម្មាភិបាលខ្មែរក្រហម និងបានធ្វើជាប្រធាន ជាអ្នកបណ្តុះបណ្តាល ឬជាវាគ្មិននៅក្នុងកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល ឬវគ្គរៀនសូត្រ នានា។ គាត់ក៏បានដើរតួយ៉ាងសំខាន់នៅក្នុងការចេញផ្សាយទស្សនាវដ្តីទង់បដិវត្ត។ អង្គជំនុំជម្រះ យល់ឃើញថា តាមរយៈឯកសារបោះពុម្ពផ្សាយសុន្ទរកថា និងសេចក្តីថ្លែងការណ៍ជាសាធារណៈទាំងនេះ នួន ជា បានជួយដល់ការបែងចែកប្រជាជនដោយញែកចេញពីគ្នារវាងកសិករ «ប្រជាជនមូលដ្ឋាន» និងអ្នកដែលជម្លៀសមកពីទីក្រុងនានា «ប្រជាជនថ្មី» និងបានសាបព្រោះធ្វើឲ្យមានការមិនទុកចិត្តគ្នានៅក្នុងចំណោមកម្មាភិបាល និងប្រជាជននៅតាមទីជនបទ ចំពោះប្រជាជនទីក្រុង។ អង្គជំនុំជម្រះយល់ឃើញថា នួន ជា បានរួមចំណែកយ៉ាងសំខាន់ដល់ការធ្វើឲ្យសម្រេចគោលបំណងរួម ហើយគាត់មានចេតនាជំរុញការអនុវត្តគោលបំណងរួមនេះ តាមរយៈសកម្មភាពទាំងឡាយរបស់គាត់។ ដូចនឹងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមដែរ គាត់ក៏មានចេតនាប្រព្រឹត្តអំពើឧក្រិដ្ឋដែលពាក់ព័ន្ធទាំងឡាយនេះ។ លើសពីនេះទៀត ចំពោះការរួមចំណែករបស់គាត់ក្នុងការរៀបចំមាគ៌ារបស់បក្សស្តីពីការតស៊ូវណ្ណៈ និងគោលនយោបាយក្នុងការកំណត់គោលដៅមកលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ អង្គជំនុំជម្រះក៏ជឿជាក់ដែរថា ដូចនឹងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមដែរ នួន ជា ក៏មានចេតនារើសអើងដែលជាលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១ និងទី២)។

**៤២.** ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា តាមរយៈសហឧក្រិដ្ឋកម្មរួម នួន ជា បានប្រព្រឹត្ត ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងទម្រង់ជា ការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ក្នុងដំណាក់កាលទី១) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមានទាំង ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) និងការធ្វើមនុស្សឃាត ព្រមទាំងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា ជនជាប់ចោទបានរៀបចំផែនការ បញ្ជា ញុះញង់ ជួយ និងជំរុញចំពោះឧក្រិដ្ឋកម្មដែលបានរៀបរាប់ខាងលើ។ ដោយពិចារណាឃើញថា ការចូលរួមរបស់ នួន ជា នៅក្នុងសហឧក្រិដ្ឋកម្មរួម បានគ្របដណ្តប់ទៅលើអំពើទាំងអស់ដែលបង្កើតបានជាមូលដ្ឋាននៃការយល់ឃើញដោយអង្គជំនុំជម្រះ ចំពោះទម្រង់នៃការទទួលខុសត្រូវផ្សេងៗទៀតទាំងអស់នេះ អង្គជំនុំជម្រះ សម្រេចផ្តន្ទាទោសតែចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋទាំងអស់នេះតាមរយៈសហឧក្រិដ្ឋកម្មរួមប៉ុណ្ណោះ។

**៤៣.** ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនានាដែលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួម មិនត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនោះ អង្គជំនុំជម្រះយល់ឃើញថា នួន ជាបានរៀបចំផែនការ បញ្ជាញុះញង់ ជួយនិងជំរុញ ចំពោះឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល (នៅក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ (នៅទួលពោធិ៍ជ្រៃ) និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមានទាំង ការបាត់ខ្លួនដោយបង្ខំ) (ក្នុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២)។

**៤៤.** លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវទាំងដោយផ្ទាល់ និងទទួលខុសត្រូវទាំងក្នុងនាមជាថ្នាក់លើ ចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលផ្លាស់ទីលំនៅ (ដំណាក់កាលទី ១ និងទី ២) ព្រមទាំងការសម្លាប់នៅទួលពោធិ៍ជ្រៃផងដែរ។ ដោយយល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ អង្គជំនុំជម្រះបដិសេធមិនស្វែងរកអំពើពិរុទ្ធដោយផ្អែកទៅលើគោលការណ៍នៃការទទួលខុសត្រូវរបស់ថ្នាក់លើទេ ហើយជាការជំនួសវិញ អង្គជំនុំជម្រះនឹងធ្វើការពិចារណាអំពីតួនាទីថ្នាក់លើរបស់ជនជាប់ចោទនេះ នៅពេលធ្វើការសម្រេចអំពីការផ្តន្ទាទោស។

## ១០. តួនាទី និងមុខងាររបស់ ខៀវ សំផន

**៤៥.** ខៀវ សំផន ហៅ «ហែម» ឬ «ណាន» កើតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣១ នៅឃុំរំចេក ឬ រំចេក ស្រុករំដួល ខេត្តស្វាយរៀង។ គាត់បានចាប់ផ្តើមសិក្សាច្បាប់នៅក្នុងទីក្រុងភ្នំពេញ ហើយបន្ទាប់មកនៅឆ្នាំ១៩៥៣ ក្រោយពីបានទទួលអាហារូបករណ៍ពីរដ្ឋាភិបាលកម្ពុជា គាត់បាន ទៅប្រទេសបារាំងដើម្បីសិក្សាច្បាប់ និងសេដ្ឋកិច្ច។ នៅក្នុងទីក្រុងប៉ារីស ខៀវ សំផន បានចូល «ក្រុមម៉ាក្សនិយម» ដែលត្រូវបានបង្កើតឡើងមុនគាត់ទៅដល់ទីក្រុងប៉ារីស ហើយក្រុមនេះមានការ ចូលរួមជាទៀងទាត់ពីសំណាក់និស្សិតខ្មែរដទៃទៀត រួមទាំង អៀង ប៉ុល ពត អៀង ធីរិទ្ធ និង សុន សេន ហើយបានក្លាយជាមេដឹកនាំក្រុមនេះ នៅពេល អៀង សារី បានចាកចេញទៅ។ ខៀវ សំផន ក៏ដូចជាសមាជិកដទៃទៀតដែរ បានចូលបក្សកុម្មុយនីស្តបារាំង។ គាត់ក៏កាន់តួនាទីជាមេដឹកនាំសហភាពនិស្សិតខ្មែរ។ នៅក្នុងឆ្នាំ១៩៥៩ ខៀវ សំផន បានឡើងការពារនិក្ខេបបទថ្នាក់បណ្ឌិតរបស់គាត់ ដែលមានចំណងជើងថា ‘L’Economie du Cambodge et ses Problèmes d’Industrialisation’ («សេដ្ឋកិច្ចកម្ពុជា និងបញ្ហាឧស្សាហូបនីយកម្ម»)។

**៤៦.** នៅឆ្នាំ១៩៦២ បន្ទាប់ពីវិលត្រឡប់មកប្រទេសកម្ពុជាវិញ ខៀវ សំផន ត្រូវបានជ្រើសរើសឲ្យបំពេញមុខងារនៅក្នុងរដ្ឋសភា និងត្រូវបានតែងតាំងជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម។ រហូតដល់ដើមទសវត្សរ៍ឆ្នាំ១៩៦០ ខៀវ សំផន មានទំនាក់ទំនងក្រៅផ្លូវការជាមួយសមាជិកជាន់ខ្ពស់មួយចំនួននៃបក្សកុម្មុយនីស្តកម្ពុជា។ នៅឆ្នាំ ១៩៧១ ខៀវ សំផន បានក្លាយជាសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា ហើយ នៅឆ្នាំ១៩៧៦ គាត់បានក្លាយជា សមាជិកពេញសិទ្ធិ។ នៅឆ្នាំ១៩៧០ ខៀវ សំផន ត្រូវបានតែងតាំងជាអនុប្រធានរណសិរ្សរួបរួម ជាតិកម្ពុជា និងជាអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា។ ជាក់ស្តែង ខៀវ សំផន ពុំមានអំណាចផ្នែកយោធាឡើយ ហើយ ប៉ុល ពត ឯណោះទេ ដែលទទួលបន្ទុកលើ កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជានោះ។ ខៀវ សំផន ក៏បានកាន់តំណែងជាឧបនាយករដ្ឋមន្រ្តី និងជារដ្ឋមន្រ្តីការពារជាតិនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ក្រោ

យពេលដួលរលំទីក្រុងភ្នំពេញក្នុងខែមេសា ឆ្នាំ១៩៧៥ ខៀវ សំផន បានរក្សាតួនាទីរបស់ខ្លួនជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ និងជាអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា។ ដូច្នេះ គាត់បានបន្តបំពេញមុខងារការទូតមួយចំនួន ដូចជាការជួបជាមួយគណៈប្រតិភូបរទេសដែលមកធ្វើទស្សនកិច្ចនៅកម្ពុជា និងការដឹកនាំគណៈប្រតិភូកម្ពុជាទៅធ្វើទស្សនកិច្ចនៅឯបរទេស។

**៤៧.** នៅក្នុងខែមេសា ឆ្នាំ១៩៧៦ ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ ដែលគ្រាន់តែជាតួនាទីនិមិត្តរូបតែប៉ុណ្ណោះ ដោយគាត់ពុំមានអំណាចផ្នែកប្រតិបត្តិទេ។ ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន បានបន្តបំពេញមុខងារផ្នែកការទូត និងក្នុងពិធីផ្សេងៗ។ ខៀវ សំផន មិនធ្លាប់ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាជាផ្លូវការម្តងណាទេ ប៉ុន្តែគាត់បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចប្រជុំមួយចំនួនរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។ នៅក្នុងខែតុលា ឆ្នាំ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាបានតែងតាំង ខៀវ សំផន ឲ្យទទួលខុសត្រូវផ្នែក «រណសិរ្ស និងរាជរដ្ឋាភិបាល និងពាណិជ្ជកម្ម ខាងបញ្ជី និងតម្លៃ»។ ក្នុងអំឡុងខែតុលា ឆ្នាំ១៩៧៥ ខៀវ សំផន បានក្លាយជាសមាជិកមួយរូបក្នុងចំណោមសមាជិកពីររូបនៃមន្ទីរ ៨៧០ ដែលត្រួតពិនិត្យទៅលើការអនុវត្តសេចក្តីសម្រេចនានារបស់គណៈកម្មាធិការអចិន្ត្រៃយ៍។ ទោះបីជាយ៉ាងណា អង្គជំនុំជម្រះជឿថា ខៀវ សំផន មិនធ្លាប់បានធ្វើជាប្រធានមន្ទីរ ៨៧០ ដូចដែលគាត់ត្រូវបានចោទប្រកាន់ឡើយ។

**៤៨.** អង្គជំនុំជម្រះយល់ឃើញថា តួនាទីរបស់ ខៀវ សំផន នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យបង្ហាញថា ខៀវ សំផន បានទទួលសេចក្តីទុកចិត្ត និងជំនឿពីសំណាក់សមាជិក ដទៃទៀតនៃមជ្ឈិមបក្ស។ ទោះបីជា ខៀវ សំផន បានកាន់តួនាទីជាច្រើនក្តី ប៉ុន្តែ ភ័ស្តុតាងបាន បង្ហាញថា ខៀវ សំផន មានសិទ្ធិធ្វើសេចក្តីសម្រេចតែទៅលើបញ្ហាសេដ្ឋកិច្ច និងពាណិជ្ជកម្ម ប៉ុណ្ណោះ។ ទោះជាយ៉ាងណា ខៀវ សំផន មានឥទ្ធិពល និងសិទ្ធិអំណាចច្រើនតាមរយៈមុខតំណែងជាន់ខ្ពស់របស់គាត់។ តាមរយៈវត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិម និង គណៈកម្មាធិការអចិន្ត្រៃយ៍ កិច្ចការរបស់គាត់នៅក្នុងមន្ទីរ ៨៧០ ការភ្ជាប់ខ្លួនជិតស្និទ្ធនិងជាបន្តរបស់គាត់ជាមួយនឹងមេដឹកនាំរបស់បក្សកុម្មុនីស្តកម្ពុជា ការគ្រប់គ្រងរបស់គាត់ទៅលើគណៈកម្មាធិការពាណិជ្ជកម្ម និងខ្លឹមសារនៃសុន្ទរកថានានា ដែលគាត់បានថ្លែងនោះ ខៀវ សំផន ពិតជាបានដឹងអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងទទួលបានព័ត៌មានអំពីសភាពការណ៍ទូទៅនៅក្នុងប្រទេសកម្ពុជា។

## ១១. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន

**៤៩.** អនុលោមតាមដីកាដំណោះស្រាយ ដែលត្រូវបានកម្រិតត្រឹមសំណុំរឿង០០២/០១ ខៀវ សំផន តាមរយៈសហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងទម្រង់ជា ការធ្វើ មនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) ក្នុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) ក្នុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) និងការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលតាមរយៈការសម្លាប់អ្នករដ្ឋការនៃរបប

សាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។ តាមដីកាដំណោះស្រាយ ខៀវ សំផន បានចូលរួមដោយចេតនា ឬបានរួមចំណែកនៅក្នុងការរៀបចំបង្កើត និងអនុវត្តគោលបំណងរួម ដែលធ្វើឲ្យ និង/ឬ មានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ទាំងមុន និងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ តាមរយៈតួនាទីរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំង សមាជិកភាពរបស់គាត់នៅក្នុងគណៈកម្មាធិការមជ្ឈិម និងមន្ទីរ ៨៧០ ដីកាដំណោះស្រាយបានចោទប្រកាន់ថា ខៀវ សំផន បានចូលរួម និងរួមចំណែកនៅក្នុងកិច្ចប្រជុំនានា រួមទាំងកិច្ចប្រជុំគណៈកម្មាធិការ អចិន្ត្រៃយ៍ ដែលនៅក្នុងកិច្ចប្រជុំនោះ គោលនយោបាយត្រូវបានពិភាក្សា និងផ្សព្វផ្សាយ។ គាត់ក៏បានធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈ ព្រមទាំងបំពេញមុខងារផ្នែកការទូត និងបានចូលរួមក្នុងវគ្គបំពាក់បំប៉នមនោគមន៍វិជ្ជា ដែលតាមរយៈសកម្មភាពទាំងនេះ គាត់អនុម័ត និងផ្សព្វផ្សាយគោលបំណងរួមទាំងនេះ ទាំងក្នុងប្រទេស និងក្រៅប្រទេស។ ផ្អែកលើមូលដ្ឋាននេះ ដីកាដំណោះស្រាយក៏បានចោទប្រកាន់ផងដែរថា ជនជាប់ចោទ បានរៀបចំផែនការ បញ្ជា ញុះញង់ ជួយ និងជំរុញ ឬបើមិនដូច្នេះទេ ទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះឧក្រិដ្ឋកម្មទាំងអស់ ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១។

៥០. អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានរួមចំណែកយ៉ាងសំខាន់នៅក្នុងការបង្កើតផែនការរួម ហើយយល់ឃើញថា ខៀវ សំផន មានចេតនាជំរុញឲ្យអនុវត្តគោលបំណងរួមនេះ តាមរយៈសកម្មភាពនានារបស់គាត់។ ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំអំពីគោលនយោបាយរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ព្រមទាំងសន្និបាតបក្ស ដែលនៅទីនោះមានការរៀបចំផែនការ និងបង្កើតគោលបំណងរួម និងគោលនយោបាយនានា។ គាត់មានវត្តមាន និងបានចូលរួមក្នុងកិច្ចប្រជុំផ្សេងៗ ដែលផ្សព្វផ្សាយអំពីសេចក្ដីណែនាំ និងមេរៀន ទាក់ទងនឹងគោលបំណងរួម និងគោលនយោបាយនានា។ ខៀវ សំផន មានវត្តមាននៅ ប-៥ រួមជាមួយនឹងកម្មាភិបាល កងទ័ពដទៃទៀត ក្នុងអំឡុងពេលនៃការវាយលុកចុងក្រោយទៅលើទីក្រុងភ្នំពេញ។ គាត់បានថ្លែងការណ៍ទៅកាន់កងទ័ព តាមរយៈការផ្សាយតាមវិទ្យុនានា។ ខៀវ សំផន មានមុខតំណែងផ្នែកសេដ្ឋកិច្ច ដោយតាមរយៈបទពិសោធន៍ និងការសិក្សារបស់គាត់ គាត់បានអនុវត្តកិច្ចការជាច្រើននៃគោលបំណងរួម ទាក់ទងនឹងផ្នែកពាណិជ្ជកម្ម ការនាំចេញ/នាំចូល និងជំនួញ។ គាត់បានធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈ ដែលគាំទ្រដល់គោលបំណងរួមនិងគោលនយោបាយនានា ហើយបានជំរុញឲ្យគ្រប់គ្នាធ្វើការកសាង និងការពារប្រទេសស្របតាមមាគ៌ាបក្ស។ ជាចុងក្រោយ តាមរយៈតួនាទីរបស់គាត់ជាអ្នកទំនាក់ទំនងជាមួយសម្ដេច នរោត្តម សីហនុ និងជាអ្នកការទូត ខៀវ សំផន បាន ផ្ដល់យុត្តិកម្ម ការពារ និងលើកសរសើរដល់គោលបំណងរួម និងគោលនយោបាយនានា ដែលធ្វើឲ្យមានការគាំទ្រដល់ខ្មែរក្រហម ទាំងនៅក្នុង និងក្រៅប្រទេស ហើយតាមរយៈគោលនយោបាយដាច់ខាត បានធ្វើឲ្យគាត់អាចអនុវត្តគោលបំណងរួមនោះបានដោយសម្ងាត់ ហើយជាទូទៅមិនមានការរាំងស្ទះអ្វីឡើយ។ ខៀវ សំផន ក៏បានរួមចំណែកជាមួយសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមនូវចេតនាប្រព្រឹត្តិអំពើឧក្រិដ្ឋទាំងនេះ។

៥១. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន តាមរយៈសហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស) ក្នុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី១)

ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស) ក្នុងពេលផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) និងការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា ជនជាប់ចោទបានរៀបចំផែនការជួយ ញុះញង់ និងជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មដូចដែលបានលើកឡើងខាងលើនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាល ទី១ និងទី២) និងទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ។ ដោយបានពិចារណាឃើញថា ការចូលរួមរបស់ជនជាប់ចោទនៅក្នុងសហឧក្រិដ្ឋកម្មរួម បានគ្របដណ្ដប់ទៅលើអំពើទាំងអស់ដែលបង្កើតបានជាមូលដ្ឋាននៃការយល់ឃើញរបស់អង្គជំនុំជម្រះ ទៅលើទម្រង់ផ្សេងៗ ទៀតនៃការទទួលខុសត្រូវនោះ អង្គជំនុំជម្រះនឹងធ្វើការផ្ដន្ទាទោស ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ តែតាមរយៈសហឧក្រិដ្ឋកម្មរួមប៉ុណ្ណោះ។

**៥២.** ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនានាដែលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួមមិនត្រូវ បានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនោះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានរៀបចំផែនការ ញុះញង់ បានជួយ និងជំរុញឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល (នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ (នៅទួលពោធិ៍ជ្រៃ) និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមទាំង ការបាត់ខ្លួនដោយបង្ខំ) (នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២)។

**៥៣.** អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន មិនបានកាន់មុខតំណែងដែលមានអំណាចគ្រប់គ្រាន់ ក្នុងការចេញបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនានាឡើយ។ ដូច្នេះអង្គជំនុំជម្រះបដិសេធការចោទប្រកាន់ដែលថា គាត់បានបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។ លើសពីនេះទៀត អង្គជំនុំជម្រះជឿថា ភ័ស្តុតាង ជារួម មិនបានបង្ហាញឲ្យឃើញថា ខៀវ សំផន បានអនុវត្តអំណាចប្រកបដោយប្រសិទ្ធភាពទៅលើចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនានា ដែលថា គាត់មានលទ្ធភាពសម្រេច និងចាត់វិធានការទប់ស្កាត់ និងដាក់ទោសចារីឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះបដិសេធការចោទប្រកាន់ ពាក់ព័ន្ធនឹងការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។

## ១២. សំណងដើមបណ្ដឹងរដ្ឋប្បវេណី

**៥៤.** ដើមបណ្ដឹងរដ្ឋប្បវេណីសរុបចំនួន ៣.៨៦៩ នាក់ ត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះ និងត្រូវបានបញ្ចូលទៅក្នុងក្រុមដើមបណ្ដឹងរដ្ឋប្បវេណីតែមួយក្នុងពេលជំនុំជម្រះ ដែលតំណាងដោយសហមេធាវីនាំមុខ។

**៥៥.** អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ជនជាប់ចោទទាំងពីររូបក្នុងសំណុំរឿង ០០២ ត្រូវបានកំណត់ថា ជាជនក្រីក្រគ្មានលទ្ធភាព។ អនុលោមតាមវិធានផ្ទៃក្នុង អ.វ.ត.ក សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អាចស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់វិធានការសំណងជាក់លាក់នោះ។ វិធានការទាំងនោះត្រូវបានបង្កើត ឬកំណត់ឡើង ដោយមានការសម្របសម្រួលគ្នាជាមួយនឹងអង្គភាពគាំពារជនរងគ្រោះ ក្នុងគោលបំណងធ្វើឲ្យមានការទទួលស្គាល់យ៉ាងត្រឹមត្រូវចំពោះព្យសនកម្ម ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរងដោយសារតែការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងឡាយ ដែលកំពុងត្រូវបានជំនុំជម្រះនៅក្នុង

សំណុំរឿង ០០២/០១ និងធ្វើឲ្យមានការ ផ្តល់អត្ថប្រយោជន៍ ដល់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីជាការដោះស្រាយចំពោះព្យសនកម្មនេះ។ នៅក្នុងសំណុំរឿង ០០២/០១ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឲ្យមានការទទួលស្គាល់តាមផ្លូវតុលាការចំពោះគម្រោងចំនួន ១៣ ថាជាសំណងសមស្រប។

៥៦. អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មទាំងឡាយដែលជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធ បានធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះជាច្រើនផ្សេងទៀតទទួលរងព្យសនកម្មយ៉ាងខ្លាំងដែលមិនអាចវាស់បាន ដែលរួមមាន ការឈឺចាប់ផ្នែករាងកាយ ការខាតបង់ផ្នែកសេដ្ឋកិច្ច ការបាត់បង់សេចក្តីថ្លៃថ្នូរ ការបាក់ស្បាតផ្លូវចិត្ត និងសេចក្តីទុក្ខព្រួយដោយសារតែការព្រាត់ប្រាសសមាជិកគ្រួសារ ឬសាច់ញាតិលោហិត។

៥៧. អង្គជំនុំជម្រះសាលាដំបូងគាំទ្រដល់គម្រោងនានាពាក់ព័ន្ធនឹង ការបង្កើតឲ្យមានទិវាជាតិនៃការចងចាំ ការសាងសង់ស្តូបនៅភ្នំពេញសម្រាប់រម្លឹកដល់ជនរងគ្រោះដោយសារការជម្លៀសដោយបង្ខំ វិធីព្យាបាលតាមរបៀបការចងក្រងជាសក្ខីកម្ម ក្រុមជួយខ្លួនឯង ការតាំងពិពណ៌ជាអចិន្ត្រៃយ៍ ការតាំងពិពណ៌ចល័ត និងគម្រោងអប់រំការបញ្ចូលជំពូកស្តីពីការជម្លៀសប្រជាជនដោយបង្ខំនិង ទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃទៅក្នុងកម្មវិធីសិក្សារបស់សាលារៀននៅកម្ពុជា ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព គម្រោងបោះពុម្ពកូនសៀវភៅអំពីអង្គហេតុដែលត្រូវបានសម្រេចសេចក្តី និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅអ.វ.ត.ក ការបោះពុម្ព និងផ្សព្វផ្សាយសាលក្រមសំណុំរឿង ០០២/០១ ជាពីរប្រភេទ និងគម្រោងផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគេហទំព័ររបស់ អ.វ.ត.ក។ អង្គជំនុំជម្រះយល់ឃើញថា មានការធានានូវមូលនិធិ និងកិច្ចសហការពេញលេញ ដើម្បីអនុវត្តគម្រោងទាំងនោះ។ សេចក្តីលម្អិតអំពីគម្រោងទាំងនេះមានបញ្ជាក់ជូនក្នុងសាលក្រម។

៥៨. ជាចុងក្រោយ អង្គជំនុំជម្រះយល់ឃើញថា ទោះបីជាសំណងដែលបានទាមទារនៅក្នុងគម្រោងចំនួនពីរទៀតដែលនៅសល់ ពាក់ព័ន្ធនឹងគម្រោងសាងសង់ស្តូបសាធារណៈ និងគម្រោងសាងសង់ស្តូបសម្រាប់រម្លឹកដល់ជនរងគ្រោះនៃរបបខ្មែរក្រហម សម្រាប់ប្រជាជនខ្មែរ ដែលរស់នៅប្រទេសបារាំង អាចដោះស្រាយបានត្រឹមត្រូវចំពោះព្យសនកម្មដែលជនរងគ្រោះបានទទួលរង និងអាចផ្តល់សំណងផ្លូវចិត្ត និងសមូហភាពចំពោះការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចសម្រេចទៅលើគម្រោងទាំងនេះបានឡើយ។ អង្គជំនុំជម្រះយល់ឃើញថា ពាក់ព័ន្ធនឹងបូជនីយដ្ឋានដែលគ្រោងនឹងសាងសង់ឡើងក្នុងប្រទេសកម្ពុជានោះ ពុំទាន់មានការផ្តល់ព័ត៌មានលម្អិតគ្រប់គ្រាន់នៅឡើយទេ ដូចជាសំណើអំពីទីតាំងបូជនីយដ្ឋានទាំងនេះ ឬកិច្ចព្រមព្រៀងរបស់ តតីយជនដែលពាក់ព័ន្ធ ហើយចំពោះគម្រោងទាំងពីរដែលនៅសល់នេះ អង្គជំនុំជម្រះមិនទាន់ឃើញមានការធានាមូលនិធិពេញលេញពីតតីយជនគ្រប់គ្រាន់នៅឡើយទេ។

## ១៣. សម្រេចសេចក្តី និងការផ្តន្ទាទោស

៥៩. សេចក្តីសង្ខេបនៃសំអាងហេតុរបស់អង្គជំនុំជម្រះចប់ត្រឹមនេះ ហើយជាបន្ត ខ្ញុំនឹងអាន ផ្នែកសម្រេចសេចក្តី។ [ ជនជាប់ចោទ ក្រោកឈរ ]

**៦០.** អនុលោមតាមបទប្បញ្ញត្តិមាត្រា ៥ មាត្រា ២៩(ថ្មី) និងមាត្រា ៣៩(ថ្មី)នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ជនជាប់ចោទ នួន ជា មាន ពិរុទ្ធ ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល (រួមទាំងការធ្វើមនុស្សឃាត) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទី លំនៅដោយបង្ខំ ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស) ដែលត្រូវបានប្រព្រឹត្តឡើងនៅលើទឹកដីប្រទេសកម្ពុជាចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ខែធ្នូ ឆ្នាំ១៩៧៧។

**៦១.** អនុលោមតាមបទប្បញ្ញត្តិមាត្រា ៥ មាត្រា ២៩(ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ជនជាប់ចោទ ខៀវ សំផន មាន ពិរុទ្ធ ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការសម្លាប់រង្គាល (រួមទាំង ការធ្វើមនុស្សឃាត) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗ ទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ និងការធ្វើឲ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស) ដែលត្រូវបានប្រព្រឹត្តឡើងនៅលើទឹកដីប្រទេសកម្ពុជា ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ខែធ្នូ ឆ្នាំ១៩៧៧។

**៦២.** អង្គជំនុំជម្រះបានពិចារណាទៅលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធ រួមទាំងស្ថានទម្ងន់ទោស និងស្ថានសម្រាលទោសពាក់ព័ន្ធនានា និងសក្ខីកម្មរបស់សាក្សីពាក់ព័ន្ធនឹងអត្តចរិតរបស់ ខៀវ សំផន។ នៅក្នុងការសម្រេចអំពីការផ្ដន្ទាទោស អង្គជំនុំជម្រះក៏បានពិចារណាផងដែរទៅលើការប្រកាសផ្ដន្ទាទោសរបស់អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសំណុំរឿង ០០១ និងយុត្តិសាស្ត្រនានាពីតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗទៀត ដែលនៅក្នុងសាលក្រមរបស់តុលាការទាំងនោះ បានធ្វើការវាយតម្លៃផងដែរទៅលើការពិចារណាផ្សេងៗក្នុងការសម្រេចអំពីការផ្ដន្ទាទោសពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលមានទ្រង់ទ្រាយធំ។ អង្គជំនុំជម្រះសម្រេចផ្ដន្ទាទោសជនជាប់ចោទ នួន ជា ដាក់ពន្ធនាគារអស់មួយជីវិត។ អង្គជំនុំជម្រះ សម្រេច ផ្ដន្ទាទោសជនជាប់ចោទ ខៀវ សំផន ដាក់ពន្ធនាគារ អស់មួយជីវិត។

**៦៣.** អង្គជំនុំជម្រះប្រកាសថា ជនជាប់ចោទ នួន ជា ត្រូវបាននាំមកឃុំខ្លួននៅមុនពេលជំនុំជម្រះលើអង្គសេចក្ដីនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ និង ខៀវ សំផន ត្រូវបាននាំមកឃុំខ្លួននៅមុនពេលជំនុំជម្រះលើអង្គសេចក្ដី នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧។ ជនជាប់ចោទទាំងពីរនាក់ស្ថិតនៅក្នុងមន្ទីរឃុំឃាំងរហូតដល់ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ដែលជាថ្ងៃប្រកាសសាលក្រម និងការសម្រេចផ្ដន្ទាទោសនេះ។ សាលក្រមនេះ ប្រកាសជាសាធារណៈ នៅក្នុងសាលសវនាការជំនៃ អ.វ.ត.ក នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ និងបើកផ្លូវឲ្យភាគីប្ដឹងសាទុក្ខ ដោយអនុលោមតាមវិធានផ្ទៃក្នុង។ ដោយសារស្ថានភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលពួកគាត់ត្រូវបានផ្ដន្ទាទោស អង្គជំនុំជម្រះរក្សាទុកពិរុទ្ធជន នួន ជា និង ខៀវ សំផន នៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក រហូតដល់សាលក្រមនេះចូលជាស្ថាពរ លើកលែងតែមានការបង្គាប់ផ្សេងពីអង្គជំនុំជម្រះតុលាការកំពូល។

**៦៤.** អង្គជំនុំជម្រះប្រកាសផ្អាកសវនាការ។ អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនពិរុទ្ធជន នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ។



# ៦. សេចក្តីសង្ខេប នៃសាលដីកា សំណុំរឿង ០០២/០១




# សេចក្តីសង្ខេបនៃសាលដីកា សំណុំរឿង ០០២/០១

**១.** នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសាលក្រមរបស់ខ្លួន ក្នុងសំណុំរឿង០០២/០១ និងបានរកឃើញថា ជនជាប់ចោទ នួន ជា និង ខៀវ សំផន មានពិរុទ្ធភាព ពីបទសម្លាប់រង្គាល (រួមបញ្ចូលបទមនុស្សឃាត) បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ដូចមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស)។

**២.** អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា បទឧក្រិដ្ឋទាំងនេះ ត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ចំនួនបី ដែលជាកម្មវត្ថុនៃសំណុំរឿង០០២/០១ ដូចជា ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅចេញពីទីក្រុងភ្នំពេញ ភ្លាមៗបន្ទាប់ពីដួលរលំទីក្រុង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ (ហៅថា ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១) ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដែលបានកើតឡើងពីចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ (ហៅថា ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ) និងការសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃក្នុងខេត្តពោធិ៍សាត់នៅចុងខែមេសា ឆ្នាំ១៩៧៥។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា បើទោះបីជាជនជាប់ចោទទាំងពីរពុំបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយដោយផ្ទាល់ក៏ដោយ ក៏ជនជាប់ចោទត្រូវបានដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងនេះ ដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវ ដែលហៅថា «សហឧក្រិដ្ឋកម្មរួម» ព្រមទាំងដោយសារជនជាប់ចោទ បានរៀបចំផែនការ ញុះញង់ ជួយនិងជំរុញ និងចំពោះជនជាប់ចោទ នួន ជា តែម្នាក់ទាក់ទងទៅនឹងការបញ្ជានៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ។

**៣.** អង្គជំនុំជម្រះសាលាដំបូង បានសម្រេចផ្តន្ទាទោសជនជាប់ចោទម្នាក់ៗ ដាក់ពន្ធនាគារអស់មួយជីវិត។ អង្គជំនុំជម្រះសាលាដំបូង បានទទួលយកផ្នែកខ្លះនៃ សំណើសុំទាមទារសំណងផ្លូវចិត្ត និងសមូហភាព ដោយបានសម្រេចផ្តល់សំណងចំនួន១១ ដល់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងបញ្ហានេះ។

**៤.** នួន ជា និង ខៀវ សំផន ព្រមទាំងសហព្រះរាជអាជ្ញាបានដាក់សារណាបណ្តឹងសាទុក្ខ និងសារណាតបរៀងៗខ្លួន។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានដាក់សារណាជាលាយលក្ខណ៍អក្សរផងដែរ។ អង្គជំនុំជម្រះតុលាការកំពូលបានបើកសវនាការនៅថ្ងៃទី០២, ០៣ និងទី០៦ ខែកក្កដា ឆ្នាំ២០១៥ ដើម្បីសួរសាក្សីចំនួនបីរូបបន្ថែមទៀត។ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ និង ចាប់ពីថ្ងៃទី១៦ ដល់១៨ ខែកុម្ភៈ ឆ្នាំ២០១៦

អង្គជំនុំជម្រះតុលាការកំពូលបានបើកសវនាការស្តាប់សារណាផ្ទាល់មាត់លើបណ្តឹងសាទុក្ខ។ បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលបានចាប់ផ្តើមពិភាក្សាសម្រេចលើបណ្តឹងសាទុក្ខនេះ។

៥. នៅថ្ងៃនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងចេញសាលដីកាពេញលេញលើបណ្តឹងសាទុក្ខទាំងបី ដែលមានអានុភាពផ្លូវច្បាប់។ ដើម្បីជួយដល់សាធារណជនឱ្យយល់ច្បាស់អំពីការសម្រេចរបស់តុលាការ ខ្ញុំសូមអានសង្ខេបនូវសំអាងហេតុ និងផ្នែកសម្រេចសេចក្តីរបស់អង្គជំនុំជម្រះតុលាការកំពូល ប៉ុន្តែសេចក្តីសង្ខេបនេះ មិនមែនជាផ្នែកមួយនៃសំអាងហេតុសម្រាប់ការសម្រេចនេះឡើយ។

៦. បណ្តឹងសាទុក្ខរបស់ នួន ជា មានទទ្បីករណ៍ចំនួន២២៣ ហើយ ខៀវ សំផន មានចំនួន១៤៨ ដែលមានលក្ខណៈត្រួតគ្នាជាច្រើន។ ដោយសារមូលហេតុនេះ ខ្ញុំសូមសង្ខេបបណ្តឹងសាទុក្ខទាំងពីរនេះរួមគ្នា ដូចមាននៅក្នុងសាលដីកាពេញលេញ។ ចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ខ្ញុំសូមសង្ខេបដាច់ដោយឡែក។

៧. ខ្ញុំសូមបញ្ជាក់ថា ដោយសារទទ្បីករណ៍នៅក្នុងបណ្តឹងសាទុក្ខមានចំនួនច្រើន ដូចនេះខ្ញុំសូមសង្ខេបចំពោះតែការយល់ឃើញទាក់ទងទៅនឹងទទ្បីករណ៍ណាដែលមានភាពចម្រូងចម្រាស ឬមានសារៈសំខាន់ ឬមានអត្ថប្រយោជន៍ចំពោះសាធារណជនប៉ុណ្ណោះ។ ជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើទទ្បីករណ៍ទាំងអស់នៃបណ្តឹងសាទុក្ខដែលបានលើកឡើងនោះ ហើយអង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ការយល់ឃើញចំពោះទទ្បីករណ៍ទាំងនេះ នៅក្នុងសាលដីកាពេញលេញត្រឹមត្រូវជាលាយលក្ខណ៍អក្សររបស់ខ្លួន ដែលនឹងត្រូវជូនដំណឹងដល់ភាគីក្នុងពេលឆាប់ៗបន្ទាប់ពីសវនាការនេះត្រូវបានបញ្ចប់។

# ១. បណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន

៨. ទទ្បីករណ៍នៃបណ្តឹងសាទុក្ខដែល នួន ជា និង ខៀវ សំផន បានលើកឡើង បានបែងចែកជាប្រាំប្រភេទជាក់លាក់ដូចខាងក្រោម។

## ១.១. ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី

៩. ជនជាប់ចោទបានលើកអំណះអំណាងមួយចំនួន ជំទាស់ទៅនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីដែលបានអនុវត្តចំពោះរូបគាត់។ ក្នុងផ្នែកនេះ មានពីរចំណុចទាក់ទងទៅនឹងអំណះអំណាងនៃបណ្តឹងសាទុក្ខនេះ។

### ១.១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការឧក្រិដ្ឋកម្មឯករាជ្យឥតលម្អៀង

១០. ជាការកត់សម្គាល់ ជនជាប់ចោទបានលើកឡើងថា សិទ្ធិរបស់ពួកគាត់ក្នុងការទទួលបានការជំនុំជម្រះនៅចំពោះមុខតុលាការឯករាជ្យឥតលម្អៀង ត្រូវបានរំលោភបំពាន។

**១១.** អង្គជំនុំជម្រះតុលាការកំពូល ពុំជឿជាក់លើអំណះអំណាង ដែលបានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានភាពលម្អៀងតាមរយៈអ្វីដែលបានបង្ហាញឱ្យឃើញ ដូចជាការយល់ឃើញពុំត្រឹមត្រូវ និងមានកំហុសនោះ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា តាមរយៈកិច្ចសម្ភាសន៍របស់លោកស្រីចៅក្រមខាត់រ៉ាយថ៍ ក្នុងឆ្នាំ២០១៣ ពុំបានបង្ហាញថា លោកស្រីមានភាពលម្អៀងឡើយ។ ចំពោះអំណះអំណាងអំពីកង្វះឯករាជ្យភាព ដោយផ្អែកលើការលើកឡើងនៅក្នុងសៀវភៅរបស់អតីតសហចៅក្រមស៊ើបអង្កេតម៉ាកសែល ឡឺម៉ុងដ៍ អង្គជំនុំជម្រះកត់សម្គាល់ថា មតិយោបល់ទាំងនោះ គឺគ្រាន់តែជាលក្ខណៈទូទៅ ហើយមិនជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿងលេខ០០២នោះទេ។ ទាក់ទងទៅនឹងការចោទប្រកាន់របស់ ថេត សម្បត្តិ ដែលថា សាក្សីសក្ដានុពលពុំបានមកផ្តល់សក្ខីកម្មដោយសារបារម្ភពីសន្តិសុខនោះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា បើទោះបីនេះជាការចោទប្រកាន់គួរឱ្យជឿក៏ដោយ ក៏ការចោទប្រកាន់នេះពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហាដែលថា អង្គជំនុំជម្រះសាលាដំបូងខ្វះឯករាជ្យភាពនោះដែរ។ ចំពោះអំណះអំណាង ដែលថា សំអាងហេតុរបស់ចៅក្រមជាតិសម្រេចមិនកោះហៅ ហេង សំរិន មកធ្វើជាសាក្សី បានបង្ហាញអំពីកង្វះឯករាជ្យភាពនោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ពុំមានភាពច្បាស់លាស់ក្នុងការសន្និដ្ឋានបានយ៉ាងដូច្នោះឡើយ ព្រោះសក្ខីកម្មដែលរំពឹងទុកនោះ អាចពុំមានការជាប់ពាក់ព័ន្ធ។

### ១.១.២. សិទ្ធិទទួលបានការការពារខ្លួនដោយប្រសិទ្ធភាព

**១២.** នួន ជា និង ខៀវ សំផន បានលើកទឡ្ហីករណ៍មួយចំនួនដើម្បីគាំទ្រអំណះអំណាងដែលថា សិទ្ធិរបស់ពួកគាត់ក្នុងការទទួលបានការការពារដោយប្រសិទ្ធភាពត្រូវបានរំលោភបំពាន ដែលមានដូចជាការសម្រេចមិនកោះហៅសាក្សីមួយចំនួន។

**១៣.** ទាក់ទងទៅនឹងសាក្សី ហេង សំរិន ដែល នួន ជា បានស្នើសុំជាច្រើនដងឱ្យកោះហៅសាក្សីរូបនេះមកផ្តល់សក្ខីកម្ម ដែលក្នុងនោះក៏មាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងផងដែរ។ អង្គជំនុំជម្រះសាលាដំបូងពុំអាចទទួលបានមតិភាគច្រើនលើសលប់សម្រាប់ការកោះហៅសាក្សី ហេង សំរិន មកធ្វើសក្ខីកម្មបានឡើយ។ បើទោះបីជាចៅក្រមបីរូបបានយល់ឃើញថា ការកោះហៅនេះពុំមានភាពចាំបាច់ក៏ដោយ ក៏ចៅក្រមពីររូបទៀតបានយល់ឃើញថា សាក្សី ហេង សំរិន គឺជាសាក្សីពាក់ព័ន្ធដែលមាន ដែលគប្បីកោះហៅ។

**១៤.** អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងសាក្សី ហេង សំរិន ពុំមានលក្ខណៈសមហេតុផលនោះទេ។ ជាការកត់សម្គាល់ ចៅក្រមបីរូបដែលបានយល់ឃើញថា សាក្សី ហេង សំរិន ពុំគប្បីកោះហៅនោះ បានបញ្ជាក់ថា ការកោះហៅនេះអាចបណ្ដាលឱ្យមានការពន្យារពេលយ៉ាងច្រើន។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថានេះគឺជា កំហុស ព្រោះតាមកំណត់ត្រាកន្លងមក ពុំមានការបង្ហាញថា សាក្សី ហេង សំរិន បានបដិសេធក្នុងការចូលរួមមកផ្តល់សក្ខីកម្មឡើយ ប្រសិនបើមានការកោះហៅនោះ។ បន្ថែមលើនេះទៀត សំណើសុំកោះហៅសាក្សី ហេង សំរិន បានធ្វើឡើងតាំងពីដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ហើយប្រសិនបើមានបញ្ហាអ្វីកើតមានមែនក៏ដោយ ក៏មិនបានបង្ហាញឱ្យឃើញថា ត្រូវបានដោះស្រាយនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ។

១៥. អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ការសន្និដ្ឋានដូចខាងលើនេះទាក់ទងទៅនឹងសាក្សី អ៊ុក ប៊ុនឈឿន ដែល នួន ជា ក៏បានស្នើសុំឱ្យសាក្សីរូបនេះមកផ្តល់សក្ខីកម្មផងដែរ។

១៦. ទាក់ទងទៅនឹងបញ្ហាបន្ទាប់ ដែលអង្គជំនុំជម្រះតុលាការកំពូលត្រូវដោះស្រាយគឺ ថាតើជនជាប់ចោទជាក់ស្តែងបានទទួលរងផលប៉ះពាល់ដោយសារកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងដែរ ឬយ៉ាងណា។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា សាក្សីទាំងពីររូបនេះ ទំនងជាមានព័ត៌មានដោះបន្ទុកជាសក្តានុពលដូចសាក្សីដទៃទៀតដែរ។ ចំពោះការបញ្ជាក់នៅក្នុងបទសម្ភាសន៍របស់ ហេង សំរិន ពីដំបូងដែលបានធ្វើឡើងទាក់ទងទៅនឹងគោលនយោបាយរបស់ខ្មែរក្រហមទៅលើទាហាននៃរបបសាធារណរដ្ឋខ្មែរអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថាកំណត់ត្រានៃបទសម្ភាសន៍នេះពិតជាបានបង្ហាញអំពីបញ្ហាដែលអាចបំភ្លឺតាមរយៈសក្ខីកម្មនេះបាន។ ទោះជាយ៉ាងនេះក្តី កំណត់ត្រានៃបទសម្ភាសន៍នេះ មាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរួចហើយ និងអាចយកមកពិចារណាបាន។ សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពុំមានការបង្ហាញថា ការសម្រេចមិនកោះហៅសាក្សី ហេង សំរិន និង អ៊ុក ប៊ុនឈឿន បានបណ្តាលឱ្យមាន «លទ្ធផលខុសឆ្គងធ្ងន់ធ្ងរនៅក្នុងកិច្ចដំណើរការនីតិវិធី» ដែលតម្រូវឱ្យបដិសេធការសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទឡើយ។

១៧. ជនជាប់ចោទបានលើកបញ្ហាជាច្រើនទៀត ទាក់ទងទៅនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី និងបានអះអាងអំពីអធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុងផងដែរ។ ដោយបានពិចារណាលើសារណារបស់ភាគី អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធអំណះអំណាងទាំងអស់នោះ ដោយផ្អែកលើសំអាងហេតុដែលបានរៀបរាប់នៅក្នុងសាលដីកាពេញលេញ។

## ១.២. វិធីសាស្ត្រទទួលយកភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង

១៨. នេះជាផ្នែកទីពីរអំពីទឡ្ហីករណ៍នៅក្នុងបណ្តឹងសាទុក្ខ ទាក់ទងទៅនឹងវិធីសាស្ត្រទទួលយកភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង និងរំឭកថា ការសង្ខេបនេះកម្រិតត្រឹមតែបញ្ហាមួយចំនួន ដែលសំខាន់បំផុតប៉ុណ្ណោះ។

### ១.២.១. ការកម្រិតឱកាសសម្រាប់ការស៊ើបសួរនៅក្នុងពេលជំនុំជម្រះ

១៩. ជនជាប់ចោទបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារបានកម្រិតឱកាសសម្រាប់ការស៊ើបសួរក្នុងពេលជំនុំជម្រះ។

២០. បញ្ហាទី១គឺ ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបញ្ជាក់ថា ភាគីការពារក្តីពុំមានសិទ្ធិធ្វើការស៊ើបសួរដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បើទោះបីជាក្របខ័ណ្ឌផ្នែកនីតិវិធីរបស់ អ.វ.ត.ក ពុំបានចែងអំពីការស៊ើបសួរពេញលេញដែលត្រូវធ្វើឡើងដោយភាគីការពារក្តីក៏ដោយ ក៏ពុំមានមូលដ្ឋាននៃលក្ខន្តិកៈ ឬហេតុផលជាក់ស្តែងណាមួយដែលគួរឱ្យជឿជាក់ បានហាមឃាត់ភាគីការពារក្តី

ក្នុងការបើកកិច្ចស៊ើបសួរក្រោមលក្ខខណ្ឌមួយចំនួន ក្នុងគោលបំណងស្វែងរកភស្តុតាងពាក់ព័ន្ធនោះឡើយ ជាពិសេស ក្នុងការអនុញ្ញាតឲ្យភាគីការពារក្តីអាចធ្វើសំណើដល់អង្គភាពនានារបស់ អ.វ.ត.ក ឲ្យបើកការស៊ើបសួរបន្ថែម។

**២១.** បញ្ហាទី២គឺ ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសដែរ ឬយ៉ាងណា ក្នុងការសម្រេចលើសំណើសុំបើកកិច្ចស៊ើបសួរ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា វិធីសាស្រ្តទូទៅរបស់អង្គជំនុំជម្រះសាលាដំបូងមានលក្ខណៈសមហេតុផល និងថា ភាពខុសឆ្គងផ្នែកនីតិវិធីណាមួយក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ត្រូវបានដោះស្រាយរួចហើយ តាមរយៈដីកាដំណោះស្រាយ។

### ១.២.២. ការអនុញ្ញាតឱ្យសាក្សីពិនិត្យចម្លើយពីមុនរបស់ខ្លួនដើម្បីបញ្ជាក់ខ្លឹមសារ

**២២.** បញ្ហាបន្ទាប់ គឺពាក់ព័ន្ធទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលអនុញ្ញាតឱ្យសាក្សីពិនិត្យចម្លើយពីមុនរបស់ខ្លួននៅមុនពេលសាក្សីចូលមកផ្តល់សក្ខីកម្ម។

**២៣.** អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការអនុម័តយកនីតិវិធីបែបនោះ បានធ្វើឱ្យមានភាពមិនស៊ីសង្វាក់គ្នាជាមួយការអនុវត្តរបស់កម្ពុជា។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញថាអង្គជំនុំជម្រះសាលាដំបូងបានរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួននៅក្នុងកាលៈទេសៈនៃរឿងក្តីនេះឡើយ។

### ១.២.៣. ការទទួលយក និងការប្រើប្រាស់ភស្តុតាងជាលាយលក្ខណ៍អក្សរ ជំនួសសក្ខីកម្មផ្ទាល់មាត់

**២៤.** ជនជាប់ចោទបានជំទាស់ទៅនឹងវិធីសាស្រ្តរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរជំនួសសក្ខីកម្មផ្ទាល់មាត់។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា នៅក្នុងកាលៈទេសៈមួយចំនួន ភស្តុតាងក្នុងទម្រង់ជាចម្លើយលាយលក្ខណ៍អក្សរ ឬប្រតិចារឹកអាចទទួលយកបាន បើទោះបីជាភាគីការពារក្តីពុំមានឱកាសសួរដេញដោលសាមីជនជាម្ចាស់ចម្លើយនេះក៏ដោយ។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងបានទទួលយកចម្លើយ និងប្រតិចារឹកជាលាយលក្ខណ៍អក្សរចំនួន ១.១២៤។

**២៥.** ដំបូងអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សិទ្ធិក្នុងការសួរដេញដោលសាក្សី ពុំមានលក្ខណៈដាច់ខាតនោះឡើយ។ ការផ្តល់សិទ្ធិទូលំទូលាយគ្មានកម្រិត ក្នុងការសួរសាក្សីប្រឆាំងនឹងជនជាប់ចោទ អាចមានហានិភ័យប៉ះពាល់ដល់លទ្ធភាពរបស់តុលាការ ក្នុងការផ្តល់យុត្តិធម៌នៅក្នុងរឿងក្តីមួយ ដែលមានទំហំធំធេង និងមានភាពស្មុគស្មាញដូចរឿងក្តីបច្ចុប្បន្ននេះ។

**២៦.** ទី២ ជនជាប់ចោទបានជំទាស់ទៅនឹងទម្ងន់ ដែលអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ទៅលើចម្លើយជាលាយលក្ខណ៍អក្សរ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ចម្លើយជាលាយលក្ខណ៍អក្សរ

ជាទូទៅត្រូវតែផ្តល់តម្លៃជាភស្តុតាងកម្រិតទាប ដោយសារភាគីពុំបានសួរដេញដោលសាក្សីដែលបានផ្តល់ចម្លើយនេះ។ អង្គជំនុំជម្រះសាលាដំបូងពិតជាបានបញ្ជាក់ថា អង្គជំនុំជម្រះបានពិចារណាលើគោលការណ៍នេះ នៅក្នុងការវាយតម្លៃភស្តុតាង ដូច្នេះពុំមានកំហុសពាក់ព័ន្ធនឹងបញ្ហានេះឡើយ។ ទោះជាយ៉ាងណាក្តី បញ្ហាដែលកាន់តែស្មុគស្មាញជាងនេះគឺ ថាតើអង្គជំនុំជម្រះសាលាដំបូងបានសំអាងយ៉ាងខ្លាំងទៅលើចម្លើយក្រៅតុលាការដែរ ឬយ៉ាងណា ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់ខ្លួននោះ។ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវពិចារណាលើបញ្ហានេះទាក់ទងទៅនឹងការយល់ឃើញជាក់លាក់នោះ។

### ១.២.៤. ការសំអាងទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

២៧. ទឡ្ហីករណ៍បន្ទាប់ដែលត្រូវលើកឡើង គឺពាក់ព័ន្ធទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូង លើភស្តុតាង ដែលបានផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងដែលបានលើកឡើងដោយជនជាប់ចោទ ទាក់ទងទៅនឹងបញ្ហានេះឡើយ។ ដំបូងបើទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិពិសេសនៅក្នុងកិច្ចដំណើរការនីតិវិធីក៏ដោយ ក៏នេះពុំមែនមានន័យថា ដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់ -- ពុំអាចផ្តល់សក្ខីកម្មបាននោះដែរ។ ទម្ងន់ដែលបានផ្តល់ទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវវាយតម្លៃដោយផ្អែកលើករណីជាក់ស្តែងនីមួយៗដោយពិចារណារួមគ្នាផងដែរ ជាមួយនឹងបញ្ហាដែលថា ដើមបណ្តឹងរដ្ឋប្បវេណីពុំបានតម្រូវឱ្យធ្វើសម្បថនោះ។

២៨. បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការសំអាងលើសេចក្តីថ្លែងអំពីទុក្ខសោក ឬសក្ខីកម្មអំពីផលប៉ះពាល់របស់ជនរងគ្រោះ ដោយសារមានការបង្ហាញច្បាស់លាស់ថា ទាំងនេះអាចមានព័ត៌មានមួយចំនួនពាក់ព័ន្ធទៅនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ។

២៩. ជនជាប់ចោទបានលើកអំណះអំណាងមួយចំនួនផ្សេងទៀត ទាក់ទងទៅនឹងវិធីសាស្ត្រទទួលយកភស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង ដូចជា ការសំអាងលើសាក្សីជំនាញ និងការអនុវត្តមួយចំនួននៅក្នុងបន្ទប់សវនាការនៅពេលសាក្សីនេះត្រូវបានស្នើសុំឱ្យផ្តល់យោបល់លើឯកសារ។ អំណះអំណាងទាំងអស់នេះ ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលវាយតម្លៃដោយប្រុងប្រយ័ត្ន ហើយបានផ្តល់ការយល់ឃើញរបស់ខ្លួននៅក្នុងសាលដីកាពេញលេញ។ ខាងក្រោមនេះ ជាការយល់ឃើញអំពីខ្លឹមសារនៃសំណុំរឿងពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាព។

## ១.៣. ការយល់ឃើញពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ ដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាព

៣០. ដូចបានលើកឡើងពីដំបូង បទចោទនៅក្នុងសំណុំរឿង០០២/០១ ជាប់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលបានចោទប្រកាន់នៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ចំនួនបីគឺ ការជម្លៀសចេញពីទីក្រុងភ្នំពេញ សំដៅលើការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ ការផ្លាស់ទីលំនៅប្រជាជនដែលចាប់ផ្តើមនៅពាក់កណ្តាល

ចុងក្រោយក្នុងឆ្នាំ១៩៧៥ រហូតដល់ក្នុងឆ្នាំ១៩៧៧ ហៅថា ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ និងការសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា មានការប្រព្រឹត្តបទឧក្រិដ្ឋមួយចំនួននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ទាំងនេះ។ ដូចបានលើកឡើងខាងលើ ជនជាប់ចោទទាំងពីរពុំបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះដោយផ្ទាល់នោះទេ។ យោងតាមអង្គជំនុំជម្រះសាលាដំបូង បើទោះបីជាបទឧក្រិដ្ឋទាំងនេះត្រូវបានប្រព្រឹត្តឡើងដោយខ្មែរក្រហមដទៃទៀតក៏ដោយ ក៏ជនជាប់ចោទទាំងពីរត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនេះដែរ។

៣១. ជាលទ្ធផល ការពិចារណាអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទអាចត្រូវបានបែងចែកជាពីរយ៉ាងជំទូលាយគឺ ទី១ បទឧក្រិដ្ឋជាក់ស្តែងដែលខ្មែរក្រហមបានប្រព្រឹត្ត និងទី២ ថាតើជនជាប់ចោទអាចត្រូវដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងនេះបានដែរ ឬយ៉ាងណា។

## ១.៣.១. ការធ្វើមនុស្សឃាត

### ១.៣.១.១. ការកំណត់និយមន័យធាតុផ្សំអត្តនោម័តនៃបទមនុស្សឃាត

៣២. ទាក់ទងទៅនឹងបទមនុស្សឃាត បញ្ហាទី១ ដែលត្រូវលើកឡើងចំពោះអង្គច្បាប់គឺ ការកំណត់និយមន័យនៃធាតុផ្សំអត្តនោម័ត។ ជនជាប់ចោទបានលើកឡើងថា លក្ខខណ្ឌនៃអំពើមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ កំណត់ថា ចារីបានប្រព្រឹត្តដោយចេតនាផ្ទាល់ក្នុងការធ្វើមនុស្សឃាត ក្នុងន័យថា គោលបំណងរបស់ចារីគឺ ធ្វើឱ្យជនដទៃទៀតស្លាប់។ មានការលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការកំណត់និយមន័យធាតុផ្សំអត្តនោម័ត ពីព្រោះបានរួមបញ្ចូលការធ្វើមនុស្សឃាតដោយប្រយោល ឬបើតាមពាក្យពេចន៍ក្នុងច្បាប់ស៊ីវិល មនុស្សឃាតដោយប្រយោល។

៣៣. បន្ទាប់ពីបានពិនិត្យលើយុត្តិសាស្ត្រពាក់ព័ន្ធ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសទាក់ទងទៅនឹងបញ្ហានេះទេ។ អាស្រ័យហេតុនេះ ក៏អាចដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌពីបទមនុស្សឃាតបានដែរ បើទោះបីជាចារីពុំមានចេតនាផ្ទាល់ក៏ដោយ។

### ១.៣.១.២. កំហុសផ្នែកអង្គហេតុទាក់ទងទៅនឹងអំពើមនុស្សឃាត

៣៤. ទឡ្ហីករណ៍ដទៃទៀតនៃបណ្តឹងសាទុក្ខគឺ ជាប់ពាក់ព័ន្ធជាចម្បងទៅនឹងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងអំពីហេតុការណ៍នៃការធ្វើមនុស្សឃាត ដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ គឺការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងហេតុការណ៍នៃការធ្វើមនុស្សឃាតនៅទួលពោធិ៍ជ្រៃ។

៣៥. ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលត្រូវដោះស្រាយលើបញ្ហា ថាតើអង្គជំនុំជម្រះសាលាដំបូងត្រូវបង្ហាញអំពីហេតុការណ៍នីមួយៗនៃការសម្លាប់ឱ្យហួសពីវិមតិសង្ស័យដែរ ឬយ៉ាងណា ដែលជាសំណួរ

មួយត្រូវបានអង្គជំនុំជម្រះតុលាការកំពូលឆ្លើយតបជាវិជ្ជមាន។ អាស្រ័យហេតុនេះ ដើម្បីបង្ហាញថា ខ្មែរក្រហមបានប្រព្រឹត្តអំពើមនុស្សឃាតនោះ ដែលករណីនៃការសម្លាប់នីមួយៗត្រូវតែបង្ហាញឱ្យហួសពីវិមតិសង្ស័យ។

៣៦. ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះតុលាការកំពូល បានពិនិត្យដោយប្រុងប្រយ័ត្នលើការយល់ឃើញផ្នែកអង្គហេតុដែលជនជាប់ចោទបានជំទាស់។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការយល់ឃើញមួយចំនួនអំពីការសម្លាប់ ពុំត្រូវបានបង្ហាញដោយសមហេតុផល ព្រោះជាចម្បងបានផ្អែកលើភស្តុតាងក្រៅតុលាការ ឬភស្តុតាងដែលពុំមានតម្លៃគ្រប់គ្រាន់។ ទោះជាយ៉ាងណាក្តី មានករណីមួយចំនួនទាក់ទងនឹងការសម្លាប់ ត្រូវបានបង្ហាញដោយសមហេតុផល ផ្អែកលើភស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ អាស្រ័យហេតុនេះ ជាការសមហេតុផលក្នុងការសន្និដ្ឋានថា បទមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ។

### ១.៣.២. ការសម្លាប់រង្គាល

៣៧. ទាក់ទងទៅនឹងបទសម្លាប់រង្គាល មានទទ្បីករណ៍ជាច្រើននៃបណ្តឹងសាទុក្ខ ជាប់ពាក់ព័ន្ធទៅនឹងការកំណត់និយមន័យច្បាស់លាស់នៃបទឧក្រិដ្ឋនេះ។ ទី១ ជនជាប់ចោទបានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា សម្រាប់ជាតុផ្សំអត្តនោម័តនៃបទឧក្រិដ្ឋនេះ ការបង្ហាញឱ្យឃើញពីចេតនាប្រយោល គឺជាការគ្រប់គ្រាន់។

៣៨. អំណះអំណាងនេះមានមូលដ្ឋានត្រឹមត្រូវ។ បន្ទាប់ពីពិនិត្យលើយុត្តិសាស្ត្រពាក់ព័ន្ធ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខុសប្លែកពីបទមនុស្សឃាត បទសម្លាប់រង្គាលតម្រូវឱ្យមានការបង្ហាញអំពីចេតនាផ្ទាល់ក្នុងការសម្លាប់ទ្រង់ទ្រាយធំ។ ដូច្នេះ ការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងអំពីជាតុផ្សំអត្តនោម័តនៃបទសម្លាប់រង្គាល មានលក្ខណៈពុំត្រឹមត្រូវដោយផ្នែក។

៣៩. ជនជាប់ចោទបានលើកឡើងផងដែរថា នៅក្នុងព្រឹត្តិការណ៍នានា ក៏មានប្រជាជនជាច្រើនបានស្លាប់ផងដែរ និងថា ពុំមានការបង្ហាញថា ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ចំនួននៃការស្លាប់លើសអត្រាកំណត់មរណភាពធម្មតាឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងនេះដោយហេតុថា តាមការបញ្ជាក់របស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ ប្រសិនបើចារីបង្កព្យសនកម្មដល់ជនរងគ្រោះនោះចារីជាអ្នកទទួលខុសត្រូវចំពោះជនរងគ្រោះ។

៤០. អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជាការពុំសមហេតុផលក្នុងការសន្និដ្ឋានថា ជាតុផ្សំសត្យានុម័តអំពី «ទំហំធំ» នៃបទសម្លាប់រង្គាលត្រូវបានបង្ហាញថា មានអត្ថិភាពទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ។ ដោយផ្អែកលើភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង មានតែការស្លាប់មួយចំនួនតូចប៉ុណ្ណោះដែលអាចចាត់ទុកថា ត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ។ ដោយសារភស្តុតាងខ្សោយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ទើបពុំអាចសន្និដ្ឋានបាន

ថា ការសម្លាប់បានកើតឡើងក្នុងទ្រង់ទ្រាយធំឡើយ។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបាន សំអាងទៅលើសញ្ញាណចេតនាប្រយោល ដូចបានពន្យល់ខាងលើ ដែលនេះពុំមានលក្ខណៈគ្រប់គ្រាន់ សម្រាប់បទសម្លាប់រង្គាលឡើយ។

**៤១.** ចំពោះការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញ ថាមានហេតុការណ៍នៃការសម្លាប់មួយចំនួនត្រូវបានបង្ហាញដោយសមហេតុផល។ ទោះជាយ៉ាងណាក្តី ពុំមានភស្តុតាងគ្រប់គ្រាន់ដែលអាចឱ្យអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានដោយសមហេតុផលថា ការធ្វើមនុស្សឃាតបានកើតឡើងក្នុងទ្រង់ទ្រាយធំ ដូចលក្ខខណ្ឌតម្រូវនៃការសម្លាប់រង្គាលឡើយ។ បន្ថែមលើនេះទៀត ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញថា ចារីបានប្រព្រឹត្តដោយចេតនាផ្ទាល់ក្នុងការសម្លាប់ទ្រង់ទ្រាយធំប៉ុន្តែបានបញ្ជាក់ថាចារីបានប្រព្រឹត្តដោយចេតនាប្រយោលដូចបានកត់សម្គាល់ខាងលើ ដែលនេះពុំមានលក្ខណៈគ្រប់គ្រាន់សម្រាប់បទសម្លាប់រង្គាលនោះទេ។

**៤២.** យោងតាមសំអាងហេតុទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា បទសម្លាប់រង្គាលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២។

**៤៣.** ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ អង្គជំនុំជម្រះបានយល់ស្របថា មានបទមនុស្សឃាតត្រូវបានប្រព្រឹត្តឡើង។ ទាក់ទងទៅនឹងដំណាក់កាលទី២ បើទោះបីជាបទសម្លាប់រង្គាលពុំត្រូវបានប្រព្រឹត្តឡើងក៏ដោយ ក៏អង្គហេតុដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា មានអត្ថិភាព និងទទួលស្គាល់នៅដំណាក់កាលបណ្តឹងសាទុក្ខនេះ បានបំពេញតាមលក្ខខណ្ឌធាតុផ្សំទាំងអស់នៃបទមនុស្សឃាតដែរ អាស្រ័យហេតុនេះ អង្គជំនុំតុលាការកំពូលសម្រេចដាក់ពិរុទ្ធភាពផ្អែកលើមូលដ្ឋាននេះ។

**៤៤.** ទាក់ទងទៅនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ ជនជាប់ចោទបានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា យ៉ាងហោចណាស់ មានទាហានចំនួន២៥០នាក់នៃរបបសាធារណរដ្ឋខ្មែរត្រូវបានសម្លាប់ក្នុងខែមេសា ឆ្នាំ១៩៧៥។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងទាំងនេះឡើយ ដោយសារអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញចំនួនអប្បបរមានៃការស្លាប់ ដោយស្របតាមគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ដូច្នេះ ដូចគ្នានេះដែរ មានភាពច្បាស់លាស់ថា ករណីនេះ ចារីបានប្រព្រឹត្តដោយចេតនាផ្ទាល់ក្នុងការសម្លាប់ទ្រង់ទ្រាយធំ។

**៤៥.** សរុបសេចក្តីមក ការស្លាប់ និងការសម្លាប់ដែលបានកើតឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២ ត្រូវចាត់ជាបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ចំណែកការសម្លាប់នៅទួលពោធិ៍ជ្រៃ ត្រូវចាត់ជាអំពើសម្លាប់រង្គាល។

### ១.៣.៣. អំពើអមនុស្សធម៌ផ្សេងៗទៀត

៤៦. អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២ ពិតជាមានការប្រព្រឹត្តអំពើអមនុស្សធម៌ផ្សេងៗទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់នៃការផ្លាស់ទីលំនៅដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ បទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងក្រោមទម្រង់នៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ។

#### ១.៣.៣.១. វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងទៅលើបទអំពើអមនុស្សធម៌ផ្សេងៗទៀត

៤៧. ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះអំពើអមនុស្សធម៌ផ្សេងៗទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ធ្វើឱ្យមានការភ័ន្តច្រឡំត្រង់ថា អង្គជំនុំជម្រះសាលាដំបូង បានកំណត់និយមន័យនៃធាតុផ្សំការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ហាក់បីដូចជាមានអត្ថិភាពក្នុងប្រភេទបទឧក្រិដ្ឋដាច់ដោយឡែកពីគ្នា។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូង គប្បីផ្តោតលើបញ្ហា ថាតើនៅពេលពិចារណាជារួម អំពើប្រព្រឹត្តនេះមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋដទៃទៀត ដែលត្រូវទទួលស្គាល់ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ឬយ៉ាងណា។ បញ្ហានេះតម្រូវឱ្យមានការពិចារណាជារួម និងលើករណីជាក់លាក់នីមួយៗ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានធ្វើឡើងទៅលើបណ្តឹងសាទុក្ខ។

#### ១.៣.៣.២. កាលៈទេសៈក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងអនីត្យានុកូលភាពនៃការផ្លាស់ទីលំនៅនេះ

៤៨. ជនជាប់ចោទ បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងលក្ខខណ្ឌ និងការប្រើប្រាស់អំពើហិង្សា ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ជាទូទៅ ការយល់ឃើញរបស់ -- ការយល់ឃើញមានលក្ខណៈសមហេតុផល បើទោះបីជាការយល់ឃើញទូទៅមួយចំនួនពុំសមហេតុផល និងពុំមានភស្តុតាងគាំទ្រគ្រប់គ្រាន់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក៏ដោយ។

៤៩. អង្គជំនុំជម្រះតុលាការកំពូល ពុំជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការកំណត់ទាក់ទងទៅនឹងការធ្វើយុត្តិកម្មចំពោះការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ជាទូទៅ អំណះអំណាងរបស់ជនជាប់ចោទបានបង្ហាញត្រឹមតែជាជម្រើសនៃការបកស្រាយអំពីភស្តុតាងប៉ុណ្ណោះ ដែលនេះជាការពុំសមហេតុផលឡើយ។

### ១.៣.៣.៣. កាលៈទេសៈក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ និងអនីត្យានុកូលភាពនៃការផ្លាស់ទីលំនៅនេះ

**៥០.** ជនជាប់ចោទបានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ទាក់ទងទៅនឹងបញ្ហានេះ ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ រួមមានការផ្លាស់ទីលំនៅប្រជាជននៅក្នុងផ្នែកផ្សេងៗ នៃប្រទេសកម្ពុជា និងក្នុងរយៈពេលយូរ។ ផ្អែកលើអង្គហេតុនេះ ការយល់ឃើញទូទៅមួយចំនួនរបស់ អង្គជំនុំជម្រះសាលាដំបូង ពុំមានលក្ខណៈសមហេតុផល ដោយសារបានផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលមានកម្រិតខ្សោយ។ ទោះជាយ៉ាងណាក្តី ជាការសមហេតុផលក្នុងការយល់ឃើញថា ជាទូទៅការខ្វះស្បៀងអាហារ ទឹក សម្ភារៈ អនាម័យ ព្រមទាំងការខ្វះថ្នាំពេទ្យ ជំនួយផ្នែកវេជ្ជសាស្ត្រ និងមានភស្តុតាងគ្រប់គ្រាន់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងការយល់ឃើញថា ប្រជាជនមួយចំនួនត្រូវបានបាត់ខ្លួន និងប្រជាជនដទៃទៀតបានស្លាប់ដោយសារលក្ខខណ្ឌនៃការផ្លាស់ទីលំនៅនេះ។ ផ្ទុយទៅវិញ ជាការពុំសមហេតុផលក្នុងការយល់ឃើញ ដែលថា «ប្រជាជនភាគច្រើនលើសលប់» ដែលត្រូវបានជម្លៀសនោះជា «ប្រជាជនថ្មី» ដែលជាអតីតអ្នកទីក្រុង ដោយសារមានភស្តុតាងបង្ហាញឱ្យឃើញថា ទាក់ទងទៅនឹងការផ្លាស់ទីលំនៅនេះ ក៏មាន «ប្រជាជនចាស់» ផងដែរ។

### ១.៣.៣.៤. ថាតើការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២ ត្រូវចាត់ជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងកាលៈទេសៈនេះដែរឬយ៉ាងណា

**៥១.** ដូចបានលើកឡើងខាងលើ អាស្រ័យលើអង្គជំនុំជម្រះតុលាការកំពូល ក្នុងការវាយតម្លៃលើបញ្ហា ថាតើការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២ ត្រូវចាត់ជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែរឬយ៉ាងណា។

**៥២.** ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា មានការបង្ហាញឱ្យឃើញយ៉ាងហោចណាស់ មានប្រជាជនចំនួន២លាននាក់ត្រូវបានផ្លាស់ទីលំនៅដោយបង្ខំចេញពីទីក្រុងភ្នំពេញដោយគ្មានការជូនដំណឹងជាមុន និងក្រោមកាលៈទេសៈគួរឱ្យភ័យខ្លាច និងហិង្សា។ មានការបង្ហាញផងដែរថា ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន មានការសម្លាប់ និងការស្លាប់ដោយសារលក្ខខណ្ឌដែលបានបង្កទៅលើប្រជាជន។ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថាក្នុងកាលៈទេសៈនេះ ការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញបានបង្កឱ្យមានការរងទុក្ខ និងព្យសនកម្មធ្ងន់ធ្ងរផ្នែករូបកាយនិងផ្លូវចិត្ត និងធ្វើឱ្យប៉ះពាល់ដល់ប្រជាជនជាច្រើននាក់។ អាស្រ័យហេតុនេះ នេះគឺជាអំពើអមនុស្សធម៌ផ្សេងៗ ទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

**៥៣.** ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ យ៉ាងហោចណាស់ មានប្រជាជនពី ៣០០.០០០ ទៅ ៤០០.០០០ នាក់ ត្រូវបានបង្ខំឱ្យផ្លាស់ទីលំនៅ។ ការយល់ឃើញនេះត្រូវចាត់ទុកជាបានការនៅដំណាក់កាលបណ្តឹងសាទុក្ខ។ បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលទទួលយកការ

យល់ឃើញដែលថា ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅទាំងនោះ បានទទួលរងនូវលក្ខខណ្ឌធ្ងន់ធ្ងរដែលបណ្តាលមកពីការខ្វះស្បៀងអាហារ ទឹក និងសម្ភារៈអនាម័យ។ គ្រួសារខ្លះត្រូវបានបំបែកចេញពីគ្នា និងខ្លះបានស្លាប់នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅនោះ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា កាលៈទេសៈ ដែលបានធ្វើឱ្យប៉ះពាល់ដល់ប្រជាជនជាច្រើន ពិតជាមានលក្ខណៈគ្រប់គ្រាន់អាចចាត់ជាបទអំពើអមនុស្សធម៌ផ្សេងៗ ទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

### ១.៣.៤. ការធ្វើទុក្ខបុកម្នេញ

**៥៤.** អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា បទធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២ ព្រមទាំងនៅទួលពោធិ៍ជ្រៃ។ ជនរងគ្រោះនៃបទល្មើសនេះគឺ ជាទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ព្រមទាំងជនស៊ីវិល ដែលរស់នៅក្នុងទីក្រុងភ្នំពេញក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ដែលហៅថា «ប្រជាជន ១៧ មេសា» ឬ «ប្រជាជនថ្មី»។

#### ១.៣.៤.១. និយមន័យនៃការធ្វើទុក្ខបុកម្នេញ

**៥៥.** ជនជាប់ចោទ បានជំទាស់ទៅនឹងការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូង អំពីការធ្វើទុក្ខបុកម្នេញ។ យោងតាមអង្គជំនុំជម្រះសាលាដំបូង ក្រុមដែលជាកម្មវត្ថុនៃការធ្វើទុក្ខបុកម្នេញ អាចរួមបញ្ចូលផងដែរនូវក្រុម ដែលសមាជិករបស់ខ្លួនពុំប្រកាន់ទស្សនៈនយោបាយរួមណាមួយ ប៉ុន្តែត្រូវបានធ្វើទុក្ខបុកម្នេញដោយសារការជំរុញទឹកចិត្ត ឬកម្មវិធីនយោបាយរបស់ចារី។

**៥៦.** អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង ពុំមានកំហុសទាក់ទងទៅនឹងបញ្ហានេះទេ។ អង្គជំនុំជម្រះវិព្ញកពីការយល់ឃើញរបស់ខ្លួនក្នុងរឿងក្តី ឌុច ថាជនរងគ្រោះត្រូវតែជាក្រុមដែលមានការកំណត់បានច្បាស់លាស់គ្រប់គ្រាន់ដោយចារី ដោយផ្អែកលើមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា។ ជាពិសេស ក្រុមអាចក្លាយជាកម្មវត្ថុនៃការធ្វើទុក្ខបុកម្នេញ ព្រោះចារីបានកំណត់ពួកគេជាមុនថាជាអ្នកប្រឆាំងសក្តានុពល ឬជាឧបសគ្គចំពោះការអនុវត្តកម្មវិធីនយោបាយ។

#### ១.៣.៤.២. ប្រជាជនថ្មី គឺជាក្រុមដែលអាចកំណត់បានច្បាស់លាស់គ្រប់គ្រាន់

**៥៧.** ជនជាប់ចោទបានលើកឡើងបន្ថែមទៀតថា «ប្រជាជនថ្មី» ពុំមែនជាក្រុមដែលអាចកំណត់បានច្បាស់លាស់គ្រប់គ្រាន់ និងថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យពុំស៊ីសង្វាក់គ្នា។ អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់លើអំណះអំណាងទាំងនេះឡើយ ដោយសារ «ប្រជាជនថ្មី» បានរួមបញ្ចូលអ្នកដែលកំពុងរស់នៅក្នុងទីក្រុងភ្នំពេញនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដោយពុំគិតថា ពួកគេបានរស់នៅក្នុងទីក្រុងរយៈពេលយូរ ឬទើបតែមកស្នាក់នៅថ្មីៗនោះទេ។

#### ១.៣.៤.៣. ការធ្វើទុក្ខបុកម្នេញក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១

៥៨. អង្គជំនុំជម្រះតុលាការកំពូល ពិចារណាបន្ថែមទៀតថា ប្រជាជនទីក្រុងភ្នំពេញទាំងមូលត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការផ្លាស់ទីលំនៅ ដោយអ្នកទាំងអស់នេះ ត្រូវបានចាត់ទុកជាប្រជាជនថ្មី។ ទោះជាយ៉ាងណាក្តី នេះពុំមែនមានន័យថា ជាការកំណត់គោលដៅដោយមិនរើសមុខ និងមិនមែន មិនអាចចាត់ជាការធ្វើទុក្ខបុកម្នេញបាននោះទេ ពីព្រោះថា «ប្រជាជនថ្មី» ត្រូវបានកំណត់គោលដៅ ដោយសារពួកគេត្រូវបានសន្មត និងចាត់ទុកថា ជាតំណាងឱ្យក្រុមនោះ។ អាស្រ័យហេតុនេះ អំណះអំណាងរបស់ជនជាប់ចោទទាក់ទងនឹងបញ្ហានេះត្រូវបដិសេធចោល។

#### ១.៣.៤.៤. ការធ្វើទុក្ខបុកម្នេញក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២

៥៩. ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ អង្គជំនុំជម្រះតុលាការកំពូល ពុំជឿជាក់លើការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាមានភស្តុតាងបង្ហាញថា អ្នកដែលត្រូវបានជម្លៀសភាគច្រើនលើសលប់គឺជាប្រជាជនថ្មីនោះទេ។ដូច្នេះពុំបានបង្ហាញឱ្យឃើញថាការផ្លាស់ទីលំនៅនេះគឺជាការរើសអើងនោះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថាការធ្វើទុក្ខបុកម្នេញត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២។

### ១.៣.៥. ធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

៦០. អង្គជំនុំជម្រះតុលាការកំពូល បដិសេធទឡ្ហីករណ៍នៅក្នុងបណ្តឹងសាទុក្ខ ពាក់ព័ន្ធទៅនឹងធាតុផ្សំតាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ចំពោះសំអាងហេតុលម្អិត សម្រាប់ការយល់ឃើញនេះ មាននៅក្នុងសាលដីកាពេញលេញ។

## ១.៤. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល

៦១. បញ្ហាទាក់ទងទៅនឹងទឡ្ហីករណ៍ អំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលគឺ ថាតើជនជាប់ចោទអាចដាក់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដែរ ឬយ៉ាងណា។

៦២. អង្គជំនុំជម្រះសាលាដំបូង បានរកឃើញថា ជនជាប់ចោទត្រូវបានដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្រោមទម្រង់មូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម ហៅថា សហឧក្រិដ្ឋកម្មរួមទម្រង់ I ព្រមទាំងទទួលខុសត្រូវចំពោះការរៀបចំផែនការ ការញុះញង់ ការជួយនិងជំរុញ និងចំពោះជនជាប់ចោទ នួន ជា តែម្នាក់ ទាក់ទងទៅនឹងការបញ្ជានៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនេះ និងបានផ្អែកទៅលើមូលដ្ឋាននៃការទទួលខុសត្រូវរបស់ថ្នាក់លើ។

### ១.៤.១. សហឧក្រិដ្ឋកម្មរួម

**៦៣.** ជនជាប់ចោទ បានលើកទឡ្ហីករណ៍មួយចំនួន នៅក្នុងបណ្តឹងសាទុក្ខទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ខ្លួនផ្អែកលើសហឧក្រិដ្ឋកម្មរួម។

#### ១.៤.១.១. អត្ថិភាពនៃការទទួលខុសត្រូវដោយផ្អែកលើសហឧក្រិដ្ឋកម្មរួមទម្រង់ I នៅក្នុងអំឡុងពេលដែលជាប់ពាក់ព័ន្ធ

**៦៤.** ជាការកត់សម្គាល់ ជនជាប់ចោទបានជំទាស់ទៅនឹងអត្ថិភាពនៃការទទួលខុសត្រូវ ដោយផ្អែកលើសហឧក្រិដ្ឋកម្មរួមទម្រង់ I ។ ជនជាប់ចោទបានលើកឡើងថា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានអត្ថិភាពនៅពេលនោះ ការទទួលខុសត្រូវ ត្រូវបានកម្រិតត្រឹមតែការរួមចំណែកនៅក្នុងឧក្រិដ្ឋកម្មជាក់លាក់ និងថា ត្រឹមតែការរួមចំណែកនៅក្នុងការអនុវត្តគោលបំណងរួម ពុំគ្រប់គ្រាន់ក្នុងការបង្កើតឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលឡើយ។

**៦៥.** អង្គជំនុំជម្រះតុលាការកំពូល ពុំជឿជាក់លើអំណះអំណាងនេះឡើយ។ បើទោះបីជាពាក្យ «សហឧក្រិដ្ឋកម្មរួម» ត្រូវបានបង្កើតឡើងដោយតុលាការ ICTY ក៏ដោយ ក៏សញ្ញាណមូលដ្ឋាននេះបានកើតមានរួចហើយនៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២។ ជាការកត់សម្គាល់ ក្រោយសង្គ្រាមលោកលើកទី២ ចារីត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋនានា ដែលខ្លួនពុំបានប្រព្រឹត្តដោយផ្ទាល់ឡើយ ដោយហេតុថាបទឧក្រិដ្ឋនេះមាននៅក្នុងគោលបំណងឧក្រិដ្ឋរួមដែលចារីបានរួមចំណែក។

**៦៦.** អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា គោលបំណងរួមត្រូវតែមានចរិតជាបទល្មើស។ នេះមានន័យថា ជាការប្រព្រឹត្តបទឧក្រិដ្ឋមួយ ឬច្រើន ឬការអនុវត្តគោលបំណងរួមដែលត្រូវតែជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋមួយ ឬច្រើន។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូង បានសំអាងទៅលើការបង្កើតរូបមន្តមួយ ដែលខុសប្លែកបន្តិច ត្រង់ថា អង្គជំនុំជម្រះសាលាដំបូង បានកំណត់ ថាតើគោលបំណងរួមក្នុងចំណោមនោះ បានបណ្តាលឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋដែរ ឬយ៉ាងណា។ នេះបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទឧក្រិដ្ឋដែលជាទូទៅបណ្តាលមកពី ការអនុវត្តគោលបំណងរួម អាចដាក់ឱ្យជនជាប់ចោទទទួលខុសត្រូវបាន បើទោះបីជាបទឧក្រិដ្ឋនេះ ពុំមែនជាផ្នែកនៃគោលបំណងរួមក៏ដោយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នេះជាការ -- នេះត្រូវចាត់ជាការទទួលខុសត្រូវមួយប្រភេទដែលជាការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ III ឬទម្រង់ទូលាយ។ ដូច្នេះ បញ្ហាគឺ ថាតើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលមានអត្ថិភាពក្នុងឆ្នាំ១៩៧៥ ជនជាប់ចោទអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវដែរ ឬយ៉ាងណា ចំពោះបទឧក្រិដ្ឋ ដែលកើតចេញតែពីការអនុវត្តគោលបំណងរួម ប៉ុន្តែពុំមាននៅក្នុងគោលបំណងរួមនោះ។

**៦៧.** ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ និងយល់ស្របជាមួយនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលថា ការទទួលខុសត្រូវនេះ ពុំមានអត្ថិភាពនៅពេលនោះឡើយ។

ដោយបានពិចារណាលើយុត្តិសាស្ត្រពាក់ព័ន្ធ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានបានថា ពិតជាពុំមានមូលដ្ឋានតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិសម្រាប់ការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ដែលពុំមាននៅក្នុងគោលបំណងរួមប្រាកដមែន។

**៦៨.** យោងតាមការយល់ឃើញនេះ តម្រូវឱ្យមានការបង្ហាញពីលក្ខណៈវិនិច្ឆ័យ ដើម្បីកំណត់ថាតើបទឧក្រិដ្ឋណាខ្លះ ដែលមាននៅក្នុងគោលបំណងរួមនេះ។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា គោលបំណងរួម ត្រូវចាត់ទុកជា ការប្រព្រឹត្តបទឧក្រិដ្ឋ នៅពេលដែលបទឧក្រិដ្ឋនេះស្ថិតក្នុងចំណោមគោលដៅចម្បងនៃគោលបំណងរួម។ ផ្ទុយទៅវិញ គោលបំណងរួមជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ នៅពេលដែលបទឧក្រិដ្ឋនោះពុំមែនជាគោលដៅផ្ទាល់នៃកិច្ចប្រតិបត្តិការ ប៉ុន្តែត្រូវបានរកឃើញថា ជាមធ្យោបាយដើម្បីសម្រេចគោលដៅចុងក្រោយមួយ។ បញ្ហា ថាតើបទឧក្រិដ្ឋមានគោលបំណងរួម -- មានក្នុងគោលបំណងរួមដែរ ឬយ៉ាងណានោះ ជាចម្បង គឺជាបញ្ហានៃអង្គហេតុ ឧទាហរណ៍ ដូចជា កត្តាពាក់ព័ន្ធនានាដែលនឹងក្លាយជាគោលដៅទូទៅនៃគោលបំណងរួម និងភវនីយភាពនៃគោលបំណងរួមនេះអាចសម្រេចបានលុះត្រាតែមានការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។

**៦៩.** សរុបសេចក្តីមកអង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការកំណត់និយមន័យអំពីធាតុផ្សំផ្នែកច្បាប់នៃការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម។ បញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការវាយតម្លៃលើបញ្ហា ថាតើធាតុផ្សំនៃការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម ប្រសិនបើបកស្រាយឱ្យត្រឹមត្រូវនោះ បានបំពេញតាមលក្ខខណ្ឌដែរ ឬយ៉ាងណា។

### ១.៤.១.២. ការកំណត់និយមន័យនៃគោលបំណងរួម

**៧០.** ទាក់ទងទៅនឹងអំណះអំណាងបន្ទាប់ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា ការទទួលខុសត្រូវក្រោមទម្រង់ I នៃសហឧក្រិដ្ឋកម្មរួមតម្រូវថា គោលបំណងរួមត្រូវតែមានចរិតជាបទល្មើស។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា ជនជាប់ចោទបានយល់ស្របទៅនឹងគោលបំណងរួម ដែលអង្គជំនុំជម្រះចាត់ទុកថា ពុំមានចរិតជាបទល្មើសនោះ គឺការកសាងបដិវត្តន៍សង្គមនិយមឆាប់រហ័សក្នុងប្រទេសកម្ពុជា។

**៧១.** ទោះជាយ៉ាងណាក្តី គោលបំណងរួមនេះត្រូវតែពិនិត្យមើលនៅក្នុងបរិបទនៃគោលនយោបាយខ្មែរក្រហមក្នុងការផ្លាស់ទីលំនៅប្រជាជន និងគោលបំណង គោលនយោបាយកំណត់គោលដៅលើទាហាននៃរបបសាធារណរដ្ឋខ្មែរ។ យោងតាមអង្គជំនុំជម្រះសាលាដំបូង គោលនយោបាយទាំងនេះត្រូវបានប្រើប្រាស់ដើម្បីជំរុញបដិវត្តន៍សង្គមនិយមក្នុងប្រទេសកម្ពុជាឱ្យទទួលបានផ្លែផ្កា។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ថា គោលនយោបាយទាំងនេះជាក់ស្តែង គឺជាផ្នែកនៃគោលបំណងរួមក៏ដោយ ក៏នៅតែមានភាពច្បាស់លាស់ថា អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកគោលនយោបាយនេះជាមធ្យោបាយសម្រាប់កសាងបដិវត្តន៍សង្គមនិយម។ ដូច្នេះ បើទោះបីជាការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអាចសន្មតថា ខ្វះភាពជាក់លាក់ក៏ដោយ ក៏នៅតែច្បាស់លាស់ថា មានទិដ្ឋភាពល្មើសនៃគោលនយោបាយទាំងពីរដែលជាស្នូលនៃសំណុំរឿង ០០២/០១។

៧២. យោងតាមហេតុផលនេះ អង្គជំនុំជម្រះតុលាការកំពូល បដិសេធអំណះអំណាងរបស់ជនជាប់ចោទ ដែលថា គោលបំណងរួម ដែលអង្គជំនុំជម្រះសាលាដំបូង បានរកឃើញនេះពុំមែនជាបទល្មើស ដូច្នេះពុំអាចបង្ហាញថា មានការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួមនោះឡើយ។

### ១.៤.១.៣. អត្ថិភាព និងខ្លឹមសារនៃគោលនយោបាយផ្លាស់ទីលំនៅប្រជាជន

៧៣. ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខមួយចំនួនបានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងអត្ថិភាព និងខ្លឹមសារនៃគោលនយោបាយផ្លាស់ទីលំនៅប្រជាជនពីទីក្រុង និងទីរួមខេត្តនានា ទៅកាន់ទីជនបទ និងពីតំបន់មួយទៅតំបន់មួយផ្សេងទៀត។

៧៤. ទាក់ទងទៅនឹងគោលនយោបាយជម្លៀសប្រជាជនចេញពីទីក្រុង និងទីរួមខេត្តនានា អង្គជំនុំជម្រះតុលាការកំពូល រកពុំឃើញកំហុសណាមួយ នៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា គោលនយោបាយ ត្រូវបានបង្ហាញឱ្យឃើញក្នុងចំណោមនោះ តាមរយៈលំនាំស៊ីសង្វាក់គ្នានៃការជម្លៀសប្រជាជនជាពិសេស ដោយសារអង្គជំនុំជម្រះសាលាដំបូងពុំបានបញ្ជាក់ថា ការផ្លាស់ទីលំនៅទាំងអស់នេះ បានធ្វើឡើងតាមវិធីសាស្រ្តដូចៗ គ្នានៅក្នុងប្រតិបត្តិការនោះឡើយ។

៧៥. ទាក់ទងទៅនឹងគោលនយោបាយផ្លាស់ទីលំនៅប្រជាជនពីតំបន់មួយទៅតំបន់មួយផ្សេងទៀត អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំណះអំណាងរបស់ជនជាប់ចោទពុំមានមូលដ្ឋានគ្រប់គ្រាន់ឡើយ ហើយ ទាក់ទងទៅនឹងបញ្ហានេះ មានពន្យល់លម្អិតនៅក្នុងសាលដីកាពេញលេញ។

### ១.៤.១.៤. ឧក្រិដ្ឋកម្មដែលមាននៅក្នុងគោលបំណងរួមទាក់ទងទៅនឹង ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២

៧៦. បញ្ហាបន្ទាប់ដែលត្រូវដោះស្រាយគឺ បទឧក្រិដ្ឋណាខ្លះ ដែលជាក់ស្តែងមាននៅក្នុងគោលបំណងរួមទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១។

៧៧. សេចក្តីសង្ខេបនេះផ្តោតតែទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូល ទាក់ទងទៅនឹង បទមនុស្សឃាត ដោយសារបទចោទនេះមានភាពចម្រូងចម្រាសខ្លាំង។ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា គោលបំណងរួម មានរួមបញ្ចូលការសម្លាប់អ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ និង មានការជាប់ពាក់ព័ន្ធទៅនឹងការស្លាប់ ដែលបណ្តាលមកពីលក្ខខណ្ឌ ដែលបានធ្វើឡើងនៅក្នុងអំឡុងពេល នៃការផ្លាស់ទីលំនៅប្រជាជន និងការសម្លាប់ជនស៊ីវិល និងអតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ។ នេះគឺ ដោយសារ ក្នុងកាលៈទេសៈនោះ សមាជិកនៃសហឧក្រិដ្ឋកម្មរួមបានដឹងអំពីលក្ខខណ្ឌចំពោះអ្នក ដែលត្រូវ ជម្លៀស នឹងត្រូវទទួលរង និងដឹងថា អ្នកដែលងាយរងគ្រោះបំផុត ទំនងជានឹងស្លាប់ដោយសារលក្ខខណ្ឌ នេះ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការផ្លាស់ទីលំនៅ គឺជាប់ពាក់ព័ន្ធទៅនឹងប្រជាជនក្នុងទីក្រុង ភ្នំពេញទាំងមូល ដែលកើតឡើងក្នុងរយៈពេលខ្លី និងក្នុងរដូវប្រាំង ដែលក្តៅបំផុត។

**៧៨.** ទាក់ទងទៅនឹងការសម្លាប់ជនស៊ីវិល និងទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបានធ្វើឡើងក្នុងរយៈពេលមួយយ៉ាងខ្លី និងតាមរយៈកងទ័ពប្រដាប់អាវុធធុនធ្ងន់។ កាលៈទេសៈនេះបង្ហាញឱ្យឃើញដោយប្រយោលថា គោលបំណងរួម មានរួមបញ្ចូលការរំពឹងទុកថា នឹងប្រើអំពើហិង្សាដល់អាយុជីវិតពីសំណាក់កងទ័ព ដែលទទួលបានភារកិច្ចក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ប្រសិនបើមានការប្រឆាំង ការចចេសរឹងរូសណាមួយនោះ។នេះគឺជាករណីដែលពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហាថាតើមានការដាក់បទបញ្ជាជាក់លាក់ឱ្យសម្លាប់ដែរ ឬយ៉ាងណា និង ថាតើនរណាជាអ្នកចេញបទបញ្ជានេះ ព្រមទាំង ថាតើបញ្ហានេះ -- ថាតើបទបញ្ជានេះត្រូវបានចេញចំពោះតែកងទ័ពនៅក្រោមមេបញ្ជាការមួយចំនួនដែរ ឬយ៉ាងណានោះឡើយ។

**៧៩.** បញ្ហាបន្ទាប់ទៀតគឺ ថាតើការធ្វើមនុស្សឃាតស្ថិតក្នុងចំណោមបទឧក្រិដ្ឋដែលមាននៅក្នុងគោលបំណងរួមដែរ ឬយ៉ាងណា ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២។ ផ្អែកលើកាលៈទេសៈនៃការផ្លាស់ទីលំនៅប្រជាជននេះ ពុំមានការបង្ហាញថា មានគោលនយោបាយផ្តល់ការយកចិត្តទុកដាក់គ្រប់គ្រាន់ចំពោះអ្នកដែលត្រូវបានជម្លៀសឬការពារពួកគេពីការរំលោភបំពាននានានោះឡើយ។អាស្រ័យហេតុនេះការស្លាប់ដែលបានកើតឡើងចំពោះអ្នកដែលត្រូវបានជម្លៀសនោះ ហើយទំនងជាជាប់ពាក់ព័ន្ធទៅនឹងសមាជិកនៃសហឧក្រិដ្ឋកម្មរួមក្នុងការអនុវត្តគោលបំណងរួមនោះ។ ដូច្នេះ គោលនយោបាយផ្លាស់ទីលំនៅប្រជាជនមានរួមបញ្ចូលដោយប្រយោលនូវបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

### ១.៤.២. អត្ថិភាព និងខ្លឹមសារនៃគោលនយោបាយកំណត់គោលដៅ

**៨០.** អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខ្មែរក្រហមមានគោលនយោបាយកំណត់គោលដៅលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលគោលនយោបាយនេះពាក់ព័ន្ធទៅនឹងការសម្លាប់នៅទួលពោធិ៍ជ្រៃ។ អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើសេចក្តីថ្លែងការណ៍របស់ខ្មែរក្រហម និងបទបញ្ជា ព្រមទាំងអត្ថិភាពនៃលំនាំស៊ីសង្វាក់គ្នានៃការសម្លាប់។ ជនជាប់ចោទបានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងបញ្ហានេះ។

**៨១.** អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ថា ទាក់ទងទៅនឹងលំនាំនៃការសម្លាប់ ដែលមានអត្ថិភាព នៅមុនខែមេសា ឆ្នាំ១៩៧៥ អង្គជំនុំជម្រះសាលាដំបូង បានផ្តោតជាសំខាន់ទៅលើការសម្លាប់នៅឧដុង្គ ក្នុងឆ្នាំ១៩៧៤។ ទោះជាយ៉ាងណាក្តី ដូចបានពន្យល់នៅក្នុងសំអាងហេតុនៃសាលដីការបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ភស្តុតាងក្នុងសំណុំរឿងមានលក្ខណៈខ្សោយពេក ពុំអាចគាំទ្រការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនេះបានឡើយ។ ភស្តុតាងដទៃទៀតនៃការសម្លាប់នៅមុនឆ្នាំ១៩៧៥ ក៏មានលក្ខណៈខ្សោយផងដែរ។

**៨២.** ចំពោះភស្តុតាងនៃការសម្លាប់នៅក្នុងអំឡុងពេលភ្លាមៗ មុន និងក្រោយព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា ជាទូទៅក៏មានកម្រិតខ្សោយដែរ លើកលែងតែហេតុការណ៍ពីរ ឬបីប៉ុណ្ណោះ។ ប្រហាក់ប្រហែលគ្នានេះដែរ ទាក់ទងទៅនឹងការសម្លាប់នៅចុងឆ្នាំ១៩៧៥ អង្គជំនុំជម្រះសាលាដំបូង បានសំអាងទៅលើភស្តុតាងដែលជាញឹកញាប់មានកង្វះព័ត៌មានលម្អិត និងជាចម្បង ជាចម្លើយក្រៅតុលាការដែលពុំមានការបញ្ជាក់បន្ថែមឡើយ។

៨៣. អង្គជំនុំជម្រះតុលាការកំពូល ពុំជឿជាក់លើភស្តុតាងដទៃទៀត ប្រហាក់ប្រហែលគ្នានេះដែរ ដែលអង្គជំនុំជម្រះសាលាដំបូង បានសំអាងទៅលើនោះ ដូចជាសុន្ទរកថា សេចក្តីថ្លែងការណ៍អំពីគោលនយោបាយ និងសេចក្តីណែនាំនានារបស់ខ្មែរក្រហម។

៨៤. សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ពុំមានលក្ខណៈគ្រប់គ្រាន់ ក្នុងការផ្តល់មូលដ្ឋានគាំទ្រសមហេតុផលដល់ការយល់ឃើញដែលថា នៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ មានគោលនយោបាយសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ។ ភស្តុតាងភាគច្រើន គឺជាចម្លើយក្រៅតុលាការ ដែលមានតម្លៃភស្តុតាងទាប។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាដំបូង ពុំបានពិចារណាលើភស្តុតាងមួយចំនួន ដែលចោទជាបញ្ហាដល់អត្ថិភាពនៃគោលនយោបាយជារួមក្នុងការសម្លាប់។ អង្គជំនុំជម្រះតុលាការកំពូល រំឭកនៅក្នុងបរិបទនេះថា ដោយសារលទ្ធផលនៃការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ទើបវិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានរឹតត្បិតត្រង់ចំណុចពាក់ព័ន្ធទៅនឹងគោលនយោបាយកំណត់គោលដៅចំពោះព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃដែលបានកើតឡើងនៅក្នុងចុងខែមេសា ឆ្នាំ១៩៧៥។ ជាលទ្ធផលបានធ្វើឱ្យការពិចារណាទទួលរងការប៉ះពាល់ ដោយសារការកម្រិតពេលវេលានេះ ដែលបណ្តាលឱ្យភស្តុតាងមួយផ្នែកជំលែងមានភាពពាក់ព័ន្ធទៅនឹងពេលវេលា ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងពុំអាចបង្ហាញ ថាតើមូលហេតុអ្វីខ្លះ ជាសេចក្តីណែនាំនានាដាក់ចេញក្នុងឆ្នាំ១៩៧៦ និងក្រោយមក បែរជាបញ្ជាក់អំពីអត្ថិភាពគោលនយោបាយក្នុងខែមេសា ឆ្នាំ១៩៧៥ ទៅវិញ។

៨៥. យោងតាមហេតុផលខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ផ្អែកលើភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ពុំមានលក្ខណៈសមហេតុផលក្នុងការយល់ឃើញថា គោលនយោបាយក្នុងការសម្លាប់ទាហាននិងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរមានអត្ថិភាពនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃទេ។ អាស្រ័យហេតុនេះ ជនជាប់ចោទពុំអាចដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃឡើយ។

## ១.៤.៣. បទដ្ឋានគតិយុត្តទាក់ទងទៅនឹងការរួមចំណែកនៅក្នុងគោលបំណងរួម

៨៦. ទាក់ទងទៅនឹងបទដ្ឋានគតិយុត្ត ទាក់ទងទៅនឹងការរួមចំណែកនៅក្នុងគោលបំណងរួម ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញថា ខ្លួនមានការរួមចំណែកក្នុងការប្រព្រឹត្តអំពើល្មើស ប៉ុន្តែគ្រាន់តែថា មានការជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពជាទូទៅ នៅក្នុងគោលបំណងកសាងបដិវត្តន៍សង្គមនិយមនៅកម្ពុជាប៉ុណ្ណោះ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងជាទូទៅបានបញ្ជាក់អំពីបទដ្ឋានគតិយុត្តត្រឹមត្រូវ ត្រង់ថា ការរួមចំណែករបស់ជនជាប់ចោទត្រូវតែសំខាន់ ប៉ុន្តែពុំចាំបាច់សំខាន់រហូតដល់ខ្វះមិនបាននោះទេ។ អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញត្រឹមត្រូវផងដែរថា ការរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួមអាចធ្វើឡើងតាមទម្រង់ជាច្រើន។ បើសូម្បីសកម្មភាពដែលតាមសេចក្តីបញ្ជាក់ដំបូងពុំជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋក៏ដោយ ក៏អាចយកមកពិចារណាបានដែរ នៅពេលកំណត់ ថាតើជនជាប់ចោទបានរួមចំណែកយ៉ាងសំខាន់ដែរ ឬយ៉ាងណានោះ។ អាស្រ័យហេតុនេះ ការកំណត់ជានិច្ចកាល គប្បីផ្អែកលើការវាយតម្លៃរាល់សកម្មភាពទាំងអស់របស់ជនជាប់ចោទ ដែលអង្គជំនុំជម្រះយល់ឃើញថា មានអត្ថិភាពនោះ។

**៨៧.** សរុបសេចក្តីមក អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសឡើយក្នុងការពិចារណាលើសកម្មភាពរបស់ជនជាប់ចោទ ដែលតាមរូបភាពខាងក្រៅ ពុំឃើញមានគោលដៅប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ឡើយ។

### ១.៤.៤. ការរួមចំណែករបស់ នួន ជា នៅក្នុងការអនុវត្តគោលបំណងរួម

**៨៨.** អង្គជំនុំជម្រះសាលាដំបូង បានកំណត់ការរួមចំណែករបស់ នួន ជា ជាពីរប្រភេទក្នុងការអនុវត្តគោលបំណងរួម។ ទី១ គឺការជាប់ពាក់ព័ន្ធរបស់គាត់នៅក្នុងការរៀបចំផែនការនៃគោលបំណងរួម និងទី២ គឺតួនាទីរបស់គាត់នៅក្នុងសកម្មភាពទាក់ទងទៅនឹងការឃោសនា ការបណ្តុះបណ្តាល អប់រំជាសាធារណៈ។ នួន ជា បានលើកទឡ្ហីករណ៍មួយចំនួននៅក្នុងបណ្តឹងសាទុក្ខប្រឆាំងនឹងការយល់ឃើញនេះ។

**៨៩.** អង្គជំនុំជម្រះតុលាការកំពូល បដិសេធទឡ្ហីករណ៍មួយចំនួននៅក្នុងបណ្តឹងសាទុក្ខ ដោយសារពុំមានសក្តានុពលអាចនាំឱ្យមោឃៈសាលក្រម ដែលមានដូចជា ការជំទាស់ទៅនឹងការដាក់ងារជាបងធំទី២។ ទាក់ទងទៅនឹងទឡ្ហីករណ៍ដទៃទៀតនៅក្នុងបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា នួន ជា បានត្រឹមតែផ្តល់ការបកស្រាយមួយបែបផ្សេងទៀតទៅលើភស្តុតាងប៉ុណ្ណោះ។ ជាពិសេស បញ្ហានេះពាក់ព័ន្ធទៅនឹងការយល់ឃើញដែលថា គាត់មានឥទ្ធិពលខ្លាំងលើគោលនយោបាយយោធា និងថា គាត់មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចចុងក្រោយនៅក្នុងបក្ស ដូច ប៉ុល ពត ដែរ។

**៩០.** ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញដោយសមហេតុផលថា នួន ជា ទទួលបន្ទុកខាងដាក់វិន័យរបស់បក្សឡើយ។ ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា កំហុសនេះ ពុំមានឥទ្ធិពលលើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា នួន ជា បានរួមចំណែកយ៉ាងសំខាន់នៅក្នុងការអនុវត្តគោលបំណងរួមនោះឡើយ។

### ១.៤.៥. ការរួមចំណែករបស់ ខៀវ សំផន នៅក្នុងការអនុវត្តគោលបំណងរួម

**៩១.** ទាក់ទងទៅនឹងការរួមចំណែករបស់ ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូង បានកំណត់សកម្មភាពដូចតទៅ។ ទី១ ខៀវ សំផន បានចូលរួមកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម និងសមាជបក្ស ព្រមទាំងកិច្ចប្រជុំផ្សព្វផ្សាយគោលនយោបាយខ្មែរក្រហមដល់កម្មាភិបាលថ្នាក់ក្រោម។ ទី២ ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចការសេដ្ឋកិច្ចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទី៣ គាត់បានធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈគាំទ្រគោលបំណងរួម និងគោលនយោបាយរបស់ខ្មែរក្រហម។ ចុងក្រោយ គាត់បានបម្រើការជាអ្នកការទូតក្នុងការគៀងគរការគាំទ្រពីខាងក្រៅខ្មែរក្រហម។ ខៀវ សំផន បានចោទប្រកាន់កំហុសមួយចំនួននៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង។

**៩២.** អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ការយល់ឃើញភាគច្រើននេះត្រូវបានធ្វើឡើងដោយសមហេតុផល។ ទោះជាយ៉ាងណាក្តី ជាការពុំសមហេតុផលក្នុងការយល់ឃើញថា ខៀវ សំផន បានចូលរួម

កិច្ចប្រជុំក្នុងខែមិថុនា ឆ្នាំ១៩៧៤ ដែលក្នុងពេលនោះមានការពិភាក្សាអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញឡើយ ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់ពីមូលហេតុដែលខ្លួនបានសម្រេចបដិសេធសក្ខីកម្មលម្អិតរបស់ នួន ជា ដែលបានលើកឡើងផ្ទុយពីការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង។ ប្រហាក់ប្រហែលគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូង ក៏មានកំហុសដែរ ក្នុងការចាត់ទុកសុន្ទរកថាដែលបានធ្វើឡើងក្នុងឆ្នាំ១៩៧៦ ថាជារបស់ ខៀវ សំផន។

**៩៣.** បើទោះបីជាការយល់ឃើញនេះមានកំហុសក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា សេចក្តីសន្និដ្ឋានទូទៅរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងការរួមចំណែករបស់ ខៀវ សំផន ជាការសមហេតុផល ដោយពិចារណាលើសកម្មភាពទាំងមូលរបស់គាត់។

### ១.៤.៦. ការយល់ឃើញថា ប.ក.ក. ជាបក្សដែលមានលក្ខណៈរួបរួម និងមានឋានានុក្រម និងថា កងទ័ពដែលបានចូលរួមក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញមានលក្ខណៈរួបរួមគ្នា

**៩៤.** ជនជាប់ចោទបានអះអាងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការយល់ឃើញថា បក្សកុម្មុយនីស្តកម្ពុជា ជាបក្សដែលមានលក្ខណៈរួបរួម និងមានឋានានុក្រម ដោយសារតែ តាំងពីដំបូងមក បក្សនេះបានបំបែកជាក្រុមតូចៗ ដ៏មានអំណាច ដែលក្រោយមកក៏បានធ្វើការបះបោរប្រឆាំងនឹងបក្ស។ ជនជាប់ចោទបានលើកឡើងថា ពុំមានតុលាការអង្គហេតុសមហេតុផលណាមួយអាចសន្និដ្ឋានបានថា ប៉ុល ពត និង នួន ជា បានរួមចំណែកក្នុងគោលបំណងរួម ជាមួយនឹងមេដឹកនាំភូមិភាគមួយចំនួនដែលធ្វើការបះបោរប្រឆាំងនឹងពួកគាត់បាននោះឡើយ។

**៩៥.** អង្គជំនុំជម្រះតុលាការកំពូល ពុំជឿជាក់លើអំណះអំណាងនេះឡើយ។ អង្គជំនុំជម្រះរំឭកថា ជនជាប់ចោទត្រូវបានរកឃើញថា ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដោយផ្អែកលើសហឧក្រិដ្ឋកម្មរួម។ អាស្រ័យហេតុនេះប្រសិនបើថា ផែនការសម្លាប់របស់មេដឹកនាំភូមិភាគមួយចំនួនមានអត្ថិភាពក៏ដោយ ក៏ពុំមែនមានន័យថាបទឧក្រិដ្ឋ ដែលជនជាប់ចោទត្រូវបានដាក់ឱ្យទទួលខុសត្រូវនោះ ពុំអាចដាក់ទៅលើសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមបាននោះទេ ដរាបណានៅតែមានការបង្ហាញថា មានគោលបំណងរួម ហើយបទឧក្រិដ្ឋគឺជាផ្នែកនៃគោលបំណងរួមនេះ។

### ១.៤.៧. កំហុសអង្គច្បាប់ទាក់ទងទៅនឹងចេតនាតម្រូវ

**៩៦.** ទាក់ទងទៅនឹងចេតនាតម្រូវសម្រាប់ការទទួលខុសត្រូវតាមទម្រង់សហឧក្រិដ្ឋកម្មរួម ខៀវ សំផន បានលើកឡើងថា បទដ្ឋានត្រឹមត្រូវ គឺ ចេតនាធ្វើឱ្យគោលបំណងរួមមានប្រសិទ្ធភាព។ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង គឺជាការត្រឹមត្រូវដែលថា ចេតនាត្រូវគ្របដណ្តប់ទាំងគោលបំណងរួម ទាំងបទឧក្រិដ្ឋនានាដែលមានក្នុងនោះ។

**៩៧.** ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការអនុវត្តបទដ្ឋានកម្រិតទាប ព្រោះអង្គជំនុំជម្រះបានវាយតម្លៃលើបញ្ហា ថាតើគាត់បានដឹងអំពីភវនីយភាពខ្ពស់នៃការប្រព្រឹត្តបទល្មើស បទឧក្រិដ្ឋដែរ ឬយ៉ាងណា។ ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ភវនីយភាពខ្ពស់ គឺពុំមែនជាបទដ្ឋានត្រឹមត្រូវនោះទេ។ ទោះជាយ៉ាងណាក្តី បទដ្ឋានត្រឹមត្រូវចាំបាច់ត្រូវកំណត់ដោយផ្អែកលើបទឧក្រិដ្ឋជាក់លាក់ដែលរងការចោទប្រកាន់នេះ។ ជាឧទាហរណ៍ ចំពោះបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លក្ខខណ្ឌតម្រូវនៃធាតុផ្សំអត្តនោម័ត គឺចេតនាផ្ទាល់ ឬចេតនាប្រយោល។ ដូច្នេះ ប្រសិនបើអំពើមនុស្សឃាតត្រូវបានប្រព្រឹត្តឡើងតាមរយៈសហឧក្រិដ្ឋកម្មរួម នេះជាការគ្រប់គ្រាន់ក្នុងការបង្ហាញថា ជនជាប់ចោទបានដឹងថា ការស្លាប់នឹងកើតមានដោយសារផលវិបាកនៃការអនុវត្តគោលបំណងរួម ប៉ុន្តែនៅតែបន្តអនុវត្តដោយពុំគិតពីអ្វីកើតឡើង និងបានទទួលយកការស្លាប់ដែលអាចកើតមាននោះ។ អាស្រ័យហេតុនេះ ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូង លើបទដ្ឋានភវនីយភាពខ្ពស់នេះ តាមធម្មតាពុំមែនជាកំហុស ប៉ុន្តែអាស្រ័យលើបទឧក្រិដ្ឋដែលពាក់ព័ន្ធនោះ។

### ១.៤.៨. ចេតនារបស់ នួន ជា

**៩៨.** មានភាពច្បាស់លាស់ថា នួន ជា បានប្រព្រឹត្តដោយចេតនាផ្ទាល់ ទាក់ទងទៅនឹងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ជាការពិត នួន ជា ក៏បានទទួលស្គាល់ថា គាត់បានចូលរួមនៅក្នុងការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

**៩៩.** ទាក់ទងទៅនឹងអំពើមនុស្សឃាត អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ទាក់ទងទៅនឹង «ជនមហាក្បត់» នួន ជា បានទទួលស្គាល់ជាក់លាក់ថា គាត់មានចេតនាសម្លាប់អ្នកទាំងនេះ។ ទាក់ទងទៅនឹងការស្លាប់ និងការសម្លាប់ដទៃទៀត ដែលបានកើតឡើងនោះ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថាគាត់បានប្រព្រឹត្តដោយចេតនាប្រយោល ដោយផ្អែកលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការដឹងរបស់គាត់អំពីកាលៈទេសៈ ដែលក្នុងនោះមានការផ្លាស់ទីលំនៅប្រជាជន។

### ១.៤.៩. ចេតនារបស់ ខៀវ សំផន

**១០០.** ខៀវ សំផន បានជំទាស់ផងដែរទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង អំពីចេតនាប្រព្រឹត្តបទឧក្រិដ្ឋរបស់គាត់។ ជាពិសេស គាត់បានអះអាងថា បក្សបានធ្វើប្រតិបត្តិការក្រោមគោលការណ៍រក្សាការសម្ងាត់ ដែលនេះបានរារាំងរូបគាត់មិនឱ្យដឹងអំពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តនោះ។

**១០១.** អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ខៀវ សំផន ពុំបានលើកមូលដ្ឋានគាំទ្រអំណះអំណាង របស់ខ្លួនឡើយ ដោយហេតុថា គាត់ពុំបានពិនិត្យលើសំអាងហេតុយ៉ាងទូលំទូលាយរបស់ អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការដឹងរបស់គាត់អំពីបទឧក្រិដ្ឋ និងពុំបានផ្តល់មូលដ្ឋានគាំទ្រអំពីផលប៉ះពាល់នៃកំហុសចំពោះការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ខ្លួនឡើយ។

**១០២.** ខៀវ សំផន បានជំទាស់លើការយល់ឃើញជាច្រើនទៀតរបស់ អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងចេតនារបស់គាត់។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ភាគច្រើននៃអំណះអំណាងរបស់គាត់ពុំបានបង្ហាញអំពីភាពមិនសមហេតុសមផលនោះឡើយ។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង មានកំហុសត្រង់ថា ខ្លួនបានសំអាងតែទៅលើវត្តមានរបស់គាត់ នៅក្នុងសមាជពិសេសថ្នាក់ជាតិដែលបានធ្វើឡើងនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ប៉ុណ្ណោះ។

**១០៣.** ទោះជាយ៉ាងណាក្តី បើទោះបីជាការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង មួយចំនួនមានកំហុសក៏ដោយ ក៏ពុំមានភាពគ្រប់គ្រាន់ ដែលអាចចោទជាបញ្ហាដល់សេចក្តីសន្និដ្ឋានទូទៅ ដែល ខៀវ សំផន បានប្រព្រឹត្តដោយចេតនាតម្រូវនោះឡើយ។

### ១.៤.១០. ទម្រង់ដទៃទៀតនៃការទទួលខុសត្រូវ

**១០៤.** អង្គជំនុំជម្រះសាលាដំបូង បានរកឃើញថា ជនជាប់ចោទមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋដែល អង្គជំនុំជម្រះ បានរកឃើញថា មានអត្ថិភាពដោយផ្អែកលើការទទួលខុសត្រូវចំពោះការរៀបចំផែនការ ការញុះញង់ ការជួយនិងជំរុញ និងចំពោះជនជាប់ចោទ នួន ជា ម្នាក់ ទាក់ទងទៅនឹងការបញ្ជានៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនេះ។ ជនជាប់ចោទបានលើកទឡ្ហីករណ៍ជាច្រើននៅក្នុងបណ្តឹងសាទុក្ខទាក់ទងទៅនឹងបញ្ហានេះ។ ទោះជាយ៉ាងណាក្តី សំអាងហេតុទាក់ទងនឹងបញ្ហានេះ មានពន្យល់ពេញលេញនៅក្នុងសាលដីកា និងដោយសារមានការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូល ទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទក្នុងសហឧក្រិដ្ឋកម្មរួចហើយ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលពុំចាំបាច់ប្រកាសទាក់ទងទៅនឹងទឡ្ហីករណ៍ទាំងនេះឡើយ។

## ១.៥. ការប្រកាសទោស

**១០៥.** ខៀវ សំផន បានជំទាស់ជាពិសេសទៅនឹងការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង អំពីការប្រកាសទោសមកលើខ្លួន។

**១០៦.** អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា អំណះអំណាងរបស់ ខៀវ សំផន ពុំបានបង្ហាញអំពីកំហុសក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ អង្គជំនុំជម្រះសាលាដំបូង ឡើយ។

**១០៧.** ចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាលើបញ្ហា ថាតើការដែល អង្គជំនុំជម្រះ បានរកឃើញកំហុសនៅក្នុងសេចក្តីសន្និដ្ឋានរបស់ អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទនោះ នាំឱ្យអង្គជំនុំជម្រះកែប្រែការប្រកាសទោសដែល អង្គជំនុំជម្រះសាលាដំបូង បានសម្រេចនោះដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ថា ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ គប្បីឆ្លុះបញ្ចាំងនៅក្នុងការប្រកាសទោសនេះ។ ដោយផ្អែកលើភាពធំធេងនៃបទឧក្រិដ្ឋ ការខ្វះការយកចិត្តទុកដាក់ទាំងស្រុងទៅលើវាសនាចុងក្រោយរបស់ប្រជាជនកម្ពុជា

ជាពិសេសក្រុម ដែលងាយទទួលរងគ្រោះបំផុត និងជាការពិត បទឧក្រិដ្ឋនេះពុំមែនជាហេតុការណ៍ដាច់ដោយឡែកឡើយ ប៉ុន្តែបានកើតឡើងក្នុងរយៈពេលយ៉ាងយូរ និងដោយសារតួនាទីយ៉ាងសំខាន់របស់ជនជាប់ចោទដែលនាំឱ្យ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា ការផ្តន្ទាទោសជនជាប់ចោទម្នាក់ៗ ឱ្យជាប់ពន្ធនាគារអស់មួយជីវិត គឺជាការសមស្រប។ អាស្រ័យហេតុនេះ គប្បីតម្កល់ការប្រកាសទោសដែលបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង។

## ២. បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា

**១០៨.** ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបការយល់ឃើញរបស់ អង្គជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

**១០៩.** សហព្រះរាជអាជ្ញា បានជំទាស់ទៅនឹងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលថាការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ III ពុំអាចអនុវត្តបាននៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអ.វ.ត.ក។សហព្រះរាជអាជ្ញាបានស្នើសុំ«ដំណោះស្រាយឱ្យធ្វើការប្រកាស»តែប៉ុណ្ណោះនិងទទួលស្គាល់ថា លទ្ធផលនៃបណ្តឹងសាទុក្ខរបស់ខ្លួន ពុំមានឥទ្ធិពលលើការសម្រេចដាក់ពិរុទ្ធភាពជនជាប់ចោទឡើយ។ ទោះជាយ៉ាងណាក្តី ដើម្បីឱ្យបណ្តឹងសាទុក្ខអាចទទួលយកបាន បណ្តឹងសាទុក្ខនេះត្រូវតែលើកឡើងអំពីកំហុសអង្គច្បាប់ ដែលនាំឱ្យមោឃៈសេចក្តីសម្រេច។ ក្នុងករណីដែលពុំមានការលើកឡើងបែបនេះទេ បណ្តឹងសាទុក្ខនេះពុំអាចទទួលយកបានឡើយ។ ទោះជាយ៉ាងណាក្តី បណ្តឹងសាទុក្ខដែលបានដាក់ដោយជនជាប់ចោទបានផ្តល់ឱកាសឱ្យ អង្គជំនុំជម្រះតុលាការកំពូល ពិចារណារួចហើយ ទៅលើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម រួមទាំងទិដ្ឋភាព ដែលជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងបញ្ហា ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា។

## ៣. ផ្នែកសម្រេចសេចក្តី

យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេចៈ

**ដោយអនុលោមតាម** វិធាន៤(១)(ខ) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ១៤ ថ្មី(១)(ខ) និងមាត្រា ៣៦ ថ្មីនៃច្បាប់ អ.វ.ត.ក និង វិធាន១១១ នៃវិធានផ្ទៃក្នុង

**បានកត់សម្គាល់** សារណាបណ្តឹងសាទុក្ខជាលាយលក្ខណ៍អក្សរនីមួយៗ របស់ភាគី និងអំណះអំណាងដែលបានលើកឡើងនៅក្នុងសវនាការនៅថ្ងៃទី១៦ ដល់១៨ ខែកុម្ភៈ ឆ្នាំ២០១៦។

**ទទួលយក** ផ្នែកខ្លះ និង **បដិសេធ** ផ្នែកខ្លះទៀតនៃបណ្តឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន ដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១។

**បដិសេធ** ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង

**តម្កល់** ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទមនុស្សឃាត បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗ ទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

ពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២

**បដិសេធ** ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទសម្លាប់រង្គាល និងបទធ្វើទុក្ខ បុកម្នេញដោយមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង

**តម្កល់** ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទអំពើអមនុស្សធម៌ផ្សេងៗទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងកែប្រែប្រភេទគតិយុត្តនៃបទល្មើសដោយសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិវិញ។ បដិសេធការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា ពីបទសម្លាប់រង្គាល បទមនុស្សឃាត និង

ពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ

**បដិសធ** ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទសម្លាប់រង្គាល បទមនុស្សឃាត និងបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

**ប្រកាសតម្កល់** ការប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតលើ នួន ជា និង ខៀវ សំផន របស់អង្គជំនុំជម្រះសាលាដំបូង។ ប្រកាសបដិសេធបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាថា ពុំអាច ទទួលយកបាន។

**បង្គាប់ថា** នួន ជា និង ខៀវ សំផន ត្រូវស្ថិតក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក រង់ចាំការរៀបចំរួចរាល់ស្របតាមច្បាប់ នឹងត្រូវផ្ទេរទៅពន្ធនាគារដែលត្រូវអនុវត្តទោសនៅទីនោះ។

សាលដីកានេះធ្វើ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ជាពីរភាសាដើម គឺភាសាខ្មែរ និងភាសាអង់គ្លេសដោយបកប្រែជាភាសាបារាំង។




# ៧. សេចក្តីសង្ខេប នៃសាលក្រម សំណុំរឿង ០០២/០២

# សេចក្តីសង្ខេបនៃសាលក្រម សំណុំរឿង ០០២/០២



## ១.១. សេចក្តីផ្តើម និងប្រវត្តិសំណុំរឿងដោយសង្ខេប

**១.** ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបសាលក្រមរបស់ អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២។ សំអាងហេតុដែលមានអានុភាពតាមផ្លូវច្បាប់មានសរសេរនៅក្នុងសាលក្រមពេញលេញជាលាយលក្ខណ៍អក្សរ ដែលនឹងមានជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង នៅពេលវេលាសមស្របខាងមុខ។ ជាបញ្ហាបឋម អង្គជំនុំជម្រះ កត់សម្គាល់ថា ក្នុងចំណោមបញ្ហាទាំងឡាយ ភាគីបានលើកឡើងអំពីបញ្ហានានាពាក់ព័ន្ធនឹងការជូនដំណឹងអំពីការចោទប្រកាន់ និងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះ ដោះស្រាយសំណើសុំទាំងអស់នេះដោលម្អិតនៅក្នុងសាលក្រមពេញលេញជាលាយលក្ខណ៍អក្សរ។

**២.** សំណុំរឿង ០០២ ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ នួន ជា និង ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ក្រោយពីសហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ដែលបានបញ្ចប់ការស៊ើបសួរតាមផ្លូវតុលាការដោយប្រើរយៈពេលអស់ជិត ៣ឆ្នាំ មក នួន ជា និង ខៀវ សំផន ត្រូវបានបញ្ជូនមកជំនុំជម្រះ។ ដំបូងឡើយ សំណុំរឿងនេះមានរួមបញ្ចូលជនជាប់ចោទពីរនាក់ផ្សេងទៀតគឺ អៀង ធីរិទ្ធ និង អៀង សារី។ នៅ ក្នុងឆ្នាំ២០១១ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង អៀង ធីរិទ្ធ ត្រូវបានផ្អាក ហើយបទចោទប្រកាន់ទាំងឡាយប្រឆាំងនឹងរូបគាត់ត្រូវបានបំបែកចេញពីសំណុំរឿង បន្ទាប់ពីអង្គជំនុំជម្រះរកឃើញថា គាត់មិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការ ដោយសារតែជំងឺវង្វេងវង្វាន់ស្មារតី ដែលចេះតែវិវត្តទៅមុខ។ អៀង ធីរិទ្ធ បានទទួលមរណភាពនៅក្នុងឆ្នាំ២០១៥។ អៀង សារី ដែលជាស្វាមីរបស់គាត់បានទទួលមរណភាពពីរឆ្នាំមុន ពោលគឺនៅដើមឆ្នាំ២០១៣។ មរណភាពរបស់ជនជាប់ចោទទាំងពីរនាក់នាំឲ្យរំលត់បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីទាំងអស់ប្រឆាំងនឹងពួកគាត់នៅចំពោះមុខ អ.វ.ត.ក.។

**៣.** សវនាការបឋមក្នុងសំណុំរឿង ០០២ ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០១១។ នៅខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបំបែកកិច្ចដំណើរការ នីតិវិធីនៅក្នុងសំណុំរឿង ០០២ ទៅជាការជំនុំជម្រះតូចៗ មួយចំនួន ដោយសារតែទំហំ និងភាពស្មុគស្មាញនៃដីកាដំណោះស្រាយព្រមទាំងបញ្ហាវ័យចាស់ និងសុខភាពរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះសាលាដំបូង បានកម្រិតវិសាលភាព

សម្រាប់ការជំនុំជម្រះវគ្គដំបូងនៃសំណុំរឿង ០០២ (ដែលចាប់ពីពេលនោះមក ត្រូវបានហៅថាជា «សំណុំរឿង ០០២/០១») ត្រឹមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តពាក់ព័ន្ធនឹង៖ ទីមួយក្នុងអំឡុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ (ត្រូវបានហៅថាជា «ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១») និងទីពីរ ក្នុងអំឡុងការផ្លាស់ទីលំនៅប្រជាជននៅតាមតំបន់ ផ្សេងៗ ទៀតក្នុងប្រទេសកម្ពុជា ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ រហូតដល់ខែធ្នូ ឆ្នាំ១៩៧៧ (ត្រូវបានហៅថាជា «ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២») និងចុងក្រោយ ទាក់ទងនឹងការចោទប្រកាន់អំពីការសម្លាប់អតីតអ្នករដ្ឋការ នៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ។ អង្គជំនុំជម្រះ បានកម្រិតវិសាលភាពសម្រាប់ការជំនុំជម្រះវគ្គទីពីរនៅក្នុងសំណុំរឿង ០០២ (ត្រូវបានហៅថា «សំណុំរឿង ០០២/០២») ត្រឹមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តនៅតាមសហករណ៍ តាមការដ្ឋានការងារ តាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សមួយចំនួន (រួមទាំងមន្ទីរសន្តិសុខ ស-២១ និងជើងឯក) ពាក់ព័ន្ធនឹងការកំណត់គោលដៅលើក្រុមមនុស្សជាក់លាក់មួយចំនួនគឺជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ការរៀបអាពាហ៍ពិពាហ៍ និងនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធជាមួយវៀតណាម។ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ អង្គជំនុំជម្រះ បានបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុផ្សេងទៀតនៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ដែលមិនត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ ឬ សំណុំរឿង ០០២/០២ នេះ។

៤. នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះ បានចាប់ផ្តើមដំណើរការសវនាការលើ អង្គសេចក្តី នៅក្នុងសំណុំរឿង០០២/០២។ ក្នុងអំឡុងសវនាការលើភ័ស្តុតាងដែលមានរយៈពេល ២៤ខែ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មរបស់បុគ្គលចំនួន ១៨៥នាក់ ដែលរួមមាន សាក្សីចំនួន ១១៤នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៣នាក់ និងអ្នកជំនាញចំនួន ៨នាក់។ ឯកសារភ័ស្តុតាងជិត ៥.០០០ ឯកសារត្រូវបានយកមកពិនិត្យដេញដោល និងទទួលយកដាក់បញ្ចូលទៅក្នុងសំណុំរឿង ដោយសរុបទៅ ឯកសារទាំងបីភាសាជាផ្លូវការមានចំនួនជាង ៨២.០០០ ទំព័រ នៅក្នុងសំណុំរឿង ០០២/០២ តែមួយ។ ដោយសារតែសំណុំរឿង ០០២/០១ និង ០០២/០២ មានលេខសំណុំរឿងដូចគ្នា ឯកសារភ័ស្តុតាងសរុបរួមមានចំនួនជាង ១០.០០០ ឯកសារ ដែលមានជាង ៣០៤.០០០ ទំព័រ។ សវនាការលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ បានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ បន្ទាប់ពីបានបើកសវនាការអស់រយៈពេលចំនួន ២៧៤ថ្ងៃ។ សេចក្តីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់ការពិភាក្សាដេញដោលត្រូវបានធ្វើឡើងនៅក្នុងខែមិថុនា ឆ្នាំ២០១៧។

## ១.២. ការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ

៥. នៅក្នុងអំឡុងចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ នួន ជា ត្រូវបានចោទប្រកាន់ថា ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ជាសមាជិកពេញសិទ្ធនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ជាប្រធានសភាតំណាងប្រជាជន ហើយពេលខ្លះជានាយករដ្ឋមន្ត្រីស្តីទីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ ខៀវ សំផន ត្រូវបានចោទប្រកាន់ថា មានតួនាទីជាច្រើនក្នុងបក្ស

កុម្មុយនីស្តកម្ពុជា និងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយធ្លាប់ធ្វើជាប្រធានគណៈប្រធានរដ្ឋផង។ គាត់ក៏ត្រូវបាន ចោទប្រកាន់ថាជាប្រធានមន្ទីរនយោបាយ ៨៧០ និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា។

៦. ជនជាប់ចោទទាំងពីររូបត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើនប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម។ ជនជាប់ចោទត្រូវបានគេយល់ថាមានគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀត ដូចជា ប៉ុល ពត ជាលេខាបក្សកុម្មុយនីស្តកម្ពុជា សុន សេន ជាប្រធានសេនាធិការ និង រស់ ញឹម ជាលេខាភូមិភាគ ដើម្បីអនុវត្តបដិវត្តសង្គមនិយមឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា តាមរយៈដំណើរការ «មហាលោតផ្លោះ មហាអស្ចារ្យ» និងដើម្បីការពារបក្ស ប្រឆាំងនឹងខ្មាំងតាមគ្រប់មធ្យោបាយដែលចាំបាច់។ ជនជាប់ចោទត្រូវបានចោទប្រកាន់ទៀតថា ដើម្បីសម្រេចគោលបំណងរួមនេះ ជនជាប់ចោទបានរៀបចំបង្កើតនូវគោលនយោបាយចំនួន ៥ រួមជាមួយអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមផ្សេងៗទៀតដែលការអនុវត្តគោលនយោបាយនេះបានបណ្តាលឲ្យនិង/ឬមានឧក្រិដ្ឋកម្មនានា ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ ហើយដែលជនជាប់ចោទមានចេតនាប្រព្រឹត្ត។ គោលនយោបាយទាំងនេះរួមមាន (១) ការផ្លាស់ទីលំនៅប្រជាជនម្តងហើយម្តងទៀតចេញពីទីក្រុង និងទីប្រជុំជនទៅកាន់ជនបទ និងពីទីជនបទមួយទៅទីជនបទមួយទៀត (២) ការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ (៣) ការបង្កើត និងដំណើរការរបស់មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស (៤) ការកំណត់គោលដៅលើក្រុមមនុស្សជាក់លាក់មួយចំនួន រួមទាំង ជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (រួមទាំងអ្នករដ្ឋការស៊ីវិល និងទាហានព្រមទាំងក្រុមគ្រួសាររបស់ពួកគេ) និង (៥) ការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍។ ជនជាប់ចោទក៏ត្រូវបានចោទប្រកាន់ថែមទៀតថា បានរៀបចំផែនការ បញ្ជា ញុះញង់ ជួយ និងជំរុញ ឲ្យមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបានរៀបរាប់ខាងលើ។ លើសពីនេះទៅទៀត ជនជាប់ចោទក៏ត្រូវបានចោទប្រកាន់ថា ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើផងដែរ។

៧. នាពេលនេះ អង្គជំនុំជម្រះ នឹងរៀបរាប់អំពីបទចោទប្រកាន់នានា ដែលត្រូវបែងចែកទៅតាមគោលនយោបាយ។ យ៉ាងណាក៏ដោយ ដោយសារតែការផ្លាស់ទីលំនៅប្រជាជនត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធតែនឹងការប្រព្រឹត្តចំពោះជនជាតិចាមនោះ គោលនយោបាយនេះនឹងត្រូវយកមកពិភាក្សាតែលើចំណុចពាក់ព័ន្ធនឹងជនជាតិចាមប៉ុណ្ណោះ។ វិសាលភាពនៃបទចោទប្រកាន់នានាដែលទាក់ទងនឹងសំណុំរឿង ០០២/០២ រួមមាន ការចោទប្រកាន់ទៅលើអង្គហេតុនានាពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទ ចំពោះឧក្រិដ្ឋកម្មដូចតទៅនេះ៖

- ពាក់ព័ន្ធនឹងការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើអមនុស្សធម៌ផ្សេងៗ ទៀត ក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ។

- ពាក់ព័ន្ធនឹងការបង្កើត និងដំណើរការរបស់មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ជនជាប់ចោទត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើអមនុស្សធម៌ផ្សេងៗ ទៀតក្រោមទម្រង់ជាការប្រព្រឹត្ត ដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ។

- ពាក់ព័ន្ធនឹងការកំណត់លើក្រុមគោលដៅជាក់លាក់ ជនជាប់ចោទត្រូវបានចោទប្រកាន់ពី៖

  - ទីមួយ ពាក់ព័ន្ធនឹងជនជាតិចាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា អំពើអមនុស្សធម៌ផ្សេងៗ ទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗ ទៀតក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្ត ដែលត្រូវបានកំណត់ថាជាការបាត់ខ្លួន ដោយបង្ខំ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត។

  - ទីពីរ ពាក់ព័ន្ធនឹងជនជាតិវៀតណាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ការនិរទេសជនស៊ីវិលដោយខុសច្បាប់ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត។

  - ទីបី ពាក់ព័ន្ធនឹងពុទ្ធសាសនិក ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា។

  - ទីបួន ពាក់ព័ន្ធនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (រួមទាំងអ្នករដ្ឋការស៊ីវិល និងទាហាន) និងក្រុមគ្រួសាររបស់ពួកគេ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

- ពាក់ព័ន្ធនឹងការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗ ទៀតក្រោមទម្រង់ជាការប្រព្រឹត្ត ដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

## ១.៣. សំអាងហេតុសំខាន់ៗរបស់អង្គជំនុំជម្រះសាលាដំបូង

៨. អង្គជំនុំជម្រះនឹងលើកឡើងអំពីសំអាងហេតុ និងសំអាងច្បាប់ ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនីមួយៗ ដោយសារតែវាពាក់ព័ន្ធនឹងគោលនយោបាយ ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ នេះ។ បន្ទាប់មក អង្គជំនុំជម្រះ នឹងលើកឡើងអំពីសហឧក្រិដ្ឋកម្មរួម មុនពេលលើកឡើងអំពីសេចក្តីសន្និដ្ឋាន ផ្សេងៗ ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ នួន ជា និង ខៀវ សំផន។

៩. មុនពេលលើកឡើងអំពីទីតាំងឧក្រិដ្ឋកម្ម ជាបឋម អង្គជំនុំជម្រះនឹងលើកឡើងអំពីធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុង ហ្សឺណែវ ឆ្នាំ១៩៤៩។ អង្គជំនុំជម្រះយល់ឃើញថា ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបន្តយ៉ាងហោចណាស់ដល់ ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ជាពេលវេលាស្ថិតក្រោមយុត្តាធិការនៃសំណុំរឿង ០០២/០២ នោះ មានការវាយប្រហារជាទូទៅ និងជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិលនៅកម្ពុជា។ ការវាយប្រហារបាន កើតឡើងក្នុងទម្រង់ជាច្រើន ដែលក្នុងនោះមានការជម្លៀសប្រជាជនដោយបង្ខំ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការបាត់ខ្លួនដោយបង្ខំ ការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការធ្វើ ទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ ការវាយប្រហារនេះ បានបណ្តាលឲ្យប្រជាជនស៊ីវិលរាប់លាន នាក់ក្នុងប្រទេសកម្ពុជារងគ្រោះ ហើយធ្វើឲ្យជនភៀសខ្លួនជាច្រើនរត់គេចទៅប្រទេសជិតខាង។ ការវាយ ប្រហារនេះត្រូវបានធ្វើឡើង ដើម្បីជំរុញ និងអនុលោមតាមគោលនយោបាយ និងផែនការរបស់បក្ស ក្នុងការកសាងសង្គមនិយម និងការការពារប្រទេស។ អង្គជំនុំជម្រះជឿជាក់ថា ការវាយប្រហារនេះមាន ទ្រង់ទ្រាយធំទាំងផ្នែកវិសាលភាពភូមិសាស្ត្រ ក៏ដូចជាចំនួនជនរងគ្រោះ។ អង្គជំនុំជម្រះ ក៏យល់ឃើញ ផងដែរថា ការវាយប្រហារនេះមានលក្ខណៈជាប្រព័ន្ធ ដោយសារតែឧក្រិដ្ឋកម្មដែលមានវិសាលភាព និង ទំហំធំបែបនេះ មិនអាចត្រូវបានធ្វើឡើងដោយគ្មានការគ្រោងទុកឡើយ ហើយត្រូវធ្វើឡើងដើម្បីជំរុញ និង អនុលោមតាមគោលនយោបាយរបស់បក្ស។ អង្គជំនុំជម្រះ យល់ឃើញថា ការវាយប្រហារនេះមាន គោលដៅប្រឆាំងនឹងប្រជាជនស៊ីវិលក្នុងប្រទេសកម្ពុជា។ អង្គជំនុំជម្រះ យល់ឃើញទៀតថា ការវាយប្រហារ ត្រូវបានធ្វើឡើងដោយមូលហេតុនយោបាយ ជាតិសាសន៍ ជាតិពន្ធុ ពូជសាសន៍ និងសាសនា ហើយថា មានទំនាក់ទំនងរវាងការវាយប្រហារនេះនិងអំពើដែលបានប្រព្រឹត្ត។ អង្គជំនុំជម្រះ ក៏យល់ឃើញដែរថា នួន ជា និង ខៀវ សំផន បានដឹងពីការវាយប្រហារនេះ ហើយថា ពួកគាត់ទាំងពីរនាក់បានដឹងថា អំពើ របស់ខ្លួនគឺជាផ្នែកមួយនៃការវាយប្រហារនេះ។

១០. អង្គជំនុំជម្រះ យល់ឃើញថា អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាង វៀតណាម និង កម្ពុជា ប្រជាធិបតេយ្យ មានចាប់តាំងពីខែឧសភា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ទាក់ទងនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ដែលបានចោទប្រកាន់ នៅមន្ទីរសន្តិសុខស-២១ អង្គជំនុំជម្រះយល់ឃើញថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនេះគឺជាប្រជាជន ស៊ីវិលវៀតណាម ឬឈ្លើយសឹកវៀតណាម ហេតុនេះ ពួកគេជាបុគ្គលដែលត្រូវទទួលបានការការពារពី អនុសញ្ញាទីក្រុងហ្សឺណែវ។ ផ្ទុយទៅវិញ ចំពោះឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់នៅមន្ទីរសន្តិសុខ អូរកន្សែង អង្គជំនុំជម្រះមិនអាចជឿជាក់ឲ្យហួសពីវិមតិសង្ស័យបានទេថា ជនជាតិចាំ៉យជាបុគ្គលដែល

ទទួលបានការការពារ ទៅតាមអត្ថន័យនៃអនុសញ្ញាទីក្រុងហ្សឺណែវនោះ។ អង្គជំនុំជម្រះ យល់ឃើញថា ឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តទៅលើបុគ្គល ដែលទទួលបានការការពារនៅមន្ទីរសន្តិសុខ ស-២១ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងជម្លោះប្រដាប់អាវុធរវាង កម្ពុជាប្រជាធិបតេយ្យ និង វៀតណាម។ អង្គជំនុំជម្រះ យល់ឃើញទៀតថា នួន ជា និង ខៀវ សំផន បានដឹងពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធជាមួយវៀតណាម ហើយថា ពួកគេទាំងពីររូបបានដឹងអំពីឋានៈជាបុគ្គលដែលត្រូវទទួលបានការការពាររបស់ជនរងគ្រោះនៅមន្ទីរសន្តិសុខ ស-២១។

## ១.៣.១. បរិបទប្រវត្តិសាស្ត្រ

**១១.** អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា ក្នុងឆ្នាំ១៩៥៩ ទូ សាមុត, ប៉ុល ពត និង នួន ជា បានចាប់ផ្តើមដំណើរការបង្កើតបក្សកុម្មុយនីស្តកម្ពុជាថ្មីមួយ ដើម្បីគេចចេញពីឥទ្ធិពលរបស់វៀតណាម ដែលមានចរិតលក្ខណៈជាបក្សកុម្មុយនីស្តឥណ្ឌូចិន។ គោលការណ៍គ្រឹះរបស់បក្សនេះគឺ ប្រជាធិបតេយ្យប្រមូលផ្តុំ និង ម៉ាក្សលេនីននិយម។ សន្និបាតបក្សលើកទីមួយត្រូវបានធ្វើឡើង ចាប់ពីថ្ងៃទី៣០ ខែកញ្ញា ដល់ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៦០ ដែលនៅក្នុងពេលនោះមានការអនុម័តលក្ខន្តិកៈបក្ស និងមានការជ្រើសតាំងគណៈកម្មាធិការដឹកនាំ។ ទូ សាមុត ត្រូវបានជ្រើសតាំងជាលេខាបក្ស ចំណែក នួន ជា ត្រូវបានជ្រើសតាំងជាអនុលេខាបក្ស។ បុគ្គលទាំងពីរនាក់នេះត្រូវបានជ្រើសតាំងទៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ជាមួយនឹង ប៉ុល ពត ក្នុងនាមជាសមាជិកពេញសិទ្ធិ ហើយ អៀង សារី ជាសមាជិកត្រៀម។ សុន សេន, សោ ភឹម និង តាម៉ុក ក៏បានចូលរួមក្នុងសន្និបាតនោះដែរ ដោយ សុន សេន និង សោ ភឹម ត្រូវបានជ្រើសតាំងជាសមាជិកត្រៀមនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍។ វន វ៉េត ត្រូវបានជ្រើសតាំងទៅក្នុងគណៈកម្មាធិការមជ្ឈិមបក្សជាមួយនឹង ទូ សាមុត, នួន ជា, ប៉ុល ពត, អៀង សារី និង សុន សេន។ នៅក្នុងសន្និបាតបក្សលើកទីពីរ នៅខែកុម្ភៈ ឆ្នាំ១៩៦៣ ប៉ុល ពត ត្រូវបានជ្រើសតាំងជាលេខាបក្ស នៅពេល ទូ សាមុត បានបាត់ខ្លួន ចំណែក នួន ជា នៅតែជាអនុលេខាបក្ស ហើយការប្រើប្រាស់ហិង្សានយោបាយ និងហិង្សាបដិវត្តន៍ត្រូវបានបញ្ជាក់សាជាថ្មីទៀត។ អៀង សារី និង សោ ភឹម ត្រូវបានតម្លើងឋានៈជាសមាជិកពេញសិទ្ធិនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ចំណែក វន វ៉េត, រស់ ញឹម, សុន សេន និង តាម៉ុក ត្រូវបានជ្រើសតាំងទៅក្នុងគណៈកម្មាធិការមជ្ឈិម។ នៅក្នុងសន្និបាតបក្សលើកទីបី ដែលត្រូវបានធ្វើឡើងនៅក្នុងខែកញ្ញា ឆ្នាំ១៩៧១ បានបញ្ជាក់សាជាថ្មីអំពីមាគ៌ាយុទ្ធសាស្ត្ររបស់បក្ស ដែលត្រូវបានអនុម័តនៅក្នុងសន្និបាតបក្សលើកទីមួយ និងលើកទីពីរ។ នេះជាលើកទីមួយដែល ខៀវ សំផន បានចូលរួមនៅក្នុងសន្និបាតបក្ស ហើយគាត់ត្រូវបានជ្រើសតាំងទៅក្នុងគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាក្នុងនាមជាសមាជិកបម្រុង រួមជាមួយនឹង ជូ ជេត, កែ ពក និង កុយ ធួន។

**១២.** រហូតដល់ឆ្នាំ១៩៦៩ សេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាបានធ្លាក់ចុះ ហើយមានភាពមិនច្បាស់លាស់អំពី ថាតើកម្ពុជាអាចនឹងធ្លាក់ចូលក្នុងសង្គ្រាមនៅក្នុងប្រទេសវៀតណាមដែរ ឬយ៉ាងណា បើទោះបីជា សម្តេច នរោត្តម សីហនុ មានគោលនយោបាយអព្យាក្រឹត្យជាផ្លូវការក៏ដោយ។ ចាប់ពីឆ្នាំ ១៩៦៩ មក ភាពហិនហោច ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនៅក្នុងប្រទេសកម្ពុជា បានរុញច្រានឲ្យកងទ័ពវៀតណាមខាងជើងកាន់តែខិតចូលមកក្នុងប្រទេសកម្ពុជា ដែលធ្វើឲ្យវិបត្តិនេះកាន់ តែមានភាពតានតឹងថែមទៀត។ នៅក្នុងឆ្នាំ១៩៧០ លន់ នល់ ក្រោមការគាំទ្រពីសហរដ្ឋអាមេរិក បានធ្វើរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ

ដែលនៅពេលនោះទ្រង់កំពុងស្ថិតនៅក្រៅប្រទេសកម្ពុជា។ សម្តេច នរោត្តម សីហនុ ក្រោយមកបានបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ដែលជាចលនានយោបាយមួយ ដើម្បីប្រយុទ្ធប្រឆាំងនឹងអ្នកទម្លាក់ព្រះអង្គ។ នៅក្នុងខែឧសភា ឆ្នាំដដែលនោះ សម្តេច នរោត្តម សីហនុ ដោយមានការគាំទ្រយ៉ាងស្ងៀមស្ងាត់ពីបក្សកុម្មុយនីស្តកម្ពុជា បានបង្កើតរដ្ឋាភិបាលនិរទេសថ្មីមួយ ដែលមានឈ្មោះថា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ខៀវ សំផន គឺជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលតាមរយៈតួនាទីនេះ គាត់បានដើរតួធ្វើជាអ្នកសម្របសម្រួលទំនាក់ទំនងរវាង សម្តេច នរោត្តម សីហនុ និង ប៉ុល ពត។ រដ្ឋបាលរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាមិនមានអំណាចជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាឡើយ បើទោះបីជា សម្តេច នរោត្តម សីហនុ នៅបន្តមានឥទ្ធិពលនៅលើឆាកអន្តរជាតិក៏ដោយ។ តាមពិតទៅ បក្សកុម្មុយនីស្តកម្ពុជាឯណោះទេ ដែលជាអ្នកទទួលខុសត្រូវលើការតស៊ូប្រដាប់អាវុធ នៅក្នុងប្រទេសកម្ពុជានោះ។ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយតឹងរ៉ឹងក្នុងការរក្សាការសម្ងាត់ ហើយមិនបង្ហាញអត្តសញ្ញាណរបស់ពួកគេជាសាធារណៈឡើយ។ ពួកគេនិយមប្រើប្រាស់ពាក្យ «អង្គការ» ដែលជាពាក្យមិនច្បាស់លាស់ និងជាពាក្យបិទបាំង សំដៅជាស្ថាប័នដែលបានដឹកនាំប្រទេស ហើយដែលប្រជាជនធម្មតាយល់ថាមានអំណាចគ្រប់គ្រងលើប្រទេសទាំងមូល។ ពួកគេថែមទាំងបានប្រើប្រាស់បុគ្គលសាធារណៈ ដែលទទួលបានការគោរព ដូចជា ខៀវ សំផន និង សម្តេច នរោត្តម សីហនុ ទាំងក្នុងប្រទេស និងលើឆាកអន្តរជាតិដើម្បីជាការបិទបាំងចំពោះសកម្មភាព និងគោលនយោបាយរបស់ពួកគេ។

១៣. នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងបក្សកុម្មុយនីស្តកម្ពុជា បានចូលក្នុងទីក្រុងភ្នំពេញ ក្នុងនាមជាកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ហើយបានចាប់ផ្តើមបណ្តេញប្រជាជនឲ្យចាកចេញពីទីក្រុងភ្នំពេញភ្លាម ដែលជាការចាប់ផ្តើមនៃរបបកម្ពុជាប្រជាធិបតេយ្យ។

## ១.៣.២. សហករណ៍ និងការដ្ឋានការងារ

១៤. អង្គជំនុំជម្រះ យល់ឃើញថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានគោលនយោបាយបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ ដែលត្រូវបានចាត់ទុកជាឧបករណ៍សំខាន់សម្រាប់ការតស៊ូវណ្ណៈ និងមានគោលដៅបង្កើតកម្លាំងពលកម្ម និងកម្លាំងផលិតរបស់ប្រជាជន ក្រោមការគ្រប់គ្រងយ៉ាងតឹងរ៉ឹង។ ទីតាំងឧក្រិដ្ឋកម្ម ដែលជាផ្នែកមួយនៃសំណុំរឿង ០០២/០២ គឺ សហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ត្រពាំងថ្ម ការដ្ឋានការងារទំនប់ ១ មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។

១៥. ចំពោះសហករណ៍ត្រាំកក់ដែលស្ថិតនៅស្រុកត្រាំកក់ តំបន់ ១៣ ភូមិភាគនិរតី (បច្ចុប្បន្ន ខេត្តតាកែវ) អង្គជំនុំជម្រះយល់ឃើញថា ប្រជាជនត្រូវបានគេបង្ខំដោយចេតនាឲ្យធ្វើការងារក្រោមបរិយាកាសនៃការគ្រប់គ្រង ការគំរាមកំហែង ភាពភ័យខ្លាច ការអត់អាហារ និងរើសអើង។ កង្វះអាហារខ្លាំងបានកើតមានច្រើនដងនៅក្នុងស្រុកត្រាំកក់ ហើយបានធ្វើឲ្យមនុស្សស្លាប់។ មនុស្សជាច្រើនបានស្លាប់ដោយសារតែកង្វះអាហារូបត្ថម្ភ ធ្វើការបាក់កម្លាំង និងមានជំងឺ។ ប្រជាជនថ្មីដែលមកពីទីក្រុង និងទីរួមខេត្ត ខុសពីប្រជាជនមកពីតំបន់ជនបទដែលគេហៅថា ប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់នោះ បានទទួលរងផលប៉ះពាល់ទាំងនេះ ជាពិសេស។ លើសពីនេះទៀត ប្រជាជនបានស្លាប់ក្នុងមន្ទីរពេទ្យស្រុក ក្នុងចំណោមទីតាំងដទៃៗទៀត ដោយសារតែការព្យាបាលមិនសមស្រប កង្វះអាហារូបត្ថម្ភ និងធ្វើការបាក់កម្លាំង។ អង្គជំនុំជម្រះ

ក៏យល់ឃើញដែរថា មនុស្សជាច្រើននាក់បានបាត់ខ្លួននៅស្រុកត្រាំកក់ ដោយគ្មានដំណើរការតាមផ្លូវច្បាប់ ដែលតាមរយៈដំណើរការនេះ ប្រជាជនអាចស្វែងរក និងទទួលបានព័ត៌មានយ៉ាងត្រឹមត្រូវអំពីជោគវាសនាសាច់ញាតិរបស់ខ្លួន។ ស្ថានភាពនេះបានបង្កើតឲ្យមានបរិយាកាសភ័យខ្លាច និងភាពមិនច្បាស់លាស់ជាបន្តទៅទៀត។ លើសពីនេះ ការប្រណិប័តន៍សាសនា និងវប្បធម៌ប្រពៃណី ត្រូវបានលុបបំបាត់ដោយបង្ខំនៅស្រុកត្រាំកក់។ អង្គជំនុំជម្រះ ក៏យល់ឃើញថា ប្រជាជនត្រូវគេគ្រប់គ្រងទាំងផ្លូវកាយ និងផ្លូវចិត្ត ដោយសារថា ពួកគេត្រូវបានរឹតត្បិតសេរីភាពក្នុងការដើរហើរ ត្រូវចូលរួមប្រជុំទិតៀន និងស្វ័យទិតៀន បាត់បង់រចនាសម្ព័ន្ធគ្រួសារដែលមាន និងទទួលរងការគំរាមកំហែងថា នឹងបញ្ជូនទៅអប់រំ ចាប់ខ្លួន ឬបាត់ខ្លួន។ ទង្វើទាំងនេះ គឺជាការបំពាក់បំប៉ន ការគំរាមកំហែង ការរឹតត្បិត សេរីភាពក្នុងការដើរហើរ ការធ្វើពលកម្មដោយបង្ខំ ការភ័យខ្លាច និងអំពើហិង្សា ដែលស្ថិតក្រោមការគ្រប់គ្រងយ៉ាងតឹងរ៉ឹង។

**១៦.** ចំពោះការដ្ឋានការងារទំនប់ត្រពាំងថ្ម ដែលស្ថិតនៅតំបន់ ៥ ភូមិភាគពាយព្យ (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) អង្គជំនុំជម្រះយល់ឃើញថា អ្នកធ្វើការត្រូវបានគេបង្ខំឲ្យសង់ទំនប់មួយ និងអាងស្តុកទឹកពីរ ដែលជារចនាសម្ព័ន្ធសំណង់រួមមួយ ដែលដំណើរការរហូតមកទល់សព្វថ្ងៃនេះ ហើយនៅតែមានទ្រង់ទ្រាយដើមដដែល។ អ្នកធ្វើការនៅទំនប់នេះគ្មានជម្រើសអ្វីផ្សេង ក្រៅពីត្រូវធ្វើការ ដោយមិនគិតពីស្ថានភាពអាកាសធាតុ ត្រូវធ្វើការធ្ងន់ជាច្រើនម៉ោង មិនត្រូវបានគេអនុញ្ញាតឲ្យមានថ្ងៃឈប់សម្រាក ត្រូវបានមេកងតាមដានជាប្រចាំ ដើម្បីពិនិត្យមើលថា តើពួកគេបំពេញការងារបានប៉ុន្មាន និងត្រូវដាក់ពិន័យបើសិនពួកគេមិនបានសម្រេចការងារតាមផែនការ។ អ្នកធ្វើការត្រូវគេគំរាមកំហែងថា នឹងត្រូវសម្លាប់ ឬបាត់ខ្លួន ឬត្រូវគេកាត់បន្ថយរបបអាហារ បើពួកគេមានអាកប្បកិរិយា ដែលគេចាត់ទុកថាប្រឆាំងនឹងអង្គការ ឬបើពួកគេមិនសម្រេចភារកិច្ច ដែលបានប្រគល់ឲ្យ។ សាក្សីបានឃើញអ្នកធ្វើការត្រូវបានគេសម្លាប់នៅនឹងមុខ ហើយត្រូវបានគេគំរាមកំហែងថា នឹងត្រូវគេសម្លាប់ដែរ បើមិនប្រឹងធ្វើការ។ អង្គជំនុំជម្រះយល់ឃើញថា ការស្លាប់នៅការដ្ឋានមិនត្រឹមតែបណ្តាលមកពីលក្ខខណ្ឌការងារ និងលក្ខខណ្ឌរស់នៅលំបាកវេទនាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយសារតែការសម្លាប់ដោយចេតនាផងដែរ។

**១៧.** ចំពោះការដ្ឋានការងារទំនប់ ១ មករា ដែលស្ថិតនៅតំបន់ ៤២ និងតំបន់ ៤៣ ភូមិភាគ កណ្តាល (ឧត្តរចាស់) (បច្ចុប្បន្នខេត្តកំពង់ធំ) អង្គជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌការងារ និងលក្ខខណ្ឌរស់នៅមានភាពលំបាកវេទនាដូចគ្នា ខ្វះអាហារ និងមានការព្យាបាលមិនគ្រប់គ្រាន់ដូចគ្នា។ អ្នកធ្វើការនៅទីនោះក៏គ្មានជម្រើសអ្វីឡើយ ដោយពួកគេត្រូវគេបង្ខំឲ្យធ្វើការផ្ទុយនឹងឆន្ទៈរបស់ខ្លួន និងក្រោមលក្ខខណ្ឌលំបាកខ្លាំងបំផុត ដែលជាហេតុបណ្តាលឲ្យស្លាប់ក្នុងករណីខ្លះ។ លើសពីនេះទៀត អ្នកធ្វើការខ្លះត្រូវបានគេសម្លាប់ដោយចេតនា។ វត្តបារាយណ៍ជាន់ដែក នៅក្បែរនោះ ជាកន្លែងដែលគេបានរកឃើញអដ្ឋិធាតុ និងសម្លៀកបំពាក់ជាច្រើនក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ត្រូវបានគេប្រើប្រាស់ធ្វើជាកន្លែងឃុំឃាំង និងសម្លាប់មនុស្ស។ អ្នកធ្វើការខ្លះត្រូវបានគេផ្ទេរពីការដ្ឋានការងារទំនប់ ១ មករា ទៅកន្លែងនោះ ហើយត្រូវបានគេសម្លាប់ ចំណែកឯអ្នកធ្វើការខ្លះទៀតបានបាត់ខ្លួនតែម្តង។ អង្គជំនុំជម្រះ យល់ឃើញទៀតថា ជនជាតិចាម និងប្រជាជនថ្មី ត្រូវបានគេរើសអើងខ្លាំងនៅការដ្ឋានការងារនេះ។ ក្នុងអំឡុងសាងសង់ អ្នកធ្វើការនៅការដ្ឋានទំនប់ ១ មករា មានចំនួនរាប់ម៉ឺននាក់ គឺចន្លោះពី ២០.០០០នាក់ ទៅ ៤០.០០០នាក់ ក្នុងពេលការងារមមាញឹកបំផុត។

១៨. ចំពោះការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងដែលស្ថិតនៅតំបន់ ៣១ ភូមិភាគបស្ចិម (បច្ចុប្បន្ន ខេត្តកំពង់ឆ្នាំង) អង្គជំនុំជម្រះយល់ឃើញថា អ្នកធ្វើការនៅការដ្ឋាននេះ គឺជាកងទ័ពមកពីតាមកងពល នានានៃកងទ័ពបដិវត្តន៍កម្ពុជា។ ការងារដែលពួកគេធ្វើ គឺសម្រាប់គោលបំណងយោធា។ ទោះជាយ៉ាងណា ក៏ដោយ អ្នកធ្វើការត្រូវគេប្រើឲ្យធ្វើការងារដូចជាទាសករ និងមិនអាចប្រកែកមិនធ្វើការងារបានឡើយ បើមិន ដូច្នេះទេពួកគេទទួលរងការគំរាមកំហែង ហើយក្នុងករណីខ្លះបាត់ខ្លួន។ ពួកគេទទួលដំណឹងថា អ្នកមិន គោរពតាមការណែនាំនឹងត្រូវដកចេញ ឬសម្លាប់ចោល។ អង្គជំនុំជម្រះ យល់ឃើញទៀតថា អ្នកធ្វើការ ប្រឈមមុខនឹងលក្ខខណ្ឌការងារគ្មានសុវត្ថិភាព និងត្រូវគេបង្ខំឲ្យធ្វើការច្រើនម៉ោង ដោយគ្មានអាហារ គ្រប់គ្រាន់ ដែលជាហេតុធ្វើឲ្យមនុស្សជាច្រើនស្លាប់។ កងទ័ពមកពីភូមិភាគបូព៌ាឬកងពល ដែលមេដឹកនាំ របស់ពួកគេត្រូវបានគេចាត់ទុកថាជាជនក្បត់ ត្រូវធ្វើការងារធ្ងន់ឬប្រកបដោយគ្រោះថ្នាក់ខ្លាំង ដើម្បីកសាង ខ្លួន។ ជាពិសេស ការវាយថ្មមានហានិភ័យខ្ពស់ ហើយអ្នកធ្វើការស្ទើរតែគ្មានមធ្យោបាយអ្វីដើម្បីការពារខ្លួន ឡើយ។ ជីវិតរបស់ពួកគេត្រូវបានចាត់ទុកដូចជាឧបករណ៍ប្រើប្រាស់។ នៅទីបំផុត អ្នកធ្វើការជាច្រើននាក់ បានបាត់ខ្លួនដោយគ្មានដំណឹង និងលែងឃើញនៅការដ្ឋានការងារទៀត ចំណែកឯអ្នកផ្សេងទៀតត្រូវបាន គេចាប់ខ្លួន ហើយក្រោយមក ក៏បាត់ខ្លួន ឬត្រូវគេបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។

១៩. អង្គជំនុំជម្រះ យល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចតទៅនេះត្រូវបានប្រព្រឹត្តទាក់ទងនឹងការ បង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ។ ឧក្រិដ្ឋកម្មទាំងនោះមាន ការធ្វើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងៗ ទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើអមនុស្សធម៌ផ្សេងៗ ទៀត ក្រោមទម្រង់ ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ។

## ១.៣.៣. មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស

២០. អង្គជំនុំជម្រះ យល់ឃើញថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានគោលនយោបាយបង្កើត និងដំណើរការ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ដើម្បីកំណត់អត្តសញ្ញាណ ចាប់ខ្លួន ដាក់ឲ្យនៅដាច់ដោយឡែក តែម្នាក់ឯង និង «កម្ទេច» អ្នកដែលគេចាត់ទុកជាខ្មាំងប្រភេទធ្ងន់ធ្ងរបំផុត។ ទីតាំងឧក្រិដ្ឋកម្ម ដែលជាផ្នែក មួយនៃសំណុំរឿង ០០២/០២ គឺមន្ទីរសន្តិសុខ ស-២១ (រួមទាំង ទីតាំងសម្លាប់មនុស្សនៅជើងឯក) មន្ទីរ សន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខ ភ្នំក្រោល។

២១. ចំពោះមន្ទីរសន្តិសុខ ស-២១ ដែលស្ថិតនៅវិទ្យាល័យពញាយ៉ាត ក្នុងទីក្រុងភ្នំពេញ ស្ទើរតែពេញមួយរបប កម្ពុជាប្រជាធិបតេយ្យ អង្គជំនុំជម្រះយល់ឃើញថា មន្ទីរសន្តិសុខ ស-២១ បានចាប់ផ្តើមដំណើរការ យូរបំផុត នៅខែតុលា ឆ្នាំ១៩៧៥។ មន្ទីរសន្តិសុខ ស-២១ មានមុខងារចម្បងក្នុងការឃុំខ្លួនបក្ខជន និងយុទ្ធជនបដិវត្តន៍ ដែលត្រូវគេសង្ស័យថាជាខ្មាំង។ អង្គជំនុំជម្រះ យល់ឃើញថា អ្នកជាប់ឃុំនៅ មន្ទីរសន្តិសុខ ស-២១ ត្រូវគេឃុំឃាំង ដោយគ្មានការការពារតាមនីតិវិធីច្បាប់ឡើយ ហើយលក្ខខណ្ឌ ឃុំឃាំងមានសភាពគួរឲ្យអាណោចអាធ័ម ដែលជាហេតុធ្វើឲ្យអ្នកជាប់ឃុំ ខ្លះស្លាប់។ ថ្វីត្បិតតែអ្នកជាប់ ឃុំខ្លះ ត្រូវគេប្រើឲ្យធ្វើការងារជាបណ្តោះអាសន្ន តែអ្នកជាប់ឃុំ ស្ទើរតែទាំងអស់ត្រូវគេសួរចម្លើយ ដោយប្រើ វិធីធ្វើបាបខុសៗ គ្នាមុននឹងយកទៅសម្លាប់ចោល។ អង្គជំនុំជម្រះ យល់ឃើញថា អ្នកជាប់ឃុំត្រូវគេនាំទៅ

បន្ទប់សួរចម្លើយទាំងដៃជាប់ខ្នោះ បិទមុខ និងជើងជាប់ច្រវាក់ ក្នុងពេលសួរចម្លើយ។ វិធីសួរចម្លើយរួមមានការវាយដំនឹងដំបង ព្រនង់ ខ្សែភ្លើង រំពាត់ និងឧបករណ៍ផ្សេងៗទៀត ការឆក់ខ្សែភ្លើង ការគ្របក្បាលនឹងថង់ប្លាស្ទិកឲ្យថប់ដង្ហើម ការយកក្រណាត់រុំមុខ ការចាក់ទឹកត្រជាក់ពីកំសៀវ និងការដកក្រចកដៃក្រចកជើង។ អ្នកជាប់ឃុំខ្លះបានស្លាប់ ក្រោយពីត្រូវបានគេបូមឈាមចេញ យកឈាមទៅព្យាបាលកងទ័ពបដិវត្តន៍កម្ពុជា ដែលបានរងរបួស។ អង្គជំនុំជម្រះ យល់ឃើញទៀតថា យ៉ាងហោចណាស់អ្នកជាប់ឃុំចំនួន ១១.៧៤២នាក់ ត្រូវបានគេសម្លាប់នៅមន្ទីរសន្តិសុខស-២១ ឬនៅជុំវិញនោះ និងនៅជើងឯក។ ឧទាហរណ៍ នៅជើងឯក អ្នកជាប់ឃុំត្រូវគេសម្លាប់ដោយវាយនឹងដែកត្រង់កញ្ចឹងក រួចអារកនឹងកាំបិតហើយសាកសពត្រូវគេវះពោះ និងកប់ក្នុងរណ្ដៅសាកសពរួម។ អង្គជំនុំជម្រះ ក៏យល់ឃើញដែរថាមានការណែនាំផ្ទាល់ពីថ្នាក់លើរួមទាំង នួន ជា និង សុន សេន ឲ្យសម្លាប់អ្នកជាប់ឃុំ ឬក្រុមអ្នកជាប់ឃុំ។ ក្នុងចំណោមអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ មានបក្ខជនសំខាន់ៗ ដូចជា រស់ ញឹម និង វន វ៉េត ព្រមទាំងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក៏ដូចជាទាហាន និងជនស៊ីវិលវៀតណាម។ បញ្ជីអ្នកជាប់ឃុំនៃមន្ទីរសន្តិសុខ ស-២១ ក៏បង្ហាញឲ្យឃើញផងដែរថា កុមារជាច្រើនត្រូវបានគេឃុំឃាំង និងសម្លាប់នៅមន្ទីរសន្តិសុខនេះ និងនៅជើងឯក នៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។

**២២.** មន្ទីរសន្តិសុខក្រាំងតាចាន់ដែលស្ថិតនៅស្រុកត្រាំកក់ ខាងលិចក្រុងតាកែវ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៣ និងបន្តដំណើរការពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះយល់ឃើញថា អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខនេះ ត្រូវបានឃុំខ្លួនដោយគ្មានការការពារតាមនីតិវិធីច្បាប់ និងក្រោមលក្ខខណ្ឌគួរឲ្យខ្លាច ត្រូវគេបង្ខំឲ្យអង្គុយទាំងជាប់ខ្នោះ និងច្រវាក់ រួមគ្នាជាជួរ លើកម្រាលអគារឃុំឃាំង។ អ្នកជាប់ឃុំមួយចំនួន ដែលភាគច្រើនជាប្រជាជនថ្មីត្រូវគេសម្លាប់ភ្លាមៗ ក្រោយពីត្រូវបានបញ្ជូនទៅដល់មន្ទីរសន្តិសុខក្រាំងតាចាន់ ដោយគ្មានសួរចម្លើយឡើយ។ អ្នកជាប់ឃុំជាច្រើនទៀត ត្រូវបានគេសួរចម្លើយរយៈពេលពីរបីសប្ដាហ៍ ក្រោយពីមកដល់។ អង្គជំនុំជម្រះយល់ឃើញថា ជារឿយៗ ការសួរចម្លើយនៅមន្ទីរសន្តិសុខក្រាំងតាចាន់មាន ការវាយដំ ការទាត់ធាក់ និងការធ្វើឲ្យថប់ដង្ហើមស្ទើរស្លាប់ ហើយការធ្វើបាបបែបនេះបានបណ្ដាលឲ្យអ្នកជាប់ឃុំខ្លះបានស្លាប់។ អ្នកជាប់ឃុំជាច្រើនក៏បានបាត់ខ្លួនផងដែរ។ អង្គជំនុំជម្រះយល់ឃើញទៀតថាមានរបបការងារសម្រាប់អ្នកជាប់ឃុំមួយចំនួនតូចដែលត្រូវគេប្រើដើម្បីជាប្រយោជន៍បក្ស ហើយក្នុងករណីជាច្រើន ពួកគេត្រូវបានសម្លាប់ចោលផងដែរ។

**២៣.** មន្ទីរសន្តិសុខអូរកន្សែង ដែលស្ថិតនៅតំបន់ ១០២ ភូមិភាគឦសាន (បច្ចុប្បន្នខេត្តរតនគិរី) ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ ហើយបន្តដំណើរការពេញមួយរបប កម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះ យល់ឃើញថា មន្ទីរសន្តិសុខអូរកន្សែងត្រូវគេប្រើជាជំនួយដល់មន្ទីរសន្តិសុខ ស-២១ សម្រាប់ឃុំខ្លួន និងលត់ដំអ្នកប្រព្រឹត្តកំហុសស្រាលមកពីភូមិភាគឦសាន ចំណែកឯកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា និងកម្មាភិបាលនៃកងពល ៨០១ ដែលត្រូវបានចាប់ខ្លួនមកពីភូមិភាគឦសាន ត្រូវបានគេបញ្ជូនទៅឃុំខ្លួន និងសម្លាប់ជាញឹកញាប់នៅមន្ទីរសន្តិសុខ ស-២១។ ចាប់ពីពាក់កណ្ដាលឆ្នាំ១៩៧៧ មក ជនស៊ីវិលដែលមិនមានតំណែងជាន់ខ្ពស់ រួមទាំងអ្នកធ្វើការមកពីសហករណ៍ និងសហជីពចម្ការកៅស៊ូ នៅទូទាំងភូមិភាគឦសានក៏ត្រូវគេឃុំខ្លួននៅមន្ទីរសន្តិសុខអូរកន្សែងផងដែរ។ អង្គជំនុំជម្រះ យល់ឃើញថា លក្ខខណ្ឌនៃការឃុំខ្លួនមានភាពខុសគ្នារវាងអ្នក ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តកំហុសធ្ងន់ និងអ្នកប្រព្រឹត្តកំហុសស្រាល ស្ត្រី និងកុមារ។ អ្នកដែលគេចាត់ទុកថាគ្រោះថ្នាក់

ត្រូវគេដាក់ច្រវាក់ ឬខ្នោះជាប់រហូតក្នុងអគារឃុំឃាំងដាច់ដោយឡែក។ អ្នកប្រព្រឹត្តកំហុសស្រាល ក៏ដូចជាស្ត្រី និងកុមារ មិនត្រូវបានគេដាក់ខ្នោះ ច្រវាក់ ឬមិនត្រូវបានគេដាក់ក្នុងបន្ទប់ឃុំឃាំងឡើយ។ អង្គជំនុំជម្រះក៏យល់ឃើញថា អ្នកជាប់ឃុំត្រូវគេសួរចម្លើយតាមរយៈការវាយដំ ការទាត់ធាក់ និងការឆក់ខ្សែភ្លើងដោយប្រើខ្សែទូរស័ព្ទ ឬមធ្យោបាយប្រហាក់ប្រហែល។ អង្គជំនុំជម្រះ មិនអាចជឿឲ្យហួសពីវិមតិសង្ស័យថា អ្នកជាប់ឃុំដែលគេគិតថា មិនអាចកែប្រែបានត្រូវគេសម្លាប់ទាំងអស់ ដោយគ្មានការលើកលែងនោះទេ ក៏ប៉ុន្តែអង្គជំនុំជម្រះជឿជាក់ថា ការសម្លាប់ពិតជាកើតមានមែន។ លើសពីនេះទៀត អ្នកខ្លះស្លាប់ដោយសារលក្ខខណ្ឌនៃការឃុំខ្លួន។ អង្គជំនុំជម្រះយល់ឃើញទៀតថា ជនជាតិចារ៉ាយយ៉ាងហោចណាស់ ១០០នាក់ ដែលក្នុងនោះ រួមមានទាំងបុរស កុមារ និងស្ត្រីប្រហែល ៥នាក់ ត្រូវគេឃុំខ្លួននៅមន្ទីរសន្តិសុខអូរកន្សែង នៅពាក់កណ្តាលឆ្នាំ១៩៧៧។ ក្រោយពីត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខនេះ បានប្រហែលមួយសប្តាហ៍ ជនជាតិចារ៉ាយទាំងនេះ ត្រូវបានគេប្រើលេសបណ្តើរចេញពីកន្លែងឃុំឃាំង រួចនាំទៅសម្លាប់ចោល។ អង្គជំនុំជម្រះ ជឿជាក់ថា បទបញ្ជាឲ្យសម្លាប់ជនជាតិចារ៉ាយ ត្រូវបានបញ្ជូនតាមរយៈ សុន សេន និង សូ សារឿន មេបញ្ជាការកងពល ៨០១ ដោយមានការចូលរួមពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ទៅឲ្យបុគ្គលិកនៅមន្ទីរសន្តិសុខ នេះដើម្បីអនុវត្ត។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះ មិនអាចជឿឲ្យហួសពីវិមតិសង្ស័យថា ជនជាតិចារ៉ាយ ដែលទំនងជាអតីតទាហាននៃរបបសាធារណរដ្ឋវៀតណាមខាងត្បូង ឬត្រូវបានគេសន្មតបែបនេះ គឺជាជនដែលត្រូវទទួលបានការការពារ នៅក្នុងអត្ថន័យនៃអនុសញ្ញាទីក្រុងហ្សឺណែវនោះឡើយ។

**២៤.** មន្ទីរសន្តិសុខភ្នំក្រោលស្ថិតនៅតំបន់ ១០៥ (បច្ចុប្បន្នខេត្តមណ្ឌលគិរី) មានមន្ទីរ ក-១៧ និង ក-១១ គុកភ្នំក្រោល និងកន្លែងកប់សាកសពត្រពាំងព្រីង។ អង្គជំនុំជម្រះ យល់ឃើញថា ពុំមានការការពារតាមប្រព័ន្ធតុលាការ ឬតាមនីតិវិធីច្បាប់ទេ នៅពេលចាប់ខ្លួនអ្នកដែលត្រូវបានគេសន្មតថាជាអ្នកទោស និងពេលឃុំខ្លួនពួកគេ នាពេលក្រោយមកនៅមន្ទីរសន្តិសុខភ្នំក្រោល ហើយនៅក្នុងអំឡុងពេលនោះ ពួកគេត្រូវបានបង្ខំឲ្យធ្វើការ។ អង្គជំនុំជម្រះ យល់ឃើញទៀតថា អ្នកជាប់ឃុំម្នាក់បានស្លាប់ដោយសារតែលក្ខខណ្ឌនៃការឃុំខ្លួន ហើយអ្នកជាប់ឃុំម្នាក់ត្រូវគេសម្លាប់ដោយចេតនា។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះ មិនអាចរកភ័ស្តុតាងបង្ហាញឲ្យឃើញថា តើកន្លែងកប់សាកសពត្រពាំងព្រីងត្រូវបានគេប្រើសម្រាប់កប់សាកសពអ្នកជាប់ឃុំទាំងនោះ ឬយ៉ាងណានោះទេ។ លើសពីនេះទៀត ទោះបីជា អង្គជំនុំជម្រះ ជឿថាត្រពាំងព្រីងពិតជាកន្លែងកប់សាកសពនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយក៏ អង្គជំនុំជម្រះ មិនអាចសន្និដ្ឋានថាត្រពាំងព្រីងត្រូវគេប្រើជាទីតាំងសម្លាប់មនុស្សបានឡើយ។

**២៥.** អង្គជំនុំជម្រះ យល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចតទៅនេះត្រូវបានប្រព្រឹត្តពាក់ព័ន្ធនឹងការបង្កើត និងដំណើរការរបស់មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស។ ឧក្រិដ្ឋកម្មទាំងនោះរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើអមនុស្សធម៌ផ្សេងៗ ទៀត ក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ។ អង្គជំនុំជម្រះ នឹងលើកឡើងអំពីការសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខ ស-២១ ដោយបង្ហាញអំពីការប្រព្រឹត្តលើជនជាតិវៀតណាម។

## ១.៣.៤. ការកំណត់គោលដៅលើក្រុមមនុស្សជាក់លាក់

**២៦.** អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានគោលនយោបាយកំណត់គោលដៅលើក្រុមមនុស្សដូចតទៅនេះ ដើម្បីបង្កើតសង្គមមួយដែលមិនជឿលើសាសនា និងមានលក្ខណៈតែមួយដោយគ្មានការបែងចែកវណ្ណៈ តាមរយៈការលុបបំបាត់នូវភាពខុសគ្នាខាងជាតិពន្ធុ ជាតិ សាសនា ពូជសាសន៍ វណ្ណៈ និងវប្បធម៌។ ក្រុមទាំងនោះរួមមាន ជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក ព្រមទាំងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (រួមទាំងអ្នករដ្ឋការស៊ីវិល និងទាហាន) និងក្រុមគ្រួសាររបស់ពួកគេ។

### ១.៣.៤.១. ជនជាតិចាម

**២៧.** ទាក់ទងនឹងជនជាតិចាម អង្គជំនុំជម្រះ យល់ឃើញថា ក្រោយការបះបោរនៅកោះផល ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ និងនៅស្វាយឃ្លាំង ក្នុងខែតុលា ឆ្នាំ១៩៧៥ ប្រជាជនចាមនៅភូមិភាគបូព៌ា ភាគច្រើនជាអ្នករស់នៅតាមដងទន្លេមេគង្គត្រូវបានគេបញ្ជូនឲ្យទៅរស់នៅបែកខ្ញែកគ្នានៅភូមិភាគកណ្តាល(ឧត្តរចាស់)។ ជនជាតិចាម ត្រូវបានកងទ័ពបក្សកុម្មុយនីស្តកម្ពុជាបញ្ជូនចេញ ដោយគ្មានការយល់ព្រម និងក្រោមការគំរាមកំហែងថានឹងចាត់ទុកជាខ្មាំង បើពួកគេមិនស្តាប់បញ្ជា។ ទោះបីជាការបំបែកនេះ គឺជាផ្នែកមួយនៃការជម្លៀសប្រជាជនក្នុងទ្រង់ទ្រាយធំពីភូមិភាគបូព៌ាទៅភូមិភាគកណ្តាល (ឧត្តរចាស់) ក្នុងគោលដៅដាក់ពង្រាយប្រជាជននៅទូទាំងប្រទេសកម្ពុជាក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ជនជាតិចាមនៅភូមិភាគបូព៌ាត្រូវបានកំណត់ជាគោលដៅជាក់លាក់ ដោយសារតែការបះបោរប្រឆាំងនឹងការរឹតត្បិតពីមុនលើសាសនា ប្រពៃណី និងវប្បធម៌ចាម។ អង្គជំនុំជម្រះ យល់ឃើញទៀតថា គេមិនត្រឹមតែជម្លៀសជនជាតិចាមពីកន្លែងដើមទៅកន្លែងថ្មី ដើម្បីបំពេញសេចក្តីត្រូវការខាងកម្លាំងពលកម្មក្នុងស្រុកប៉ុណ្ណោះទេ គឺថែមទាំងបំបែកជនជាតិចាមឲ្យរស់នៅរាយប៉ាយនៅតាមភូមិខ្មែរ ដើម្បីរំលាយសហគមន៍ជនជាតិចាម និងប្រចាច់បញ្ចូលពួកគេជាមួយប្រជាជនកម្ពុជា។ ហេតុដូច្នេះ ជនជាតិចាមត្រូវបានកំណត់ជាគោលដៅ មិនមែនជាបុគ្គលទេ ប៉ុន្តែផ្អែកលើសមាជិកក្រុមរបស់ពួកគេ។

**២៨.** លើសពីនេះទៀត អង្គជំនុំជម្រះ យល់ឃើញថា ប្រជាជនចាមបានទទួលរងការរើសអើងឧទាហរណ៍ នៅការដ្ឋានការងារទំនប់ ១ មករា ពួកគេត្រូវបានបង្ខំឲ្យហូបសាច់ជ្រូក ហើយត្រូវបានរារាំងមិនឲ្យគោរពបូជាសាសនា និងនិយាយភាសាចាមឡើយ។ អង្គជំនុំជម្រះ ក៏យល់ឃើញផងដែរថា បក្សកុម្មុយនីស្តកម្ពុជាបានដាក់កំហិតលើការប្រណិប័តន៍សាសនា និងវប្បធម៌ចាម នៅស្រុកក្រូចឆ្មារ តាមទីតាំងជាច្រើនក្នុងភូមិភាគកណ្តាល (ឧត្តរចាស់) និងតាមទីតាំងនានាផ្សេងទៀត នៅក្នុងប្រទេសកម្ពុជា ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ ការដាក់កំហិតបែបនេះរួមមាន ការហាមសំយ៉ាំងជារៀងរាល់ថ្ងៃ ការបង្ខំជនជាតិចាមឲ្យហូបសាច់ជ្រូក ព្រមទាំងស្លៀក សម្លៀកបំពាក់ និងកាត់សក់ដូចប្រជាជនខ្មែរ ការបង្ខំឲ្យនិយាយតែភាសាខ្មែរ ក៏ដូចជា ការដុតគម្ពីរអាល់គូរ៉ាន និងការរុះរើព្រះវិហារ ឬការប្រើប្រាស់ព្រះវិហារសម្រាប់គោលបំណងខុសពីការបួងសួង។ អ្នករឹងទទឹងត្រូវគេចាប់ខ្លួន និង/ឬសម្លាប់ចោល។

**២៩.** លើសពីនេះទៀត អង្គជំនុំជម្រះ យល់ឃើញថា មនុស្សជាច្រើន រួមទាំងជនជាតិចាមភាគច្រើនមកពីស្រុកកងមាស (បច្ចុប្បន្នខេត្តកំពង់ចាម) តំបន់ ៤១ ភូមិភាគកណ្តាល (ឧត្តរចាស់) ត្រូវគេចាប់យកទៅសម្លាប់នៅ

វត្តអូរត្រកួន ក្នុងឆ្នាំ១៩៧៧។ អង្គជំនុំជម្រះ យល់ឃើញទៀតថា នៅឆ្នាំ១៩៧៨ ប្រជាជនចាមជាច្រើន មកពីស្រុកក្រូចឆ្មារ (បច្ចុប្បន្នខេត្តត្បូងឃ្មុំ) ត្រូវគេចាប់យកទៅមន្ទីរសន្តិសុខភូមិទ្រា ក្នុងស្រុកក្រូចឆ្មារដដែល ហើយនៅទីនោះ សមាជិកក្រុមចាមត្រូវបានគេពិនិត្យផ្ទៀងផ្ទាត់។ អ្នកដែលគេចាត់ទុកថាជាចាម ត្រូវគេសម្លាប់ ចំណែកឯអ្នកដែលមិនមែនជាចាម ត្រូវគេទុកឲ្យរួចជីវិត។ អង្គជំនុំជម្រះ ក៏យល់ឃើញផងដែរថា បញ្ជាឲ្យកំណត់គោលដៅលើជនជាតិចាមនៅភូមិភាគកណ្តាល (ឧត្តរចាស់) និងជាពិសេស នៅតំបន់ ៤១ ចេញមកពីថ្នាក់លើ។ អង្គជំនុំជម្រះ ក៏យល់ឃើញដែរថា បញ្ជាឲ្យកំណត់គោលដៅលើជនជាតិចាមនៅភូមិភាគបូព៌ា និងជាពិសេស នៅស្រុកក្រូចឆ្មារ ចេញមកពីថ្នាក់លើ។ ប៉ុន្តែទោះបីជាយ៉ាងណា អង្គជំនុំជម្រះ មិនអាចកំណត់ចំនួនជនរងគ្រោះបានជាក់លាក់ក៏ដោយក៏ អង្គជំនុំជម្រះ ជឿជាក់ថា ជនស៊ីវិលចាមជាច្រើន ត្រូវគេនាំយកទៅមន្ទីរសន្តិសុខវត្តអូរត្រកួន និងមន្ទីរសន្តិសុខភូមិទ្រា រួចត្រូវបានគេសម្លាប់ចោលក្នុងទ្រង់ទ្រាយធំ។ អង្គជំនុំជម្រះ ជឿជាក់ថា ចារិនៅមន្ទីរសន្តិសុខវត្តអូរត្រកួន និងមន្ទីរសន្តិសុខភូមិទ្រា បានបង្ហាញអំពីស្ថានភាពផ្លូវចិត្តក្នុងការប្រល័យពូជសាសន៍ជនជាតិចាម ដែលត្រូវបានរកឃើញថា ត្រូវបានគេសម្លាប់នៅទីតាំងទាំងនោះ។ អង្គជំនុំជម្រះ យល់ឃើញទៀតថា នៅឆ្នាំ១៩៧៨ ជនជាតិចាមមកពីស្រុកក្រូចឆ្មារត្រូវគេចាប់យកទៅមន្ទីរសន្តិសុខភូមិទ្រា ឃុំខ្លួនតាមទំនើងចិត្ត និងដកហូតសិទ្ធិទទួលបានដំណើរការក្តីតាមផ្លូវច្បាប់ ហើយនៅទីនោះ អ្នកខ្លះត្រូវបានគេសួរចម្លើយ និងវាយដំ។

៣០. ដូច្នេះ អង្គជំនុំជម្រះ យល់ឃើញថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានប្រព្រឹត្តលើជនជាតិចាម តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងអំពើអមនុស្សធម៌ផ្សេងៗ ទៀតក្រោមទម្រង់ជាការប្រព្រឹត្ត ដែលត្រូវបានកំណត់ថាជាការជម្លៀសដោយបង្ខំ។

### ១.៣.៤.២. ជនជាតិវៀតណាម

៣១. ចំពោះជនជាតិវៀតណាម អង្គជំនុំជម្រះ យល់ឃើញថា ចាប់ពីឆ្នាំ១៩៧៥ ដល់ចុងឆ្នាំ១៩៧៦ មានគោលនយោបាយថ្នាក់ជាតិសំដៅបណ្តេញជនជាតិវៀតណាម ដែលរស់នៅប្រទេសកម្ពុជា។ គោលនយោបាយនេះត្រូវបានអនុវត្ត ក្រោយពីមានការព្រមព្រៀងគ្នាជាមួយអាជ្ញាធរ វៀតណាម។ កម្មាភិបាលខ្មែរក្រហមបានរៀបចំ និងឃ្លាំមើលការដឹកជញ្ជូនប្រជាជនវៀតណាមទៅព្រំដែនវៀតណាម តាមកាណូត និងរថយន្ត។ ប្តី ឬប្រពន្ធជាជនជាតិខ្មែរ ដែលមានគ្រួសារចម្រុះជាតិសាសន៍ត្រូវនៅកម្ពុជា។ អង្គជំនុំជម្រះ ក៏យល់ឃើញដែរថា ថ្នាក់លើរបស់បក្សកុម្មុយនីស្តកម្ពុជា បានបញ្ជាឲ្យកំណត់អត្តសញ្ញាណជនជាតិវៀតណាម ហើយក្រោយមក ចាប់ពីខែមេសា ឆ្នាំ១៩៧៥ ថ្នាក់ក្រោមបានរៀបចំបញ្ជីឈ្មោះនិងប្រវត្តិរូប រួចបញ្ជូនទៅថ្នាក់លើ ដើម្បីចាត់វិធានការបន្តទៀត។ ចាប់ពីឆ្នាំ១៩៧៥ មក បក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកថា ប្រសិនបើគ្រួសារណាមានម្តាយជាជនជាតិវៀតណាម ហើយឪពុកជាខ្មែរនោះ ត្រូវបញ្ជូនម្តាយនិងកូនៗ ទៅប្រទេសវៀតណាមដោយទុកឪពុក។ ស្រដៀងគ្នានេះដែរ ប្រសិនបើគ្រួសារណាមានឪពុកជាជនជាតិវៀតណាម ហើយម្តាយជាខ្មែរ ត្រូវបញ្ជូនឪពុកទៅប្រទេសវៀតណាមវិញ ដោយទុកម្តាយនិងកូនៗ នៅប្រទេសកម្ពុជា។ អង្គជំនុំជម្រះ យល់ឃើញថា ជនជាតិវៀតណាមដែលចេញពីខេត្តព្រៃវែង ខេត្តស្វាយរៀង និងស្រុកត្រាំកក់ ក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ ត្រូវគេបង្ខំឲ្យធ្វើបែបនេះក្នុងបរិយាកាសបង្ខិតបង្ខំ។

៣២. អង្គជំនុំជម្រះ ក៏យល់ឃើញដែរថា មានភស្តុតាងបង្ហាញពីករណីជាក់លាក់មួយចំនួននៃការសម្លាប់ជនស៊ីវិលវៀតណាម ឧទាហរណ៍ នៅខេត្តស្វាយរៀង ក្នុងឆ្នាំ១៩៧៨ ក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ ក្រោយខែមេសា ឬខែឧសភា ឆ្នាំ១៩៧៧ និងនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨, នៅខេត្តកំពង់ឆ្នាំង ក្នុងឆ្នាំ១៩៧៧, នៅវត្តខ្សាច់ (ខេត្តសៀមរាប) នៅចុងឆ្នាំ១៩៧៨ និងនៅក្រចេះ ក្នុងខែកញ្ញា ឆ្នាំ១៩៧៨។ ការសម្លាប់ដោយចេតនាទ្រង់ទ្រាយធំទាំងនេះ ត្រូវបានរៀបចំឡើងជាប្រព័ន្ធ និងកំណត់គោលដៅទៅលើជនជាតិវៀតណាម។ ក្នុងករណីនីមួយៗ ជនជាតិវៀតណាម ត្រូវបានគេកំណត់គោលដៅមិនមែនជាបុគ្គលទេ គឺដោយសារតែសមាជិកក្រុមរបស់ពួកគេ និងដោយសារតែពួកគេត្រូវបានសន្មតថា ជាជនជាតិវៀតណាម។ ករណីទាំងនេះបានកើតឡើងក្រោមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំណត់គោលដៅជាក់លាក់ទៅលើក្រុមជនជាតិ វៀតណាម រួមទាំងជនស៊ីវិលផង។ រហូតដល់ចុងឆ្នាំ១៩៧៦ ជនជាតិវៀតណាមត្រូវគេកំណត់គោលដៅ ដើម្បីបណ្តេញចេញ និងដើម្បីកម្ទេច ចាប់ពីខែមេសា ឆ្នាំ១៩៧៧ មក។

៣៣. ទាក់ទងនឹងការប្រព្រឹត្តលើជនជាតិវៀតណាម ដែលត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខ ស-២១ អង្គជំនុំជម្រះយល់ឃើញថា ជនស៊ីវិល និងទាហានវៀតណាមរាប់រយនាក់ត្រូវបានគេសម្លាប់ក្រោយពីសួរចម្លើយ ដោយប្រើវិធីបង្ខិតបង្ខំ និងទទួលរងនូវលក្ខខណ្ឌលំបាកវេទនា នៅមន្ទីរសន្តិសុខ ស-២១។ អ្នកដែលត្រូវបានគេសម្លាប់ជាជនស៊ីវិល ឬឈ្លើយសឹកវៀតណាម ដែលជាជនត្រូវទទួលបានការការពារតាមអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។ ចម្លើយសារភាព ដែលយកពីអ្នកជាប់ឃុំជាជនជាតិវៀតណាម ត្រូវគេចុះផ្សាយក្នុងឯកសារនានារបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងគោលដៅបង្ហាញអំពី «ការឈ្លានពាន» របស់វៀតណាមមកលើកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះយល់ឃើញទៀតថា អ្នកជាប់ឃុំជាជនជាតិវៀតណាមដែលចូលមកមន្ទីរសន្តិសុខ ស-២១ មិនទទួលបានការការពារតាមនីតិវិធី ឬសិទ្ធិដែលអាចឲ្យពួកគេការពារខ្លួនបាននៅក្រោយពេលចាប់ខ្លួន ត្រូវបានគេដកហូតដំណើរការមួយដែលស្រដៀងនឹងការកាត់ក្តីដោយយុត្តិធម៌ ហើយត្រូវគេបង្ខំឲ្យឆ្លើយសារភាពថាជាគិញ មុនពេលត្រូវបានគេសម្លាប់។ ទាហាន និងជនស៊ីវិលវៀតណាមទាំងអស់ ដែលចូលមកមន្ទីរសន្តិសុខ ស-២១ ត្រូវគេចោទថាជាគិញ និងចាត់ទុកថាជាខ្មាំង។ ជោគវាសនារបស់អ្នកជាប់ឃុំទាំងនេះត្រូវបានសន្និដ្ឋានទុកជាមុន ដោយសារជាចុងក្រោយ ពួកគេទាំងអស់ត្រូវបានសម្លាប់ចោល។

៣៤. ដូច្នេះ អង្គជំនុំជម្រះ យល់ឃើញថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស និងការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ ត្រូវបានប្រព្រឹត្តលើជនជាតិវៀតណាម។ លើសពីនេះទៀត ដោយរម្លឹកអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ដែលកំពុងកើតមាននៅពេលនោះ រវាងវៀតណាមនិងកម្ពុជាប្រជាធិបតេយ្យ ចាប់ពីខែឧសភា ឆ្នាំ១៩៧៥ និងឋានៈទទួលបានការការពាររបស់ជនរងគ្រោះ អង្គជំនុំជម្រះ យល់ឃើញថា ការបំពារបំពានយ៉ាងធ្ងន់ធ្ងរជាច្រើនលើអនុសញ្ញាទីក្រុងហ្សឺណែវ ក៏ត្រូវបានប្រព្រឹត្តផងដែរលើក្រុមនេះ នៅមន្ទីរសន្តិសុខ ស-២១ រួមទាំងការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនដោយខុសច្បាប់។

### ១.៣.៤.៣. ពុទ្ធសាសនិក

៣៥. ចំពោះការប្រព្រឹត្តលើពុទ្ធសាសនិក ដែលបទចោទទាំងនេះ ត្រូវបានកម្រិតត្រឹមតែសហករណ៍ត្រាំកក់ អង្គជំនុំជម្រះ យល់ឃើញថា ព្រះពុទ្ធសាសនាត្រូវបានហាមឃាត់ និមិត្តរូបតំណាងឲ្យព្រះពុទ្ធត្រូវបានបំផ្លិចបំផ្លាញ ហើយវត្តអារាមមិនត្រូវបានអនុញ្ញាតឲ្យប្រើសម្រាប់គោលបំណងសាសនាទៀតទេ។ អង្គជំនុំជម្រះ ក៏យល់ឃើញផងដែរថា ព្រះសង្ឃជាង ១០០អង្គ ត្រូវបានគេប្រមូលដោយចេតនាយកទៅដាក់នៅវត្តអង្គរកានិងបង្ខំឲ្យសឹក។ ព្រះសង្ឃក៏ត្រូវគេបង្ខំឲ្យសឹកនៅតាមវត្តផ្សេងៗ ទៀត ហើយករណីនេះឆ្លុះបញ្ចាំងអំពីលំនាំទូទៅនៅទូទាំងស្រុកត្រាំកក់។ ថ្វីត្បិតតែភ័ស្តុតាងមិនអនុញ្ញាតឲ្យអង្គជំនុំជម្រះសន្និដ្ឋានឲ្យបានច្បាស់លាស់អំពីចំនួនព្រះសង្ឃ ដែលលាចាកសិក្ខាបទសរុបនៅស្រុកត្រាំកក់ក៏ដោយ ក៏អង្គជំនុំជម្រះ យល់ឃើញថាមានភ័ស្តុតាងអាចឲ្យជឿទុកចិត្តបានដែលបង្ហាញថា ព្រះសង្ឃរាប់រយអង្គត្រូវបានគេផ្សឹកនៅតាមឃុំនានា។ ចេតនារើសអើងនៅពីក្រោយដំណើរការនេះ ត្រូវបានបញ្ជាក់ដោយការហៅព្រះសង្ឃថាជា «តេនញ៉ា» ឬជា «ឈ្លើង» សង្គម និងការប្រកាសបដិសេធព្រះពុទ្ធសាសនាដោយថាជា អបិយជំនឿសុទ្ធសាធ និងថា ព្រះពុទ្ធបដិមា «គ្រាន់តែជាស៊ីម៉ង់ត៍ប៉ុណ្ណោះ»។

៣៦. ហេតុដូច្នេះ អង្គជំនុំជម្រះ យល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ត្រូវបានប្រព្រឹត្តឡើងលើពុទ្ធសាសនិក។

### ១.៣.៤.៤. អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

៣៧. ចំពោះអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលបទចោទប្រកាន់ត្រូវបានកម្រិតត្រឹមសហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ ១ មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់ អង្គជំនុំជម្រះ យល់ឃើញថា ក្រុមនេះត្រូវបានគេធ្វើទុក្ខបុកម្នេញនៅតាមទីតាំងឧក្រិដ្ឋកម្មទាំងបួននេះ។ ឧទាហរណ៍ អង្គជំនុំជម្រះ យល់ឃើញថា នៅក្នុងស្រុកត្រាំកក់ភ្លាមៗ ក្រោយថ្ងៃទី១៧ ខែ មេសា ឆ្នាំ១៩៧៥ អតីតទាហាន និងនគរបាលនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានគេសម្រិតសម្រាំងនៅវត្តចម្ប៉ា ហើយក្រោយពីបានប្រាប់អត្តសញ្ញាណរបស់ខ្លួនរួចហើយ ពួកគេជាច្រើនត្រូវបាននាំយកទៅ រួចបាត់ខ្លួន។ ដំណើរការដូចគ្នានេះបានកើតឡើងនៅតាមកន្លែងផ្សេងៗ ទៀតក្នុងស្រុកត្រាំកក់។ ថ្វីត្បិតតែមានផែនការច្បាស់លាស់ក្នុងការបោសសម្អាត និងសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅស្រុកត្រាំកក់ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក៏ដោយ ក៏យ៉ាងហោចណាស់ នៅពេលមួយនោះមានការផ្សព្វផ្សាយមិនឲ្យប៉ះពាល់អតីតទាហាន ចាប់ពី ស័ក្តិ ១ ដល់ស័ក្តិ ៥។ អង្គជំនុំជម្រះ យល់ឃើញថា ទោះជាយ៉ាងនេះក្តី ក្រោយមក អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវគេកំណត់គោលដៅជាថ្មីម្តងទៀត ដើម្បីចាប់ខ្លួន និង សម្លាប់។ គ្រួសារអតីតទាហានជាច្រើនត្រូវគេកម្ទេចនៅឃុំពពេល ក្នុងខែឧសភា ឆ្នាំ១៩៧៧ ហើយប្រតិបត្តិការសម្លាប់ដោយមានការរៀបចំត្រូវបានធ្វើឡើងនៅស្រុកត្រាំកក់ ចាប់ពីខែមេសា ឆ្នាំ១៩៧៧ ដោយមនុស្សជាច្រើនត្រូវគេយកទៅមន្ទីរសន្តិសុខក្រាំងតាចាន់។ អង្គជំនុំជម្រះជឿជាក់ថាអ្នកទាំងនេះត្រូវគេកំណត់គោលដៅដោយផ្អែកលើតួនាទីពិតប្រាកដរបស់ពួកគេនៅក្នុងរបបមុន ឬតាមការសន្មត។

៣៨. អង្គជំនុំជម្រះ យល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយត្រូវបានប្រព្រឹត្តនៅសហករណ៍ត្រាំកក់ ពីថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ដល់ចុងខែឧសភា ឆ្នាំ១៩៧៥ និងពីដើមឆ្នាំ១៩៧៧ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ នៅការដ្ឋានការងារទំនប់ ១ មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ លើសពីនេះទៀត អង្គជំនុំជម្រះ យល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានប្រព្រឹត្តលើអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅមន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់។

## ១.៣.៥. ការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍

៣៩. អង្គជំនុំជម្រះយល់ឃើញថា មានគោលនយោបាយនៅទូទាំងប្រទេសក្នុងការកំណត់បទបញ្ជាលើការកសាងគ្រួសារ និងការរៀបអាពាហ៍ពិពាហ៍ ដែលត្រូវកម្មាភិបាលបក្សអនុវត្តនៅតាមបណ្តាញរដ្ឋបាល និងអង្គភាពយោធាគ្រប់ជាន់ថ្នាក់។បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតគោលនយោបាយនេះឡើង ដើម្បីឲ្យបក្សអាចជំនួសតួនាទីរបស់ឪពុកម្តាយក្នុងការជ្រើសរើសគូស្រករសមស្រប ហើយបង្ខំបុរសនិងស្ត្រីឲ្យរៀបការនឹងគ្នា និងបង្ខំឲ្យបង្កើតកូនក្នុងគោលបំណងបង្កើនចំនួនប្រជាជននៅក្នុងប្រទេសក្នុងរយៈពេលពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ខាងមុខ។

៤០. អង្គជំនុំជម្រះយល់ឃើញថា ការរៀបអាពាហ៍ពិពាហ៍តាមការរៀបចំនៅក្នុងវប្បធម៌កម្ពុជាមានភាពខុសគ្នាពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ ការរៀបអាពាហ៍ពិពាហ៍តាមការរៀបចំនៅក្នុងវប្បធម៌កម្ពុជាមុនរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានធ្វើឡើងដោយផ្អែកទៅលើការជឿទុកចិត្តគ្នាទៅវិញទៅមករវាងកូនៗ និងឪពុកម្តាយ ដែលជាអ្នកជ្រើសរើសគូស្រករឲ្យកូន ហើយមិនមានចំណុចនេះទេ នៅពេលដែលបក្សមកជំនួសតួនាទីជាឪពុកម្តាយនៅក្នុងការរៀបចំអាពាហ៍ពិពាហ៍នោះ។ ភ័ស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះ បង្ហាញយ៉ាងច្បាស់អំពីការអនុវត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមិនបានឆ្លុះបញ្ចាំងទាល់តែសោះអំពីការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ដោយគ្រួសាររបស់អនាគតប្តីប្រពន្ធនោះមិនបានចូលរួមទាល់តែសោះនៅក្នុងការចរចា សហគមន៍មិនត្រូវបានឲ្យចូលរួម មិនមានប្រពៃណីនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ហើយសាមីខ្លួនយល់ព្រមរៀបការដោយខ្លាចបក្សដាក់ទណ្ឌកម្ម។ អង្គជំនុំជម្រះ យល់ឃើញថា អាជ្ញាធររបបកម្ពុជាប្រជាធិបតេយ្យបានរៀបចំអាពាហ៍ពិពាហ៍នៅគ្រប់ពេលវេលាក្នុងរបបនេះ និងនៅតាមទីតាំងភូមិសាស្ត្រជាច្រើននៅទូទាំងប្រទេសកម្ពុជា។ បុគ្គលទាំងឡាយបានរៀបអាពាហ៍ពិពាហ៍នៅក្នុងបរិយាកាសភ័យខ្លាច ហើយនៅក្នុងករណីភាគច្រើនការព្រមព្រៀងនៅមុនពេល ឬក្នុងអំឡុងពិធីរៀបអាពាហ៍ពិពាហ៍ ដែលបានលើកឡើងនោះ មិនមែនជាការយល់ព្រមពិតប្រាកដឡើយ។ អង្គជំនុំជម្រះ យល់ឃើញថាក្រោយពិធីរៀបអាពាហ៍ពិពាហ៍ ជាធម្មតាអាជ្ញាធរបានរៀបចំឲ្យប្តីប្រពន្ធថ្មីថ្មោងនោះ ផ្សំដំណេកជាមួយគ្នានៅក្នុងទីតាំងកំណត់មួយ ក្រោមការតាមដានពីកងឈ្លប ជាពិសេស ដើម្បីឲ្យមានការរួមភេទ។ ទាំងបុរស និងស្ត្រីយល់ថាពួកគេត្រូវបានគេបង្ខំឱ្យរួមភេទជាមួយប្តីឬប្រពន្ធថ្មីថ្មោងរបស់ពួកគេ ហេតុដូច្នេះ ពួកគេបានធ្វើផ្ទុយនឹងឆន្ទៈរបស់ពួកគេ។ ប្តីប្រពន្ធ ដែលត្រូវបានរកឃើញថាមិនបានរួមភេទ ត្រូវបានយកមកអប់រំ ឬគំរាមកំហែងថានឹងដាក់ទណ្ឌកម្ម ឬសម្លាប់ចោល ។

៤១. អង្គជំនុំជម្រះ យល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានប្រព្រឹត្តឡើង។

## ១.៣.៦. សហឧក្រិដ្ឋកម្មរួម

៤២. អង្គជំនុំជម្រះ យល់ឃើញថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបន្ត យ៉ាងហោចណាស់ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាមួយចំនួនមានគោលបំណងរួមក្នុងការអនុវត្តបដិវត្តន៍សង្គមនិយមនៅកម្ពុជាឲ្យបានលឿនតាមរយៈ «មហាលោតផ្លោះ មហាអស្ចារ្យ» ដែលត្រូវបានបង្កើតឡើង ដើម្បីកសាងនិងការពារប្រទេសពីខ្មាំង ហើយផ្លាស់ប្តូរប្រជាជនឱ្យក្លាយទៅជាសង្គមកម្មករ-កសិករ ដែលមានជាតិសាសន៍ខ្មែរតែមួយ។ គោលបំណងរួមនេះ ត្រូវបានអនុវត្តគ្រប់ពេលក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយបណ្តាញរដ្ឋបាលទាំងមូលរបស់បក្ស គឺលេខាភូមិភាគ តំបន់ ស្រុក និងថ្នាក់មូលដ្ឋាន និងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា តាមរយៈការអនុវត្តយ៉ាងហោចណាស់គោលនយោបាយចំនួនប្រាំ។ គោលនយោបាយដែលត្រូវបានរៀបចំ និងអនុវត្តឡើងដើម្បីសម្រេចគោលបំណងរួម គឺ (១) ការផ្លាស់ទីលំនៅប្រជាជនម្តងហើយម្តងទៀតពីទីប្រជុំជន និងទីក្រុង ទៅកាន់តំបន់ជនបទ ព្រមទាំងពីទីជនបទមួយទៅកាន់ទីជនបទមួយទៀត (២) ការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ (៣) ការបង្កើត និងដំណើរការមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស ដើម្បីកំណត់អត្តសញ្ញាណ ចាប់ខ្លួន ដាក់ឲ្យនៅដាច់ដោយឡែក និង «កម្ទេច» អ្នកដែលត្រូវបានគេចាត់ទុកថាជាប្រភេទខ្មាំងធ្ងន់ធ្ងរបំផុត និងដើម្បីអប់រំ «សមាសភាពមិនល្អ» (៤) ការកំណត់គោលដៅទៅលើក្រុមជាក់លាក់ រួមទាំង ជនជាតិចាម និងវៀតណាម ពុទ្ធសាសនិក និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ រួមទាំង អ្នករដ្ឋការស៊ីវិល ទាហាន និងក្រុមគ្រួសាររបស់ពួកគេ និង (៥) ការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះយល់ឃើញថា គោលនយោបាយទាំងនេះមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងគោលបំណងរួម ហើយមានការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា គោលបំណងរួមនេះមានលក្ខណៈឧក្រិដ្ឋ។

៤៣. អង្គជំនុំជម្រះ យល់ឃើញទៀតថា គោលបំណងនេះគឺជាគោលបំណងរួមនៅក្នុងចំណោមមនុស្សជាច្រើន រួមទាំងមេដឹកនាំជាន់ខ្ពស់ ប៉ុល ពត, នួន ជា, ខៀវ សំផន, អៀងសារី,អៀង ធីរិទ្ធ, សុន សេន និង វន វ៉េត (រហូតដល់ពេលចាប់ខ្លួននៅចុងឆ្នាំ១៩៧៨) ព្រមទាំងលេខាភូមិភាគ រួមទាំង តាម៉ុក, កែ ពក, កុយ ធួន (រហូតដល់ពេលមានការឃុំខ្លួនក្នុងផ្ទះនៅពាក់កណ្តាលឆ្នាំ១៩៧៦) ជូ ជេត (រហូតដល់ពេលមានការចាប់ខ្លួននៅក្នុងខែមីនា ឆ្នាំ១៩៧៨) រស់ ញឹម (រហូតដល់ពេលមានការចាប់ខ្លួននៅក្នុងខែឧសភា-ខែមិថុនា ឆ្នាំ១៩៧៨) និង សោ ភឹម (រហូតដល់ពេលធ្វើអត្តឃាតនៅខែមិថុនា ឆ្នាំ១៩៧៨)។ មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាបានត្រួតពិនិត្យផ្ទាល់ទៅលើការអនុវត្តគោលនយោបាយជាច្រើន និងបានប្រើប្រាស់ចារីផ្ទាល់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ដើម្បីសម្រេចគោលបំណងរួមនេះ។ អង្គជំនុំជម្រះ យល់ឃើញថាជាការត្រឹមត្រូវ ដែលថា សមាជិកសហឧក្រិដ្ឋកម្មរួមនេះ ត្រូវបានកំណត់ឲ្យទទួលខុសត្រូវលើឧក្រិដ្ឋកម្មទាំងនេះ។

## ១.៤. ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ

**៤៤.** នៅពេលនេះ អង្គជំនុំជម្រះ ពិនិត្យមើលការសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងការទទួលខុសត្រូវរបស់ នួន ជា និង ខៀវ សំផន វិញម្តង។

### ១.៤.១. ការទទួលខុសត្រូវរបស់ នួន ជា

**៤៥.** អង្គជំនុំជម្រះ យល់ឃើញថា ក្នុងនាមជាបុគ្គលម្នាក់ ដែលមានតួនាទីនាំមុខក្នុងការកសាងមូលដ្ឋានគ្រឹះសម្រាប់របបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានចូលរួមសន្និបាតបក្ស និងកិច្ចប្រជុំរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ចាប់ពីពេលចាប់ផ្តើមការធ្វើបដិវត្តន៍រហូតមក។ នួន ជា ត្រូវបានជ្រើសតាំងជាអនុលេខាបក្សនៅក្នុងខែកញ្ញា ឆ្នាំ១៩៦០ ហើយបានបន្តកាន់មុខតំណែងនេះនៅគ្រប់ពេល ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់ក៏ជាសមាជិកពេញសិទ្ធិមួយរូបផងដែរ ទាំងនៅក្នុងគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន។ នួន ជា បានចូលរួមក្នុងកិច្ចប្រជុំសំខាន់ៗ ទាំងអស់ហើយក៏ចូលរួមនៅក្នុងការសម្រេចចិត្តសំខាន់ៗ ទាំងអស់របស់បក្ស នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ពេញមួយរបបនេះ នួន ជា នៅតែជាឥស្សរជនដ៏សំខាន់មួយនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ដោយគាត់គឺជាបុគ្គលដែលស្គាំដ៏ស្មោះត្រង់របស់ ប៉ុល ពត។ លើសពីនេះទៀត នួន ជា ត្រូវបានតែងតាំងឲ្យជំនួស ប៉ុល ពត ធ្វើជានាយករដ្ឋមន្ត្រីស្តីទី នៅពេលដែល ប៉ុល ពត សុំការអនុញ្ញាតសម្រាកជាផ្លូវការចាប់ពីខែកញ្ញា ឆ្នាំ១៩៧៦ រហូតដល់ ខែកញ្ញា ឆ្នាំ១៩៧៧។ ដោយសារតែតួនាទីខ្ពង់ខ្ពស់នៅក្នុងថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា នួន ជា ធ្វើការគ្រប់គ្រងលើសកម្មភាពទាំងអស់របស់បក្សដោយលើសពីតួនាទី និងការទទួលខុសត្រូវ ដែលត្រូវបានប្រគល់ឲ្យគាត់ជាផ្លូវការនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទៅទៀត។ អង្គជំនុំជម្រះ យល់ឃើញថា នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ នួន ជា និង ប៉ុល ពត មានអំណាចធ្វើសេចក្តីសម្រេចចុងក្រោយរបស់បក្ស។ ក្នុងឋានៈជាអនុលេខាបក្ស ការគ្រប់គ្រងរបស់គាត់មិនមែនមានត្រឹមតែការធ្វើសេចក្តីសម្រេចផ្នែកនយោបាយប៉ុណ្ណោះទេ ប៉ុន្តែមានរហូតដល់ខាងផ្នែករដ្ឋាភិបាល និងរដ្ឋបាលរបស់របបកម្ពុជាប្រជាធិបតេយ្យ រួមទាំង កិច្ចការយោធាផងដែរ។ ហេតុដូច្នេះហើយ អង្គជំនុំជម្រះ ជឿជាក់ថា នួន ជា មិនត្រឹមតែបានគាំទ្ររួមគ្នាលើគោលបំណងរួមប៉ុណ្ណោះទេ ប៉ុន្តែគាត់បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបង្កើត និងគ្រប់គ្រងលើដំណើរការនៃគោលបំណងរួមនោះដែរ។

**៤៦.** ការគាំទ្ររបស់ នួន ជា លើគោលបំណងរួមដែលគាត់បានចូលរួមបង្កើតឡើង គឺមិនមានការប្រែប្រួលទេក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ។ គាត់បានបន្តអនុវត្ត និងផ្សព្វផ្សាយពីគោលបំណងរួមនេះ ដោយក្តាប់យ៉ាងតឹងណែនទៅលើការអះអាង ដែលត្រូវបានបង្កើតឡើងយ៉ាងប្រុងប្រយ័ត្ន ដោយបក្សកុម្មុយនីស្តកម្ពុជា តាមរយៈការឃោសនា និងសកម្មភាពបណ្តុះបណ្តាលនានា។ នួន ជា ទទួលខុសត្រូវជាចម្បងទៅលើបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងការឃោសនា និងការអប់រំកសិករ កម្មាភិបាល និងសមាជិកបក្សផ្សេងទៀតដោយផ្តោតជាពិសេសទៅលើគោលការណ៍ សំខាន់ៗ និងគោលនយោបាយសេដ្ឋកិច្ចរបស់បក្ស។ នៅក្នុងតួនាទីនេះ នួន ជា បានថ្លែងសុន្ទរកថា និងដឹកនាំវគ្គរៀនសូត្រសម្រាប់កម្មាភិបាលមកពីតាមតំបន់ផ្សេងៗ ទាំងនៅក្នុងក្រុងភ្នំពេញ និងនៅកន្លែងផ្សេងៗ ទៀតក្នុងប្រទេស រួមទាំង សហករណ៍ និងការដ្ឋាន

ការងារផងដែរ។ នួន ជា គឺជាអ្នកនិពន្ធដ៏សំខាន់ម្នាក់នៃទស្សនាវដ្ដីអប់រំឈ្មោះថា ទង់បដិវត្តន៍ ដែលជាឧបករណ៍ឃោសនាចម្បងរបស់បក្សក្នុងការផ្សព្វផ្សាយយ៉ាងទៀងទាត់នូវសុន្ទរកថាដែល ប៉ុល ពត, នួន ជា និង ខៀវ សំផន បានថ្លែង។ នួន ជា បានចូលរួមនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលក្នុងអំឡុងពេលនោះមានការពិភាក្សាទៅលើយុទ្ធវិធីអំពីអ្វីដែលត្រូវលាតត្រដាង និងអ្វីដែលត្រូវរក្សាការសម្ងាត់ ហើយការរក្សាការសម្ងាត់គឺជាសមាសធាតុសំខាន់នៃការឃោសនាដ៏មានប្រសិទ្ធភាពមួយ។ នួន ជា ទទួលខុសត្រូវជាចម្បងទៅលើបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងការឃោសនា និងការអប់រំកសិករ កម្មាភិបាល និងសមាជិកបក្សផ្សេងទៀត ដោយផ្ដោតជាពិសេសទៅលើគោលការណ៍សំខាន់ៗ និងគោលនយោបាយសេដ្ឋកិច្ចរបស់បក្ស។ ការទទួលខុសត្រូវជាផ្លូវការរបស់ នួន ជា ខាងផ្នែកឃោសនាការ និងបញ្ហាពាក់ព័ន្ធនឹងការអប់រំ រួមទាំងកិច្ចការវិន័យសីលធម៌របស់កម្មាភិបាល និងបញ្ហាសន្តិសុខផ្ទៃក្នុងផ្សេងៗទៀត ព្រមទាំងសភាពការណ៍ខ្មាំងជាទូទៅផងដែរ ដោយគាត់បានជំរុញឲ្យវែកមុខ និងកម្ចាត់ខ្មាំង។ ដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា តាមរយៈតួនាទីរបស់គាត់នៅក្នុងយុទ្ធនាការឃោសនា និងយុទ្ធវិធីផ្សេងៗ ក៏ដូចជាការបណ្ដុះបណ្ដាលកម្មាភិបាលទាំងមុន និងក្រោយខែមេសា ឆ្នាំ១៩៧៥ នួន ជា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្ត និងផ្សព្វផ្សាយគោលបំណងរួមនេះ។

៤៧. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះ យល់ឃើញថា ការចូលរួមចំណែករបស់ នួន ជា នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មមានលើសពីការបង្កើតគោលនយោបាយ ការអនុវត្ត និងការផ្សព្វផ្សាយគោលបំណងរួមតាមរយៈការឃោសនា និងការអប់រំ។ នួន ជា បានអនុវត្តគោលបំណងរួមដោយផ្ទាល់ និងបានចូលរួមយ៉ាងសកម្មក្នុងការបោសសម្អាតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។ គាត់មិនត្រឹមតែជួយរៀបចំធ្វើការបោសសម្អាតភូមិភាគពាយព្យ ភូមិភាគកណ្ដាល (ឧត្តរចាស់) និងភូមិភាគបូព៌ាប៉ុណ្ណោះទេ គាត់ថែមទាំងបានចូលរួមដោយផ្ទាល់នៅក្នុងការត្រួតពិនិត្យទៅលើមន្ទីរសន្តិសុខ ស-២១ និងការបោសសម្អាតសមាជិកសំខាន់ៗរបស់បក្ស ដូចជា រស់ ញឹម ដែលជាលេខាភូមិភាគពាយព្យ ជាដើម។

៤៨. ទាក់ទងនឹងមន្ទីរសន្តិសុខ ស-២១ ឯកសារនាសម័យនោះ ជាពិសេស ចម្លើយសារភាពរបស់អ្នកជាប់ឃុំបង្ហាញថា ចាប់តាំងពីពេលមន្ទីរសន្តិសុខ ស-២១ ដំណើរការដំបូង នួន ជា បានដឹង និងចូលរួមនៅក្នុងការចាប់ខ្លួនការឃុំខ្លួនការធ្វើទារុណកម្មនិងការសម្លាប់កម្មាភិបាលដែលត្រូវបានកំណត់ជាគោលដៅសម្រាប់ការបោសសម្អាត។ អង្គជំនុំជម្រះ យល់ឃើញទៀតថា នួន ជា បានបំពេញតួនាទីជាអ្នកគ្រប់គ្រងផ្ទាល់លើ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ បន្ទាប់ពី សុន សេន បានចាកចេញទៅសមរភូមិនៅភូមិភាគបូព៌ា រហូតដល់ពេលដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅដើមខែមករា ឆ្នាំ១៩៧៩។ នៅក្នុងមុខនាទីនេះ នួន ជា បានជួបប្រជុំជាទៀងទាត់ជាមួយ ឌុច និងផ្ដល់ការណែនាំនានារួមទាំងការណែនាំទាក់ទងនឹងអ្នកជាប់ឃុំសំខាន់ៗ មួយចំនួន។ នួន ជា បានទទួល និងអានចម្លើយសារភាពពីមន្ទីរសន្តិសុខ ស-២១ ហើយនៅពេលគាត់យល់ឃើញថាចាំបាច់ គាត់បញ្ជាឲ្យកែតម្រូវ។ លើសពីនេះទៀត អង្គជំនុំជម្រះ យល់ឃើញថា នួន ជា ស្ថិតនៅក្នុងចំណោមអ្នកដែលធ្វើសេចក្ដីសម្រេចចិត្តថាត្រូវចាប់ខ្លួននរណាខ្លះ ដើម្បីបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។ នួន ជា បានបញ្ជាឱ្យសម្លាប់មនុស្សមួយក្រុមៗ ជាច្រើននាក់ ដូចជា អ្នកទាំងឡាយដែលបានមកដល់មន្ទីរសន្តិសុខ ស-២១ ដោយសារតែការបោសសម្អាតភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៨ និងអ្នកដែលត្រូវបានឃុំខ្លួនដោយផ្ទាល់នៅមន្ទីរសន្តិសុខ ស-២១ មុនពេលបោះបង់មន្ទីរនេះចោល ព្រមទាំងបុគ្គលជាក់លាក់មួយចំនួន

ទៀត។ ដោយសារតែកងទ័ពវៀតណាម បានសម្រុកចូលក្រុងភ្នំពេញភ្លាមៗ និងការបោះបង់ចោលមន្ទីរសន្តិសុខ ស-២១ ទាំងតក់ក្រហល់ នៅតក្នុងខែមករា ឆ្នាំ១៩៧៩ មិនមានការប៉ះពាល់អ្វីទេទៅលើឯកសារផ្ទៃក្នុងរបស់មន្ទីរនេះ ដែលរៀបរាប់លម្អិតអំពីដំណើរការមន្ទីរសន្តិសុខ ដោយឯកសារទាំងនោះស្ថិតនៅទីកន្លែងដដែល។ ក្រោយមក នួន ជា បានស្តីបន្ទោស ឌុច ដោយសារតែមិនបានបំផ្លាញឯកសារទាំងនោះចោល។

**៤៩.** សរុបមកវិញ អង្គជំនុំជម្រះ យល់ឃើញថា នួន ជា បានចូលរួមក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម។ នួន ជា បានចូលរួមរៀបចំបង្កើត អនុវត្ត និងផ្សព្វផ្សាយគោលបំណងរួមនេះ តាមរយៈការពន្យល់ជាសាធារណៈ ការឯកភាព និងជំរុញគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា។ គាត់បានធ្វើដូច្នេះតាមរយៈតួនាទីដឹកនាំក្នុងនាមជាដៃស្តាំរបស់ ប៉ុល ពត ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការ អចិន្ត្រៃយ៍បក្ស និងតាមរយៈការចូលរួមយ៉ាងសកម្មរបស់គាត់ក្នុងការឃោសនា និងការអប់រំ។ លើសពីនេះទៀត តាមរយៈការចូលរួមដោយផ្ទាល់និងយ៉ាងទូលំទូលាយរបស់គាត់ក្នុងការបោសសម្អាតនិងដំណើរការរបស់មន្ទីរសន្តិសុខស-២១ នួន ជា បានអនុវត្តគោលបំណងរួមនេះដោយប្រើអន្តរការី ដូចជា ឌុច និងចារីផ្ទាល់ផ្សេងៗ ទៀត ដូចជាបុគ្គលិកមន្ទីរសន្តិសុខ ស-២១ ជាឧបករណ៍នៃសហឧក្រិដ្ឋកម្មរួម អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា នួន ជា បានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។

**៥០.** ម្យ៉ាងវិញទៀត ដូចបានរៀបរាប់ខាងលើមកហើយ អង្គជំនុំជម្រះ យល់ឃើញថា នួន ជា មានចេតនាដែលជាចេតនារួមរបស់សមាជិកសហឧក្រិដ្ឋកម្មរួមផ្សេងៗ ទៀត រួមទាំង ចេតនាជាក់លាក់ និងចេតនារើសអើង ដែលជាលក្ខខណ្ឌកំណត់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងៗ ដែលស្ថិតនៅក្នុងគោលបំណងរួមលើកលែងតែឧក្រិដ្ឋកម្មមួយប៉ុណ្ណោះ។ អង្គជំនុំជម្រះ មិនអាចកំណត់ ឬ សន្និដ្ឋានពីចេតនាប្រល័យពូជសាសន៍របស់ នួន ជាទាក់ទងនឹងជនជាតិចាមនោះទេ ហើយក៏មិនអាចសន្និដ្ឋានឲ្យហួសពីវិមតិសង្ស័យថា នួន ជា បានដឹងថាអំពើប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិចាមដែរ។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះ ជឿជាក់ថា នួន ជា យ៉ាងហោចណាស់ ក៏មានហេតុផលដឹងថា អំពើប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្ត ឬគ្រោងនឹងប្រព្រឹត្តលើជនជាតិចាម។

**៥១.** អង្គជំនុំជម្រះ យល់ឃើញថា នួន ជា បានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម (ក) ឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្ស ធម៌ផ្សេងៗ ទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការជម្លៀសដោយបង្ខំអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទ

នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (ខ) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍វៀតណាម និង (គ) ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនដោយខុសច្បាប់នៅមន្ទីរសន្តិសុខ ស-២១ ប្រឆាំងនឹងបុគ្គលទាំងឡាយ ដែលត្រូវទទួលបានការការពារស្របតាមអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះ សម្រេចផ្តន្ទាទោសចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈសហឧក្រិដ្ឋរួម ត្រង់ចំណុចដែល នួន ជា មានចេតនាដោយផ្ទាល់ ចេតនារើសអើង និងចេតនាជាក់លាក់ ដូចចេតនារបស់សមាជិកសហឧក្រិដ្ឋកម្មរួមផ្សេងទៀតដែរ។

៥២. លើសពីនេះទៀត ពាក់ព័ន្ធនឹងការស្លាប់នៅសហករណ៍ ការដ្ឋានការងារ និងមន្ទីរសន្តិសុខដោយសារតែចេតនាដោយប្រយោល (ដែលមិនស្ថិតក្នុងគោលបំណងរួម) អង្គជំនុំជម្រះយល់ឃើញថា នួន ជា បានជួយ និងជំរុញឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ដែលត្រូវបានអនុវត្តដោយចេតនាដោយប្រយោល នៅសហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ ១ មករា ការដ្ឋានការងារទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការប្រព្រឹត្តរបស់ នួន ជា ត្រូវបានចាត់ទុកថា ជាទម្រង់នៃការជួយ និងជំរុញ។ គាត់បានផ្តល់ការលើកទឹកចិត្ត និងការគាំទ្រផ្លូវចិត្ត ដោយលើកទឹកចិត្តឲ្យកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា អនុវត្តគោលនយោបាយរបស់មជ្ឈិមបក្សយ៉ាងក្លៀវក្លា តាមរយៈតួនាទីដ៏សំខាន់របស់គាត់ក្នុងការឃោសនា ព្រមទាំងការបង្ហាញខ្លួនជាច្រើនលើកនៅក្នុងកិច្ចប្រជុំ និងថ្លែងសុន្ទរកថានៅក្នុងវគ្គអប់រំនៅទូទាំងប្រទេស។ អង្គជំនុំជម្រះ យល់ឃើញថា ទង្វើនេះមានឥទ្ធិពលយ៉ាងខ្លាំងលើការប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយ នួន ជា បានដឹងអំពីរឿងនេះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះ សម្រេចផ្តន្ទាទោសចំពោះការជួយ និងជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដោយចេតនាដោយប្រយោល នៅទីតាំងដែលកើតមានឧក្រិដ្ឋកម្មខាងលើទាំងនេះ។

៥៣. ជាចុងក្រោយ អង្គជំនុំជម្រះ យល់ឃើញថា នួន ជា បានប្រើអំណាចសម្រេចចិត្តចុងក្រោយជាមួយនឹង ប៉ុល ពត ហើយមានសិទ្ធិអំណាចក្នុងការដាក់វិន័យសមាជិកថ្នាក់ក្រោមនៅក្នុងបក្ស និងនៅក្នុងជួរយោធា។ ហេតុដូច្នេះ អង្គជំនុំជម្រះ យល់ឃើញថា នួន ជា ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលបានប្រព្រឹត្តឡើងតាមគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។ ឧក្រិដ្ឋកម្មទាំងនេះ រួមបញ្ចូលទាំងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជាតិពន្ធុចាម និងសាសនា។ យ៉ាងណាក៏ដោយ ដោយយល់ឃើញថា ទីមួយ នួន ជា ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះបទល្មើសទាំងនេះ តាមរយៈការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម លើកលែងតែឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិចាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តដោយចេតនាដោយប្រយោល ដូចបាន

បញ្ជាក់ច្បាស់ខាងលើ ហើយទីពីរ នួន ជា ត្រូវទទួលខុសត្រូវចំពោះការជួយ និងជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ដែលបានប្រព្រឹត្តដោយចេតនាដោយប្រយោល អង្គជំនុំជម្រះ សម្រេចផ្តន្ទាទោសក្រោមទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជាតិពន្ធុចាម និងសាសនា។ ចំពោះចំណុចផ្សេងៗទៀត អង្គជំនុំជម្រះ បានពិចារណាលើតួនាទីរបស់ នួន ជា នៅក្នុងការកំណត់ទោស។

## ១.៤.២. ការទទួលខុសត្រូវរបស់ ខៀវ សំផន

**៥៤.** នៅឆ្នាំ១៩៧១ ខៀវ សំផន បានក្លាយជាសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ហើយនៅឆ្នាំ១៩៧៦ គាត់បានក្លាយជាសមាជិកពេញសិទ្ធិ។ នៅឆ្នាំ១៩៧០ ខៀវ សំផន ត្រូវបានតែងតាំងជាអនុប្រធានរណសិរ្សរួបរួមជាតិកម្ពុជា និងជាអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា។ ជាក់ស្តែង ខៀវ សំផន ពុំមានអំណាចផ្នែកយោធាដោយផ្ទាល់នោះឡើយ ហើយ ប៉ុល ពត ឯណោះទេ ដែលទទួលបន្ទុកលើកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជានោះ។ ខៀវ សំផន ក៏បានកាន់តំណែងជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាផងដែរ។ ក្រោយពេលដួលរលំទីក្រុងភ្នំពេញ ក្នុងខែមេសា ឆ្នាំ១៩៧៥ ខៀវ សំផន បានរក្សាតួនាទីរបស់ខ្លួនជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ និងជាអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា។ ដូច្នេះហើយ គាត់បានបន្តបំពេញមុខងារការទូតមួយចំនួន ដូចជាការជួបជាមួយគណៈប្រតិភូបរទេស ដែលមកធ្វើទស្សនកិច្ចនៅកម្ពុជា និងការដឹកនាំគណៈប្រតិភូកម្ពុជាទៅធ្វើទស្សនកិច្ចនៅឯបរទេស។

**៥៥.** នៅក្នុងខែតុលា ឆ្នាំ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាបានតែង តាំង ខៀវ សំផន ឲ្យទទួលខុសត្រូវផ្នែក «រណសិរ្ស និងរាជរដ្ឋាភិបាល និងពាណិជ្ជកម្ម ខាងបញ្ជី និងតម្លៃ»។ ក្នុងអំឡុងខែតុលា ឆ្នាំ១៩៧៥ ខៀវ សំផន បានក្លាយជាសមាជិកមួយរូបក្នុងចំណោមសមាជិកពីររូបនៃមន្ទីរ ៨៧០ ដែលត្រួតពិនិត្យលើការអនុវត្តរាល់សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។ ទោះបីជាយ៉ាងណាអង្គជំនុំជម្រះ ជឿជាក់ថា ខៀវ សំផន មិនធ្លាប់បានធ្វើជាប្រធានមន្ទីរ ៨៧០ ដូចដែលគាត់ត្រូវបានចោទប្រកាន់នោះឡើយ។ នៅក្នុងខែមេសា ឆ្នាំ១៩៧៦ ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ ដែលគ្រាន់តែជាតួនាទីនិមិត្តរូបតែប៉ុណ្ណោះ ដោយគាត់ពុំមានអំណាចផ្នែកប្រតិបត្តិនោះឡើយ។ ក្នុងនាមជាប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន បានបន្តបំពេញមុខងារផ្នែកការទូត និងក្នុងពិធីការផ្សេងៗ។

**៥៦.** ខៀវ សំផន មិនធ្លាប់ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាជាផ្លូវការម្តងណាទេ ប៉ុន្តែគាត់មានវត្តមាន និងបានចូលរួមយ៉ាងទៀងទាត់នៅក្នុងកិច្ចប្រជុំផ្សេងៗ របស់គណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ដែលមានការពិភាក្សាទៅលើបញ្ហាសំខាន់ៗទាក់ទងនឹងគោលបំណងរួមនេះ។ ក្នុងនាមជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ខៀវ សំផន បានចូលរួមនៅក្នុងសន្និបាតបក្សលើកទីបី លើកទីបួន និងលើកទីប្រាំ ដែលបានអនុម័តទៅលើគោលនយោបាយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ទាក់ទងនឹងមាគ៌ានយោបាយរួម ស្របទៅនឹងគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ។ ខៀវ សំផន គឺជាសមាជិក

ពេញសិទ្ធិនៅពេល ដែលគណៈកម្មាធិការមជ្ឈិមបក្សយល់ព្រមប្រគល់ «សិទ្ធិកម្ទេច» ឲ្យទៅបក្សកុម្មុយនីស្តកម្ពុជានៅថ្នាក់ក្រោមៗ។ ក្នុងនាមជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមបក្ស ដែលមានសិទ្ធិបោះឆ្នោត ខៀវ សំផន បានចូលរួមចំណែកក្នុងការអនុម័តអនុស្សរណៈរបស់គណៈកម្មាធិការមជ្ឈិមបក្សនៅពាក់កណ្តាលឆ្នាំ១៩៧៨ ដែលធ្វើការអំពាវនាវឱ្យមានការអាណិតអាសូរចំពោះ «ជនដែលត្រូវគេបោកបញ្ឆោត» ឲ្យធ្វើជាគិញយួន ដែលនេះជាគោលនយោបាយមួយ ដែល អង្គជំនុំជម្រះ យល់ឃើញថាគ្មានឥទ្ធិពលជាក់ស្តែងនោះទេ។ អង្គជំនុំជម្រះ ជឿជាក់ថា ខៀវ សំផន មិនត្រឹមតែបានចូលរួមគាំទ្រជាមួយអ្នកផ្សេងទៅនឹងគោលបំណងរួមប៉ុណ្ណោះទេ ប៉ុន្តែគាត់ថែមទាំងបានគាំទ្រទៅលើគោលបំណងរួមនេះជាសាធារណៈ នៅគ្រប់ពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទៀតផង។

៥៧. លើសពីនេះទៀត អង្គជំនុំជម្រះ យល់ឃើញថា នៅក្នុងទម្រង់មួយដែលបានបន្តគ្រប់ពេលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានផ្សព្វផ្សាយ អះអាង និងយល់ស្របជាសាធារណៈទៅលើគោលបំណងរួមនេះ។ គាត់ជាប្រធានសន្និបាតជាតិវិសាមញ្ញមួយ ដែលបានធ្វើឡើងនៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយបានចូលរួមប្រជុំផ្សេងៗ នៅខែឧសភា ឆ្នាំ១៩៧៥ នៅវិហារព្រះកែវមរកត ក្នុងក្រុងភ្នំពេញ។ លើសពីនេះទៀត ខៀវ សំផន បានរក្សាមាគ៌ាបក្សដោយបានដឹកនាំវគ្គបំពាក់បំប៉ននៅក្នុងអង្គមីទ្ទីង និងវគ្គរៀនសូត្រ សម្រាប់អ្នកផ្សេងៗ រួមទាំងអ្នកដែលវិលត្រឡប់មកពីបរទេស និងកម្មាភិបាលក្រសួងពាណិជ្ជកម្ម ក្នុងគោលបំណងពង្រឹងស្មារតីសង្គមនិយម បង្កើតអត្តសញ្ញាណកម្មករ-កសិករ និងធ្វើឲ្យមានការគាំទ្រគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ នៅខួបអនុស្សាវរីយ៍ថ្ងៃទី១៧ ខែមេសា និងនៅព្រឹត្តិការណ៍ផ្សេងៗ ទៀត ខៀវ សំផន បានកោតសរសើរជាសាធារណៈចំពោះភាពជោគជ័យរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយបានលើកទឹកចិត្តឲ្យប្រជាជនគាំទ្រកម្មវិធីរបស់អង្គការ ក្នុងការកសាង និងការពាររបបកម្ពុជាប្រជាធិបតេយ្យ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន មិនត្រឹមតែមានការគាំទ្ររួមជាមួយអ្នកផ្សេងលើគោលបំណងរួមនេះប៉ុណ្ណោះនោះទេ ប៉ុន្តែក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ គាត់បានលើកទឹកចិត្តយ៉ាងសកម្ម យ៉ាងខ្លាំងក្លា និងជាសាធារណៈ អះអាងបញ្ជាក់ និងគាំទ្រគោលបំណងរួមនេះនៅក្នុងប្រទេស និងនៅលើឆាកអន្តរជាតិ។ លើសពីនេះទៀត តាមរយៈសុន្ទរកថា និងសេចក្តីថ្លែងការណ៍ជាសាធារណៈជាច្រើនរបស់គាត់ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានលើកទឹកចិត្ត និងញុះញង់ឱ្យមានការអនុវត្តគោលនយោបាយផ្សេងៗរបស់បក្សកុម្មុយនីស្តកម្ពុជា។

៥៨. សរុបមក អង្គជំនុំជម្រះ យល់ឃើញថា ខៀវ សំផន បានចូលរួមនៅក្នុងគោលបំណងរួម។ ក្នុងនាមជាអ្នកតំណាងឲ្យកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានគាំទ្រ និងជំរុញគោលបំណងរួមនេះ ហើយបានលើកទឹកចិត្ត ញុះញង់ និងផ្តល់ភាពស្របច្បាប់ដល់ការអនុវត្តគោលបំណងរួម តាមរយៈគោលនយោបាយឧក្រិដ្ឋ។ គាត់ក៏បានណែនាំឲ្យកម្មាភិបាលអនុវត្តគោលនយោបាយទាំងនោះ ហើយនៅពេលជាមួយគ្នានោះ គាត់បានផ្តល់លទ្ធភាព និងគ្រប់គ្រងទៅលើគោលនយោបាយទាំងនោះផងដែរ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះ យល់ឃើញថា ខៀវ សំផន បានចូលរួមចំណែកយ៉ាងសំខាន់លើការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានប្រព្រឹត្តឡើង ហើយស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។

**៥៩.** ម្យ៉ាងវិញទៀត ដូចបានរៀបរាប់ខាងលើរួចមកហើយ អង្គជំនុំជម្រះ យល់ឃើញថា ខៀវ សំផន មានចេតនារួមជាមួយនឹងសមាជិកសហឧក្រិដ្ឋកម្មផ្សេងៗ ទៀត រួមទាំង មានចេតនាជាក់លាក់ និងចេតនារើសអើងដែលជាលក្ខខណ្ឌកំណត់ ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងគោលបំណងរួម លើកលែងតែឧក្រិដ្ឋកម្មមួយប៉ុណ្ណោះ។ អង្គជំនុំជម្រះ មិនអាចកំណត់ ឬ សន្និដ្ឋានពីចេតនាប្រល័យពូជសាសន៍របស់ ខៀវ សំផន ទាក់ទងនឹងជនជាតិចាមបានឡើយ។

**៦០.** ដូច្នេះ អង្គជំនុំជម្រះ យល់ឃើញថា ខៀវ សំផន បានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម (ក) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប្រព្រឹត្ត ដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗ ទៀតក្រោមទម្រង់ជាការប្រព្រឹត្ត ដែលត្រូវបានកំណត់ថាជាការជម្លៀសដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (ខ) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជាតិ ជាតិពន្ធ និងពូជសាសន៍វៀតណាម និង (គ) ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនដោយខុសច្បាប់នៅមន្ទីរសន្តិសុខ ស-២១ ប្រឆាំងនឹងបុគ្គលទាំងឡាយ ដែលត្រូវទទួលបានការការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះ សម្រេចផ្តន្ទាទោសចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម តាមរយៈសហឧក្រិដ្ឋកម្មរួម ដែល ខៀវ សំផន មានចេតនាដោយផ្ទាល់ ចេតនារើសអើង និងចេតនាជាក់លាក់ ដូចសមាជិកសហឧក្រិដ្ឋកម្មរួមដទៃទៀតដែរ។

**៦១.** លើសពីនេះទៀត ពាក់ព័ន្ធនឹងការស្លាប់អ្នកធ្វើការ និងកសិករនៅសហករណ៍ នៅការដ្ឋានការងារ និងនៅមន្ទីរសន្តិសុខ ដោយសារតែចេតនាដោយប្រយោល (ដែលមិនស្ថិតនៅក្នុងគោលបំណងរួម) អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានជួយ និងជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតនៅសហករណ៍ត្រាំកក់ នៅការដ្ឋានការងារទំនប់ ១ មករា ការដ្ឋានការងារទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល។ ហេតុដូច្នេះ អង្គជំនុំជម្រះ យល់ឃើញថា ការប្រព្រឹត្តរបស់ ខៀវ សំផន គួរតែត្រូវចាត់ទុកថាជាទម្រង់នៃការជួយ និងជំរុញ។ គាត់បានផ្តល់ការលើកទឹកចិត្ត និងការគាំទ្រផ្នែកស្មារតី ដោយបានចូលរួមនៅក្នុងកិច្ចប្រជុំ និងមានវត្តមាន ព្រមទាំងថ្លែងសុន្ទរកថានៅក្នុងវគ្គរៀនសូត្រនៅទូទាំងប្រទេស ដោយបានលើកទឹកចិត្តយ៉ាងចំហ និងសកម្ម ហើយផ្តល់ការគាំទ្រផ្នែកស្មារតីដល់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ក្នុងការអនុវត្តគោលនយោបាយរបស់គណៈកម្មាធិការមជ្ឈិមបក្ស។ អង្គជំនុំជម្រះ យល់ឃើញថា ទង្វើទាំងនេះមានឥទ្ធិពលយ៉ាងខ្លាំងលើការប្រព្រឹត្ត

ឧក្រិដ្ឋកម្មទាំងនេះ ហើយ ខៀវ សំផន បានដឹងអំពីរឿងនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះ សម្រេចផ្តន្ទាទោសចំពោះការជួយ និងជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដោយចេតនាដោយប្រយោល នៅតាមទីតាំងដែលកើតមានឧក្រិដ្ឋកម្មខាងលើទាំងនេះ។

៦២. ជាចុងក្រោយ ភស្តុតាងពុំបានបង្ហាញដល់កម្រិតមួយ ដែលថា ខៀវ សំផន បានជួយ និងសម្របសម្រួលយ៉ាងសកម្ម លើការអនុវត្តគោលនយោបាយប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាមឡើយ។ អង្គជំនុំជម្រះ ជឿជាក់ថា ខៀវ សំផន មិនមែនជាថ្នាក់លើក្នុងន័យថា គាត់មានលទ្ធភាពទប់ស្កាត់ ឬដាក់ទណ្ឌកម្មលើការប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះ យល់ឃើញថា ខៀវ សំផន មិនត្រូវទទួលខុសត្រូវ ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជាតិពន្ធុចាម និងសាសនា នោះទេ ហើយគាត់ក៏មិនមែនជាអ្នកជួយ និងជំរុញ និងជាថ្នាក់លើដែរ។

## ១.៥. សំណងចំពោះដើមបណ្តឹងរដ្ឋប្បវេណី

៦៣. ដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន ៣.៨៦៥នាក់ ត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះ និងត្រូវបានបញ្ចូលទៅក្នុងក្រុមដើមបណ្តឹងរដ្ឋប្បវេណីតែមួយក្នុងពេលជំនុំជម្រះ ដែលតំណាងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

៦៤. អង្គជំនុំជម្រះ កត់សម្គាល់ឃើញថា ជនជាប់ចោទទាំងពីរនាក់ក្នុងសំណុំរឿង ០០២ ត្រូវបានកំណត់ថាជាជនក្រីក្រគ្មានលទ្ធភាព។ អនុលោមតាមវិធានផ្ទៃក្នុង អ.វ.ត.ក. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចស្នើឲ្យ អង្គជំនុំជម្រះសាលាដំបូង ទទួលស្គាល់នូវវិធានការសំណងជាក់លាក់នោះ។ វិធានការទាំងនោះត្រូវបានបង្កើត ឬកំណត់ឡើង ដោយមានការសម្របសម្រួលគ្នាជាមួយនឹងអង្គភាពគាំពារជនរងគ្រោះ ក្នុងគោលបំណងធ្វើឲ្យមានការទទួលស្គាល់យ៉ាងត្រឹមត្រូវចំពោះព្យសនកម្ម ដែលដើមបណ្តឹងរដ្ឋប្បវេណី បានទទួលរង ដោយសារតែការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយ ដែលកំពុងត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ និងធ្វើឲ្យមានការផ្តល់ជាអត្ថប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីជាការដោះស្រាយចំពោះព្យសនកម្មនេះ។ នៅក្នុងសំណុំរឿង ០០២/០២ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំឲ្យមានការទទួលស្គាល់តាមផ្លូវតុលាការចំពោះគម្រោងចំនួន ១៤ ថាជាសំណងសមស្របក្នុងចំណោមគម្រោងចំនួន១៨ ដែលបានស្នើសុំពីដំបូង។

៦៥. អង្គជំនុំជម្រះ យល់ឃើញថា ឧក្រិដ្ឋកម្មទាំងឡាយ ដែលជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធ បានធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះជាច្រើនផ្សេងទៀត ទទួលរងព្យសនកម្មយ៉ាងខ្លាំង ដែលមិនអាចវាស់បាន ដែលរួមមាន ការឈឺចាប់ផ្នែករាងកាយ ការខាតបង់ផ្នែកសេដ្ឋកិច្ច ការបាត់បង់សេចក្តីថ្លៃថ្នូរ ការបាក់ស្បាតផ្លូវចិត្ត និងសេចក្តីទុក្ខព្រួយដោយសារតែការព្រាត់ប្រាសនិរាសសមាជិកគ្រួសារ ឬសាច់ញាតិលោហិត។

៦៦. អង្គជំនុំជម្រះ យល់ឃើញថា គម្រោងខាងក្រោមនេះស្របតាមលក្ខខណ្ឌតម្រូវនៃវិធាន២៣ ស្ទួនបួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក. ហេតុដូច្នេះ អង្គជំនុំជម្រះ សម្រេចទទួលយកគម្រោងទាំងនេះ។ គម្រោងទី១ គម្រោងទី២

និងគម្រោងទី៣ ពាក់ព័ន្ធនឹងទម្រង់នៃការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានគោលបំណងមិនឲ្យរបបបែបនេះកើតឡើងសាជាថ្មី។ គម្រោងទី៤ គម្រោងទី៥ គម្រោងទី៦ និងគម្រោងទី១២ គឺការចងក្រងឯកសារស្តីពី បទពិសោធន៍របស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងជនរងគ្រោះ ដែលទទួលរងការប៉ះពាល់ដោយការប្រព្រឹត្តលើជនជាតិចាម ការប្រព្រឹត្តលើជនជាតិវៀតណាម និងការចេញបទបញ្ជា ស្តីពីការរៀបអាពាហ៍ពិពាហ៍ ដើម្បីទប់ស្កាត់ការកើតឡើងវិញនៃឧក្រិដ្ឋកម្ម ដែលកំណត់គោលដៅទៅលើក្រុមទាំងនេះ។ គម្រោងទី៧ គម្រោងទី៨ គម្រោងទី៩ និងគម្រោងទី១០ រម្លឹកពីការចងចាំអំពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចឲ្យសង្គមទូទៅដឹងរឿងរ៉ាវទាំងនេះ ដែលផ្តល់ជាមធ្យោបាយធ្វើឲ្យពួកគាត់អាចមានការស្ងប់អារម្មណ៍។ គម្រោងទី១១ និងផ្នែកស្តីពីការថែទាំសុខភាពនៃគម្រោងទី១៣ ផ្តល់ការថែទាំសុខភាពផ្លូវចិត្ត និងផ្លូវកាយទៅដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្តោតលើការស្តារនីតិសម្បទា។

**៦៧.** អង្គជំនុំជម្រះ យល់ឃើញថា ផ្នែកជាក់លាក់មួយនៃគម្រោងទី១៣ ដែលទាក់ទងនឹងការគាំទ្រផ្នែកជីវភាព មានបំណងផ្តល់អត្ថប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងទម្រង់សំណងជាថវិកាផ្ទាល់ទៅបុគ្គលម្នាក់ៗ។ ដោយសារតែការផ្តួចផ្តើមទាំងនេះស្ថិតនៅក្រៅវិសាលភាពនៃវិធាន ២៣ ស្ទួនបួន (១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក. ដែលចែងថា អង្គជំនុំជម្រះ អាចផ្តល់ត្រឹមតែសំណងផ្លូវចិត្ត និងជាសមូហភាពតែប៉ុណ្ណោះ ហើយមិនមានសំណងជាថវិកាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ហេតុដូច្នេះហើយ អង្គជំនុំជម្រះ មិនអាចអនុម័តទៅលើគម្រោងទាំងនេះ ថាជាវិធានការសំណងបានឡើយ។ លើសពីនេះទៅទៀត អង្គជំនុំជម្រះមិនអាចអនុម័តទៅលើគម្រោងទី១៥ ដែលចង់ឲ្យមានការទទួលស្គាល់លើការឈឺចាប់ ដែលជនជាតិដើមភាគតិចនៅខេត្តរតនគិរី និងខេត្តមណ្ឌលគិរី បានទទួលរង ដោយសារតែការមាក់ងាយ ការរើសអើង និងការធ្វើទុក្ខបុកម្នេញបានឡើយ។ អង្គជំនុំជម្រះ រម្លឹកថា សំណុំរឿង ០០២/០២ មិនមានការចោទប្រកាន់ទាក់ទងនឹងការកំណត់គោលដៅ ការរើសអើង ឬការធ្វើទុក្ខបុកម្នេញលើជនជាតិភាគតិចដែលរស់នៅក្នុងខេត្តរតនគិរី និងខេត្តមណ្ឌលគិរីឡើយ។ ទោះបីជាបានទទួលស្គាល់អំពីគុណតម្លៃនៃគម្រោងនេះក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា គម្រោងនេះមិនបំពេញតាមលក្ខខណ្ឌនៃវិធាន ២៣ ស្ទួនបួន (១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក. នោះទេ គឺថាវិធានការសំណង ត្រូវទទួលស្គាល់ថា វាជាព្យសនកម្មដែលកើតមានឡើងដោយសារតែការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលជនជាប់ចោទត្រូវបានផ្តន្ទាទោសប៉ុណ្ណោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះ បដិសេធការអនុម័តលើគម្រោងនេះ។

**៦៨.** សេចក្តីសង្ខេបនៃសំអាងហេតុរបស់ អង្គជំនុំជម្រះចប់ត្រឹមនេះ ហើយជាបន្ត យើងនឹងអានផ្នែកសេចក្តីសម្រេច។

## ១.៦. ផ្នែកសេចក្តីសម្រេច និងការផ្តន្ទាទោស

**៦៩.** អង្គជំនុំជម្រះ បដិសេធសំណើរបស់ក្រុមមេធាវីការពារក្តី **ខៀវ សំផន** ដែលសុំឲ្យកម្រិតវិសាលភាពនៃសំណុំរឿង ០០២/០២។

៧០. អង្គជំនុំជម្រះ សម្រេចផ្លាស់ប្តូរការកំណត់បទចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការសម្លាប់រង្គាលទៅជាការធ្វើមនុស្សឃាត ដោយរួមបញ្ចូលចេតនាដោយប្រយោល ពាក់ព័ន្ធនឹងការស្លាប់ដែលបានកើតឡើងក្រោមលក្ខខណ្ឌ និងកាលៈទេសៈនានា ដែលត្រូវបានប្រព្រឹត្តទៅលើជនរងគ្រោះនៅតាមទីតាំងឧក្រិដ្ឋកម្មដូចតទៅនេះ៖ សហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ ១ មករា ការដ្ឋានការងារទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល។

៧១. អង្គជំនុំជម្រះសាលាដំបូង រកឃើញថា ជនជាប់ចោទ **នួន ជា** មានពិរុទ្ធ ដែលបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជា ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដូចបានរៀបរាប់ដោយសង្ខេបខាងលើ និងដោយលម្អិតនៅក្នុងសាលក្រមជាលាយលក្ខណ៍អក្សរ តាមរយៈអំពើសកម្ម និងអកម្ម ចំពោះឧក្រិដ្ឋកម្មទាំងឡាយដូចខាងក្រោម ៖

- **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ** តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗ ទៀតក្រោម ទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ អំពើអមនុស្សធម៌ ផ្សេងៗ ទៀតក្រោមទម្រង់ជាការប្រព្រឹត្ត ដែលត្រូវបានកំណត់ថាជាការជម្លៀសដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗ ទៀតក្រោមទម្រង់ជាការប្រព្រឹត្ត ដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អនុលោមតាមបទប្បញ្ញត្តិមាត្រា ៥ និង មាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

- **ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ** តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ អនុលោមតាមមាត្រា ៦ និងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

- **ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍** តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជនជាតិ វៀតណាម និងជនជាតិចាម អនុលោមតាមមាត្រា ៤ និងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

៧២. អង្គជំនុំជម្រះសាលាដំបូង រកឃើញថា ជនជាប់ចោទ **ខៀវ សំផន** មានពិរុទ្ធ ដែលបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជា ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដូចបានរៀបរាប់ដោយសង្ខេបខាងលើ និងដោយលម្អិតនៅក្នុងសាលក្រមជាលាយលក្ខណ៍អក្សរ តាមរយៈអំពើសកម្ម និងអកម្ម ចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដូចខាងក្រោម៖

- **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ** តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្ត ដែលត្រូវបានកំណត់ថាជាការជម្លៀសដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អនុលោមតាមបទប្បញ្ញត្តិមាត្រា ៥ និងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.។

- **ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ** តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់អនុលោមតាមមាត្រា ៦ និងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.។

- **ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍** តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជនជាតិ វៀតណាម អនុលោមតាមមាត្រា ៤ និងមាត្រា ២៩ (ថ្មី) នៃច្បាប់ស្ដីពីការ បង្កើត អ.វ.ត.ក.។

៧៣. អង្គជំនុំជម្រះរកឃើញថា ជនជាប់ចោទ **នួន ជា** និង **ខៀវ សំផន** មិនមានពិរុទ្ធចំពោះបទចោទផ្សេងទៀតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចឲ្យជនជាប់ចោទទាំងពីរនាក់រួចផុតពីបទចោទប្រកាន់ទាំងនេះ។

៧៤. អង្គជំនុំជម្រះ បានពិចារណាទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម រួមទាំងទំហំ និងភាពសាហាវព្រៃផ្សៃ ក៏ដូចជាចំនួន និងភាពទន់ខ្សោយរបស់ជនរងគ្រោះ ដែលជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធ រួមទាំងស្ថានទម្ងន់ទោស និងស្ថានសម្រាលទោសនានាដែលពាក់ព័ន្ធ។

៧៥. អនុលោមតាមមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. អង្គជំនុំជម្រះសម្រេចផ្ដន្ទាទោសជនជាប់ចោទ **នួន ជា** ដាក់ពន្ធនាគារ **អស់មួយជីវិត**។ ដោយពិចារណាទៅលើការផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះគាត់ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះ រួមបញ្ចូលគ្នានូវការផ្ដន្ទាទោសទាំងពីរ ទៅជាការផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតតែមួយ ។

៧៦. អនុលោមតាមមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. អង្គជំនុំជម្រះសម្រេច ផ្ដន្ទាទោសជន

ជាប់ចោទ **ខៀវ សំផន** ដាក់ពន្ធនាគារអស់មួយជីវិត។ ដោយពិចារណាទៅលើការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះគាត់ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះរួមបញ្ចូលគ្នានូវការផ្តន្ទាទោសទាំងពីរ ទៅជាការផ្តន្ទាទោសដាក់ពន្ធនាគារ **អស់មួយជីវិត** តែមួយ ។

៧៧. ប្រកាសថា ដើមបណ្តឹងរដ្ឋប្បវេណី ដែលរួមបញ្ចូលជាក្រុម ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ដែលជាឧបសម្ព័ន្ធ២ ពិតជាបានទទួលរងព្យសនកម្ម ដែលជាផលវិបាកដោយផ្ទាល់ ដែលកើតចេញពីឧក្រិដ្ឋកម្មដែល នួន ជា និង ខៀវ សំផន ត្រូវបានរកឃើញថាមានពិរុទ្ធ និងដោយអនុលោមតាមវិធាន ២៣ ស្ទួនបួន (ខ)(៣) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. អង្គជំនុំជម្រះសម្រេចទទួលយកផ្នែកខ្លះនៃសំណើសុំសំណងផ្លូវចិត្ត និងជាសមូហភាព ដូចមានចែងលម្អិតនៅក្នុងផ្នែកទី២១ នៃសាលក្រមជាលាយលក្ខណ៍អក្សរ អង្គជំនុំជម្រះ សម្រេចទទួលយកនូវគម្រោងសំណង ដែលមានលក្ខណៈសមស្រប និងដែលអាចអនុវត្តបាន ចំនួន ១៣គម្រោង ដែលទាក់ទងនឹងទិវានៃការចងចាំចំពោះជនរងគ្រោះ និងពិធីរម្លឹកផ្សេងៗ ចំពោះការឈឺចាប់ដែលពួកគាត់បានទទួលរង វិធីព្យាបាលតាមរយៈការចងក្រងនូវសក្ខីកម្ម និងការព្យាបាលជំងឺផ្លូវចិត្តដល់ជនរងគ្រោះ និងការតាំងពិព័រណ៍ឯកសារ និងគម្រោងអប់រំ។ អង្គជំនុំជម្រះ សម្រេចបដិសេធគម្រោងសំណង ដែលបានស្នើសុំចំនួន២ (មួយបដិសេធទាំងស្រុង និងមួយទៀតបដិសេធផ្នែកខ្លះ) ដែលមិនស្របតាមលក្ខខណ្ឌតម្រូវនៃវិធាន ២៣ ស្ទួនបួន(ខ)(៣) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. ដូចមានចែងលម្អិតនៅក្នុងផ្នែកទី២១ នៃសាលក្រមជាលាយលក្ខណ៍អក្សរ។

៧៨. សាលក្រមនេះ ប្រកាសជាសាធារណៈនៅក្នុងសាលសវនាការជំនៃ អ.វ.ត.ក. ក្នុងរាជធានីភ្នំពេញ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

៧៩. សាលក្រមនេះបើកផ្លូវឲ្យភាគីប្តឹងសាទុក្ខអនុលោមតាមវិធានផ្ទៃក្នុង។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថា អនុលោមតាមវិធាន១០៧(៤) នៃវិធានផ្ទៃក្នុង និងមាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក. រយៈពេលកំណត់សម្រាប់ការដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ ប្រសិនបើមាន នឹងត្រូវចាប់ផ្តើមរាប់មួយថ្ងៃបន្ទាប់នៃថ្ងៃប្រក្រតីទិន ក្រោយពីការបញ្ជូននូវការជូនដំណឹងពីសាលក្រមជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុពេញលេញជាភាសាខ្មែរ និងភាសាផ្លូវការណាមួយផ្សេងទៀតរបស់ អ.វ.ត.ក. ដែលភាគីនីមួយៗ បានជ្រើសរើស ដោយអនុលោមទៅតាមមាត្រា ២.២ នៃសេចក្តីណែនាំអនុវត្ត។

៨០. លោកចៅក្រម **យូរ ឧត្តរា** មានមតិដោយឡែកពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលមានភ្ជាប់ជាមួយនឹងសាលក្រម។

៨១. អង្គជំនុំជម្រះប្រកាសបិទបញ្ចប់សវនាការលើសំណុំរឿង ០០២/០២ ។



# ៨. សេចក្តីសង្ខេប នៃសាលដីកា សំណុំរឿង ០០២/០២

# សេចក្តីសង្ខេបនៃសាលដីកា សំណុំរឿង ០០២/០២



១. ដំណើរការនិតិវិធី

២. តុលាការចាប់ផ្តើម៖ ម៉ោង ០៩ និង ៣០ នាទី ព្រឹក

៣. ប្រធាន៖ ថ្ងៃនេះ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យបន្តប្រកាសសាលដីកាស្តាពរលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន និងសហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០២។ សូមក្រឡាបញ្ជីរាយការណ៍ពីវត្តមានរបស់ភាគី និងមេធាវី។

៤. ក្រឡាបញ្ជី៖ រាយការណ៍វត្តមានរបស់ភាគី និងមេធាវី

៥. ប្រធាន៖ រឿងក្តីបច្ចុប្បន្ន ហៅថា «សំណុំរឿង ០០២/០២» ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ព្រៃផ្សៃបំផុតមួយចំនួនដែលបានកើតឡើងក្នុងចំណោមមហាសោកនាដកម្ម និងមហន្តរាយក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។ នៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ បក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានស្គាល់ថា ជាខ្មែរក្រហម បានគ្រប់គ្រងប្រទេសកម្ពុជា ដែលក្រោយមកត្រូវបានប្តូរទៅជាកម្ពុជាប្រជាធិបតេយ្យ។ ក្រោយពីដណ្តើមបានអំណាច បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តបដិវត្តសង្គមនិយមទូទាំងប្រទេសតាមរយៈទ្រឹស្តី «មហាលោតផ្លោះមហាអស្ចារ្យ» ក្នុងគោលបំណងកសាងប្រទេស ការពារពីខ្មាំងសត្រូវ និងកែប្រែប្រជាជនទាំងស្រុងឱ្យក្លាយជាសង្គមកម្មករកសិករខ្មែរមួយដូចៗគ្នា និងគ្មានការប្រតិបត្តិសាសនា។ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនស៊ីវិលត្រូវបានដកសិទ្ធិសេរីភាពជាមូលដ្ឋាន និងដាក់ឱ្យស្ថិតក្រោមអំពើឃោរឃៅហួសប្រមាណ ដែលរីករាលដាល។ វប្បធម៌ភ័យខ្លាចមានអត្ថិភាពគ្រប់ទីកន្លែង តាមរយៈការសម្លាប់ទ្រង់ទ្រាយធំ ការធ្វើទារុណកម្ម អំពើហិង្សា ការធ្វើទុក្ខបុកម្នេញ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការធ្វើការដោយបង្ខំ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងអំពើអមនុស្សធម៌ដទៃទៀត។ ក្រោមការគ្រប់របស់បក្សកុម្មុយនីស្តកម្ពុជា ដែលស្ថិតក្នុងចំណោមរបបឃោរឃៅហួសហេតុជាងគេបំផុតក្នុងសតវត្សទីម្ភៃ បានបណ្តាលឱ្យមានការបាត់បង់ជីវិតប្រជាជនកម្ពុជាប្រមាណពី ១,៥ ទៅ ២ លាននាក់។

៦. រឿងក្តីនេះមានទំហំធំធេង និងស្មុគស្មាញ។ ការបំបែកដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ តម្រូវឱ្យមានការជំនុំជម្រះពីរបន្តបន្ទាប់គ្នាលើបទចោទដាច់ដោយឡែកពីគ្នាសម្រាប់ជនជាប់ចោទបួននាក់ដូចគ្នា ដែលវិធានការនេះធ្វើឡើងសម្រាប់គោលបំណងនៃការគ្រប់គ្រងការជំនុំជម្រះ ព្រមទាំងបញ្ហាសុខភាព និងវ័យចាស់ជរារបស់ជនជាប់ចោទ។ ជនជាប់ចោទបីនាក់ក្នុងចំណោមបួននាក់ ដែលត្រូវបានចោទប្រកាន់កន្លងមកបានទទួលមរណភាព។ ឯកសារភាគច្រើនក្នុងសំណុំរឿងត្រូវបានបកប្រែជាបីភាសាផ្លូវការរបស់ អ.វ.ក.ត.។ ក្រៅពីការប្រឈមជាច្រើននេះ ពិភពលោកបានជួបប្រទះបញ្ហាជំងឺឆ្លង COVID-19 ដែលតម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងលក្ខណៈបទបែន និងផ្នែប្រឹងខិតពីសំណាក់បុគ្គលិកនីមួយៗ នៃស្ថាប័នតុលាការក្នុងការបន្តនីតិវិធីរឿងក្តីនេះ ឱ្យដំណើរការទៅមុខដោយគ្មានការអាក់ខាន ក្នុងការចេញសាលដីកានេះ។

៧. អាស្រ័យហេតុនេះ បញ្ហាផ្នែកនីតិវិធី ផ្នែកអង្គហេតុ និងអង្គច្បាប់ដែលអាចប្តឹងសាទុក្ខបាន ត្រូវបានពិចារណាត្រឹមត្រូវ និងសម្រេចដោយចៅក្រមទាំងអស់នៃ អង្គជំនុំជម្រះតុលាការកំពូល។ បន្ថែមលើនេះ ដោយពិចារណាលើបញ្ហាសុខភាព និងវ័យចាស់ជរារបស់ជនជាប់ចោទ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា ជាការចាំបាច់ក្នុងការធានាថា សាលដីកាត្រូវប្រកាសឱ្យបានឆាប់រហ័ស។

៨. សាលដីកាក្នុងរឿងក្តីនេះ ជាប់ពាក់ព័ន្ធទៅនឹង ខៀវ សំផន ដែលត្រូវបានរកឃើញថាបានទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌសម្រាប់តួនាទីរបស់គាត់ ពាក់ព័ន្ធទៅនឹងខ្មែរក្រហម ក្រោយពីការជំនុំជម្រះរយៈពេលយ៉ាងយូរ។ សាលដីកានេះមានកម្រាស់រាប់រយទំព័រ។ សូមប្រកាសសេចក្តីសង្ខេបដែលគូសបញ្ជាក់តែការយល់ឃើញសំខាន់ៗ និងការសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូល ក្នុងផ្នែកសម្រេចសេចក្តីនៃរឿងក្តីនេះប៉ុណ្ណោះ។ សាលដីកាពេញលេញនឹងមានតាមក្រោយក្នុងពេលឆាប់ៗ បន្ទាប់ពីដំណើរការនៃការកែសម្រួល និងការបកប្រែត្រូវបានបញ្ចប់។ មានតែសាលដីកាជាលាយលក្ខណ៍អក្សរមានសំអាងហេតុពេញលេញប៉ុណ្ណោះ ដែលមានអានុភាពចងកាតព្វកិច្ចផ្លូវច្បាប់។

៩. ខៀវ សំផន បានកើតនៅក្នុងខេត្តស្វាយរៀងក្នុងឆ្នាំ ១៩៣១ និងមានអាជីពជាអ្នកនយោបាយល្បីល្បាញដ៏យូរលង់ក្នុងកម្ពុជា។ គាត់បានក្លាយជាសមាជិកនៃក្រុមអ្នកឆ្វេងនិយមបញ្ញវន្តខ្មែរ ដែលសិក្សានៅទីក្រុងប៉ារីសក្នុងទសវត្សរ៍ ១៩៥០ ខណៈពេលដែលគាត់កំពុងបន្តការសិក្សានៅសាកលវិទ្យាល័យថ្នាក់បណ្ឌិតក្នុងប្រទេសបារាំង។ នៅចុងក្រោយ គាត់បានលេចធ្លោយ៉ាងឆាប់រហ័ស ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ កាន់កាប់តួនាទីជាន់ខ្ពស់នានាក្នុងបក្សកុម្មុយនីស្តកម្ពុជា រួមទាំងជាប្រធានគណៈប្រធានរដ្ឋ និងជាប្រមុខរដ្ឋ។

១០. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. បានចេញសាលក្រមរបស់ខ្លួនក្នុងសំណុំរឿង ០០២/០២ ជាសេចក្តីសង្ខេប និងបានជូនដំណឹងដល់ភាគីនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ដោយបានយល់ឃើញថា ខៀវ សំផន មានពិរុទ្ធភាពពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត អំពើសម្លាប់រង្គាល ការនិរទេស ការដាក់ឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ សាសនា និងពូជសាសន៍ និងអំពើអមនុស្សធម៌ដទៃទៀត ដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការធ្វើឱ្យបាត់ខ្លួន

ដោយបង្ខំ ការផ្លាស់ទីដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធភាពផងដែរពីបទប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកក្រុមជនជាតិវៀតណាម និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដូចជាអំពើមនុស្សឃាតគិតទុកជាមុន ការធ្វើទារុណកម្ម ការធ្វើបាបដែលបង្កដោយចេតនានូវព្យសនកម្ម ឬការឈឺចាប់ធ្ងន់ធ្ងរលើរូបកាយ ឬសុខភាព និងការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ និងទៀងទាត់ និងការឃុំឃាំងខុសច្បាប់ជនស៊ីវិល។

១១. អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា បើទោះបីជា ខៀវ សំផន ពុំបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះដោយផ្ទាល់ក៏ដោយ ក៏គាត់ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងនេះ ដោយសារជាផ្នែកនៃសហឧក្រិដ្ឋរួម និងតាមរយៈការជួយទំនុកបម្រុង។ អង្គជំនុំជម្រះសាលាដំបូង បានដាក់ទោស ខៀវ សំផន ជាប់ពន្ធនាគារអស់មួយជីវិត រួមបញ្ចូលគ្នាជាមួយទោសមួយជីវិត ដែលបានដាក់នៅក្នុងសំណុំរឿង ០០២/០១ និងបានបង្គាប់ថា ជនជាប់ចោទត្រូវទទួលទោសទាំងនេះត្រួតគ្នាតែមួយ។ អង្គជំនុំជម្រះសាលាដំបូង បានទទួលយកផ្នែកខ្លះនៃសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំសំណងផ្លូវចិត្តនិងសមូហភាព ព្រមទាំងបានយល់ព្រមទៅលើការសាងសង់ស្តូបរម្លឹកការចងចាំតាមឃុំជាក់លាក់ចំនួន ១៣ គម្រោង។

១២. ខៀវ សំផន និងសហព្រះរាជអាជ្ញា បានដាក់សារណាបណ្តឹងសាទុក្ខ និងសារណាតបរៀងៗខ្លួន ហើយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សារណាជាលាយលក្ខណ៍អក្សរជំនួសឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

១៣. នៅបណ្តឹងសាទុក្ខ ខៀវ សំផន បានលើកឡើងថា សាលក្រមអង្គជំនុំជម្រះសាលាដំបូង មានកំហុសប្រមាណជា ១.៨២៤ និងបានជំទាស់ទៅនឹងសាលក្រម អង្គជំនុំជម្រះសាលាដំបូង ទាំងមូល។ ចំណោះបញ្ហានេះ គាត់បានចោទប្រកាន់កំហុសក្នុងការចេញ និងការប្រកាសសាលក្រមដោយ អង្គជំនុំជម្រះសាលាដំបូង ដំបូង និងបានចោទប្រកាន់កំហុសផងដែរពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី វិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ និងការជំនុំជម្រះ បទឧក្រិដ្ឋមូលដ្ឋាន និងបញ្ហានៃការទទួលខុសព្រហ្មទណ្ឌជាលក្ខណៈបុគ្គល។ គាត់បានអះអាងថា កំហុសនោះតម្រូវឱ្យបដិសេធការដាក់ពិរុទ្ធភាព និងទោស ដែលបានប្រកាសលើគាត់។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ខៀវ សំផន ពុំបាន ជំទាស់ដោយជាក់លាក់ចំពោះការយល់ឃើញរបស់ អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងបទចោទអំពើរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុហ្សឺណែវនោះឡើយ។ ទោះបីជានៅក្នុងបណ្តឹងសារទុក្ខរបស់គាត់បានលើកយកបញ្ហាជាច្រើនដោយបានចោទប្រកាន់ថា កំហុសទាក់ទងនឹងសុច្ចរិតភាពទូទៅនៃកិច្ចដំណើរការនីតិវិធីចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង ក៏ត្រូវសំដៅផងដែរចំពោះការពិចារណារបស់ អង្គជំនុំជម្រះ ទាក់ទងនឹងបទចោទនេះក៏ដោយ ក៏បណ្តឹងសាទុក្ខរបស់គាត់ ដែលពាក់ព័ន្ធទៅនឹងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវបានកម្រិតត្រឹមកំហុស ដែលរងការចោទប្រកាន់ទាំងនោះតែប៉ុណ្ណោះ។ សហព្រះរាជអាជ្ញា បានលើកទឡ្ហីករណ៍តែមួយគត់នៃបណ្តឹងសាទុក្ខដោយបានជំទាស់ទៅនឹងការសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលថា ការ

រួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំពុំមែនជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀត ក្នុងករណីដែលជនរងគ្រោះជាបុរស។

**១៤.** អង្គជំនុំជម្រះតុលាការកំពូល បានស្តាប់សារណាផ្ទាល់មាត់របស់ភាគីលើបណ្តឹងសាទុក្ខនៅថ្ងៃទី១៦ ដល់ ១៩ ខែសីហា ឆ្នាំ២០២១។ បន្ទាប់មក អង្គជំនុំជម្រះ បានថយទៅធ្វើការពិភាក្សាសម្រេច ហើយនៅថ្ងៃនេះ អង្គជំនុំជម្រះ ចេញសាលដីការបស់ខ្លួនលើបណ្តឹងសាទុក្ខទាំងពីរ ដែលនឹងប្រកាសរួមជាមួយគ្នាដោយសារត្រូវបានបញ្ចប់ពេញលេញក្នុងសាលដីកាជាលាយលក្ខណ៍អក្សរ។ ដោយសារការជំទាស់នៃបណ្តឹងសាទុក្ខមានចំនួនច្រើន ដែលបានលើកឡើងដោយ ខៀវ សំផន នៅក្នុងសវនាការនេះ សូមប្រកាសតែសេចក្តីសង្ខេបនៃការយល់ឃើញ និងការសម្រេចទាក់ទងទៅនឹងការជំទាស់ទាំងនេះ ដែលមានលក្ខណៈចម្បងចម្រាស់ជាពិសេសប៉ុណ្ណោះ។ ការយល់ឃើញ និងការសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូលទាក់ទងទៅនឹងបណ្តឹងសាទុក្ខទាំងពីរនេះ ត្រូវបានបង្ហាញនៅក្នុងសាលដីកាពេញលេញជាលាយលក្ខណ៍អក្សរ ដែលនឹងជូនដំណឹងក្នុងពេលសមស្រប។ ខ្ញុំសូមបញ្ជាក់សាជាថ្មីថា មានតែសាលដីកាពេញលេញជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ ដែលមានអានុភាពផ្លូវច្បាប់។

**១៥.** ការសង្ខេបនៃការជំទាស់របស់ ខៀវ សំផន លើបណ្តឹងសាទុក្ខនឹងត្រូវដោះស្រាយតាមលំដាប់លំដោយខាងក្រោម។

## ការចោទប្រកាន់កំហុសទាក់ទងទៅនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី

**១៦.** ជាបញ្ហាបឋម ខៀវ សំផន បានជំទាស់ថា តាមរយៈការខកខានក្នុងការចេញសាលក្រមជាលាយលក្ខណ៍អក្សរមានសំអាងហេតុពេញលេញ នៅថ្ងៃដែលសេចក្តីសម្រេចសង្ខេបសាលក្រមត្រូវបានប្រកាស អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ធ្ងន់ធ្ងរដែលធ្វើឱ្យការប្រកាសសាលក្រមនោះគ្មានសុពលភាព និងមិនគោរពតាមវិធានបញ្ញត្តិ។ បន្ថែមលើនេះ គាត់បានអះអាងថា ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តហួសវិសាលភាពនៃការជំនុំជម្រះរបស់ខ្លួននៅពេលដែលសាលក្រមមានសំអាងហេតុពេញលេញត្រូវបានជូនដំណឹង និងថា អាស្រ័យហេតុនេះ ផ្នែកដទៃទៀតនៃបណ្តឹងសាទុក្ខរបស់គាត់ត្រូវចាត់ទុកជាអសារបង់ ពីព្រោះពិរុទ្ធភាព ឬភាពគ្មានទោសរបស់គាត់ពុំត្រូវបានជំនុំជម្រះត្រឹមត្រូវតាមច្បាប់។

**១៧.** អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ថា ខៀវ សំផន បានដឹងច្បាស់លាស់ពីចេតនារបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការចេញសាលក្រមសង្ខេប ដែលសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរនឹងត្រូវជូនដំណឹងតាមក្រោយ។ អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងជាសាធារណៈអំពីចេតនារបស់ខ្លួន និងបានផ្តល់ពេលវេលាគ្រប់គ្រាន់ដល់ភាគី ជាពិសេសជនជាប់ចោទក្នុងការលើកការជំទាស់ណាមួយ ប៉ុន្តែពុំមានការលើកនោះឡើយ។ វិធាន ១០២(១) នៃវិធានផ្ទៃក្នុងចែងថា សាលក្រមត្រូវតែចេញ និងប្រកាសក្នុងសវនាការសាធារណៈមួយ និងថា សេចក្តីសង្ខេបនៃការយល់ឃើញ និងផ្នែកសម្រេចសេចក្តីត្រូវតែអានខ្លាំងដោយប្រធាន ឬចៅក្រមនៃអង្គជំនុំជម្រះនោះ។ វិធានដូចគ្នានេះបានចែងផងដែរថា ក្រឡាបញ្ជីត្រូវផ្តល់ច្បាប់ចម្លងនៃសាលក្រមដល់ភាគី និងជានាថា សាលក្រមត្រូវបាន

ផ្សព្វផ្សាយដោយការិយាល័យរដ្ឋបាលតាមមធ្យោបាយសមស្រប។ ទោះជាយ៉ាងណាក្តី ពុំមានការចែងជាក់លាក់ថា ការផ្តល់ ឬការផ្សព្វផ្សាយសាលក្រមត្រូវតែធ្វើឡើងក្នុងថ្ងៃតែមួយនៃសវនាការជាសាធារណៈនោះឡើយ។ ជាក់ស្តែង នេះជាការអនុវត្តន៍ធម្មតាក្នុងរឿងក្តីព្រហ្មទណ្ឌអន្តរជាតិដែលមានទំហំបែបនេះ ដែលត្រូវចេញសាលក្រមសង្ខេបផ្ទាល់មាត់ជាមុន ដោយអនុញ្ញាតឱ្យការបញ្ចប់នូវការកែសម្រួល និង/ឬ ដំណើរការនៃការបកប្រែពេញលេញ។

១៨. សាលក្រមអង្គជំនុំជម្រះសាលាដំបូង ត្រូវបានចេញ និងប្រកាសស្របតាមច្បាប់នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ជាទម្រង់សេចក្តីសង្ខេប បើទោះបីជាសាលក្រមពេញលេញជាលាយលក្ខណ៍អក្សរត្រូវបានជូនដំណឹង និងផ្សព្វផ្សាយនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។ សិទ្ធិរបស់ ខៀវ សំផន ក្នុងការពិនិត្យលើសេចក្តីសម្រេចដែលជាមូលដ្ឋាននៃការដាក់ពិរុទ្ធភាព និងការដាក់ទោសលើរូបគាត់ នៅតែមានសុពលភាពទាំងស្រុងក្រោយពេលការជូនដំណឹង និងការផ្សព្វផ្សាយសាលក្រម ដូចបានបង្ហាញតាមរយៈការជំនុំជម្រះបច្ចុប្បន្នលើបណ្តឹងសាទុក្ខរបស់គាត់ប្រឆាំងនឹងសាលក្រម អង្គជំនុំជម្រះសាលាដំបូង នេះ។ អាស្រ័យហេតុនេះ សារណារបស់ ខៀវ សំផន ទាក់ទងនឹងបញ្ហានេះត្រូវបដិសេធចោល។

១៩. ខៀវ សំផន បានលើកឡើងបន្ថែមថា ពេញមួយអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០២ «សិទ្ធិជាមូលដ្ឋានរបស់គាត់ដែលត្រូវបានទទួលស្គាល់ដោយក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក. ពុំត្រូវបានគោរពដោយសារលទ្ធផលនៃវិធីសាស្ត្រលម្អៀងរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តគោលការណ៍ណែនាំនៃកិច្ចដំណើរការនីតិវិធី និងវិធានស្តីពីភស្តុតាង»។ ខៀវ សំផន អះអាងថា វិធីសាស្ត្រ ដែលមានកំហុសជាមូលដ្ឋានបាននាំឱ្យអង្គជំនុំជម្រះសាលាដំបូងរំលោភបំពានដដែលៗ លើសិទ្ធិភាគច្រើនរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះត្រឹមត្រូវ ដែលបណ្តាលឱ្យមានកំហុសជាច្រើនក្នុងអំឡុងពេលនៃការជំនុំជម្រះ។ ការចោទប្រកាន់របស់គាត់អំពីភាពលម្អៀងបានពន្លាតបន្ថែមដល់ការបំបែកសំណុំរឿង ០០២ របស់អង្គជំនុំជម្រះសាលាដំបូង។ គាត់បានអះអាងថា អានុភាពត្រួតគ្នាកំហុសទាំងនេះ បានធ្វើឱ្យការជំនុំជម្រះទាំងមូលទៅជាមិនយុត្តិធម៌ និងបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលបដិសេធការដាក់ពិរុទ្ធភាព និងទោសរបស់គាត់។

២០. ខាងក្រោមនេះ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ថា ពាក់ព័ន្ធទៅនឹងការអះអាងរបស់គាត់អំពីភាពលម្អៀងពីសំណាក់អង្គជំនុំជម្រះសាលាដំបូង ខៀវ សំផន បានលើកច្រំដែលនូវការចោទប្រកាន់របស់គាត់ពីមុនដែលថា សាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ បានបុរេវិនិច្ឆ័យពិរុទ្ធភាពរបស់គាត់ក្នុងសំណុំរឿង ០០២/០២ និងបានអះអាងថា ជាការដែលពុំអាចធ្វើទៅបានសម្រាប់អង្គជំនុំជម្រះសាលាដំបូង ក្នុងការមិនអើពើទៅលើការសម្រេចរបស់ខ្លួនក្នុងរឿងក្តីពីមុន នៅពេលសម្រេចថាតើត្រូវជំនុំជម្រះសំណុំរឿងបន្តបន្ទាប់ដូចម្តេច។ ទាំងនេះពុំមែនជាបញ្ហាថ្មីនោះទេ និងកន្លងមកជាកម្មវត្ថុនៃសំណើរបស់ ខៀវ សំផន សុំដិតចិត្តចៅក្រមអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលក្នុងឆ្នាំ ២០១៤ និង ២០១៩ ផ្សេងៗគ្នា។ ក្រុមប្រឹក្សានៃចៅក្រម ដែលត្រូវបានជ្រើសតាំងជាពិសេសបានពិចារណាពេញលេញ និងបានបដិសេធការចោទប្រកាន់អំពីភាពលម្អៀងនេះ។ ដោយសារពុំមានអំណះអំណាងថ្មី ដែលមានមូលដ្ឋានគ្រប់គ្រាន់គាំទ្រការជំទាស់សច្ចធារណ៍នៃអនាគតិរបស់ចៅក្រម អំណះអំណាងនេះត្រូវបដិសេធចោលដោយពុំចាំបាច់ពិនិត្យបន្ថែមទៀត។

**២១.** ការចោទប្រកាន់បន្ថែមទៀតរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានភាពលម្អៀងតាមរយៈការពិនិត្យភស្តុតាងដែលនេះបានធ្វើឱ្យមានការរំលោភបំពានដទៃទៀតលើសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ និងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ត្រូវបានបដិសេធប្រហាក់ប្រហែលគ្នាដោយសារពុំមានមូលដ្ឋានគាំទ្រ។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់ក្នុងសាលដីកាជាលាយលក្ខណ៍អក្សរ។

## ការចោទប្រកាន់កំហុសទាក់ទងទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ និងការជំនុំជម្រះ

**២២.** ទាក់ទងទៅនឹងការចោទប្រកាន់របស់គាត់ស្តីពីវិសាលភាពនៃការជំនុំជម្រះ ខៀវ សំផន បានលើកការជំទាស់សំខាន់ៗ ប្រាំចំណុចពាក់ព័ន្ធទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ និងការជំនុំជម្រះដូចជាថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ដោយសារៈ (i) កំណត់ចរិតលក្ខណៈនៃសំណើរបស់គាត់ពាក់ព័ន្ធទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរថាជាអញ្ញត្រកម្មដាក់យឺតពេលតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង និងបានយល់ឃើញថា អញ្ញត្រកម្មនេះពុំអាចទទួលយកបាន (ii) បដិសេធលើអំណះអំណាងរបស់គាត់ពាក់ព័ន្ធទៅនឹងលក្ខណៈពុំគ្រប់គ្រាន់នៃបទចោទលើរូបគាត់ដោយសារខ្វះភាពច្បាស់លាស់ (iii) ការមិនអើពើលើអំណះអំណាងរបស់គាត់ ដែលលើកឡើងថា អង្គជំនុំជម្រះ ពុំបានវិនិច្ឆ័យអង្គហេតុ ដែលពុំត្រូវបានទទួលយក និងពុំត្រូវបានកំណត់ផ្នែកច្បាប់ដោយសហចៅក្រមស៊ើបអង្កេត ដែលនេះបានបណ្តាលឱ្យអង្គជំនុំជម្រះ ប្រព្រឹត្តហួសវិសាលភាពនៃការជំនុំជម្រះ (iv) ការចេញសាលក្រមផ្អែកលើអង្គហេតុដែលអង្គជំនុំជម្រះបានវិនិច្ឆ័យរួចរាល់ហើយក្នុងសំណុំរឿង ០០២/០១ ឬលើអង្គហេតុដែលអង្គជំនុំជម្រះបានដកចេញពីសំណុំរឿង ០០២/០២ និងអង្គហេតុសម្រាប់បញ្ចប់កិច្ចដំណើរការនីតិវិធី និង (v) ពិចារណាលើ «ភស្តុតាងដែលពាក់ព័ន្ធ ប៉ុន្តែនៅក្រៅវិសាលភាព» អំពីអង្គហេតុ ដែលអង្គជំនុំជម្រះពុំតម្រូវឱ្យធ្វើការជំនុំជម្រះ។ ខាងក្រោមនេះជាការសង្ខេបការយល់ឃើញ អង្គជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធទៅនឹងការជំទាស់ទាំងប្រាំនោះតាមលំដាប់លំដោយ។

**២៣.** ពាក់ព័ន្ធទៅនឹងអំណះអំណាងទីមួយរបស់គាត់ អង្គជំនុំជម្រះតុលាការកំពូល យល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា ដោយសារ ខៀវ សំផន បានជំទាស់ទៅនឹងវិសាលភាពជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើការចោទប្រកាន់កំហុសផ្នែកនីតិវិធី ក្នុងដីកាដំណោះស្រាយ ពុំមែនលើយុត្តាធិការរបស់ អ.វ.ត.ក. ដូចនេះការជំទាស់របស់គាត់ពុំស្ថិតក្នុងវិសាលភាពនៃយុត្តាធិការដាច់ខាតនិងអាស្រ័យលើការកែតម្រូវ តាមរយៈការជូនដំណឹងគ្រប់គ្រាន់អំពីបទចោទ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង ពុំមានកំហុសក្នុងការបញ្ជាក់ថា អញ្ញត្រកម្មរបស់ ខៀវ សំផន ត្រូវស្ថិតក្រោមកាលបរិច្ឆេទដែលបានកំណត់ក្នុងវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង។

**២៤.** ចំពោះអំណះអំណាងទីពីរ អង្គជំនុំជម្រះតុលាការកំពូល រកពុំឃើញកំហុសក្នុងការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងនូវសារណារបស់គាត់ពាក់ព័ន្ធទៅនឹងបទចោទពុំគ្រប់គ្រាន់ប្រឆាំងនឹងគាត់ ដោយសារកង្វះភាពច្បាស់លាស់ ហើយសម្រាប់ហេតុផលពេញលេញត្រូវបានពន្យល់ក្នុងសាលដីកានេះ។

២៥. ចំពោះអំណះអំណាងទីបី អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង ពុំមានកំហុសអង្គច្បាប់ក្នុងការកំណត់នូវវិសាលភាពនៃការជំនុំជម្រះលើអង្គហេតុដែលមានក្នុងដីកាដំណោះស្រាយ។ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាលើអំណះអំណាងផ្នែកអង្គហេតុ និងអង្គច្បាប់របស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងវិសាលភាពនៃការជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូង និងយល់ឃើញថា ខៀវ សំផន ពុំបានបង្ហាញកំហុសណាមួយពីសំណាក់ អង្គជំនុំជម្រះសាលាដំបូងឡើយ ហើយសម្រាប់ហេតុផលពេញលេញ ត្រូវបានពន្យល់នៅក្នុងសាលដីកានេះ។

២៦. ចំពោះអំណះអំណាងទីបួន អង្គជំនុំជម្រះតុលាការកំពូល ពុំជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុស ដោយសារការចេញសាលក្រមផ្អែកលើអង្គហេតុ ដែលអង្គជំនុំជម្រះបានវិនិច្ឆ័យរួចហើយ ក្នុងសំណុំរឿង ០០២/០១ ឬអង្គហេតុ ដែលអង្គជំនុំជម្រះបានដកចេញពីសំណុំរឿង ០០២/០២ និងសម្រាប់ការបញ្ចប់កិច្ចដំណើការនីតិវិធីនោះទេ ហើយសម្រាប់ហេតុផលពេញលេញ ត្រូវបានពន្យល់នៅក្នុងសាលដីកានេះ។

២៧. ចុងក្រោយ ចំពោះអំណះអំណាងទីប្រាំ ដែលថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ដោយសារការអនុវត្តវិធីសាស្ត្រ «ផ្អែកលើប្រវត្តិសាស្ត្រ» ក្នុងការពិចារណាលើ «ភស្តុតាងក្រៅវិសាលភាព ប៉ុន្តែជាប់ពាក់ព័ន្ធ» អំពីអង្គហេតុដែល អង្គជំនុំជម្រះ ពុំតម្រូវឱ្យជំនុំជម្រះ អង្គជំនុំជម្រះតុលាការកំពូល រកពុំឃើញកំហុសនៅក្នុងការសន្និដ្ឋានរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលថា អង្គជំនុំជម្រះអាចសំអាងទៅលើភស្តុតាងក្រៅវិសាលភាព នៃយុត្តាធិការពេលវេលា ឬភូមិសាស្ត្រនៃដីកាដំណោះស្រាយសម្រាប់គោលបំណងតិចតួចក្នុងការបំភ្លឺបរិបទណាមួយ ដោយបង្ហាញ តាមរយៈការសន្និដ្ឋានអំពីជាតុផ្សំនៃអំពើល្មើស ដែលបានកើតឡើងក្នុងអំឡុងពេលនោះ ឬបង្ហាញនូវលំនាំនៃអំពើគិតទុកជាមុន។

## ការចោទប្រកាន់កំហុសពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋជាមូលដ្ឋាន

២៨. ទាក់ទងទៅនឹងផ្នែកយល់ឃើញពាក់ព័ន្ធទៅនឹងខ្លឹមសារនៃរឿងក្តីប្រឆាំងនឹង ខៀវ សំផន ដូចជាបទឧក្រិដ្ឋដែល ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធភាព។

### អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

២៩. អង្គជំនុំជម្រះតុលាការកំពូល សង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូង បានអនុវត្តនូវបទដ្ឋានអត្តនោម័តិនៃចេតនាប្រយោល នៅពេលវាយតម្លៃលើអង្គហេតុពាក់ព័ន្ធទៅនឹងអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានធ្វើឡើងក្នុងសំណុំរឿង ០០២/០១ ហើយអង្គជំនុំជម្រះតុលាការកំពូល បានតម្កល់នៅបណ្តឹងសាទុក្ខក្នុងរឿងក្តីនោះ។ ខៀវ សំផន បានអះអាងថា បទដ្ឋាននេះពុំត្រឹមត្រូវ ដោយសារពុំមានអត្ថិភាពក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ១៩៧៥ និងបន្ថែមថា គាត់ពុំអាចដឹងជាមុនបានអំពីការកំណត់និយមន័យនោះថា មានច្បាប់ចែង ឬជាបទល្មើសនៅពេលនោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូល ពុំយល់ស្របជាមួយលើចំណុចនេះ និងសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង ពុំមានកំហុស។

៣០. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបង្ហាញនៅសហករណ៍ត្រាំកក់ ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ការដ្ឋានធ្វើការទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ដែលបានផ្អែកក្នុងផ្នែកខ្លះលើអំពើអសកម្មល្មើស ដោយគ្មានការបង្កើតការយល់ឃើញជាមុនថា មានកាតព្វកិច្ចត្រូវធ្វើដូច្នោះ។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុស។

៣១. បញ្ហាថាតើ អំពើមនុស្សឃាតត្រូវបានបង្ហាញនៅការដ្ឋានខាងក្រោមនេះ ដែរ ឬទេ៖ (i) សហករណ៍ត្រាំកក់ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុដោយបានយល់ឃើញថា មានមនុស្សស្លាប់ដោយសារការអត់អាហារ និងការខ្វះការថែទាំជាមូលដ្ឋានផ្នែកវេជ្ជសាស្ត្រនៅសហករណ៍ត្រាំកក់ និងមានកំហុសក្នុងការយល់ឃើញថា កម្រិត ដែលជាលក្ខខណ្ឌតម្រូវត្រូវបានបង្ហាញ។ អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូង។ (ii) ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃលើបញ្ហាថាតើ អាជ្ញាធរបានប្រព្រឹត្តក្នុងកម្រិត ដែលជាលក្ខខណ្ឌតម្រូវនៃចេតនាពាក់ព័ន្ធទៅនឹងការស្លាប់មនុស្សនៅការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ដោយសារមានកត្តាដែលហួសពីការគ្រប់គ្រងរបស់ពួកគេ ដែលបាននាំទៅរកលក្ខខណ្ឌបណ្ដាលឱ្យមានមនុស្សស្លាប់នៅទីនោះដែរឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូល បានវិភាគអំណះអំណាងនេះ និងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូង។ (iii) ការដ្ឋានធ្វើការទំនប់១មករា ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា អំពើមនុស្សឃាត បានកើតឡើងនៅការដ្ឋានធ្វើការទំនប់១មករាដោយសារការដាក់លក្ខខណ្ឌការរស់នៅ និងធ្វើការងារ រួមទាំងកង្វះថ្នាំពេទ្យ និងថា អ្នកធ្វើការបានស្លាប់ដោយសារគ្រោះថ្នាក់នានា។ គាត់បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ចារីបានដឹងថា ពុំមានស្បៀង និងថ្នាំពេទ្យគ្រប់គ្រាន់ និងនៅតែជម្រុញឱ្យពួកគេបំពេញលក្ខខណ្ឌការងារនោះ។ អង្គជំនុំជម្រះតុលាការ កំពូលសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូង។ (iv) ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការយល់ឃើញថា ការស្លាប់ដោយសារការដាក់លក្ខខណ្ឌនោះត្រូវបានប្រព្រឹត្តឡើងក្នុងកម្រិតដែលជាលក្ខខណ្ឌតម្រូវនៃចេតនា ពីព្រោះមានកត្តា ដែលហួសពីការគ្រប់គ្រងរបស់ពួកគេ ដែលបានបង្កឱ្យមានលក្ខខណ្ឌបែបនោះកើតឡើងដែលបណ្ដាលឱ្យមានមនុស្សស្លាប់។ អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា ខៀវ សំផន ខកខាន ក្នុងការបង្ហាញកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូង។ (v) មន្ទីរសន្តិសុខភ្នំក្រោល អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា មានការស្លាប់មនុស្សពីរនាក់បានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល ដែលនេះអាចស្មើនឹងអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អ្នកទីមួយគឺអ្នកជាប់ឃុំឈ្មោះ ហៀស ដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ត្រូវបានសម្លាប់ដោយសន្តិសុខ ដែលយាមនៅទីនោះ។ អ្នកទីពីរជាអ្នកជាប់ឃុំឈ្មោះ ទូច ដែលបានស្លាប់ដោយសារលក្ខខណ្ឌដ៏អាក្រក់នៃការឃុំឃាំង ដែលគាត់បានទទួលរង។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារបានយល់ឃើញថា អំពើមនុស្សឃាតទាំងពីរនេះ ត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ។ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូង មាន

កំហុសក្នុងការយល់ឃើញពាក់ព័ន្ធទៅនឹងការស្លាប់របស់ ហៀស និង ទូច ដោយសារបានផ្អែកដោយច្បាស់លាស់ទៅលើចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី ដែលបានទទួលមរណភាព ដែល ខៀវ សំផន ពុំអាចសួរដេញដោលបាន។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូល បដិសេធការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅមន្ទីរសន្តិសុខភ្នំក្រោល។

## ការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

**៣២.** ការសម្លាប់រង្គាលជនជាតិចាមៈ អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញទាក់ទងទៅនឹងការសម្លាប់ដោយចេតនាជនជាតិចាមនៅមន្ទីរសន្តិសុខអូរត្រកួនក្នុងឆ្នាំ ១៩៧៧ និងមន្ទីរសន្តិសុខភូមិទ្រាក្នុងឆ្នាំ ១៩៧៨។ អង្គជំនុំជម្រះសាលាដំបូង ពុំអាចបង្ហាញចំនួនជាក់លាក់របស់ជនរងគ្រោះ ប៉ុន្តែបានជឿជាក់ថា ជនស៊ីវិលជនជាតិចាម ក្នុងចំនួនដ៏ច្រើនត្រូវបាននាំទៅមន្ទីរសន្តិសុខទាំងពីរនេះ។ អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា អំពើមនុស្សឃាតនេះ បំពេញតាមលក្ខខណ្ឌតម្រូវនៃការសម្លាប់ក្នុងទ្រង់ទ្រាយធំ និងជាផ្នែកនៃប្រតិបត្តិការសម្លាប់មនុស្សដូចគ្នា។ អង្គជំនុំជម្រះសាលាដំបូង បានកំណត់ថា ការសម្លាប់រង្គាល ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានស្រូបបញ្ចូលអំពើមនុស្សឃាត ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបានសម្រេចដាក់ពិរុទ្ធភាពតែពីបទសម្លាប់រង្គាលប៉ុណ្ណោះ។ ខៀវ សំផន បានជំទាស់ទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាងដែលបង្ហាញថា ការសម្លាប់នោះបានកើតឡើងនៅ ភូមិទ្រាង វត្តអូរត្រកួន។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូល ពុំចាត់ទុកការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ថា ពុំសមហេតុផលឡើយ។ ខៀវ សំផន បានជំទាស់បន្ថែមទៀតលើបញ្ហាថាតើ លក្ខខណ្ឌអំពីតួលេខសម្រាប់ការសម្លាប់រង្គាលត្រូវបានបំពេញដែរ ឬយ៉ាងណា ដោយសារ អង្គជំនុំជម្រះសាលាដំបូង ពុំអាចបង្ហាញនូវចំនួនជាក់លាក់របស់ជនរងគ្រោះ ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា អង្គហេតុបានគាំទ្រការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការសម្លាប់ក្នុងទ្រង់ទ្រាយធំបានកើតឡើង។ ចុងក្រោយ ខៀវ សំផន បានជំទាស់ទៅនឹងបញ្ហាថាតើ មានចេតនាសម្លាប់ក្នុងទ្រង់ទ្រាយធំ ដែរ ឬយ៉ាងណា ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូល រកពុំឃើញកំហុសនៅក្នុងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូងឡើយ។

**៣៣.** ការសម្លាប់រង្គាលជនជាតិវៀតណាមៈ ខៀវ សំផន បានចោទប្រកាន់កំហុសជាច្រើនផ្នែកអង្គហេតុ និងអង្គច្បាប់នៅក្នុងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិវៀតណាម ក្នុងខេត្តស្វាយរៀង ក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ ក្នុងខេត្តកំពង់ឆ្នាំង នៅវត្តខ្សាច់ និងខេត្តក្រចេះ ព្រមទាំងមន្ទីរសន្តិសុខអូរកន្សែង និងបានលើកឡើងថា អំពើមនុស្សឃាត និងការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពុំអាចត្រូវបានបង្ហាញទាក់ទងទៅនឹងការសម្លាប់ទាំងនេះឡើយ។

**៣៤.** អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ការសម្លាប់បានកើតឡើងនៅទីតាំងខាងលើ។ ទាក់ទងទៅនឹងបញ្ហាថាតើ

ការសម្លាប់នេះអាចស្មើនឹងការសម្លាប់រង្គាលដែរឬយ៉ាងណាអង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសណាមួយក្នុងការកំណត់តួលេខរបស់ អង្គជំនុំជម្រះសាលាដំបូង អំពីការសម្លាប់ដែលបានប្រព្រឹត្តឡើងក្នុងទីតាំងជាច្រើន ដោយសារការយល់ឃើញដែលថា ការសម្លាប់នោះគឺជាផ្នែកនៃប្រតិបត្តិការសម្លាប់មនុស្សតែមួយ។

## ការដាក់ឱ្យទៅជាទាសករក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

៣៥. ខៀវ សំផន បានជំទាស់ទៅនឹងបញ្ហាថាតើ ការដាក់ឱ្យទៅជាទាសករក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល ដែរ ឬយ៉ាងណា និងបានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងត្រឹមតែតម្រូវឱ្យជំនុំជម្រះលើការដាក់ឱ្យទៅជាទាសករនៅទីតាំងមួយកន្លែងប៉ុណ្ណោះ គឺ ក-១១ ក្នុងមន្ទីរសន្តិសុខភ្នំក្រោល និងថា ភស្តុតាងនៃការដាក់ឱ្យទៅជាទាសករនៅ ក-១១ ពុំមានលក្ខណៈគ្រប់គ្រាន់។ អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសណាមួយពីសំណាក់ អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងបញ្ហានេះ។

## ការនិរទេសក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

៣៦. អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា ខៀវ សំផន មានពិរុទ្ធភាពពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការនិរទេសជនជាតិវៀតណាម ចេញពីសហករណ៍ស្រុកត្រាំកក់ និងខេត្តព្រៃវែង។ ខៀវ សំផន បានជំទាស់ទៅនឹងការសន្និដ្ឋានរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលថា ជនជាតិវៀតណាមត្រូវបាននិរទេសចេញពីសហករណ៍ត្រាំកក់ឆ្លងកាត់ព្រំប្រទល់ជាតិ ព្រមទាំងខេត្តព្រៃវែង។ ខៀវ សំផន បានជំទាស់ផងដែរលើភាពគ្រប់គ្រាន់នៃភស្តុតាងដែលបង្ហាញថា មានចេតនានិរទេសជនជាតិវៀតណាម។ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសណាមួយពីសំណាក់ អង្គជំនុំជម្រះសាលាដំបូង។

## ការធ្វើទារុណកម្មក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

៣៧. ខៀវ សំផន បានជំទាស់ទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាង ដែលត្រូវបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងការបង្ហាញបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទារុណកម្មជនជាតិចាមនៅភូមិទ្រា។ អង្គជំនុំជម្រះតុលាការកំពូល រកពុំឃើញកំហុសពីសំណាក់ អង្គជំនុំជម្រះសាលាដំបូង និងសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា ការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលថា ជនជាតិចាមត្រូវបានធ្វើទារុណកម្មនោះ គឺជាការយល់ឃើញ ដែលគ្មានតុលាការអង្គហេតុសមហេតុផលណាមួយអាចធ្វើទៅបាននោះឡើយ។

## ការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

៣៨. ខៀវ សំផន បានអះអាងថា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិឆ្នាំ ១៩៧៥ ការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឱ្យមានគោលបំណងដកបុគ្គលដែលត្រូវបានកំណត់គោលដៅចេញពីសហគមន៍ដែលពួកគេរស់នៅជាមួយចារីនោះ ឬចេញពីសង្គមមនុស្សជាតិផ្ទាល់។ ក្នុងសាលដីកាសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូល បានដោះស្រាយបញ្ហានេះ និងបានសន្និដ្ឋានថា គោលបំណងនោះ ពុំមែនជាធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ឡើយ។ ទោះជាយ៉ាងណាក្តី ខៀវ សំផន បានទទូចសុំឱ្យមានការអនុវត្តប្រាសចាកពីការយល់ឃើញដំបូងរបស់ អង្គជំនុំជម្រះតុលាការកំពូល ដែលបានផ្អែកលើការវិភាគទៅលើយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ។ ចំពោះបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូល បដិសេធក្នុងការធ្វើដូច្នោះ។ ជាលទ្ធផល ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសពីសំណាក់ អង្គជំនុំជម្រះសាលាដំបូង។

៣៩. ខៀវ សំផន បានចោទប្រកាន់ផងដែរថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ក្នុងការកំណត់ចរិតលក្ខណៈលើការប្រព្រឹត្តដូចគ្នាៗ ជាពិសេសទៅលើក្រុមបុគ្គលមួយប្រភេទថា ជាការរើសអើងជាក់ស្តែង។ គាត់បានអះអាងថា ការរើសអើងដោយប្រយោល គឺជាគោលគំនិតថ្មីៗ នៃសិទ្ធិមនុស្សដែលពុំត្រូវបានចាត់ទុកថា ជាការរើសអើងជាក់ស្តែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥។ ទាក់ទងទៅនឹងការអះអាងនេះ អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានជាសង្ខេបដូចខាងក្រោម៖

## ការធ្វើទុក្ខបុកម្នេញផ្អែកនយោបាយលើជនជាតិចាម

៤០. អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា ជនជាតិចាមត្រូវបានកំណត់គោលដៅផ្អែកលើមូលហេតុនយោបាយ និងត្រូវបានដកចេញដើម្បីបំបែកសហគមន៍របស់ពួកគេ។ ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញនេះ និងបានអះអាងថា អង្គជំនុំជម្រះសាលាដំបូង ខកខានក្នុងការបង្ហាញថា ការផ្លាស់ទីប្រជាជនបានប៉ះពាល់ជាពិសេស ឬយ៉ាងហោចណាស់ជាចម្បងទៅលើជនជាតិចាម និងដូច្នេះ ជាការរើសអើង។ ប្រហាក់ប្រហែលគ្នានេះដែរ ខៀវ សំផន បានអះអាងថា ពុំមានភស្តុតាងបង្ហាញថា ក្នុងអំឡុងពេលនៃការផ្លាស់ទីនោះ ជនជាតិចាមត្រូវបានប្រព្រឹត្តទៅលើខុសប្លែកពីអ្នកដទៃទៀតដែលតាមការអះអាងរបស់គាត់ គឺជាបទដ្ឋានដែល អង្គជំនុំជម្រះតុលាការកំពូល បានប្រើប្រាស់ក្នុងសំណុំរឿង ០០២/០១ ទាក់ទងទៅនឹង «ប្រជាជនថ្មី»។ អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា ខៀវ សំផន បានបកស្រាយពុំត្រឹមត្រូវលើយុត្តិសាស្ត្រនៃសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តបទដ្ឋានផ្លូវច្បាប់ត្រឹមត្រូវក្នុងការកំណត់ថាតើ ការធ្វើទុក្ខបុកម្នេញបានកើតឡើងដែរ ឬយ៉ាងណា។ ខៀវ សំផន បានជំទាស់ផងដែរទៅលើបញ្ហាថាតើ ធាតុផ្សំអត្តនោម័តិត្រូវបានបង្ហាញត្រឹមត្រូវដោយ អង្គជំនុំជម្រះសាលាដំបូង ដែរ ឬយ៉ាងណា និងបានអះអាងថា ពុំមានមូលដ្ឋានរើសអើងសម្រាប់ការផ្លាស់ទីជនជាតិចាមឡើយ។ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា អំណះអំណាងនេះខកខានក្នុងការបង្ហាញថា ការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធបញ្ហានេះមានលក្ខណៈពុំសមហេតុផល។ ខៀវ សំផន ចុងក្រោយបានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូង

មានកំហុសក្នុងការវាយតម្លៃលើបញ្ហាថាតើ ភាពធ្ងន់ធ្ងរនៃអំពើរើសអើងអាចស្មើនឹងការធ្វើទុក្ខបុកម្នេញ ដែរឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា អំពើនេះឈានដល់កម្រិតដែលជាលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរ ដែលអាចស្មើនឹងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើជនជាតិចាម ត្រូវបដិសេធចោល។

## ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើ «សត្រូវពិត ឬតាមការសន្មត»

៤១. ខៀវ សំផន បានជំទាស់ទៅនឹងភាព ដែលអាចកំណត់នៃក្រុមគោលដៅថាជា «សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា» ទាក់ទងទៅនឹងការយល់ឃើញនៃការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយនៅមន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខអូរកន្សែង។ អង្គជំនុំជម្រះតុលាការកំពូល បានដោះស្រាយបញ្ហានេះក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០២/០១ និងបានសន្និដ្ឋានថា ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយត្រូវបានយល់ថា ជាការរួមបញ្ចូលស្ថានការណ៍ ដែលចារីបានកំណត់គោលដៅលើក្រុមតាមការសន្មតទូលំទូលាយ ដោយគ្មានការអង្កេតមើលទស្សនៈ នយោបាយរបស់បុគ្គល ដែលពាក់ព័ន្ធនោះឡើយ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល «បានយល់ស្របតាមលទ្ធភាព ដែលថា ការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចកំណត់គោលដៅលើក្រុមប្រមូលផ្ដុំ ដោយគ្មានការកំណត់អត្តសញ្ញាណ ឬរបៀបវារៈរួមគ្នាឡើយ»។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូល បដិសេធអំណះអំណាងរបស់ ខៀវ សំផន ដែលថា «សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា» ពុំមែនជាក្រុម ដែលអាចកំណត់បានគ្រប់គ្រាន់សម្រាប់ការយល់ឃើញ អំពីការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយឡើយ។

## ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយនៅសហករណ៍ និងមន្ទីរសន្តិសុខ

៤២. (i) សហករណ៍ត្រាំកក់៖ ខៀវ សំផន អះអាងថា ពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការយល់ឃើញថា អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានធ្វើទុក្ខបុកម្នេញនៅសហករណ៍ត្រាំកក់ដោយសារមូលហេតុនយោបាយ។ អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសណាមួយពីសំណាក់ អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធបញ្ហានេះ។ (ii) ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម៖ ខៀវ សំផន បានលើកឡើងថា អំពើនៃការធ្វើទុក្ខបុកម្នេញដែលចោទជាបញ្ហានេះនៅការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ត្រឹមតែជាការដកប្រជាជនថ្មីចេញពីតួនាទីដឹកនាំ និងការដែលពួកគេត្រូវបានតាមដានដោយប្រជាជនមូលដ្ឋានប៉ុណ្ណោះ ដែលតាមការអះអាងរបស់គាត់ថា ពុំគ្រប់គ្រាន់ក្នុងការយល់ឃើញថា សិទ្ធិជាមូលដ្ឋាននោះ ត្រូវបានរំលោភបំពាន ឬថា លក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរ ដើម្បីបង្កើតឱ្យបានជាការធ្វើទុក្ខបុកម្នេញក្នុង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបំពេញឡើយ។ អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសណាមួយពីសំណាក់ អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធបញ្ហានេះ។ (iii) ការដ្ឋានធ្វើការទំនប់១មករា៖ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុស (១) អង្គហេតុក្នុងការសន្និដ្ឋានថា អត្ថិភាពនៃការរើសអើងលើ

ប្រជាជនថ្មីនៅការដ្ឋានធ្វើការទំនប់១មករា (២) អង្គច្បាប់ដោយសារការបញ្ជាក់នូវអត្ថិភាពនៃសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការប្រព្រឹត្តទៅលើស្មើភាពគ្នា (៣) កំហុសអង្គច្បាប់ និងអង្គហេតុតាមរយៈការយល់ឃើញថា ការប្រព្រឹត្តទៅលើនោះ បានរំលោភបំពានលើសិទ្ធិជាមូលដ្ឋានរបស់ប្រជាជនថ្មីក្នុងការទទួលបានការប្រព្រឹត្តទៅលើស្មើភាពគ្នា និង (៤) កំហុសអង្គច្បាប់ដោយសារការខកខានក្នុងការគូសបង្ហាញនូវកម្រិត ដែលជាលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរដែលចាំបាច់ត្រូវបំពេញសម្រាប់អំពើជាមូលដ្ឋានដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការធ្វើទុក្ខបុកម្នេញ។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់ក្នុងសាលដីកានេះ។ អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការយល់ឃើញអំពីអត្ថិភាពនៃសិទ្ធិទទួលបានការប្រព្រឹត្តទៅលើស្មើភាពគ្នានៅក្នុងច្បាប់សន្ធិសញ្ញា ឬទំនៀមទម្លាប់អន្តរជាតិ ដែលត្រូវបានរំលោភបំពាន និងអាស្រ័យហេតុនេះបដិសេធការដាក់ពិរុទ្ធភាពលើគាត់ពីបទធ្វើទុក្ខបុកម្នេញផ្អែកនយោបាយលើប្រជាជនថ្មីនៅការដ្ឋានធ្វើការទំនប់១មករា។ ខៀវ សំផន បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូង បានសំអាងទៅលើភស្តុតាងមិនគ្រប់គ្រាន់ក្នុងការយល់ឃើញថា អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយនៅការដ្ឋានធ្វើការទំនប់១មករា។ អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសណាមួយពីសំណាក់ អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធបញ្ហានេះ។ (iv) មន្ទីរសន្តិសុខ ស-២១៖ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការយល់ឃើញថា អំពើដែលកំណត់គោលដៅលើ «សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា» គឺជាការរើសអើងជាក់ស្តែង និងបានអះអាងថា ការចាប់ខ្លួនក្នុងទ្រង់ទ្រាយធំបានបង្ហាញថា នេះជាការមិនរើសមុខ។ គាត់បានអះអាងថា ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ស្តីពីការធ្វើទុក្ខបុកម្នេញផ្អែកលើមូលហេតុនយោបាយ ដោយសារ អង្គជំនុំជម្រះតុលាការកំពូល បានយល់ឃើញថា ពុំមានលក្ខណៈវិនិច្ឆ័យស្តីពីភាពអាចកំណត់បានជាក់លាក់ត្រូវបានអនុវត្តក្នុងការកំណត់គោលដៅលើជនរងគ្រោះ។ ខៀវ សំផន បានអះអាងថា ភស្តុតាងក្នុងសំណុំរឿង ០០២/០២ គ្មានអ្វីខុសគ្នាដែលគាំទ្រការយល់ឃើញផ្សេងគ្នាក្នុងរឿងក្តីនេះទេ។ អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា ការពិតដែលថា ប្រជាជនត្រូវបានចាប់ខ្លួនក្នុងទ្រង់ទ្រាយធំពុំបានរារាំងការយល់ឃើញអំពីការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ ដរាបណាមានសមាជិកនៃក្រុមគោលដៅត្រូវបានចាប់ខ្លួន ដោយសារតែពួកគេស្ថិតក្នុងក្រុមគោលដៅនោះ។ ការបដិសេធរបស់ អង្គជំនុំជម្រះតុលាការកំពូល នូវការដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយក្នុងសំណុំរឿង ០០១ មានលក្ខណៈជាក់លាក់ចំពោះ ឌុច ប៉ុណ្ណោះ។ ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការយល់ឃើញថា អំពើនោះគឺជាការរើសអើង។ (v) មន្ទីរសន្តិសុខអូរកន្សែង ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការយល់ឃើញថា ការធ្វើទុក្ខបុកម្នេញបានកើតឡើងនៅមន្ទីរសន្តិសុខអូរកន្សែង និងថាជាសំខាន់ភស្តុតាង ដែលបានសំអាងទៅលើនោះ ពុំបានបង្ហាញអំពីការប្រព្រឹត្តដោយរើសអើងឡើយ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូង។

## ការធ្វើទុក្ខបុកម្នេញផ្នែកសាសនា

៤៣. អង្គជំនុំជម្រះសាលាដំបូង បានបង្កើតការយល់ឃើញផ្នែកអង្គច្បាប់ ពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនាជាពីរផ្នែកក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង៖ ផ្នែកទីមួយជាពិសេសទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាមនៅការដ្ឋានធ្វើការទំនប់១មករា និងទីពីរទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាមទូទៅ។ ពាក់ព័ន្ធទៅនឹងការដ្ឋានធ្វើការទំនប់១មករា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អ្នកធ្វើការជនជាតិចាមបានទទួលរងការរើសអើង ដោយសារពួកគេត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក ហាមឃាត់ការអធិដ្ឋាន និងការនិយាយភាសាកំណើតរបស់ខ្លួន។ ទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាមទូទៅ អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា ការហាមឃាត់នានា និងការហាមឃាត់ផ្នែកវប្បធម៌ ត្រូវបានដាក់កំហិត រួមទាំងការហាមឃាត់ការអធិដ្ឋានរាល់ថ្ងៃ ការបង្ខំឱ្យបរិភោគសាច់ជ្រូក ការបង្ខំឱ្យស្លៀកសំលៀកបំពាក់ និងកាត់សក់ខ្លីដូចជនជាតិខ្មែរ ការបង្ខំឱ្យនិយាយតែភាសាខ្មែរ និងការដុតគម្ពីរអាល់គូរ៉ាន និងការរុះរើវិហារអ៊ីស្លាម ឬប្រើប្រាស់សម្រាប់គោលបំណងមិនពាក់ព័ន្ធសាសនា។ អង្គជំនុំជម្រះសាលាដំបូង ជឿជាក់ថា ការរឹតត្បិតនេះគឺជាការរើសអើង និងត្រូវបានប្រព្រឹត្តដោយចេតនាគិតទុកជាមុន ក្នុងការរើសអើងលើជនជាតិចាម ដោយសារតែការប្រតិបត្តិសាសនា និងវប្បធម៌របស់ពួកគេ។

៤៤. ខៀវ សំផន បានជំទាស់ទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាង ដែលបង្ហាញថា អំពើរើសអើងមួយចំនួនបានកើតឡើងនៅការដ្ឋានធ្វើការទំនប់១មករា និងកន្លែងផ្សេងទៀតក្នុងកម្ពុជា។ គាត់បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសដោយសារខកខានក្នុងការពិចារណាលើបញ្ហាថាតើ ការរឹតត្បិតលើសេរីភាពផ្នែកសាសនា ត្រូវបានអនុញ្ញាតក្នុងច្បាប់ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសពីសំណាក់ អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធបញ្ហានេះ។

៤៥. ខៀវ សំផន បានអះអាងថា អំពើរើសអើងពុំមានអត្ថិភាព ដោយសារមានការអនុវត្តស្មើភាពគ្នាចំពោះប្រជាជនគ្រប់រូប។ អង្គជំនុំជម្រះតុលាការកំពូល រំឭកថា ការរើសអើងជាក់ស្តែងបានកើតឡើងនៅពេលមានលទ្ធផលមិនស្មើគ្នា សម្រាប់ក្រុមជាក់លាក់មួយតាមរយៈការអនុវត្តន៍ទូទៅនៃអំពើសកម្ម ឬអសកម្ម។ អង្គជំនុំជម្រះតុលាការកំពូល រកពុំឃើញកំហុសណាមួយក្នុងការសន្និដ្ឋានរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលថា ជនជាតិចាម «ជាចម្បង និងជាពិសេសបានទទួលរងផលប៉ះពាល់» ដោយសារការរឹតត្បិតផ្នែកសាសនា និងវប្បធម៌ ដូច្នេះមានអត្ថិភាពនៃការរើសអើងជាក់ស្តែង។

៤៦. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការយល់ឃើញថា មានការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន ពីព្រោះការរឹតត្បិតផ្នែកសាសនា និងវប្បធម៌ពុំបានរំលោភបំពានលើសិទ្ធិណាមួយដែល អង្គជំនុំជម្រះសាលាដំបូង បានយោងទៅលើនៅក្នុងការយល់ឃើញផ្នែកច្បាប់របស់ខ្លួន និងបានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំ បានយល់ឃើញថា សិទ្ធិខាងសេរីភាពផ្នែកសាសនាត្រូវបានរំលោភបំពានទាក់ទងទៅនឹងការប្រព្រឹត្តលើជនជាតិចាមទូទៅ លើកលែងតែនៅការដ្ឋានធ្វើការទំនប់១មករាប៉ុណ្ណោះ។ អង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង បាន

បញ្ជាក់ថា អង្គជំនុំជម្រះ បានយល់ឃើញថា សិទ្ធិនៃសេចក្តីថ្លៃថ្នូររបស់បុគ្គលត្រូវបានរំលោភបំពាន ដោយសារការរឹតត្បិតផ្នែកសាសនា និងវប្បធម៌ដែលចោទជាបញ្ហានោះ និងថា ការយល់ឃើញនេះមានលក្ខណៈសមហេតុផល។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូល បដិសេធអំណះអំណាងរបស់ ខៀវ សំផន។

៤៧. ខៀវ សំផន បានជំទាស់ផងដែរទៅលើបញ្ហាថាតើ មានចេតនាក្នុងការរើសអើងផ្អែកលើមូលហេតុសាសនាដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសពីសំណាក់ អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធបញ្ហានេះ។

៤៨. អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញផ្អែកសាសនាលើពុទ្ធសាសនិក ត្រូវបានបង្ហាញនៅសហករណ៍ត្រាំកក់។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ព្រះសង្ឃពុទ្ធសាសនាជាង ១០០អង្គ ត្រូវបានប្រមូលផ្តុំនៅវត្តអង្គរកា និងត្រូវបានបង្ខំឱ្យលាចាកសិក្ខាបទ។ អង្គជំនុំជម្រះបានពិចារណាឃើញថា ការសំដៅទៅលើព្រះសង្ឃថា ជា «ដង្កូវ» ឬ «ឈ្លើង» និងការប្រកាសបដិសេធសាសនាព្រះពុទ្ធថា ជាអបិយជំនឿ និងព្រះពុទ្ធបដិមា «គ្រាន់តែជាស៊ីម៉ង់ត៍» បានបង្ហាញនូវចេតនារើសអើង នៅពីក្រោយដំណើរការនោះ។ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់បន្ថែមទៀតថា និមិត្តរូបតំណាងពុទ្ធសាសនាត្រូវបានបំផ្លិចបំផ្លាញ និងវត្តអារាមត្រូវបានប្រើប្រាស់ សម្រាប់គោលបំណងមិនពាក់ព័ន្ធសាសនាទូទាំងស្រុកត្រាំកក់។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ភស្តុតាងបានបង្ហាញអំពីការលុបបំបាត់ទាំងស្រុងនូវការប្រតិបត្តិសាសនាព្រះពុទ្ធ ដែលនេះជា «ការវាយប្រហារជានិរន្តរ៍ និងតាមការរៀបចំប្រឆាំងនឹងសាសនា» ដែលត្រូវបានចាត់ទុកថា ពុំស្របជាមួយនឹងការអនុវត្តន៍នៃបដិវត្ត។ ដោយផ្អែកលើការពិចារណាទាំងនេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ផលប៉ះពាល់ផ្លូវចិត្ត និងចិត្តសាស្ត្រពីព្រឹត្តិការណ៍នេះបានរំលោភបំពានលើសិទ្ធិជាមូលដ្ឋានក្នុងកម្រិតធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៤៩. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការយល់ឃើញថា ការធ្វើទុក្ខបុកម្នេញផ្អែកសាសនា ត្រូវបានបង្ហាញ និងបានអះអាងថា ពុំមានភស្តុតាងគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងផលប៉ះពាល់ផ្លូវចិត្ត ឬរូបកាយដោយសារការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិកឡើយ។ បន្ថែមលើនេះ គាត់បានអះអាងថា ដោយសារគ្មានភស្តុតាងបង្ហាញ អំពីការប្រព្រឹត្តដោយរើសអើងលើព្រះសង្ឃពុទ្ធសាសនា និងពុទ្ធសាសនិក អ្នកទាំងនេះត្រូវបានប្រព្រឹត្តទៅលើដូចប្រជាជនដទៃទៀតដែរ។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ពុំបានបង្ហាញកំហុសណាមួយ ពីសំណាក់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធបញ្ហានេះ។

## ការធ្វើទុក្ខបុកម្នេញផ្អែកពូជសាសន៍

៥០. អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញផ្អែកពូជសាសន៍លើជនជាតិវៀតណាមត្រូវបានបង្ហាញនៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខអូរកន្សែង ខេត្តព្រៃវែង និងខេត្តស្វាយរៀង។ អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា

បទឧក្រិដ្ឋនេះ ត្រូវបានប្រព្រឹត្តឡើងជាផ្នែកនៃគោលនយោបាយកំណត់គោលដៅលើជនជាតិវៀតណាម «សម្រាប់ការចាត់ទុកជាសត្រូវពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេស សម្រាប់ការនិរទេសនៅមុនខែ មេសា ឆ្នាំ ១៩៧៧ និងសម្រាប់ការកម្ទេចដោយសារជាក្រុមពូជសាសន៍ក្រោយមក» ពីព្រោះជនជាតិវៀតណាមត្រូវបានចាត់ទុកថា ជា «សត្រូវគ្រោះថ្នាក់បំផុតដល់របបកម្ពុជាប្រជាធិបតេយ្យ»។ ខៀវ សំផន បានជំទាស់ទៅនឹងបញ្ហាថាតើ ការធ្វើទុក្ខបុកម្នេញផ្នែកពូជសាសន៍បានកើតឡើងនៅទីតាំងខាងលើ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសពីសំណាក់ អង្គជំនុំជម្រះសាលាដំបូង។

## អំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

៥១. ខៀវ សំផន បានជំទាស់ទៅនឹងបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូង បានវាយតម្លៃត្រឹមត្រូវលើគោលការណ៍នីត្យានុកូលភាព ដែរ ឬយ៉ាងណា នៅពេលអង្គជំនុំជម្រះ បានយល់ឃើញថា ជនជាប់ចោទអាចដឹងជាមុនបានថា មានច្បាប់ចែង និងជាបទល្មើសក្នុងន័យទូទៅថា អំពើអមនុស្សធម៌ដទៃទៀតនេះអាចដាក់ទោសបានក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រឹមឆ្នាំ ១៩៧៥។ យោងតាម ខៀវ សំផន ថា ជាការពុំគ្រប់គ្រាន់ក្នុងការនិយាយថា អំពើអមនុស្សធម៌ដទៃទៀតអាចដឹងជាមុនបានថា មានច្បាប់ចែង ដោយសារអំពើប្រភេទនេះអាចគ្របដណ្ដប់ការប្រព្រឹត្តច្រើនប្រភេទ។ ផ្ទុយទៅវិញ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង គប្បីបានកំណត់ជាក់លាក់នូវការប្រព្រឹត្ត ដែលចោទជាបញ្ហានេះ និងបានពិនិត្យលើបញ្ហាថាតើ អំពើនេះត្រូវបានកំណត់និយមន័យថា ជាបទល្មើសនៅពេលនោះ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូល ពិតចារណាឃើញថា ខៀវ សំផន បានយល់ពុំត្រឹមត្រូវអំពីការអនុវត្តគោលការណ៍នីត្យានុកូលភាពពាក់ព័ន្ធទៅនឹងអំពើអមនុស្សធម៌ដទៃទៀត។ អ្វីដែលតម្រូវគឺថា តើជនជាប់ចោទអាចដឹងជាមុនបាននូវអំពើអមនុស្សធម៌ដទៃទៀតប្រភេទនេះថា មានច្បាប់ចែង និងជាបទល្មើស ដែរ ឬទេ ដែលអង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញក្នុងករណីនេះ។ ជាលទ្ធផល ពុំមានកំហុស។

៥២. ខៀវ សំផន បានអះអាងផងដែរថា អំពើនោះត្រូវតែរំលោភបំពានការហាមឃាត់ជាក់លាក់ ដែលមានចែងក្នុងលិខិតុបករណ៍ស្ដីពីសិទ្ធិមនុស្ស ដែលអាចស្មើនឹងអំពើអមនុស្សធម៌ដទៃទៀត។ ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូល បានអនុវត្តតាមវិធីសាស្ត្រ ដែលបានប្រើប្រាស់ដោយ អង្គជំនុំជម្រះសាលាដំបូង នៃ តុលាការ ICTY ក្នុងរឿងក្ដី *Kupreškić* «ដែលបានភ្ជាប់ទំនាក់ទំនង» អំពើអមនុស្សធម៌ដទៃទៀត «ទៅនឹងអំពើ ដែលរំលោភបំពានលើសិទ្ធិជាមូលដ្ឋានពាក់ព័ន្ធទៅនឹងមនុស្សជាតិ ដូចបានកំណត់ក្នុងលិខិតុបករណ៍គតិយុត្តអន្តរជាតិ»។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូល បានពន្យល់ថាពុំមានលក្ខខណ្ឌតម្រូវថាអំពើជាក់លាក់ត្រូវតែជាបទល្មើសច្បាស់លាស់ក្រោមច្បាប់អន្តរជាតិឡើយដោយសារនេះអាចធ្វើឱ្យគោលគំនិតនៃអំពើអមនុស្សធម៌ដទៃទៀត ដែលជាប្រភេទមិនជាក់លាក់លែងមានភាពចាំបាច់។ អាស្រ័យហេតុនេះ សារណារបស់ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះ ត្រូវបដិសេធចោល។

## ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ

៥៣. ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលថា អំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ត្រូវបានបង្ហាញនៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់ក្នុងសាលដីកានេះ។ អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង បានបង្ហាញដោយត្រឹមត្រូវថា បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថាជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ បានកើតឡើងនៅត្រាំកក់ ក្រាំងតាចាន់ និងភ្នំក្រោល។

## ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

៥៤. អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា បទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍ គឺជាផ្នែកមួយនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានបង្កើតឡើង និងបានអនុវត្តដើម្បីសម្រេចគោលដៅបដិវត្តសង្គមនិយមក្នុងកម្ពុជា។ គោលនយោបាយនេះ ជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើ ដែលត្រូវបានកំណត់ចរិតលក្ខណៈដោយអង្គជំនុំជម្រះថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ អង្គជំនុំជម្រះសាលាដំបូង បានរកឃើញថា ខៀវ សំផន មានពិរុទ្ធភាពដោយសារបានប្រព្រឹត្តអំពើអមនុស្សធម៌ដទៃទៀតទាំងនេះ ដែលជាបទឧក្រិដ្ឋ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈសហឧក្រិដ្ឋកម្មរួម។

៥៥. ខៀវ សំផន បានជំទាស់ទៅនឹងការដាក់ពិរុទ្ធភាពលើគាត់សម្រាប់បទឧក្រិដ្ឋទាំងនេះ ដោយផ្អែកលើបទបញ្ជានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍ និងបានអះអាងថា ជាការរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព និងបានជំទាស់ទៅនឹងការយល់ឃើញផ្អែកអង្គហេតុ និងជំទាស់ទៅនឹងភាពធ្ងន់ធ្ងរនៃអំពើនោះ។ សហព្រះរាជអាជ្ញា បានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលបានដកជនរងគ្រោះជាបុរសនៃការរំលោភសេពសន្ថវៈ ចេញពីបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

## ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

៥៦. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសដោយបានសំអាងទៅលើរឿងក្តីយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ ក្នុងការបង្ហាញនីត្យានុកូលភាព នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងខកខានក្នុងការបញ្ជាក់ថាតើ អំពើនោះបានរំលោភបំពានសិទ្ធិជាមូលដ្ឋានដែរ ឬយ៉ាងណា និងខកខានក្នុងការពិចារណាលើនីត្យានុកូលភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្រោមរបបដទៃទៀតស្តីពីគ្រួសារ និងក្នុងកម្ពុជាពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ និងខកខានក្នុងការពិចារណាត្រឹមត្រូវលើ

គោលការណ៍ស្តីពីអត្ថិភាពប្រហាក់ប្រហែលគ្នាក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នានៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងពេលជម្លោះដទៃទៀត។ សម្រាប់សំអាងហេតុពេញលេញត្រូវបានពន្យល់ក្នុងសាលដីកានេះ។ អង្គជំនុំជម្រះតុលាការកំពូល បដិសេធអំណះអំណាងទាំងអស់នេះ។

៥៧. ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងវិធីសាស្ត្ររបស់ខ្លួន ក្នុងការពិចារណាលើការរំលោភសេពសន្ថវៈ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ សហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខលើអ្វី ដែលខ្លួនបានអះអាងថា ជាកំហុសនៅក្នុងវិធីសាស្ត្ររបស់ អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងជនរងគ្រោះជាបុរសនៃការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ជាពិសេស សហព្រះរាជអាជ្ញាបានយោងទៅលើការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ស្តីពីជាតុផ្សំនៃអំពើអមនុស្សធម៌ដទៃទៀតពាក់ព័ន្ធទៅនឹងអំពើ ដែលត្រូវបានចោទប្រកាន់ថា ជាការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបានអះអាងថា អង្គជំនុំជម្រះសាលាដំបូង ខកខានក្នុងការបង្កើតការយល់ឃើញសមស្របពាក់ព័ន្ធទៅនឹងបទពិសោធន៍នៃជនរងគ្រោះជាបុរសនៃឧក្រិដ្ឋកម្មនេះ។

៥៨. អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការព្យាយាមកំណត់ជាតុផ្សំនៃការរំលោភសេពសន្ថវៈនៅក្នុងការវិភាគរបស់ខ្លួន។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូង គប្បីបានពិចារណាតែលើអំពើ ដែលត្រូវបានចោទប្រកាន់ ដែលបានកើតឡើង ដែលជាអំពើនៃការរួមភេទដោយបង្ខំរវាងជនរងគ្រោះទាំងបុរស និងស្ត្រី ដែលត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញបន្ថែមទៀតថា ការប្រព្រឹត្តដោយបង្ខំនេះ បានរំលោភបំពានច្បាស់ណាស់លើសិទ្ធិស្តីពីបូរណភាពផ្នែករូបកាយ និងសេចក្តីថ្លៃថ្នូររបស់មនុស្សដែលជាធរមាននៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និងមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នានោះ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា អំពើនេះដែលត្រូវបានពិពណ៌នាត្រឹមត្រូវថា ជាការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំស្ថិតក្នុងវិសាលភាពនៃបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀត។ អង្គជំនុំជម្រះតុលាការកំពូល បំភ្លឺថា ជនរងគ្រោះនៃការរួមភេទដោយបង្ខំមានទាំងបុរស និងស្ត្រី។ ផ្អែកតាមការវិភាគនេះ អង្គជំនុំជម្រះតុលាការកំពូល ទទួលយកបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងកំហុសក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះជនរងគ្រោះជាបុរស។

## លក្ខណៈ និងការអនុវត្តន៍គោលនយោបាយរៀបអាពាហ៍ពិពាហ៍

៥៩. ខៀវ សំផន បានលើកការជំទាស់ផ្នែកអង្គហេតុផ្សេងៗ ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីគោលបំណងនៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍ ដូចជា៖ ការបង្កើនប្រជាជន និងគ្រប់គ្រងទំនាក់ទំនងផ្លូវភេទ។ គាត់បានចោទប្រកាន់អំពីភាពផ្ទុយគ្នារវាងគោលបំណងពីរនោះ និងបានអះអាងថា ការរឹតត្បិតទំនាក់ទំនងផ្លូវភេទបុរស និងស្ត្រី គឺផ្ទុយគ្នាទៅនឹងគោលបំណងបង្កើនចំនួនប្រជាជន។ ខៀវ សំផន បានជំទាស់ផងដែរទៅនឹងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលថា គោលការណ៍បក្សកុម្មុយនីស្តកម្ពុជានៃការស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ត្រូវបានអនុវត្តពុំត្រឹមត្រូវជាក់ស្តែង

ព្រមទាំងការយល់ឃើញអំពីការរៀបអាពាហ៍ពិពាហ៍របស់អតីតយោធិនពិការ និងពិធីរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះតុលាការកំពូល បដិសេធរាល់ការជំទាស់ទាំងអស់នេះ។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់នៅក្នុងសាលដីកាជាលាយលក្ខណ៍អក្សរនេះ។

៦០. ប្រហាក់ប្រហែលគ្នានេះ អង្គជំនុំជម្រះតុលាការកំពូល បដិសេធការអះអាងរបស់ ខៀវ សំផន ដែលថា ពុំមានគោលនយោបាយនៃរួមភេទដោយបង្ខំ ព្រមទាំងការបដិសេធរបស់គាត់ ដែលថា ការរួមភេទត្រូវបានបង្ខំ។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់នៅក្នុងសាលដីកាជាលាយលក្ខណ៍អក្សរនេះ ។

៦១. ខៀវ សំផន បានជំទាស់ផងដែរ ទៅលើការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ស្តីពីបទបញ្ជាចេញពីថ្នាក់លើឱ្យរៀបចំការរៀបអាពាហ៍ពិពាហ៍នេះ របាយការណ៍ស្តីពីការរៀបអាពាហ៍ពិពាហ៍ទៅថ្នាក់លើនិងរបាយការណ៍ស្តីពីការតាមដានការរួមដំណេកនៃការរៀបអាពាហ៍ពិពាហ៍ ព្រមទាំងការជាប់ពាក់ព័ន្ធផ្ទាល់ខ្លួនគាត់នៅក្នុងបទបញ្ជារៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា ខៀវ សំផន ក្នុងករណីដ៏ច្រើនលើសលុប បានបំភ្លៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងភស្តុតាងទាក់ទងនឹងបញ្ហានេះ។ អាស្រ័យហេតុនេះ សារណារបស់គាត់ត្រូវបដិសេធចោល។

## ការយល់ឃើញផ្នែកអង្គច្បាប់ស្តីពីធាតុផ្សំអំពើអមនុស្សធម៌ដទៃទៀត

៦២. អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា អំពើដែលត្រូវបានចោទប្រកាន់ថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងជាការរំលោភសេពសន្ថវៈក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានកើតឡើង។ ទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍ ដោយបង្ខំ អង្គជំនុំជម្រះសាលាដំបូង បានពិចារណាឃើញថា ការឈឺចាប់ផ្នែករូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ បានបង្កទៅលើបុគ្គលតាមរយៈការគំរាមកំហែងបង្ខិតបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយអ្នក ដែលខ្លួនពុំដែលស្គាល់ និងការភ័យខ្លាចត្រូវបានបង្កឡើង ដើម្បីដាក់សម្ពាធលើពួកគេឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍ និងបានយល់ឃើញថា អំពើនោះត្រូវបានប្រព្រឹត្តដោយចេតនា។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង ជឿជាក់ថា អំពើដែលត្រូវបានចាត់ទុកថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានបង្ហាញ និងបានបំពេញតាមលក្ខខណ្ឌនៃអំពើអមនុស្សធម៌ដទៃទៀត។ ពាក់ព័ន្ធទៅនឹងអំពើដែលត្រូវបានចោទប្រកាន់ថា ជាការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា ការរំលោភសេពសន្ថវៈបានកើតឡើងពាក់ព័ន្ធទៅនឹងជនរងគ្រោះជាស្ត្រី និងបានបង្កការឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត។ ជាលទ្ធផល ផ្អែកតាមលក្ខណៈដែលធ្វើឱ្យប៉ះពាល់ដល់ជនរងគ្រោះជាបុរស ការរួមភេទដោយបង្ខំក៏ជាអំពើអមនុស្សធម៌ផងដែរ។

៦៣. ទោះជាយ៉ាងណាក្តី ទាក់ទងទៅនឹងជនរងគ្រោះជាបុរសនៃការរួមភេទដោយបង្ខំ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានថា ផ្អែកលើកាលៈទេសៈ ពួកគេពុំអាចត្រូវបានចាត់ទុកថា ជាជនរងគ្រោះនៃការរំលោភសេពសន្ថវៈឡើយ។ អង្គជំនុំជម្រះសាលាដំបូង បានពិចារណាលើបញ្ហាថាតើជនរងគ្រោះជាបុរសនោះបានឆ្លងកាត់បទពិសោធន៍នៃអំពើហិង្សាផ្លូវភេទក្នុងកម្រិតធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះ បានសន្និដ្ឋានថា បើទោះបីជាពួកគេបានឆ្លងកាត់

អំពើហិង្សាផ្លូវភេទដែលជាការរំលោភបំពានលើសេចក្តីថ្លៃថ្នូររបស់មនុស្សក៏ដោយ ក៏ពុំមានភស្តុតាងបង្ហាញច្បាស់លាស់ពាក់ព័ន្ធទៅនឹងភាពធ្ងន់ធ្ងរនៃអំពើប្រភេទនេះ និងផលប៉ះពាល់លើជនរងគ្រោះជាបុរសឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានថា ធាតុផ្សំនៃអំពើអមនុស្សធម៌ដទៃទៀត ពុំត្រូវបានបង្ហាញទាក់ទងទៅនឹងជនរងគ្រោះជាបុរស នៃការរួមភេទដោយបង្ខំ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

អង្គជំនុំជម្រះតុលាការកំពូល បានពិនិត្យលើភស្តុតាងនៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង និងសន្និដ្ឋានថា ជាក់ស្តែងមានភស្តុតាងគ្រប់គ្រាន់ក្នុងការគាំទ្រសេចក្តីសន្និដ្ឋានថា ជនរងគ្រោះជាបុរសបានឆ្លងកាត់ផលប៉ះពាល់ប្រហាក់ប្រហែលគ្នាទៅនឹងជនរងគ្រោះជាស្ត្រី ដែលបានឆ្លងកាត់ការបង្ខំឱ្យរួមភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ជាលទ្ធផលឃើញថា ការរួមភេទដោយបង្ខំ គឺជាអំពើអមនុស្សធម៌ចំពោះជនរងគ្រោះជាបុរសដែលជាកត្តាមួយអង្គជំនុំជម្រះបានពិចារណា និងទទួលយកបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងវិធីសាស្ត្ររបស់ អង្គជំនុំជម្រះសាលាដំបូង ចំពោះជនរងគ្រោះជាបុរស។

**៦៤.** ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តកំហុសនៅក្នុងការយល់ឃើញ ដែលបានបង្កើតឡើងស្តីពីធាតុផ្សំសត្យានុម័ត នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការខកខានក្នុងការពិចារណាលើបរិបទនៃការរៀបអាពាហ៍ពិពាហ៍ផ្សំផ្គុំតាមប្រពៃណី ដែលតាមការលើកឡើងរបស់គាត់ មានលក្ខណៈដូចគ្នាទៅនឹងការរៀបអាពាហ៍ពិពាហ៍ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ និងក្នុងការយល់ឃើញដែល អង្គជំនុំជម្រះ បានបង្កើតឡើងស្តីពីការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្តក្នុងករណីបុគ្គលផ្សេងៗ នោះ។ អង្គជំនុំជម្រះតុលាការកំពូល បដិសេធអំណះអំណាងនីមួយៗ នេះ។ បន្ថែមលើនេះ ការជំទាស់របស់ ខៀវ សំផន ពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងភស្តុតាង ដែលបង្ហាញអំពីបទពិសោធន៍បុគ្គល ដែលឆ្លងកាត់ព្យសនកម្មនោះ។ ខៀវ សំផន បានលើកការសន្និដ្ឋានមួយបែបផ្សេង ដែលពុំមានភស្តុតាងគាំទ្រ និងបានបំភ្លៃភស្តុតាង និងសាលក្រម អង្គជំនុំជម្រះសាលាដំបូង ឬត្រឹមតែមិនយល់ស្របជាមួយនឹងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ដោយគ្មានការលើកបង្ហាញកំហុសណាមួយឡើយ។

**៦៥.** បន្ទាប់មក ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ស្តីពីជនរងគ្រោះជាស្ត្រីនៃអំពើដែលត្រូវបានចោទប្រកាន់ថា ជាការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ អង្គជំនុំជម្រះតុលាការកំពូល រកពុំឃើញកំហុសក្នុងការយល់ឃើញរបស់ អង្គជំនុំជម្រះ ពាក់ព័ន្ធបញ្ហានេះ។ សហព្រះរាជអាជ្ញា បានជំទាស់ផងដែរទៅនឹងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងជនរងគ្រោះជាបុរសក្នុងបរិបទនៃអំពើ ដែលត្រូវបានចោទប្រកាន់ថា ជាការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ អង្គជំនុំជម្រះតុលាការកំពូល រំឭកការយល់ឃើញរបស់ខ្លួនថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការព្យាយាមបង្ហាញនូវធាតុផ្សំនៃការរំលោភសេពសន្ថវៈពាក់ព័ន្ធទៅនឹងជនរងគ្រោះជាបុរស ផ្ទុយទៅវិញគប្បីបានពិចារណាតែលើបញ្ហាថាតើអំពើដែលត្រូវបានចោទនៃការរួមភេទដោយបង្ខំនោះ បានកើតឡើងក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែរ ឬយ៉ាងណា។ ក្រោយពីបានពិនិត្យលើភស្តុតាងនៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋាថា មានភស្តុតាងគ្រប់គ្រាន់ក្នុងការគាំទ្រសេចក្តីសន្និដ្ឋាន ដែលថា

អំពើដែលត្រូវបានចោទនេះ នៃការរួមគេទដោយបង្ខំក្នុងបរិបទ នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាក់ស្ដែងបានកើតឡើង។

៦៦. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង ប្រព្រឹត្តកំហុសនៅក្នុងការយល់ឃើញរបស់ខ្លួន ស្ដីពីព្យសនកម្មដែលត្រូវបានឆ្លងកាត់ដោយជនរងគ្រោះជាស្ត្រីជាច្រើននាក់ និងបានចោទប្រកាន់កំហុសផងដែរ ក្នុងការខកខានពិចារណាលើភស្តុតាងមួយចំនួនដទៃទៀត។ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា អំណះអំណាងទាំងនេះពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់។ ខៀវ សំផន បានបំភ្លៃភស្តុតាង ឬត្រឹមតែមិនយល់ស្របជាមួយនឹងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ដោយគ្មានការបង្ហាញកំហុសណាមួយឡើយ។

## អំពើប្រល័យពូជសាសន៍

៦៧. អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា ជនជាតិវៀតណាមគឺជាក្រុមពូជសាសន៍ជាតិពន្ធដែលត្រូវបានការពារក្នុងអំឡុងពេលនៃយុត្តាធិការដីកាបញ្ជូនទៅជំនុំជម្រះ។ បន្ទាប់ពីបានកំណត់ថា ក្រុមជនជាតិវៀតណាមស្ថិតក្នុងចំណោមជនរងគ្រោះនៃបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត និងការសម្លាប់រង្គាល និងថា បក្សកុម្មុយនីស្តកម្ពុជា បានកំណត់គោលដៅលើពួកគេដោយសារពួកគេជាជនជាតិវៀតណាម ដោយមានចេតនាកម្ទេចក្រុមនេះ អង្គជំនុំជម្រះសាលាដំបូង ជឿជាក់ថា អំពើប្រល័យពូជសាសន៍ត្រូវបានបង្ហាញ។ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការសន្និដ្ឋានថា ការសម្លាប់ជនជាតិវៀតណាមបានកើតឡើង ឬថាការសម្លាប់នៅអូរកន្សែង មន្ទីរស-២១ និងក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យរួមទាំងផែអូរឈើទាល ត្រូវបានប្រព្រឹត្តទៅលើសមាជិកនៃក្រុម ដែលត្រូវបានការពារ។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសដោយសារខកខានក្នុងការកំណត់ថាតើ មានចេតនាបំផ្លាញក្រុម ដែលត្រូវបានការពារ «ទាំងមូល ឬផ្នែកខ្លះ» ព្រមទាំងបញ្ហាថាតើមានចេតនាបំផ្លាញក្រុម ដែលត្រូវបានការពារនោះ ដែរ ឬយ៉ាងណា។

៦៨. អង្គជំនុំជម្រះតុលាការកំពូល រកពុំឃើញមានកំហុសក្នុងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិវៀតណាម ក្នុងខេត្តស្វាយរៀង ដែនទឹកកម្ពុជាប្រជាធិបតេយ្យ ខេត្តកំពង់ឆ្នាំង វត្តខ្សាច់ និងខេត្តក្រចេះ។ អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ត្រឹមត្រូវនូវច្បាប់ជាធរមានពាក់ព័ន្ធទៅនឹងអំពើប្រល័យពូជសាសន៍។ បន្ថែមលើនេះ ក្នុងការកំណត់ថា ជាតុផ្សំអត្តនោម័តិនៃអំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់ត្រូវបានបង្ហាញ អង្គជំនុំជម្រះសាលាដំបូង បានសំអាងត្រឹមត្រូវលើកត្តានានាបន្ថែមទៅលើទំហំនៃអំពើឃោរឃៅ ដូចជា អត្ថិភាពនៃគោលនយោបាយកំណត់គោលដៅលើជនជាតិវៀតណាមក្នុងការចាត់ទុកជាសត្រូវពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា អំណះអំណាងរបស់ ខៀវ សំផន ពុំមានមូលដ្ឋានគាំទ្រ និងត្រូវបដិសេធចោលពាក់ព័ន្ធទៅនឹងអំពើប្រល័យពូជសាសន៍។ សម្រាប់សំអាងហេតុពេញលេញត្រូវបានពន្យល់ក្នុងសាលដីកានេះ។

# ការចោទប្រកាន់កំហុសទាក់ទងទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល

## តួនាទី និងការទទួលខុសត្រូវរបស់ ខៀវ សំផន ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ

៦៩. ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង អំពីតួនាទី និងការទទួលខុសត្រូវក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការយល់ឃើញជាច្រើននេះបូករួមជាមួយនឹងភស្តុតាងដទៃទៀត បង្កើតបានជាមូលដ្ឋាននៃការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង អំពីការរួមចំណែក ចេតនានិងការដឹងរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម។ អង្គជំនុំជម្រះតុលាការកំពូល បានកំណត់ថា អំណះអំណាងជាច្រើនរបស់ ខៀវ សំផន ពុំមានមូលដ្ឋានគាំទ្រ។ គាត់គ្រឹមតែលើកការបកស្រាយជាជម្រើសមួយផ្សេងនៃអង្គហេតុ ដែលដកយកតែផ្នែកខ្លះ និងមិនអើពើផ្នែកពាក់ព័ន្ធជាច្រើននៃភស្តុតាង និងខកខានក្នុងការបង្ហាញថា ការវាយតម្លៃរបស់ អង្គជំនុំជម្រះសាលាដំបូង លើភស្តុតាងពុំមានលក្ខណៈសមហេតុផលនោះ។

## ឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិ និងប្រធាននៃគណៈប្រធានរដ្ឋ

៧០. អង្គជំនុំជម្រះតុលាការកំពូល តម្កល់ការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលថា ក្នុងនាមជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិ ខៀវ សំផន បានជម្រុញរបៀបវារៈបក្សកុម្មុយនីស្តកម្ពុជាតាមរយៈការអានសេចក្តីថ្លែងការណ៍សារព័ត៌មាននៃសមាជជាតិពិសេសខែមេសា ឆ្នាំ១៩៧៥ និងសមាជជាតិលើកទីបី ខែធ្នូ ឆ្នាំ១៩៧៥។ ការដែល អង្គជំនុំជម្រះសាលាដំបូង ពុំអាចកំណត់បញ្ហាថាតើព្រឹត្តិការណ៍នេះ បានកើតឡើងពិតប្រាកដ ដែរ ឬយ៉ាងណា ពុំជាប់ពាក់ព័ន្ធទៅនឹងការពិតដែលពុំអាចជំទាស់បានថា ការអានរបស់ ខៀវ សំផន នូវសេចក្តីថ្លែងការណ៍នេះត្រូវបានចាក់ផ្សាយតាមវិទ្យុ និងថានេះជាការជម្រុញមាគ៌ាបក្ស។

៧១. អង្គជំនុំជម្រះតុលាការកំពូល បដិសេធអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំអាចសំអាងទៅលើសកម្មភាពរបស់គាត់ជាប្រធានគណៈប្រធានរដ្ឋ ពីព្រោះតួនាទីនេះ «គ្រឹមតែជានិមិត្តរូប» ដោយសារគាត់បានយល់ច្រឡំលើសារៈសំខាន់នៃការពិពណ៌នារបស់ អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូល បដិសេធផងដែរលើអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូង ពុំបានអើពើទៅលើភស្តុតាងដែលថា បក្សកុម្មុយនីស្តពុំបានផ្តល់ទំនុកចិត្តលើគាត់ឡើយ។អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធផងដែរ នូវអំណះអំណាងច្រំដែលរបស់គាត់ដែលថា គាត់មិនអាចរួមចំណែកក្នុងគោលបំណងរួមតាមរយៈការបំពេញកាតព្វកិច្ចការទូត និងជាទូទៅតាមរយៈការជម្រុញមាគ៌ាបក្សកុម្មុយនីស្តកម្ពុជានៅក្នុងសុន្ទរកថារបស់គាត់ ពីព្រោះតាមការអះអាងរបស់គាត់ថា នេះពុំមែនជាបទល្មើសដោយខ្លួនឯងនោះទេ ឬថា គាត់គ្រឹមតែបានគាំទ្រសកម្មភាពស្លូតត្រង់ប៉ុណ្ណោះ។ ការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង បានបង្ហាញគ្រប់គ្រាន់ថា សុន្ទរកថារបស់ ខៀវ សំផន បានជម្រុញគោលនយោបាយល្មើសរបស់បក្សកុម្មុយនីស្តជាច្រើនផ្សេងៗ។

៧២. បើទោះបីជា អង្គជំនុំជម្រះតុលាការកំពូល យល់ស្របជាមួយនឹង ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសន្មតពុំត្រឹមត្រូវថា សុន្ទរកថាថ្លែងនៅសម័យប្រជុំលើកទីមួយរបស់សភាតំណាងប្រជាជនជារបស់គាត់ក៏ដោយ ក៏កំហុសទាំងនេះពុំបានបណ្តាលឱ្យមានភាពមិនយុត្តិធម៌ដែរ ដោយសារកំហុសនេះពុំមែនសំខាន់បំផុតដែលខ្វះមិនបាន ចំពោះការសន្និដ្ឋានពាក់ព័ន្ធរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

## សមាជិកភាពក្នុងគណៈមជ្ឈិម

៧៣. ខៀវ សំផន បានទទួលស្គាល់ថា គាត់ «ដំបូងគឺជាសមាជិកបម្រុង និងក្រោយមកជាសមាជិកពេញសិទ្ធិ» នៃគណៈមជ្ឈិម។ តាមទស្សនៈរបស់គាត់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសដោយសារ (១) ការពន្លាតសិទ្ធិអំណាចរបស់គណៈអចិន្ត្រៃយ៍ (២) ការសន្មតសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ថា ជារបស់គណៈមជ្ឈិម (៣) «ដោយឆ្លៀតឱកាស» កំណត់កាលបរិច្ឆេទនៃការចូលរបស់គាត់ជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម ដើម្បីដាក់ឱ្យគាត់មានការជាប់ពាក់ព័ន្ធនៅក្នុងសេចក្តីសម្រេចគណៈមជ្ឈិមចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ និង (៤) ការយល់ឃើញពុំត្រឹមត្រូវថា គាត់បានចូលរួមក្នុងសមាជបក្ស។

៧៤. អង្គជំនុំជម្រះតុលាការកំពូល បដិសេធអំណះអំណាងទាំងនេះ។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់ក្នុងសាលដីកានេះ។ អង្គជំនុំជម្រះតុលាការកំពូល ទទួលយកអំណះអំណាងរបស់គាត់ ដែលថា ពុំមែនរាល់ទូរលេខដែលបានផ្ញើទៅមជ្ឈិមបក្ស បានទៅដល់ដៃសមាជិកគណៈអចិន្ត្រៃយ៍ទាំងអស់គ្នានោះទេ ប៉ុន្តែសន្និដ្ឋានថា គាត់ត្រូវបានផ្តល់ព័ត៌មានដោយសារជាសមាជិកនៃមន្ទីរ ៨៧០។

៧៥. អង្គជំនុំជម្រះតុលាការកំពូល ពិចារណាលើសារណារបស់ ខៀវ សំផន ទាក់ទងទៅនឹងសេចក្តីសម្រេចចំនួនបួនរបស់គណៈមជ្ឈិម៖ (១) សេចក្តីសម្រេចក្នុងខែឧសភា ឆ្នាំ១៩៧២ ឱ្យបិទផ្សារ បញ្ឈប់ការប្រើប្រាស់លុយ និងរៀបចំសហករណ៍ក្នុងតំបន់រំដោះ (២) សេចក្តីសម្រេចនៅពាក់កណ្តាលឆ្នាំ១៩៧៤ ឱ្យបិទបញ្ចប់ការចូលជាសមាជិកបក្សដើម្បីរារាំងគិញមិនឱ្យជ្រៀតចូលក្នុងបក្ស (៣) សេចក្តីសម្រេចខែមិថុនា ឆ្នាំ១៩៧៤ ឱ្យធ្វើការវាយសម្រុកចុងក្រោយ និងការជម្លៀសទីក្រុងភ្នំពេញក្នុងរដូវប្រាំងឆ្នាំ១៩៧៤ ដល់ ១៩៧៥ និង (៤) «សេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ របស់គណៈមជ្ឈិមពាក់ព័ន្ធទៅនឹងបញ្ហាមួយចំនួន»។ អង្គជំនុំជម្រះតុលាការកំពូល ពុំឃើញមានកំហុសនៅក្នុងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ឬក្នុងសេចក្តីសន្និដ្ឋានដែលថា ខៀវ សំផន បានដឹងអំពីសេចក្តីម្រេចទាំងបីលើកដំបូងនោះ ដែលមានមូលដ្ឋានរឹងមាំជាភស្តុតាងឡើយ។ អង្គជំនុំជម្រះតុលាការកំពូល រកពុំឃើញកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គណៈមជ្ឈិមបានតែងតាំង ខៀវ សំផន នូវតួនាទីប្រធានគណៈប្រធានរដ្ឋ។ ប្រហាក់ប្រហែលគ្នានេះដែរ អង្គជំនុំជម្រះ ពុំឃើញមានហេតុផលត្រូវជ្រៀតជ្រែកក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាខៀវសំផនបានរួមចំណែកក្នុងគោលបំណងរួមតាមរយៈការយល់ព្រមទៅនឹងខ្លឹមសារនៃសេចក្តីសម្រេចនោះ។ បន្ថែមលើនេះ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា គាត់បានចូលរួមក្នុងសមាជបក្សលើកទីបួន និងទីប្រាំមានភស្តុតាងគ្រប់គ្រាន់គាំទ្រ។

## វត្តមាន និងការចូលរួមក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍

**៧៦.** អង្គជំនុំជម្រះតុលាការកំពូល ពុំឃើញមានកំហុសក្នុងការសន្និដ្ឋានរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលថា ការចូលរួមញឹកញាប់របស់ ខៀវ សំផន ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍បានផ្តល់ឱ្យគាត់នូវតួនាទីពិសេសក្នុងបក្ស។ គាត់ត្រឹមតែលើកការបកស្រាយមួយផ្សេងអំពីភស្តុតាង និងលើកប្រច៉ ដែលនូវអំណះអំណាងនៃការជំនុំជម្រះពីសំណុំរឿង ០០២/០១ និង ០០២/០២ ដោយគ្មានការបង្ហាញថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ពុំសមហេតុផល។ អំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារការដាក់ឱ្យគាត់ទទួលខុសត្រូវតាមរយៈការចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ពុំមានមូលដ្ឋានគាំទ្រឡើយ។ ផ្ទុយទៅនឹងសារណារបស់គាត់ អង្គជំនុំជម្រះសាលាដំបូង ពុំបានសន្និដ្ឋានពង្រីកបញ្ចូលការចូលរួមរបស់គាត់យ៉ាងសកម្មក្នុងកិច្ចប្រជុំពីរ ដែលគាត់បានចូលរួមក្នុងពេលផ្សេងគ្នា ឬក្នុងការធ្វើសេចក្តីសម្រេច និងពុំបានដាក់ឱ្យគាត់ទទួលខុសត្រូវផ្អែកលើមូលដ្ឋាននេះឡើយ។

**៧៧.** ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលថា គាត់បានរួមចំណែកក្នុងផែនការរួមតាមរយៈកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ពិភាក្សាអំពីព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។ អង្គជំនុំជម្រះតុលាការកំពូល ទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការយល់ឃើញថា គាត់បានចូលរួមក្នុងកិច្ចប្រជុំថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ ប៉ុន្តែកំហុសនេះពុំបានបណ្តាលឱ្យមានភាពមិនយុត្តិធម៌នោះទេ។ អង្គជំនុំជម្រះតុលាការកំពូល រកពុំឃើញកំហុសក្នុងការកំណត់ចរិតលក្ខណៈនៃភស្តុតាងពាក់ព័ន្ធទៅនឹងកិច្ចប្រជុំពីរដ៏ទៃទៀត ដែលពិភាក្សាអំពីព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។ អង្គជំនុំជម្រះតុលាការកំពូល រកពុំឃើញកំហុសនៅក្នុងការសំអាងរបស់ អង្គជំនុំជម្រះសាលាដំបូង ក្នុងចំណោមនោះទៅលើការអះអាងរបស់ អៀង សារី ក្នុងការយល់ឃើញថា ខៀវ សំផន មានវត្តមានក្នុងកិច្ចប្រជុំខែ កញ្ញា ឆ្នាំ ១៩៧៥ ដែលពិភាក្សាអំពី «កសិកម្ម ភាពរាំងស្ងួត និងឧស្សាហ៍កម្ម»។

**៧៨.** ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសដោយសារបានផ្អែកទៅលើគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ក្នុងការយល់ឃើញថា គាត់អាចធ្វើអន្តរាគមន៍ក្នុងកិច្ចប្រជុំរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍។ អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំក្នុងការដាក់ឱ្យ ខៀវ សំផន ទទួលខុសត្រូវចំពោះសេចក្តីសម្រេចគណៈមជ្ឈិម ប៉ុន្តែលើសមាជិកភាពពេញលេញក្នុងនោះ។ អង្គជំនុំជម្រះតុលាការកំពូល ពុំឃើញមានកំហុសក្នុងវិធីសាស្ត្រនេះទេ។ ដោយសារ អង្គជំនុំជម្រះសាលាដំបូង ពុំបានយល់ឃើញថា ខៀវ សំផន បានចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ សារណារបស់គាត់ដែលថា គាត់អាចធ្វើអន្តរាគមន៍បាននោះចាត់ទុកជាអសារបង់។

## តួនាទីបន្ទាប់បន្សំ

**៧៩.** ខៀវ សំផន បានជំទាស់ទៅនឹងការសំអាងរបស់ អង្គជំនុំជម្រះសាលាដំបូង ទៅលើភស្តុតាងរបស់ អែម អឿន និង ឯក ហេន ក្នុងការយល់ឃើញថា គាត់បាននិយាយអំពីខ្មាំងក្នុងអំឡុងពេលនៃវគ្គបណ្តុះបណ្តាលនយោបាយ ដែលធ្វើឡើងនៅបុរីកីឡា (ក-៦) និងនៅវិទ្យាស្ថានបច្ចេកទេសមិត្តភាព

ខ្មែរ-សូវៀត (ក-១៥)។ អង្គជំនុំជម្រះតុលាការកំពូល បានពិនិត្យលើភស្តុតាង និងរកពុំឃើញកំហុសក្នុងការវាយតម្លៃរបស់ អង្គជំនុំជម្រះសាលាដំបូង ឡើយ។ អង្គជំនុំជម្រះតុលាការកំពូល បដិសេធសារណារបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូង ពុំបានអើពើលើភស្តុតាងដទៃទៀតរបស់សាក្សី ដែលចម្លើយរបស់ពួកគេបានគាំទ្រការសន្និដ្ឋានថា គាត់ជាប់ពាក់ព័ន្ធទៅនឹងវគ្គបណ្តុះបណ្តាលនយោបាយ។ អង្គជំនុំជម្រះតុលាការកំពូល បដិសេធអំណះអំណាងរបស់គាត់ ដែលថា ចម្លើយ «ពាក់ព័ន្ធទៅនឹងផែនការសេដ្ឋកិច្ចទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជា» អាចជាការរួមចំណែកយ៉ាងច្រើនក្នុងសហឧក្រិដ្ឋកម្មរួម។

៨០. អង្គជំនុំជម្រះតុលាការកំពូល បដិសេធសារណារបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការយល់ឃើញថា គាត់បានចូលរួមមន្ទីរ ៨៧០ ក្នុងខែតុលា ឆ្នាំ១៩៧៥។ គាត់បានលើកច្រំដែលនូវអំណះអំណាង ដែលត្រូវបានបដិសេធដោយ អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០២/០១ និងខកខានក្នុងការបង្ហាញឱ្យជឿជាក់បានថា អង្គជំនុំជម្រះសាលាដំបូង មានកំហុស។ ទីពីរ អង្គជំនុំជម្រះតុលាការកំពូល បដិសេធការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូង បានបំផ្លើសភស្តុតាងពាក់ព័ន្ធទៅនឹងតួនាទីរបស់គាត់ក្នុងមន្ទីរ ៨៧០។

៨១. ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង អំពីតួនាទីរបស់គាត់ក្នុងជំនួញ និងពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យ។ ការជំទាស់ប្រហាក់ប្រហែលគ្នាជាច្រើននេះត្រូវបានបដិសេធចោលដោយ អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០២/០១ ដោយសារគាត់ត្រឹមតែលើកការបកស្រាយមួយផ្សេងនៃភស្តុតាង។ ខៀវ សំផន បានចាត់ទុកខ្លួនគាត់ថាមានតួនាទីតូចតាចខាងបច្ចេកទេសក្នុងគណៈកម្មាធិការពាណិជ្ជកម្ម។ សារណានេះត្រូវបដិសេធចោលប្រហាក់ប្រហែលគ្នាដែរ។ អង្គជំនុំជម្រះតុលាការកំពូល ពុំឃើញមានកំហុសនៅក្នុងការសំអាងរបស់ អង្គជំនុំជម្រះសាលាដំបូង លើភស្តុតាងរបស់ សគឹម លួត, យ៉ិន គុជ ឬ ប៊ិត ហឿន ហៅ ប៊ិត ណា។

៨២. អង្គជំនុំជម្រះតុលាការកំពូល ពុំបានចាត់ទុកថា ជាការពុំសមហេតុផល ដែល អង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានថា ខៀវ សំផន បានដឹងអំពីខ្លឹមសារនៃលិខិតចំនួនពីរ ដែលបានផ្ញើទៅឱ្យគាត់ដោយអង្គការលើកលែងទោសអន្តរជាតិ ក្នុងឆ្នាំ ១៩៧៧ និង ១៩៧៨ ដោយសារការទំនាក់ទំនងរបស់គាត់ក្នុងផ្នែកខ្លះជាមួយនឹង អៀង សារី និងក្រសួងកិច្ចការបរទេស។

## សហឧក្រិដ្ឋកម្មរួម

៨៣. អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា ត្រឹមថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបានបន្តរហូតយ៉ាងហោចណាស់ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ខៀវ សំផន បានរួមចំណែកគោលបំណងរួមល្មើសក្នុងការអនុវត្តន៍ឆាប់រហ័សបដិវត្តសង្គមនិយមក្នុងកម្ពុជាតាមរយៈទ្រឹស្តី «មហាលោតផ្លោះមហាអស្ចារ្យ»។ យោងតាម អង្គជំនុំជម្រះសាលាដំបូង បានឱ្យដឹងថា គោលបំណងរួមគឺជាបទល្មើស ពីព្រោះមានទំនាក់ទំនងយ៉ាងស្អិតល្មួតជាមួយនឹងគោលនយោបាយ ដែលជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ។ គោលនយោបាយនេះគឺជា៖ (១) ការបង្កើត និងប្រតិបត្តិសហករណ៍ និងការដ្ឋានធ្វើការ (២) ការបង្កើត និងប្រតិបត្តិមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស (៣) ការកំណត់គោលដៅលើក្រុមជាក់លាក់ និង (៤)

បទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះសាលាដំបូង បានកំណត់បន្ថែមទៀតថា ខៀវ សំផន បានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តដោយកម្មាភិបាលបក្សកុម្មុយនីស្ត កម្ពុជាក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ និងថា គាត់បានរួមចំណែកចេតនាជាមួយនឹងមេដឹកនាំជាន់ខ្ពស់ដទៃទៀត ក្នុងសហឧក្រិដ្ឋកម្មរួមតាមរយៈការចូលរួម និងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលបានរួមបញ្ចូលតាមរយៈគោលបំណងរួម។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា ខៀវ សំផន មានពិរុទ្ធដោយសារការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួមនូវបទប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ។

៨៤. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ និងអង្គហេតុជាច្រើនក្នុងការកំណត់គោលបំណងរួមរបស់មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យថាជាបទល្មើស។ គាត់បានជំទាស់ទៅនឹងការចាត់ទុកថា ជាបទល្មើសចំពោះគោលនយោបាយនីមួយៗ របស់បក្សកុម្មុយនីស្តកម្ពុជា។ គាត់បានជំទាស់បន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសនៅពេលយល់ឃើញថា គាត់បានរួមចំណែកទិដ្ឋភាពល្មើសនៃគោលបំណងរួម និងថា គាត់បានរួមចំណែកសំខាន់ដល់គោលបំណងនេះ ព្រមទាំងក្នុងការយល់ឃើញថា គាត់មានចេតនាចូលរួមគោលបំណងរួម និងក្នុងបទឧក្រិដ្ឋដែលនៅពីក្រោយគោលបំណងនោះ។

៨៥. ការចោទប្រកាន់មួយចំនួនរបស់ ខៀវ សំផន អំពីកំហុសជាប់ពាក់ព័ន្ធទៅនឹងការបញ្ជាក់របស់ អង្គជំនុំជម្រះសាលាដំបូង អំពីច្បាប់ដែលអាចអនុវត្តបានចំពោះសហឧក្រិដ្ឋកម្មរួម។ ជាឧទាហរណ៍ គាត់បានលើកឡើងក្នុងចំណោមនោះថា អំពើអសកម្មល្មើសពុំគ្រប់គ្រាន់ក្នុងការបង្ហាញនូវការចូលរួមក្នុងគោលបំណងរួម និងថាទំនាក់ទំនង ដែលជាលក្ខខណ្ឌតម្រូវ ត្រូវតែមានអត្ថិភាពរវាងសមាជិកសហឧក្រិដ្ឋកម្មរួម និងជាមួយចារីផ្ទាល់ទាំងអស់ នៃឧក្រិដ្ឋកម្មមិនត្រឹមតែម្នាក់នោះទេ។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់ក្នុងសាលដីកានេះ។ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងបញ្ហានេះ ដោយសារខកខានក្នុងការបង្ហាញនូវកំហុសដែលអាចប្តឹងសាទុក្ខបាន។

## លក្ខណៈល្មើសនៃគោលបំណងរួម

៨៦. ខៀវ សំផន បានជំទាស់ដដែលៗទៅនឹងការដែល អង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានថា ផែនការបដិវត្តសង្គមនិយមរបស់បក្សកុម្មុយនីស្តកម្ពុជា មានលក្ខណៈល្មើស។ អង្គជំនុំជម្រះតុលាការកំពូល រំឭកថា ដើម្បីឱ្យឈានដល់កម្រិតនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ គោលបំណងរួមដែលជាកម្មវត្ថុនៃសកម្មភាពផែនការរវាងបុគ្គលមួយចំនួន ត្រូវតែមានចរិតលក្ខណៈល្មើស ក្នុងន័យថា អាចស្មើទៅនឹង ឬពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ខៀវ សំផន អះអាងថា គោលបំណងនៃការអនុវត្តន៍ឆាប់រហ័សបដិវត្តសង្គមនិយមក្នុងកម្ពុជា ពុំមែនជាបទល្មើស ប៉ុន្តែផ្ទុយទៅវិញជាបញ្ហានយោបាយសុទ្ធសាធ។ ការកំណត់ចរិតលក្ខណៈបែបនេះ ពុំបានអើពើទាំងស្រុងលើការពិតថា ផែនការជាមូលដ្ឋានគឺ ត្រូវប្រើប្រាស់មធ្យោបាយចាំបាច់ដើម្បីសម្រេចបដិវត្តសង្គមនិយមក្នុងប្រទេសរួមទាំងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងទ្រង់ទ្រាយធំលើប្រជាជនកម្ពុជាក្នុងអំឡុងពេលនៃដំណើរការអនុវត្តន៍នោះ។ អង្គជំនុំជម្រះតុលាការកំពូល ពិចារណាឃើញថា ទោះបីព្យាយាមពង្រីកការស្រមៃយ៉ាងណាក៏ពុំអាចជឿបានថា បដិវត្តន៍បក្សកុម្មុយនីស្តកម្ពុជា

ត្រូវបានអនុវត្តដោយមានក្ដីមេត្តា ឬគិតគូរដល់សុខទុក្ខប្រជាជនឡើយ។ បើទោះបីជាបដិវត្តន៍សង្គមនិយម អាចមានអត្ថិភាព និងបានផ្ដល់អត្ថប្រយោជន៍ដល់សង្គមដោយគ្មានការបង្ហូរឈាម ឬសកម្មភាពល្មើសក៏ដោយ ក៏នេះពុំអាចអនុវត្តចំពោះរឿងក្ដីបច្ចុប្បន្ននេះឡើយ។ អាស្រ័យហេតុនេះ ការចោទប្រកាន់របស់គាត់អំពីកំហុសពាក់ព័ន្ធទៅនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់លក្ខណៈល្មើសនៃគោលបំណងរួមត្រូវបដិសេធចោល។

៨៧. ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូង យល់ពុំត្រឹមត្រូវលើសញ្ញាណរបស់បក្សកុម្មុយនីស្ដកម្ពុជាអំពីសត្រូវ និងបានបង្ហាញពុំត្រឹមត្រូវនូវអត្ថិភាពនៃគោលនយោបាយលុបបំបាត់សត្រូវនៅតាមមន្ទីរសន្ដិសុខ និងទីតាំងសម្លាប់មនុស្ស។ គាត់បានអះអាងថា កំហុសរបស់អង្គជំនុំជម្រះសាលាដំបូង បានរារាំងការសន្និដ្ឋានដែលថា បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរសន្ដិសុខ ស-២១ ក្រាំងតាចាន់ អូរកន្សែង និងមន្ទីរសន្ដិសុខភ្នំក្រោល និងបានអះអាងដដែលថា អង្គជំនុំជម្រះសាលាដំបូង ខកខានក្នុងការពិចារណាលើភស្ដុតាងក្នុងបរិបទត្រឹមត្រូវដូចជាបរិបទនៃការប្រទូសរ៉ាយប្រដាប់អាវុធជាមួយរបបលន់នល់និងក្រោយមកជាមួយប្រទេសវៀតណាម។

៨៨. អង្គជំនុំជម្រះតុលាការកំពូល បានពិនិត្យឡើងវិញយ៉ាងហ្មត់ចត់លើភស្ដុតាងទាក់ទងទៅនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលា ដំបូងចំពោះសត្រូវពិត និងតាមការសន្មតរបស់បក្សកុម្មុយនីស្ដកម្ពុជា និងបានសន្និដ្ឋានថា អំណះអំណាងរបស់គាត់ ពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់។ ការចោទប្រកាន់របស់គាត់អំពីកំហុសក្នុងការយល់ឃើញរបស់ អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងអត្ថិភាព និងលក្ខណៈល្មើសនៃគោលនយោបាយបង្កើត និងប្រតិបត្តិមន្ទីរសន្ដិសុខ និងទីតាំងសម្លាប់មនុស្សក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យត្រូវបដិសេធចោល។

៨៩. ទាក់ទងទៅនឹងការបង្កើតសហករណ៍ និងការដ្ឋានធ្វើការ ខៀវ សំផន បានជំទាស់ទៅនឹងការសន្និដ្ឋានរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលថា គោលនយោបាយនេះមានទំនាក់ទំនងយ៉ាងស្និតល្អួតជាមួយនឹងគោលបំណងរួម និងពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ គាត់បានជំទាស់ក្នុងចំណោមនោះថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវលើការតម្រង់ទិសផ្នែកនយោបាយរបស់បក្សកុម្មុយនីស្ដកម្ពុជាទាក់ទងទៅនឹងសហករណ៍ ដោយសារការមើលតែផ្នែកៗនៃឯកសារផ្លូវការរបស់បក្សកុម្មុយនីស្ដកម្ពុជាពីជ្រុងស្ដីពី «សត្រូវ» ដែលជាការដាក់បន្ទុក ប៉ុន្តែពុំបានអើពើលើភស្ដុតាងដោះបន្ទុកដែលបង្ហាញក្ដីបារម្ភជាដរាបចំពោះប្រជាជន។ បើទោះបីនេះពុំមានភាពចាំបាច់ក្នុងការយោងទៅលើភស្ដុតាងនីមួយៗ នៅក្នុងកំណត់ត្រាជំនុំជម្រះក៏ដោយ ក៏ អង្គជំនុំជម្រះសាលាដំបូង ជាក់ស្ដែងបានយោងទៅលើឯកសារភាគច្រើន ដែល ខៀវ សំផន បានចង្អុលបង្ហាញនោះដែរ។ ការបកស្រាយមួយបែបផ្សេងទៀតរបស់គាត់លើឯកសារទាំងនោះ ពុំគ្រប់គ្រាន់ក្នុងការបដិសេធ ការសន្និដ្ឋានរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលបានផ្អែកលើការបកស្រាយសមហេតុផល និងត្រឹមត្រូវរបស់ អង្គជំនុំជម្រះសាលាដំបូងលើឯកសារដដែលនោះឡើយ។ ការចោទប្រកាន់របស់គាត់អំពីកំហុសពាក់ព័ន្ធទៅនឹងអត្ថិភាព និងលក្ខណៈល្មើសនៃគោលនយោបាយក្នុងការបង្កើត និងប្រតិបត្តិសហករណ៍ និងការដ្ឋានធ្វើការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យត្រូវបដិសេធចោល។

## គោលនយោបាយកំណត់គោលដៅក្រុមជាក់លាក់ និងបទបញ្ជារៀបអាពាហ៍ពិពាហ៍

៩០. ទាក់ទងទៅនឹងគោលនយោបាយកំណត់គោលដៅក្រុមជាក់លាក់ អង្គជំនុំជម្រះតុលាការកំពូល សន្និដ្ឋានថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការយល់ឃើញថា គោលនយោបាយកំណត់គោលដៅយ៉ាងទូលំទូលាយលើពុទ្ធសាសនិក ជនជាតិចាម ជនជាតិវៀតណាម ឬអតីតទាហាន និង អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់ក្នុងសាលដីកាជាលាយលក្ខណ៍អក្សរ។

៩១. ទាក់ទងទៅនឹងគោលនយោបាយស្តីពីបទបញ្ជារៀបអាពាហ៍ពិពាហ៍ ខៀវ សំផន បានលើកឡើងថា ជាការពុំអាចធ្វើទៅរួចក្នុងការបង្ហាញអត្ថិភាពនៃគោលនយោបាយល្មើសពាក់ព័ន្ធទៅនឹងការរៀបចំការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការប្រព្រឹត្តនៃការរំលោភសេពសន្ថវៈក្នុងបរិបទនេះ។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងនេះ។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់ក្នុងសាលដីកានេះ។ ការចោទប្រកាន់កំហុសរបស់គាត់ ក្នុងការយល់ឃើញពាក់ព័ន្ធទៅនឹងអត្ថិភាព និងលក្ខណៈល្មើស នៃគោលនយោបាយដាក់បទបញ្ជារៀបអាពាហ៍ពិពាហ៍ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យត្រូវបដិសេធចោល។

## ការរួមចំណែករបស់ ខៀវ សំផន

៩២. បញ្ហាចាំបាច់ពីរចំណុចដទៃទៀត នៃសហឧក្រិដ្ឋកម្មរួម គឺជាប់ពាក់ព័ន្ធទៅនឹងការរួមចំណែករបស់ ខៀវ សំផន និងចេតនារបស់គាត់ក្នុងការចូលរួមក្នុងគោលបំណងរួមល្មើស។ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញពុំត្រឹមត្រូវថា ការគាំទ្ររបស់គាត់ ការចូលរួម និង/ឬការរួមចំណែកក្នុងទិដ្ឋភាពនៃគោលបំណងរួម ដែលពុំមែនជាបទល្មើស ក្នុងការអនុវត្តបដិវត្តសង្គមនិយមក្នុងកម្ពុជា មានលក្ខណៈគ្រប់គ្រាន់បង្ហាញនូវការរួមចំណែកដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មនានា ដែលអាចពាក់ព័ន្ធជាមួយនឹងគោលបំណងនោះ។ អង្គជំនុំជម្រះតុលាការកំពូល រំឭកថា ការរួមចំណែកនេះអាចធ្វើឡើងតាមទម្រង់ជាច្រើន និងដូចបានកំណត់ពីដំបូងដោយ អង្គជំនុំជម្រះតុលាការកំពូល «សូម្បីសកម្មភាពដែលតាមភិនភាគខាងក្រៅពុំជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មក៏ដោយ ក៏អាចត្រូវបានយកមកពិចារណានៅពេលកំណត់លើបញ្ហាថាតើ ជនជាប់ចោទបានរួមចំណែកសំខាន់ដែរ ឬយ៉ាងណា»។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូល បដិសេធអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូង ពុំអាចពិចារណាលើសកម្មភាពដែលតាមភិនភាគខាងក្រៅបានកំណត់គោលដៅលើការអនុវត្តបដិវត្តសង្គមនិយម ដែលខុសពីការប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ នៅពេលកំណត់ថា គាត់បានរួមចំណែកយ៉ាងសំខាន់ដល់ការជម្រុញគោលបំណងរួមល្មើសនៃសហឧក្រិដ្ឋកម្មរួមនោះ។

